ទស្សនាវដ្ដីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- យុត្តិធម៌សម្រាប់ជនរងគ្រោះ និងជនដៃដល់
- តើជាកម្មវៀរពីអតីតកម្មអ្វី? បទសម្ភាសន៍ជាមួយព្រះមហាសុមេធាធិបតី ទេព វង្ស

# ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ២៨ ខែធ្នូ ឆ្នាំ២០០១


## មាតិកា


◆ សំបុត្រៈ យុត្តិធម៌សម្រាប់ជនរងគ្រោះនិងជនដែលរស់............. ១

**ផ្នែកឯកសារ**

◆ ហ៊ូ នឹមៈ អ្នកទោសអគ្គការ.................................................២

◆ សមមិត្តនារី វ៉ា ឡាន.................................................... ៥

◆ លេខាទី២នៃស្ថានទូតកម្ពុជាប្រចាំនៅគុយបា............................៧

◆ វាលពិឃាតនៅស្រុកអូររាំងឪ...............................................៩

◆ តើជាកម្មពៀរពីអតីតឬអ្វី? ...............................................១៧

◆ រូបថតឯកសារ...............................................................២២

◆ ទិន្នន័យទីតាំងរួមនៃអំពើប្រល័យពូជសាសន៍...........................២៤

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ខ្មាន់កាំភ្លើងខ្មែរក្រហម....................................................២៦

◆ សម្លេងពីមន្ទីរ ស-២១ ......................................................២៩

◆ ភ្នំសន្ទុងៈ មន្ទីរសន្តិសុខភូមិភាគនិរតីរបស់ តាម៉ុក...................៣៤

**ផ្នែកច្បាប់**

◆ តម្លៃនៃភ័ស្តុតាង...........................................................៣៧

◆ ច្បាប់សិទ្ធិមនុស្សអន្តរជាតិ...............................................៤២

**វេទិកាពិភាក្សាសាធារណៈ**

◆ អន្តរាគមន៍របស់អគ្គការណាតូនៅកូសូវ៉ូ...................................៤៤

◆ ច្បាប់ព្រហ្មទណ្ឌអន្តរជាតិគ្មានបំណងជំនួសច្បាប់ក្នុងស្រុក...........៥១

◆ ភាពខុសគ្នារវាង “ឈ្មោះក្មេង” និង “ឈ្មោះហៅក្រៅ”.......... ៥៤

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ សោកនាដកម្មគ្រួសារខ្ញុំ...................................................៥៧

**សិល្បៈខ្មែរក្រហម**

◆ ចម្រៀងៈ មហាជោគជ័យជាង៥ឆ្នាំចិញ្ចែង................ក្របក្រោយ




ព្រះមហាសុមេធាធិបតី ទេព វង្ស (ឆ្នាំ១៩៨១)


**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា



អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងពត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងពត៌មាន
លេខ ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**វាគ្មិនលេខនេះ ៖** ដេង ពង្សរ៉ាសុី, អៀ ម៉េងទ្រី, ហ៊ុយ វណ្ណៈ, ទូច បូរ៉ា, សារ៉ុត ម៉ារីនលិន, ដេវីត ឆេនដល័រ, ចន ឆរឆីអារី, រ៉េមិន ចូហាន់សាន់, អេលីហ្សាប៊ែត វ៉ាន់ស្កាក់ **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** សាន់ កល្យាណ, លី សុផល, ជួង សុភារិទ្ធ **ជំនួយការនិពន្ធនាយក ៖** អែម សុខឃីម **និពន្ធនាយករងទី១ ៖** ដាត កុសល **និពន្ធនាយករងទី២ ៖** សឹម សុរិយ៉ា **អ្នកបកប្រែ ៖** សួ ប៊ុនសួ **និពន្ធនាយកទូទៅ ៖** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រ ៖** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយ ៖** សុខ វណ្ណៈ

*សំបុត្រ:*

# យុត្តិធម៌សម្រាប់ជនរងគ្រោះនិងជនដៃដល់

◆ ប្រសិនបើ តាម៉ុក ត្រូវបានសភាជាតិអនុម័តច្បាប់ឲ្យមានការពន្យារពេលឃុំឃាំងខ្លួនជាបន្តទៅទៀត គឺជារឿងមួយដែលមិនយុត្តិធម៌ទេ ។ ថ្វីដ្បិតតែ តាម៉ុក ជាមេដឹកនាំខ្មែរក្រហមម្នាក់ដែលកំពុងទទួលការចោទប្រកាន់ពីសាធារណជនថាបានចូលរួមចំណែកធ្វើឲ្យប្រជាជនខ្មែរស្លាប់អស់រាប់លាននាក់យ៉ាងណាក៏ដោយ ក៏ តាម៉ុក ត្រូវតែទទួលបាននូវការវិនិច្ឆ័យទោសដោយយុត្តិធម៌ពីសំណាក់អង្គតុលាការឯករាជ្យមួយ ។ ការឃុំឃាំង តាម៉ុក អស់រយៈពេលបីឆ្នាំកន្លងមកនេះ គឺគ្រប់គ្រាន់សម្រាប់ភាពជាមនុស្សម្នាក់ដូច តាម៉ុក ។ រយៈពេលនៃការឃុំឃាំងនេះទៀតសោតគឺបានផ្តល់ពេលវេលាហួសពីសមរម្យសម្រាប់រាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ ដើម្បីពិចារណានិងបង្កើតនូវអង្គតុលាការឯករាជ្យមួយដើម្បីវិនិច្ឆ័យទោស តាម៉ុក និងមេដឹកនាំខ្មែរក្រហមដទៃទៀត ។

◆ ប្រសិនបើ តាម៉ុក ត្រូវបានដោះលែងឲ្យនៅក្រៅឃុំឃាំងដោយត្រឹមត្រូវតាមនីតិវិធីវិញនោះ គឺជារឿងមួយដែលមិនយុត្តិធម៌សម្រាប់ជនរងគ្រោះរាប់លាននាក់ដែលបានបាត់បង់ជីវិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ គ្រួសារខ្មែរទាំងអស់ រាប់ចាប់តាំងពីរាស្ត្ររហូតដល់ព្រះមហាក្សត្រ យ៉ាងហោចណាស់ក៏មានសមាជិកក្រុមគ្រួសារម្នាក់ត្រូវបានស្លាប់នៅក្នុងរបបខ្មែរក្រហមយ៉ាងព្រៃផ្សៃ និងអយុត្តិធម៌ ។ អស់រយៈពេលជាង២០ឆ្នាំមកហើយដែលជនរងគ្រោះនៅតែទាមទារចង់ដឹងថាតើហេតុអ្វីបានជាខ្មែរក្រហមសម្លាប់មនុស្សដើម្បីកសាងបដិវត្តន៍យ៉ាងដូច្នេះ ។ ការដោះលែង តាម៉ុក នឹងធ្វើឲ្យជនរងគ្រោះក្លាយទៅជាជនរងគ្រោះម្តងទៀត ហើយក៏ជាការបំផ្លាញចោលទាំងស្រុងនូវការជឿជាក់ទៅលើប្រព័ន្ធច្បាប់នៅក្នុងប្រទេសកម្ពុជាដែលរាជរដ្ឋាភិបាលកម្ពុជាព្រមទាំងសហគមន៍អន្តរជាតិកំពុងប្រឹងប្រែងស្តារឡើងវិញអស់រយៈពេលជាច្រើនឆ្នាំមកហើយ ។



តាម៉ុក

◆ រាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិមានកាតព្វកិច្ចជាប្រវត្តិសាស្ត្រមួយចំពោះមុខប្រជាជនកម្ពុជានិងសកលលោក ។ កាតព្វកិច្ចនេះគឺត្រូវធ្វើយ៉ាងណាបង្កើតឲ្យបាននូវតុលាការឯករាជ្យមួយឲ្យទាន់ពេលវេលាដែលមាននិងបានផ្តល់ឲ្យដើម្បីៈ ១) បំភ្លឺដល់ជនរងគ្រោះនូវអ្វីដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ២) ដាក់ទណ្ឌកម្មដល់ជនទាំងឡាយណាដែលបាននិងចូលរួមប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ហើយនិង ៣) បញ្ចប់ភាពសោកសៅរបស់កម្ពុជាតាមនីតិវិធីរួមមួយ រវាងជាតិនិងអន្តរជាតិ ដែលអាចទទួលយកបានដោយជនរងគ្រោះនិងជនដៃដល់ ។

**ឆាំង យុ**

# ហ៊ូ នឹម : អ្នកទោសអង្គការ




នៅក្នុងជំហានដំបូងនិងជាបន្តបន្ទាប់នៃដំណើរការតស៊ូរបស់ខ្លួន បក្សកុម្មុយនិស្តកម្ពុជាបានពឹងផ្អែកលើសកម្មជនដ៏ច្រើនលើសលប់ដែលលះបង់ទាំងកម្លាំងកាយនិងកម្លាំងចិត្តចូលរួមក្នុងចលនាតស៊ូ នៅក្នុងព្រៃដើម្បីរំដោះទឹកដីកម្ពុជាចេញពីអ្វីដែលខ្មែរក្រហមហៅថា "ពួកចក្រពត្តិអាមេរិកនិងបរិវារ" ។ បក្សកុម្មុយនិស្តកម្ពុជាបានប្រើប្រាស់សកម្មជនទាំងនោះដើម្បីកៀងគរប្រជាជននៅក្នុងប្រទេស និងស្វែងរកការគាំទ្រនៅក្រៅប្រទេស ប្រយោជន៍ឲ្យចលនាតស៊ូរបស់ខ្លួនបានសម្រេចជោគជ័យ ។ នៅពេលដែលការតស៊ូបក្សកុម្មុយនិស្តកម្ពុជាបានទទួលជោគជ័យនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មេដឹកនាំជាន់ខ្ពស់របស់ខ្មែរក្រហមបែរជាបាត់ការទុកចិត្តចំពោះយុទ្ធមិត្តតស៊ូរបស់ខ្លួន ហើយបានចោទអ្នកតស៊ូទាំងនោះថាជា "ខ្សែក្បត់" ឬ "ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងបដិវត្តន៍" ហើយនិងបានចាប់ផ្តើមកម្ទេចអ្នកទាំងនោះម្តងមួយៗ ។ សកម្មជនដែលធ្វើការនៅក្រៅប្រទេសត្រូវបានហៅឲ្យត្រឡប់ចូលស្រុកវិញទាំងអស់ក្រោមអង្គការចាត់តាំងឲ្យមករៀនសូត្រគោលនយោបាយរបស់បក្ស រួចក៏ត្រូវបញ្ជូនទៅមន្ទីរឃុំឃាំង និងសម្លាប់ចោល ។ សកម្មជនដែលធ្វើការនៅក្នុងប្រទេសស្រាប់ ក៏ត្រូវចាប់ខ្លួននិងសម្លាប់ជាបន្តបន្ទាប់ដែរ ។ សកម្មជនខ្មែរក្រហមមួយចំនួនដែលធ្លាប់ចូលរួមយ៉ាងសកម្មក្នុងចលនាតស៊ូរួមមាន ភោគ ឆាយ, ហ៊ូ យន់, ហ៊ូ នឹម, ស៊ាន អាន, កែ មាស, អ៊ីស៊ូប គន្ធី, កុយ ធួន, នង សួន, វ៉ាន់ ពីនី, ហួត សម្បត្តិ, សារិន ឆាក បានក្លាយទៅជាអ្នកទោសនៅមន្ទីរ ស-២១ និងត្រូវសម្លាប់ចោលទាំងអស់ ។

ហ៊ូ នឹម ហៅ ភាស់ ត្រូវបានសមមិត្ត ប៉ង់ បញ្ឆោតតាមទូរស័ព្ទ ហៅមកធ្វើការជាមួយអង្គការ ហើយក៏ត្រូវចាប់ខ្លួនបញ្ជូនមកមន្ទីរ ស-២១ ។ នៅក្នុងចម្លើយសារភាពរបស់ខ្លួនជូនអង្គការ ហ៊ូ នឹម បានសម្តែងនូវការភ្ញាក់ផ្អើលយ៉ាងខ្លាំងដែលត្រូវបានបញ្ឆោតចាប់ខ្លួនមកដាក់នៅក្នុងមន្ទីរឃុំឃាំងបែបនេះ ។ តាមរយៈការសួរចម្លើយ ហ៊ូ នឹម បានដឹងថាខ្លួនជាប់ចោទពីបទចង់បង្កើតបក្សថ្មីមួយទៀតផ្សេងពីបក្សកុម្មុយនិស្តកម្ពុជា ។

នៅមន្ទីរ ស-២១ ហ៊ូ នឹម ជាប់ឃុំឃាំងនៅក្នុងផ្ទះលេខ៣១ បន្ទប់ធំលេខ១ បន្ទប់តូច លេខ១ ។ ហ៊ូ នឹម មានជំងឺថ្លើមប្រចាំកាយ គួបផ្សំនឹងទារុណកម្មដែលកម្មាភិបាលសួរចម្លើយបានអនុវត្តមកលើ ជាហេតុធ្វើឲ្យសុខភាពរបស់ ហ៊ូ នឹម ចុះទ្រុឌទ្រោមដុនដាបទៅៗជាលំដាប់ពីមួយថ្ងៃទៅមួយថ្ងៃ ។ "បក្សឃុំឃាំងខ្ញុំក៏ឃុំចុះ តែសូមបក្សអនុគ្រោះកុំចងប្រវាក់ជើង ។ ខ្ញុំពុំធ្លាប់ ហើយសម្រាកពុំបាន ខ្ញុំឈឺថ្លើម ខ្ញុំពុំសូវមានកម្លាំងទេ ។...ដោយខ្ញុំអង្គុយមិនបានយូរ ខ្ញុំសូមរាយការណ៍..." ។ "ប៉ុន្មានថ្ងៃហើយដែលសុខភាពខ្ញុំកាន់តែចុះធូន់ធ្ងរ ។ ដល់ប៉ុណ្ណឹងហើយខ្ញុំមិនត្រូវលាក់ទេ..." ។

ហ៊ូ នឹម ត្រូវចាប់ខ្លួននៅថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៧៧ និងត្រូវសួរចម្លើយភ្លាមៗនៅក្នុងថ្ងៃនោះតែម្តង ។ ឆ្លងកាត់ការសួរចម្លើយក្នុងដំណាក់កាលដំបូង ហ៊ូ នឹម បានប្រកែកដាច់អហង្ការនិងរក្សាជំហររឹងប៉ឹងមិនសារភាពតាមអ្វីដែលអង្គការបានចោទប្រកាន់នោះឡើយ ។ "ខ្ញុំសូមជំរាបបក្សដាច់ខាតថាខ្ញុំពុំដែលក្បត់បក្ស ពុំដែលធ្វើភ្នាក់ងារសេ.អ៊ី.អា ឬភ្នាក់ងារពួកយួន ពួក សឹង ង៉ុកថាន់ ឬពួកសេរីនិយម ឬបរទេសណា មកបង្កប់

*ក្នុងបក្ស ហើយបំផ្លាញបក្សទេ ។ ទោះបក្សយកខ្ញុំទៅសម្លាប់ក៏ខ្ញុំនៅតែឆ្លើយនិងមានជំហរដាច់ខាតយ៉ាងនេះ» ។ «បក្សយើងមហាអស្ចារ្យ ជាបក្សកុម្មុយនិស្តកម្ពុជាដ៏រុងរឿងភ្លឺស្វាងត្រឹមត្រូវយ៉ាងនេះ មានបងៗរឹងប៉ឹងដឹកនាំវាងវៃយ៉ាងនេះ តើខ្ញុំខ្វះក្រិដ្ឋអីទៅរកបង្កើតបក្សទៀត ។ ខ្ញុំស្រលាញ់ជាតិទឹកដី ប្រជាជន ប្រពន្ធកូន គ្រួសារខ្ញុំ តើខ្ញុំក្បត់បក្សយើងបានផលអី? ខ្ញុំសព្វថ្ងៃជាប្រធានគណៈបក្ស ក-៣៣ ហើយបក្សប្រគល់នាទីរដ្ឋមន្ត្រីទៀត បក្សទុកចិត្តទៀត តើខ្ញុំមានសុភមង្គលអីជាងនេះទៅទៀត?...ដូច្នេះការចោទប្រកាន់មកលើខ្ញុំ ខ្ញុំយល់ថាជាឧបាយកលរបស់ខ្មាំងគ្រប់ប្រភេទ ទាំងចក្រពត្តិអាមេរិក ទាំងពួកសេរីរ៉ីទាំងពួកយួន មកលើខ្ញុំ ។ សូមអង្គការបងៗនិងសមមិត្តទាំងអស់ជួយរកយុត្តិធម៌ឱយខ្ញុំនិងជូនបក្សផង»* ។

ក៏ប៉ុន្តែបន្ទាប់ពីទទួលទារុណកម្ម ហ៊ូ យន់ បានសារភាពថាខ្លួនជាសេអ៊ីអាបង្កប់ធ្វើសកម្មភាពយូរអង្វែងដើម្បីផ្តួលរំលំបក្សកុម្មុយនិស្តកម្ពុជា ។ សកម្មភាពគ្រប់យ៉ាងដែលខ្លួនបានធ្វើពីមុនមក គឺសុទ្ធសឹងបង្កប់រូបភាពសេ.អ៊ី.អានៅពីក្រោយខ្នងទាំងអស់ ។ សូម្បីតែគុណបំណាច់ដែលខ្លួនធ្លាប់បានសាងដើម្បីបដិវត្តន៍ទាំងប៉ុន្មាន ក៏ជារូបភាពបិទបាំងនយោបាយសេ.អ៊ី.អារបស់ខ្លួនដែរ ។ *«ជំរាបស.មសន្តិបាលជាទីគោរព, ឥឡូវបក្សវិនិច្ឆ័យខ្ញុំថាខ្មាំងហើយ ។ ខ្ញុំសូមប្រគល់ខ្លួនខ្ញុំជូនបក្សហើយ ។ ...ខ្ញុំជាភ្នាក់ងារសេ.អ៊ី.អាម្នាក់ដែលស៊ីជម្រៅ បេះក្រឡិចក្រឡុចមានឧបាយកល...ជាអ្នកបម្រើមូលធននិយម ចក្រពត្តិនិយមពិសេសចក្រពត្តិអាមេរិក តែរូបភាពពាក្យសម្តី អាកប្បកិរិយាខាងក្រៅគឺលាក់ពុតបិទបាំងប្រឡំខ្លួនថាស្នេហាជាតិ ខ្លួនចំរើន... ។ ទោះជាយ៉ាងណា ខ្ញុំសុំប្រកាសថាខ្ញុំជាភ្នាក់ងារសេ.អ៊ី.អាដែលបង្កប់យូរអង្វែងក្នុងបក្ស ដើម្បីបំផ្លាញបក្ស ពិសេសបង្វែរមាគ៌ាបក្ស ។ ខ្ញុំសុំទទួលការវិនិច្ឆ័យរបស់បក្សទាំងស្រុង ។ ខ្ញុំប្រគល់ខ្លួនជូនបក្សហើយ...»* ។ ទន្ទឹមនឹងនេះ ហ៊ូ នឹម ក៏បានរាយការណ៍អំពី «ប្រវត្តិបក្សម៉ាក្សលេនីនដែលពួកសេ.អ៊ី.អាបង្កើតដើម្បីប្រឆាំងបក្សកុម្មុយនិស្តកម្ពុជា» តាមរយៈការទាក់ទងជាមួយខ្លួន ។ អ្វីដែលហៅថារបាយការណ៍អំពីប្រវត្តិបក្សម៉ាក្សលេនីននោះ គឺគ្រាន់តែនិយាយអំពីការចាប់ផ្តើមការប្រជុំគ្នាមួយនៅឆ្នាំ ១៩៦៧ ក្នុងសមាគមនិស្សិតខ្មែរ ដែល ហ៊ូ នឹម ហៅថាជាការពិភាក្សាជាលើកដំបូងអំពីការបង្កើតបក្សម៉ាក្សលេនីនតាមការចាត់តាំងរបស់ ម៉ៅ សាយ (មេដឹកនាំ សេ.អ៊ី.អានៅក្រុងភ្នំពេញ) ។ ឈ្មោះមនុស្សមួយចំនួនដែលបានរាយនៅក្នុងរបាយការណ៍ ត្រូវបាន ហ៊ូ នឹម ប្រាប់ថាជាកម្លាំងសេ.អ៊ី.អាដូចខ្លួនដែរ ។ កម្លាំងទាំងនេះសោត ភាគច្រើនជាមនុស្សដែលត្រូវអង្គការចាប់ខ្លួនប្តូកម្ទេចចោលរួចទៅហើយ ។

ហ៊ូ នឹម បានសរសេរនៅក្នុងសេចក្តីសារភាពលើកក្រោយដែលបង្ហាញនូវលក្ខណៈនៃមនុស្ស «ឈឺហើយខ្លាចរអា» ហើយក៏សារភាពតាមអ្វីដែលកម្មាភិបាលសួរចម្លើយចង់ឲ្យនិយាយ ដើម្បីបានរួចផុតពីការឈឺចាប់មួយរយៈពេលសិន ។ នៅលើឯកសារចម្លើយសារភាពលើកទីពីររបស់ ហ៊ូ នឹម មានចំណាររបស់អ្នកសួរចម្លើយឈ្មោះសមមិត្ត ប៉ុន ដែលសរសេរជូនទៅ ឌុច ជាប្រធានមន្ទីរស-២១ ថាៈ *«ជំរាបបង ឌុច, នេះចម្លើយ ភាស់ ពេលយើងវាយ៤-៥រំពាត់បំបាក់ជំហរវាមុនយកវាទៅប្រកទឹក ។ ដោយគោរព ១៤-៤-៧៧ ប៉ុន»* ។ *«ជំរាបបង ឌុច, អំពីខ្លឹមសារចម្លើយសារភាពរបស់ ភាស់ លើកនេះគឺវាលាក់កម្លាំងក្បត់ដទៃ គឺវានិយាយថាវាជាភ្នាក់ងារសេ.អ៊ី.អាឯករាជដែលបង្កប់ខ្លួនយូរអង្វែង ពុំធ្វើសកម្មភាពប្រឆាំងបក្សតក់ក្រហល់ដូចពួក អាយួន អាយ៉ា ទេ ។ ខ្ញុំបានធ្វើទារុណកម្មឲ្យវាសរសេរម្តងទៀតហើយ ។ ដោយគោរព ថ្ងៃ ២២ មេសា ១៩៧៧ ប៉ុន»* ។

នៅមន្ទីរ ស-២១ ការធ្វើទារុណកម្មដើម្បីយកចម្លើយសារភាពពីអ្នកទោស គឺជាការងាររបស់អ្នកសួរចម្លើយ ។ រៀងរាល់លើកនៃការសួរចម្លើយ អ្នកទោសតែងតែត្រូវបានលួងលោមដើម្បីឲ្យយល់ព្រមសារភាពអំពីអ្វីដែលអង្គការចង់បាន ។ ប៉ុន្តែនៅពេលដែលការលួងលោមមិនបានសម្រេច ការធ្វើទារុណកម្មក៏ចាប់ផ្តើម ។ ទារុណកម្មអាចចាប់ផ្តើមពីការវាយដំតិចតួច រហូតដល់ទារុណកម្មធ្ងន់ធ្ងរដូចជា ដកក្រចក ឆក់ខ្សែភ្លើង ជ្រមុជទឹក នៅទីបំផុតអ្នកទោសត្រូវយកទៅសម្លាប់ចោលនៅទីពិឃាតជើងឯក ។ ហ៊ូ នឹម បានព្យាយាមអង្វរករហើយអង្វរករទៀតឲ្យបក្សអនុគ្រោះនិងទុកជីវិតឲ្យខ្លួន ។ *«សូមបក្សវិនិច្ឆ័យដោយ*

អនុគ្រោះ ឲ្យខ្ញុំបានចូលរួមបុណ្យខួបទី២ នៃ ១៧ មេសា ផង ។ ខ្ញុំបំរើបក្សមួយជីវិត ស្លាប់ក្រោមទង់បក្ស ។...ខ្ញុំគ្មានលាក់បាំងអ្វីទៀតទេ ។ ខ្ញុំសារភាពប៉ុណ្ណឹងហើយ មិនមែនអាសេ.អ៊ី.អាទេ ដែលមកស្រោចស្រង់ខ្ញុំបាន មានតែបក្ស ។ ហើយខ្ញុំលាក់ក៏គ្មានអ្វីចំណេញចំពោះខ្ញុំ ព្រោះខ្ញុំត្រូវតែស្លាប់ទៅហើយ ។ បើខ្ញុំមានកម្លាំងណាបង្កប់ ខ្ញុំច្បាស់ជាជំរាបអង្គការហើយ" ។ ទោះជា ហ៊ូ នឹម បានផ្តល់នូវចម្លើយសារភាពតាមអ្វីដែលបក្សចង់បាន និងខំប្រឹងអង្វរករសុំការអនុគ្រោះទុកជីវិតយ៉ាងណាក៏ដោយ ក៏នៅទីបំផុត ហ៊ូ នឹម បានទទួលវាសនាមិនខុសពីអ្នកទោសដទៃទៀតដែរ គឺត្រូវកម្ទេចចោលនៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩៧៧ ។

---

## ប្រវត្តិរូបសង្ខេបរបស់ ហ៊ូ នឹម

- ឈ្មោះកំណើតៈ ហ៊ូ នឹម ឈ្មោះបដិវត្តន៍ៈ ភាស់ ។
- កើតនៅឆ្នាំមមី (ឆ្នាំ១៩៣០) នៅឃុំមៀន ស្រុកព្រៃឈរ ខេត្តកំពង់ចាម ។
- ឪពុកឈ្មោះ ហ៊ូ ស្លាប់នៅឆ្នាំ១៩៣៦ (ពេលដែល ហ៊ូ នឹម មានអាយុ៦ឆ្នាំ) ។
- ម្តាយឈ្មោះ ស៊ិន ។
- ប្រពន្ធឈ្មោះ វ៉ា ឡាន ហៅ សាយ ឈ្មោះបដិវត្តន៍ៈ យាត រៀបការនៅឆ្នាំ១៩៥២ ។
- កម្រិតវប្បធម៌ៈ អនុបណ្ឌិតច្បាប់ពីប្រទេសបារាំង ឆ្នាំ១៩៥៧ ។
- ថ្ងៃចាប់ខ្លួនៈ ១០ មេសា ១៩៧៧ ។
- ថ្ងៃកម្ទេចៈ ៦ កក្កដា ១៩៧៧ ។

## សង្ខេបប្រវត្តិការងាររបស់ ហ៊ូ នឹម

- ឆ្នាំ១៩៥០ រៀននៅវិទ្យាល័យស៊ីសុវត្ថិ ភ្នំពេញ ។
- ឆ្នាំ១៩៥៣ បង្រៀននៅអនុវិទ្យាល័យ ចុងអ៊ុក (ក្រោយមកដូរឈ្មោះជាអនុវិទ្យាល័យកម្ពុជបុត្រ) ។
- ឆ្នាំ១៩៥៤ រៀននៅវិទ្យាស្ថានច្បាប់និងសេដ្ឋកិច្ច និងបានចូលក្របខ័ណ្ឌមហាផ្ទៃ ជាអ្នកតែងសេចក្តី ជំនួសក្របខ័ណ្ឌក្រមការ ។
- ឆ្នាំ១៩៥៥ ចូលរួមឃោសនាបោះឆ្នោតឲ្យបក្សប្រជាធិបតេយ្យ ។
- ឆ្នាំ១៩៥៥-៥៧ បានអាហារូបករណ៍ទៅរៀននៅសាលាណើយយី ប្រទេសបារាំង ។
- ឆ្នាំ១៩៥៧ ត្រឡប់មកប្រទេសកម្ពុជាវិញធ្វើគយ បន្ទាប់មកធ្វើជាតំណាងរាស្ត្រ ។
- ឆ្នាំ១៩៥៨ ទៅធ្វើទស្សនកិច្ចនៅអឺរ៉ុបខាងកើត ។
- ឆ្នាំ១៩៥៩ ចូលរួមគណៈប្រតិភូសារពត៌មានដែលមាន ស៊ីង កៀកថ ជាប្រធាន ទៅធ្វើទស្សនកិច្ចនៅសហភាពសូវៀត ប៉ូឡូញ ឆេកូស្លូវ៉ាគី អាល្លឺម៉ង់ខាងកើត និងអារ៉ាប់រួម ។
- ឆ្នាំ១៩៦១ ជាប់ឆ្នោតជាអនុប្រធានរដ្ឋសភា ។ បានទៅចូលរួមសន្និសីទលើកទី១នៃប្រទេសមិនចូលបក្សសម្ព័ន្ធនៅទីក្រុងបែលក្រាដ រួចបន្តទៅចូលរួមមហាសន្និបាតនៅអង្គការសហប្រជាជាតិ ។
- ឆ្នាំ១៩៦២ ចូលរួមក្នុងគណៈប្រតិភូតំណាងសមាគមអ្នកសារពត៌មានកម្ពុជា ជាមួយ អ៊ុច វ៉ែន ទៅចូលរួមសន្និសីទលើកទី១នៃសមាគមអ្នកសារពត៌មានអាស៊ី-អាហ្វ្រិកនៅទីក្រុងហ្សាកាតា (ប្រទេសឥណ្ឌូនេស៊ី) ។
- ឆ្នាំ១៩៦៣ ទៅធ្វើទស្សនកិច្ចនៅប្រទេសចិនប្រជាមានិត រួចបន្តដំណើរទៅប្រទេសកូរ៉េខាងជើង ។ ឆ្នាំនេះដែរ ហ៊ូ នឹម ត្រូវបានសម្តេច សីហនុ តែងតាំងឲ្យធ្វើជាសមាជិកគណៈកម្មការកំណែទម្រង់សេដ្ឋកិច្ច និងជាសមាជិកក្រុមប្រឹក្សាភិបាលអង្គការសូណិចស៊ីម ។
- ឆ្នាំ១៩៦៣ ចូលរួមសរសេរអត្ថបទឲ្យកាសែត "អ្នកជាតិនិយម" ។
- ឆ្នាំ១៩៦៤ ចូលរួមបង្កើតសមាគមមិត្តភាពខ្មែរ-ចិន ។
- ឆ្នាំ១៩៦៥ ជាប្រធានគណៈប្រតិភូសមាគមមិត្តភាពខ្មែរ-ចិន ទៅធ្វើទស្សនកិច្ចនៅប្រទេសចិនប្រជាមានិត ។
- ឆ្នាំ១៩៦៦ ជាប់ឆ្នោតជាតំណាងរាស្ត្រប្រចាំមណ្ឌលជ្រៃវៀន (ស្រុកព្រៃឈរ) ។
- ថ្ងៃទី៧ ខែតុលា ឆ្នាំ១៩៦៧ គៀសខ្លួនចូលព្រៃ ធ្វើការជាមួយ ខៀវ សំផន និង ហ៊ូ យន់ ក្រោយមកទៅធ្វើការជាមួយ តាម៉ុក និងសមមិត្ត ញឹម នៅភាគនិរតី ។
- តួនាទីក្នុងរបបខ្មែរក្រហមៈ លេខាក្រសួងឃោសនាការ មន្ទីរ ក-៣៣ ។

**សាន់ កល្យាណ**

# សមមិត្តនារី ង៉ា ឡាន ប្រពន្ធរបស់ ហ៊ុំ នឹម

(កត់ត្រាតាមឯកសារដើមឆាំងស្រុង)

ជំរាបអង្គការជាទីគោរពរបស់កូន

យើងខ្ញុំសូមជូនប្រវត្តិរូបជូនបក្សដូចតទៅ÷

១) ឈ្មោះដើម ង៉ា ឡាន ហៅ សាយ ឈ្មោះបដិវត្តន៍ យាត ស្រុកកំណើតនៅឃុំទន្លេបិទ ក្នុងខែត្រកំពង់ចាម ជាតិខ្មែរ ឪពុកឈ្មោះ ង៉ា ស្លាប់ពីឆ្នាំ១៩៦៨ ម្តាយឈ្មោះ ឡេង អាយុ ៧៣ គាត់នៅរស់ របររកស៊ីធ្វើជាងរាស់និងស៊ីឈ្នួលដឹកឈើឱ្យគេ ។

យើងខ្ញុំបានចងក្រងគ្រួសារពីឆ្នាំ១៩៥២ គ្រួសារខ្ញុំគាត់ជាកូនកសិករក្រ កំព្រាឪពុកតាំងពីគាត់អាយុបាន៦ឆ្នាំ រស់ជាមួយម្តាយរកស៊ីធ្វើអាកោលក់ ក្រោយមកដោយការរកស៊ីចិញ្ចឹមកូនពីរនាក់ពិបាកពេក ហើយនៅជាមួយគេ គេបានបង្ខំឱ្យគាត់មានប្តីទៀត ដោយឪពុកចុងចិត្តមិនបានធ្វើបាបកូន គាត់យកគ្រួសារខ្ញុំទៅផ្ញើវត្តលោក បានលោកជួយចិញ្ចឹម បានរៀនសូត្រ ។ រហូតមកជួបយើងខ្ញុំ យើងខ្ញុំតែងតែឮគាត់និយាយស្អប់ការជិះជាន់ពីវណ្ណៈជិះជាន់ គាត់រំលឹកពីការតស៊ូរបស់ប្រជាជន រំលឹកពីអ្នកតស៊ូប្រាប់យើងខ្ញុំនិងកូនពីប្រជាជនសំឡូត ។ មកដល់បោះឆ្នោតចុងក្រោយគឺឆ្នាំ១៩៦៧ ក្រោយខ្មាំងបុករុកពេក ដោយបំពេញភារកិច្ចជាចំហជូនបក្សមិនកើត អង្គការដកទៅព្រៃ ពេលនោះខ្ញុំមានផ្ទៃពោះ៨ខែក៏បានរៀបចំឲ្យគាត់ចេញទៅបំពេញភារកិច្ចជូនបក្សក្នុងភ្លើងបដិវត្តន៍ក្រោមការដឹកនាំរបស់បក្ស ។

ក្រោយពីគ្រួសារយើងខ្ញុំចេញទៅបាន៣ថ្ងៃ ខ្មាំងវាឡើងឆែកផ្ទះយើងខ្ញុំ រើរកឯកសារ ហើយវាទៅព័ទ្ធផ្ទះបងយើងខ្ញុំដែលនៅជិតនោះ ខ្មាំងវាចាប់គាត់ទៅវាធាក់គាត់បាក់ឆ្អឹងជំនីពីរនិងធ្មេញពីរ វាសួរគាត់រកគ្រួសារខ្ញុំតែគាត់អត់បានឆ្លើយ វាវាយគាត់សន្លប់ ចាប់គាត់ហើយវាចាក់ប្រេងសាំងក្នុងផ្ទះគាត់រួចហើយពួកវាស្រែកថាគាត់ដុតខ្លួន សីហនុ ស្រែកដេរថាយៀកកុងដុតខ្លួន លុះបាន៣ថ្ងៃក្រោយមក វាប្រាប់គាត់ស្លាប់ហើយ ឱយទៅយកគាត់មកដុត តាមការពិតគឺវាសម្លាប់គាត់ ។

ក្រោយមក១ខែ យើងខ្ញុំសំរាលកូន ខ្មាំងវានៅទៅតាមយាមដល់ផ្ទះពេទ្យ កូនខ្ញុំបាន១៨ខែ អង្គការស្នើដកយើងខ្ញុំទៅព្រៃទៀត យើងខ្ញុំបានប្រគល់កូនតូចៗទាំង៤ជូនអង្គការ ។ ហើយយើងខ្ញុំទៅព្រៃចូលរួមចំណែកជាគ្រួសារដោយស្លួចស្មើងជូនបក្សដែលតែងតែមានគុណូបការៈចំពោះយើងខ្ញុំទាំងពីរដ៏ធ្ងន់សែនធ្ងន់ដែលកូនមិនអាចបំភ្លេចបាន ។ បក្សជួយរំដោះផុតពីខ្មាំងបក្សបានជួយអប់រំរៀងរាល់ពេលជួបធ្វើការ ពេលបើកវគ្គ បក្សតែងតែណែនាំបំពាក់ជាគោលជំហរជាអង្គការវិន័យ បំពាក់ជំនឿលើបក្ស លើជាតិឯងជាដរាប ទន្ទឹមនេះ រាល់តែពេលគាត់ទទួលការណែនាំពីបក្ស តែងតែមកបើកជាវគ្គអប់រំមហាជនឱយមានជំនឿលើបក្ស លើជាតិ នៅពេលថ្មីនេះគាត់បានបើកវគ្គមួយបំផុសមហាជនឱយធ្វើកុនឱយខំថតចំរៀង នៅពេលយប់ខ្ញុំឃើញគាត់សរសេរចំរៀងឱយបងប្អូនថតឱយទាន់ពេលបុណ្យនេះ ទន្ទឹមនឹងនេះកូនមិនដែលឃើញគាត់ទាក់ទងនឹងអ្នកណាដែលជាសមាសភាពមិនល្អនោះទេ តាំងពីយើងខ្ញុំនៅក្នុងសង្គមចាស់យើងខ្ញុំមិនដែលឃើញគាត់មានមិត្តភក្តិណាក្រៅពីមិត្តយើងពីរ-បីនាក់ មិត្តខ្លះស្លាប់ ដូចមិត្ត កុមារ ហៅ ប៉ុក មិត្ត អ៊ុច វ៉ែន និង ខៀវ សំផន ដែលធ្វើកាសែតជាមួយគ្នា ។ ហើយបើមានថ្ងៃឈប់សំរាកនាំកូនចៅទៅស្រុកម្តាយ ដោយគាត់ចាស់ៗពេលទៅម្តងៗមកវិញ សីហនុ ដេរតាមវិទ្យុថាមានបាចគ្រាក់គាត់មានការឈឺចាប់នឹង សីហនុ គាត់តែងតែនិយាយបើគាត់ដឹងថាបក្សនៅទីណា គាត់ទៅតាមបក្ស ហើយក្រោយមកសឹមយើងបានភ្ជាប់ខ្សែបក្សគាត់តែងរីករាយ ។ ហើយគាត់បានប្រាប់យើងខ្ញុំថា ចំពោះគាត់បើថ្ងៃណាបក្សត្រូវការ គាត់ចូលរួមចំណែកជូនបក្សហើយ ។ គាត់ប្រាប់យើងខ្ញុំថា ចាំថ្ងៃក្រោយបើមានការអីបក្សនឹងដោះស្រាយឱយ ហើយខ្ញុំទៅមុន មិត្តទៅមិនកើតទេ កូនច្រើនហើយមានផ្ទៃពោះផង ក្រោយបក្សបានដកយើងខ្ញុំទៀត ។ បក្សជាទីគោរព សូមបក្សអធ្យាស្រ័យឱយកូន

ទាំងពីរផង ។ កូនឥតធ្វើអ្វីប្រឆាំងបក្សទេ កូនទាំងពីរមានតែពង្រឹងកូនចៅឱ្យបំពេញភារកិច្ចជូន ខិតខំគោរពអង្គការវិន័យ ទោះបីទៅទីណាក៏ដោយ បំរើបក្សដោយឥតល័ក្ខខ័ណ្ឌ ។ បក្សមានតែបក្សទេអាចជួយកូនបាន កន្លងកូនមិនដឹងមិនឃើញគ្រួសារកូនធ្វើអ្វីទេ ឃើញតែជួយពង្រឹងទាំងសតិអារម្មណ៍បំពាក់គោលជំហរស្នេហាជាតិ បំពាក់ជំនឿលើបក្ស ស្មោះត្រង់នឹងបក្សដើរតាមលុះអស់ជីវិត កូនបានប្តេជ្ញាចំពោះទង់បក្សថាយើងទាំងពីរត្រូវកាន់ដៃគ្នាដើរតាមបក្ស យើងចំណាស់នេះហើយសុខភាពទ្រុឌទ្រោម ខិតខំបំពេញភារកិច្ចជូនបក្សដល់ទីចុងបំផុតប្តេជ្ញានៅក្រោមការដឹកនាំរបស់បក្សរៀងរហូត ។

នៅទីបញ្ចប់នេះ កូនមិនដឹងធ្វើយ៉ាងណាជូនបក្សមើលឃើញជំរៅចិត្តកូនដែលមានការស្មោះត្រង់នឹងបក្សនេះទេ មានតែពាក្យជាលាយលក្ខណ៍អក្សរនេះជូនចំពោះបក្សជាទីគោរពរបស់កូន ។

យើងខ្ញុំសូមគោរពជូនពរបក្សមានសុខភាពមាំ អាយុយឺនវែង ដឹកនាំប្រទេសទៅថ្ងៃមុខឆាប់រហ័ស ។

គួរពុំគួរសូមបក្សអធ្យាស្រ័យ កូនមិនចេះសរសេរទេ កូនបានតិចណាស់ ។

**យាត**



**លើកទំនប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ**

# អតីតលេខាទី២នៃស្ថានទូតកម្ពុជានៅគុយបា

(តចប់)

**ក) ផ្នែកនយោបាយៈ**

១) ធ្វើឲ្យកម្ពុជាគាំទ្រនយោបាយសន្តិភាពរបស់សូវៀត ២) ធ្វើឲ្យកម្ពុជាការពារនយោបាយអព្យាក្រឹតភាវូបនីយកម្មសូវៀតនៅប៉ែកអាស៊ី-អាគ្នេយ៍ ក្នុងទិសដៅដើម្បីឯកោចិនប្រជាមានិត ៣) បញ្ចូលវប្បធម៌សូវៀតទៅគ្រប់មជ្ឈដ្ឋាន និង ៤) បញ្ចូលទ្រឹស្តីម៉ាក្សឡេនីនទៅគ្រប់មជ្ឈដ្ឋាន ។

ផ្នែកនយោបាយនេះមានទិសដៅឲ្យភ្នាក់ងារនីមួយៗនៅតាមក្រសួង មន្ទីរ ឬភូមិ ទិតខំទាក់ទងប្រជាជន ជាពិសេសកម្មាភិបាល ដោយពន្យល់ឲ្យយល់ច្បាស់ពីអត្ថន័យនិងទិសដៅនៃនយោបាយសន្តិភាព និងអព្យាក្រឹតភាវូបនីយកម្មសូវៀតនៅអាស៊ី-អាគ្នេយ៍ ។ ផ្តោតជាសំខាន់ចំពោះក្រសួងការបរទេស ។ ផ្តល់ឯកសារជាជំនួយពីស្ថានទូតគុយបានិងវៀតណាម ។ លើកសរសើរពីកម្រិតវប្បធម៌សូវៀតដោយសំអាងថាធ្លាប់រស់នៅសូវៀត ។ បញ្ចូលទ្រឹស្តីម៉ាក្ស-លេនីនដោយការប្រុងប្រយ័ត្ន និងឈ្លាសវៃ ។ ទិតខំទាក់ទងពិសេសជាមួយកម្មាភិបាលជាន់ខ្ពស់ ។ ផ្តល់ពត៌មានឲ្យបានទៀងទាត់ដល់ស្ថានទូតគុយបាឬវៀតណាមតាមកាលកំណត់នៅពេលក្រោយតាមភ្នាក់ងារនីមួយៗក្នុងករណីចាំបាច់ ។ ជ្រើសរើសមជ្ឈដ្ឋានដែលត្រូវទាក់ទងជាមុន ដែលត្រូវការពេលយូរ ហើយត្រូវធ្វើជាប់រហូត និងបញ្ចូលពួកចារកម្មវៀតណាមមកបន្ថែមទៀតដោយចាំត្រួតពិនិត្យឲ្យបានល្អិតល្អន់ ពីព្រោះខ្មែរភាគច្រើនមិនសូវចូលចិត្តវៀតណាម ។ តែមានលទ្ធភាពបញ្ចូលចារកម្មលាវមកច្រើនជាង ។

**ខ) ផ្នែកសេដ្ឋកិច្ច**

១) ធ្វើឲ្យកម្ពុជារណបសេដ្ឋកិច្ចសូវៀត ២) បញ្ចូលបច្ចេក-ទេសសូវៀតមកក្នុងប្រទេស ៣) បញ្ចូលអ្នកឯកទេសសូវៀតដើម្បីជំនួសអ្នកឯកទេសចិន ៤) ជំនួយសូវៀតគ្រប់ផ្នែក គ្រប់វិស័យ ខាងសេដ្ឋកិច្ច បើកទ្វារចំហរហូត ៦) ជំនួយសេដ្ឋកិច្ចសូវៀតនឹងបញ្ចូលមកកម្ពុជាតាមរយៈជំនួយបរទេស ។ ៧) សូវៀតអាចលក់ប្រេងកាត ធ្យូងថ្ម រ៉ែ មកកម្ពុជាដោយយកតម្លៃបន្ធូររហូតដល់ឆ្នាំ១៩៨០ ។

ផ្នែកសេដ្ឋកិច្ចនេះមានទិសដៅ ៈ ១) ភ្នាក់ងារនីមួយៗត្រូវទិតខំបំផុសប្រជាជនឬកម្មាភិបាលឲ្យទទួលជំនួយបរទេស ដោយចាត់ទុកថាជាការចាំបាច់ ២) ត្រូវយកចិត្តទុកដាក់ជាពិសេសលើក្រសួងឧស្សាហកម្ម ៣) សូវៀតនឹងពង្រីងវៀតណាម លាវខាងវិស័យបច្ចេកទេស ដើម្បីជាគំរូដល់កម្ពុជា ។

**គ) ផ្នែកយោធា**

ក្នុងផ្នែកយោធាមានចំណុចសំខាន់តែពីរប៉ុណ្ណោះ ។ ទី១ បញ្ចូលចារកម្មវៀតណាមមកទឹកដីកម្ពុជា ទី២ ពង្រឹងកម្លាំងយោធានៅវៀតណាមនិងលាវក្នុងពេលបច្ចុប្បន្ន (១៩៧៦) ដើម្បីត្រៀមលក្ខណៈសង្គ្រាមរវាងវៀតណាមនិងកម្ពុជានៅអនាគត ។ ជាការកត់សម្គាល់របស់ ហៃ គីមស៊ាង គឺថាសូវៀតយល់ថា បើក្តាប់នយោបាយនិងសេដ្ឋកិច្ចប្រទេសកម្ពុជាបានហើយ ការប្រើយោធាមិនជាការចាំបាច់ឡើយ ។ ម្យ៉ាងទៀតក្នុងសកម្មភាពយោធា សូវៀតមិនប្រើភ្នាក់ងារខ្មែរទេ គឺប្រើភ្នាក់ងារវៀតណាមឬលាវ ។

អ្នកទទួលខុសត្រូវធំខាងការផ្តល់បញ្ជានិងប្រមូលពត៌មានគឺជាលេខាធិការទី៣ មានមុខនាទីជាអ្នកបកប្រែនៅស្ថានទូត ។ ចំណែកឯអ្នកទាក់ទងជាជំហានដំបូងជាខ្មែរនៅក្នុងស្រុកនិងនៅក្រៅស្រុកដែលមានចំនួន១៩នាក់ មានៈ ហាក់ស៊ាង ឡាយនី, គ្រិន លាន, ម៉ែល សុវណ្ណ, ជា ខន, អ៊ុក សុក, ព្រហ្ម កឿន, ប៉ូច មាឃបូរី, យូ ស៊ីមហ៊ុន, វឿង ម៉ាច, ថាច់ សួង, កុយ ជា, ជិន ឈុនលាង, ឡាំ វ៉ារ, ជិន កុកហួរ, ប៉ែន ថោងអាន, ហេង ពេជ្រ និង អៀង សីហា ជាកម្លាំងនៅក្នុងប្រទេសនិងជាអតីតនិស្សិតខ្មែរនៅសហភាពសូវៀត ។ ម៉ែន មុនីដាម និង គាន់ នៃហេង ជាកម្លាំងនៅក្រៅប្រទេស ។

នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៧៦ ហៃ គីមសៀង បានធ្វើដំណើរវិលត្រឡប់មកដល់ទីក្រុងប៉េកាំងវិញ ។ បន្ទាប់មក នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៧៦ ហៃ គីមសៀង បានចូលមកដល់ទីក្រុងភ្នំពេញ ។ ចាប់តាំងពីចូលមកដល់កម្ពុជា ហៃ គីមសៀង ត្រូវបានអង្គការចាត់ទៅធ្វើការនៅមន្ទីរ ក-១៥ បន្ទាប់មកទៅនៅបឹងត្របែក និងត្រូវបានផ្លាស់ទៅកន្លែងផ្សេងៗទៀត ។ ហៃ គីមសៀង ក្តាប់សភាពការណ៍នៅកម្ពុជាមិនបានសោះ ពីព្រោះត្រូវបានអង្គការចល័តឲ្យធ្វើការចុះឡើងៗពីកន្លែងមួយទៅកន្លែងមួយ ។

ក្នុងមជ្ឈដ្ឋានរបៀបនេះ ហៃ គីមសៀង បានគិតថា ការប្រព្រឹត្តចារកម្មគឺជាការមួយលំបាក ពីព្រោះមានការតាមដានក្តាស្អិតណាស់ ។ ពេលចូលមកដល់កម្ពុជា ហៃ គីមសៀង បានជួបប្រទះរបបនយោបាយនិងការរស់នៅមួយថ្មីសន្លាង គឺរបបសមូហភាព ។ គីមសៀង បានត្អូញត្អែរពីការលំបាកខាងផ្នែកសុខភាពនិងរបបរស់នៅហូបចុក ។ គីមសៀង មិននឹកស្មានដូច្នេះឡើយមុនចូលមកដល់កម្ពុជា ។

នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៧៦ ហៃ គីមសៀង ត្រូវបានអង្គការចាប់ខ្លួនបញ្ជូនមកមន្ទីរស-២១ ។ ចម្លើយសារភាពលើកទី១របស់ ហៃ គីមសៀន ធ្វើឡើងនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៧៦ បន្ទាប់ពីត្រូវអង្គការចាប់ខ្លួន ។ ក្នុងចម្លើយលើកទី១នេះ ហៃ គីមសៀង បានសារភាពថា “យើងខ្ញុំសូមសារភាពថាបានប្រព្រឹត្តអំពើមួយក្បត់ប្រជាជនទៅបម្រើផលប្រយោជន៍បរទេសអាចក្រពត្តិមែន ហើយសង្ឃឹមថា អង្គការមុខជាលើកលែងទោសដល់យើងខ្ញុំមិនខានឡើយ ហើយប្តេជ្ញាថានឹងមិនប្រព្រឹត្តអំពើដ៏ខ្មៅកខ្វក់ក្បត់ជាតិប្រជាជនទៀតឡើយ” ។ ចម្លើយលើកទី២ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៧៦ ហៃ គីមសៀង បានសារភាពថា “ខ្ញុំសូមសារភាពជូនអង្គការថា មកដល់ពេលចាប់យើងខ្ញុំ យើងខ្ញុំមិនបានបំពេញភារកិច្ចទី១ទេ ។ ម្យ៉ាងទៀត សូមសារភាពថាបានប្រព្រឹត្តអំពើឧក្រិដ្ឋក្បត់ប្រជាជាតិខ្លួនដោយខ្លួនធ្លាក់ក្នុងឧបាយកលដ៏ខ្មៅងងឹតរបស់ចក្រពត្តិសូវៀតដែលចង់មកជិះជាន់ប្រទេសយើង ។ យើងខ្ញុំសង្ឃឹមថា ដោយសារភាពនូវទោសកំហុសខ្លួន អង្គការមុខជាលើកលែងទោសដល់យើងខ្ញុំមិនខានឡើយ ។ យើងខ្ញុំប្តេជ្ញាថាឈប់ប្រព្រឹត្តអំពើឧក្រិដ្ឋក្បត់ជាតិក្បត់ប្រជាជនទៀតហើយ” ។ ចម្លើយលើកទី៣ចុះថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៧ ហៃ គីមសៀង បានបញ្ជាក់ថា “មុនពេលអង្គការចាប់ខ្លួនខ្ញុំមក បានទាក់ទងតែប៉ុណ្ណោះជាមួយអា កុយ ជា, អា ឡាយនី, អា ជិន ឈុនលាង និងអា ឡាំ វ៉ារី គឺ៤នាក់ក្នុងចំណោម១៩នាក់ ដែលបម្រើផលប្រយោជន៍អាចក្រពត្តិសេរីសូវៀត” ។

ចម្លើយសារភាពទាំង៣លើកនេះ ត្រូវបានសួរដោយអ្នកសួរចម្លើយក្នុងពួក៣ឈ្មោះ ណោ ចុម ។ ទោះបីជាមានការសារភាពនូវទោសកំហុស និងការបញ្ជាក់ជូនអង្គការដោយស្មោះត្រង់ឥតលាក់លៀមយ៉ាងណាក៏ដោយ ក៏អង្គការមិនលើកលែងឲ្យដែរ ព្រោះចម្លើយនេះមានចំណាររបស់ ឌុច ជាប្រធានមន្ទីរ ស-២១ បានសរសេរថា “ស្នើអាននិងក្តាប់ឲ្យជាប់, ឌុច” ។

ក្នុងចំណោមជនពាក់ព័ន្ធក្នុងចម្លើយទាំងនោះ មិនដឹងថាតើមានអ្នកទោសប៉ុន្មាននាក់ត្រូវបានចាប់យកមកសួរចម្លើយនិងត្រូវសម្លាប់ចោលនោះទេ ។ ហៃ គីមសៀង ត្រូវអង្គការយកទៅសម្លាប់នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៧ ។

**ឋ្លូង សុភារិទ្ធ**

## ពន្យល់ពាក្យខ្មែរក្រហម

◆ **ធាតុវណ្ណៈកម្មករៈ** គឺជាធាតុវណ្ណៈកម្មកររបស់បក្សដែលជាចំរើនជឿនលឿនជាងគេបំផុត ។

*(កំណត់ហេតុលេខ១២ កណាប ១៨១)*

◆ **ធាតុឈានមុខៈ** គឺឈានមុខខាងជំហរខាងស្មារតីខាងសកម្មភាពនិងប្រយុទ្ធមិនរុញរា ។

◆ **ធាតុពលកម្មៈ** គឺបង្កបង្កើនផលច្នៃប្រឌិត គឺធ្វើការគ្រប់បែបយ៉ាង ទាំងខាងដៃជើង ទាំងខាងខួរក្បាល ។

*(កំណត់ហេតុលេខ១២ កណាប ១៨១)*

◆ **អប់រំមនុស្សៈ** គឺការអប់រំកសាងសង្គមនិយម ។

*(កំណត់ហេតុ កណាប ២០៩)*

# ទាលពិឃាតនៅស្រុកអូររាំងឪ

(តចប់)

## ឃុំទួលសុភី

### ៧) ទីតាំងសម្លាប់ទួលមនោរម្យ

**លេខកូដភូមិសាស្ត្រ ៖ ០៣១ ១១០**

**ចំណុចខ្សែស្រប ៖ (N) ១១° ៤៨' ៥៦:៨៣"**

**រយៈបណ្តោយ ៖ (E) ១០៥° ៣៣' ៣២:៩១"**

ទីតាំងសម្លាប់ទួលមនោរម្យជាទីតាំងមួយដែលបច្ចុប្បន្នមានទួលខ្ពស់ ស្ថិតនៅក្នុងទឹកដីភូមិចន្ទអណ្តែត ឃុំទួលសុភី ស្រុកអូររាំងឪ ។ ប្រជាជនកសិករនៅទីនោះប្រមាណ៤គ្រួសារ នាំគ្នាដាំដំណាំនៅលើទួលនោះដូចជាខ្នុរ ដូង និងដំណាំហូបផ្លែមួយចំនួន ។ កាលពីជំនាន់ខ្មែរក្រហម ទួលមនោរម្យនេះគឺជាកន្លែងសម្លាប់មនុស្សយ៉ាងសាហាវមួយប្រចាំឃុំទួលសុភី ។ នៅលើទួលនេះមានរណ្តៅធំៗចំនួនពីរ ។ នៅពេលដែលខ្ញុំធ្វើដំណើរទៅដល់ ខ្ញុំសង្កេតឃើញប្រជាកសិករនាំគ្នាធ្វើស្មៅសម្អាតចម្ការសណ្តែកប្រមាណ៤-៥នាក់ ។ រណ្តៅដែលធំបង្អស់ត្រូវបានម្ចាស់ចម្ការដាំដើមខ្នុរមួយដើមទុកជាសម្គាល់ ។ គាត់និយាយថា គាត់ដាំសម្រាប់ចំណាំ និងងាយស្រួលប្រាប់ទៅក្មេងៗក្រោយៗថា កន្លែងដែលដាំដើមខ្នុរនេះជាកន្លែងសម្លាប់មនុស្សអស់រាប់ពាន់នាក់កាលពីជំនាន់ខ្មែរក្រហម ។ ការសម្លាប់មនុស្សនៅលើទួលមនោរម្យនេះប្រព្រឹត្តទៅនៅចុងឆ្នាំ១៩៧៨ គឺនៅពេលដែលខ្មែរក្រហមខាងភូមិភាគនិរតីចូលមកត្រួតត្រា ។ លោកអ៊ឹ អ៊ិនអៀន បានបញ្ជាក់ប្រាប់ថា នៅក្រោយពេលដែលសម្លាប់មនុស្សរួច ខ្មែរក្រហមបានលុបដី ហើយបានយកដើមចេកនិងដើមអំពៅមកដាំពីលើរណ្តៅនេះទៀត ។ លោកអ៊ឹនិយាយបន្តថា មូលហេតុដែលខ្មែរក្រហមធ្វើយ៉ាងនេះគឺដើម្បីបំភាន់ភ្នែកអ្នកស្រុកមិនឲ្យដឹងអំពីការសម្លាប់ ។ លោកអ៊ឹព្រមទាំងមិត្តភ័ក្តិម្នាក់ទៀតឈ្មោះ គាត់បាននាំគ្នារត់ចេញពីទីតាំងរណ្តៅដែលមានសាកសពរាប់ពាន់នោះទាំងសភាពភ័យតក់ស្លុត ។ នៅឆ្នាំ១៩៧៨ប្រជាជនភាគច្រើនទាំងមូលដ្ឋានចាស់និងថ្មី សុទ្ធតែត្រូវបានជម្លៀសបន្តទៅកាន់ខេត្តកំពង់ធំ និងមួយចំនួនទៀតត្រូវកម្ទេចចោលទាំងគ្មានកំហុស ។ មានប្រជាជនជាងមួយពាន់នាក់បានស្លាប់និងកប់នៅលើដីទួលមនោរម្យនេះ ។ ល្បិចបោកបញ្ឆោតមនុស្សយកទៅសម្លាប់នៅលើទួលមនោរម្យ ត្រូវបានលោកតូ សាំង សៀន អាយុ៥២ឆ្នាំ ជាប្រជាជនរស់នៅភូមិចន្ទអណ្តែត ឃុំទួលសុភី អធិប្បាយថា ខ្មែរក្រហមបានប្រមូលទាំងប្រជាជនទាំងយោធាខ្មែរក្រហមនៃភូមិភាគបូព៌ា ពីកន្លែងផ្សេងៗក្នុងឃុំទួលសុភីមកប្រជុំដើម្បីរំសាយឲ្យទៅកាន់អង្គភាពវិញ ។ ចំពោះប្រជាជនដែលជម្លៀសមកពីទីក្រុងភ្នំពេញ ខ្មែរក្រហមប្រកាសថាឲ្យវិលត្រឡប់ទៅស្រុកកំណើតឬទៅភ្នំពេញវិញ ។ តាមការពិត នេះគឺជាពាក្យភូតកុហករបស់ខ្មែរក្រហមប៉ុណ្ណោះ ។ មនុស្សទាំងអស់ក្នុងឃុំទួលសុភីត្រូវបានសម្លាប់ ។ លោកតូ សាំង សៀន ប្រាប់បន្តថា "បើនិយាយពីឃុំទួលសុភីគឺ១៩ភូមិ ហើយមានយកមកពីឃុំចកខ្លះទៀត គឺប្រមូលមកទាំងអស់ ។ នេះបានន័យថាវាច្រើនដែររណ្តៅ២ហ្នឹងគឺពេញៗ" ។ លោកតូ សាំង សៀន បានឃើញការបណ្តើរមនុស្សមកសម្លាប់នៅលើទួលមនោរម្យផ្ទាល់នឹងភ្នែក ។ គាត់លបមើលតាមប្រឡោះដើមចេកនិងដើមអំពៅ ពេលដែលគាត់កំពុងឃ្វាលគោ ។ លោកតូបានប្រាប់ទៀតថា អ្នកទោសទាំងនោះភាគច្រើនជាអ្នកជាប់និន្នាការជាមួយរបបសាធារណរដ្ឋខ្មែរ និងកម្មាភិបាលខ្មែរក្រហមដូចគ្នាដែលត្រូវបានចាត់ទុកថាជាខ្មាំងក្បត់នឹងអង្គការ ។ ការសម្លាប់នៅលើទួលនេះប្រព្រឹត្តទៅនៅចុងឆ្នាំ១៩៧៨ គឺប្រើរយៈពេលបីថ្ងៃប៉ុណ្ណោះក្នុងការសម្លាប់ ហើយគ្មានការសួរចម្លើយទេនៅមុនពេលសម្លាប់ ។ ភាគច្រើននៃនារីភេទត្រូវបានចាប់រំលោភជាមុនទើបសម្លាប់ជាក្រោយ ។ ឃាតករគឺជាកម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីដែលមានសម្តីរដឹនៗ និងកម្មាភិបាលខ្មែរក្រហមមកពីខាងភូមិភាគកណ្តាល ។ ការសម្លាប់ប្រព្រឹត្តទៅជាមួយនឹងការចាក់មីក្រូកងរំពងពេញព្រៃ ។

លោកអ៊ឹ អ៊ិន អៀន មានប្រសាសន៍ថា "សំឡេងមីក្រូច្រើនបន្លឺឡើងនៅម៉ោង៤រសៀល"។ លោកតា ឡូញ ឡាញ់ និយាយថា គាត់បានឃើញខ្មែរក្រហមកំពុងសម្លាប់មនុស្សនៅលើទួលមនោរម្យនៅពេលដែលគាត់តាមរកគោ។ លោកតាឡូញ ឡាញ់ បានបន្តថា ខ្មែរក្រហមមានគ្នាប្រមាណពី៥០ទៅ៦០នាក់បានស្នាក់នៅក្នុងមន្ទីរមួយនៅក្បែរទួលមនោរម្យ។ បរិវេណជុំវិញកន្លែងសម្លាប់ជាតំបន់ហាមឃាត់ ក្មេងឃ្វាលគោទាំងឡាយត្រូវបណ្តេញចេញទៅឆ្ងាយ។ ក្រោយឆ្នាំ១៩៧៩ លោកតូ សាំង សៀន បានទៅមើលរណ្តៅដែលសម្លាប់មនុស្សកាលពីចុងឆ្នាំ១៩៧៨ គាត់បានឃើញរណ្តៅទាំងពីរនេះស្រុតចុះហើយឃើញស្នាមមាត់រណ្តៅយ៉ាងធំ។ ក្រោយមករណ្តៅទាំងពីរនេះត្រូវបានគាស់យកឆ្អឹងដាក់លើមាត់រណ្តៅចំនួនពីរគំនរ។ លោកតូ សាំង សៀន បានប៉ាន់ស្មានថាមានចំនួនសាកសពរាប់ពាន់នាក់ក្នុងរណ្តៅទាំងពីរ។ រណ្តៅទាំងពីរនេះមានចម្ងាយប្រហែល១០ម៉ែត្រពីគ្នា។ រណ្តៅមួយៗមានទំហំប្រហែលជា១០ម៉ែត្របួនជ្រុង និងជម្រៅពី៥ទៅ៦ម៉ែត្រ។ លោកតា ទន អ៊ីម អាយុ៦១ឆ្នាំ រស់នៅភូមិដំណាក់កែវ ឃុំទួលសុភី បានឲ្យដឹងថាគាត់ជាម្ចាស់ចម្ការដែលមានរណ្តៅទាំងពីរនេះ។ ក្រោយឆ្នាំ១៩៧៩ លោកតាបានមកឃើញរណ្តៅនៅក្រហូត ហើយមានឆ្អឹងជាប់សាច់ និងលលាដ៍ក្បាលដែលមិនទាន់ជ្រុះសក់អស់នៅឡើយ។ ឪពុករបស់លោកតាបានប្រមូលឆ្អឹងដែលនៅលើដីនោះដាក់ចូលក្នុងរណ្តៅវិញ និងលុបដីពីលើ។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ពេលដែលលោកតាភ្ជួររាស់ធ្វើចម្ការរាល់រដូវកាលពីមុន គាត់តែងតែជួបប្រទះឃើញឆ្អឹងលលាដ៍ក្បាលពាសវាលពាសកាលពេញដី ហើយគាត់ក៏រើសបោះចូលក្នុងរណ្តៅ។ បន្ទាប់មក ដោយឃើញថាលែងបានជួបទៀត គាត់ក៏លុបដីពីលើមួយសាទៀត ហើយបានដាំដើមខ្នុរមួយដើមពីលើដីដែលលុប។ ចំពោះចំនួនប៉ាន់ប្រមាណមនុស្សដែលស្លាប់វិញគឺមានចំនួនរហូតដល់ទៅ៤០០នាក់ក្នុងរណ្តៅទាំងពីរនេះ។

**៨) ទីតាំងគុកសន្តិសុខនិងកន្លែងសម្លាប់ភ្នំដី**

**លេខកូដភូមិសាស្ត្រ៖ ០៣១ ១១១**

**ចំណុចខ្សែស្របៈ (N) ១១º ៤៨' ២៧:៨១"**

**រយៈបណ្តោយៈ (E) ១០៥º ៣៣' ០៨:១៨"**

ភ្នំដីជាទីតាំងមួយស្ថិតនៅក្នុងភូមិភ្នំដី ឃុំទួលសុភី។ បច្ចុប្បន្នភ្នំនេះនៅតែឈរជន្រ្ទឹងយ៉ាងសង្ហាបង្ហួតគេឯងគ្រប់គ្នាថាខ្លួននៅតែមានមនុស្សគោរពកោតខ្លាច។ ក្នុងជំនាន់ខ្មែរក្រហម ភ្នំនេះគឺជាមន្ទីរសន្តិសុខរបស់ភូមិភាគបូព៌ាដែលគ្រប់គ្រងដោយឈ្មោះតែម ជាមនុស្សបន្ទាប់ពី សោ ភឹម (ប្រធានភូមិភាគបូព៌ា)។ មន្ទីរសន្តិសុខនេះត្រូវបានសាងសង់ឡើងពីខឿនក្រោមជាបេតុងនិងមានជញ្ជាំងក្តារប្រក់ស្បៀង។ ក្រោយឆ្នាំ១៩៧៩ ប្រជាជនដែលនៅសល់ពីស្លាប់បាននាំគ្នាទៅគាស់យកក្តារជញ្ជាំងមកធ្វើផ្ទះ។ ឯខឿនក្រោមជាបេតុងនោះគឺស្ថិតនៅរហូតដល់សព្វថ្ងៃ។ ខ្ញុំបានធ្វើដំណើរទៅកាន់ទីតាំងនោះដែលមានចម្ងាយប្រមាណ៧០០ម៉ែត្រពីទីតាំងសម្លាប់ទួលមនោរម្យ។

រឿងរ៉ាវដែលបានកើតឡើងនៅលើភ្នំដីមិនត្រូវបានបំភ្លេចពីអារម្មណ៍របស់មនុស្សវ័យចំណាស់ៗក្នុងឃុំថ្នាដានិងឃុំទួលសុភីទេ។ គ្រាន់តែរំឭកពីការសម្លាប់មនុស្សកាលពីជំនាន់ខ្មែរក្រហមភ្លាម អ្នកស្រុកនៅទីនោះហាក់ពេញចិត្តនឹងនិយាយប្រាប់ខ្ញុំទាំងអស់គ្មានលាក់លៀមឡើយ។ លោកពូ លី ងៀន អាយុ៤៨ឆ្នាំ រស់នៅភូមិចន្ទអណ្តែត ឃុំទួលសុភី ស្រុកអូររាំងឪ បាននិយាយថា អ្នកទោសដែលយកមកដាក់ក្នុងមន្ទីរឃុំឃាំងភូមិភាគបូព៌ានេះគឺជាមនុស្សដែលមានឋានៈជាកម្មាភិបាលនិងយោធាខ្មែរក្រហម។ លោកពូ លី ងៀន បន្តថា គុកភូមិភាគនេះបានបង្កើតឡើងតាំងពីឆ្នាំ១៩៧៥មកម្ល៉េះ សម្រាប់ឃុំឃាំងកម្មាភិបាលនិងយោធាខ្មែរក្រហមដែលមានកំហុស។ លោកពូម៉ៅ ម៉ុន អាយុ៥២ឆ្នាំ បាននិយាយពីការដែលខ្មែរក្រហមបោកបញ្ឆោតកម្មាភិបាលខ្លាំងៗមកដាក់គុកថា មានបញ្ជាមួយឲ្យហៅកម្មាភិបាលដែលនៅខេត្តព្រៃវែង ខេត្តស្វាយរៀង និងកន្លែងផ្សេងៗ មករៀនសូត្រនៅកន្លែងនេះ(ភ្នំដី)។ អ្នកទោសទាំងអស់ត្រូវទទួលទណ្ឌកម្មឲ្យលើកដូវមួយខ្សែពីភូមិចូលមកកាន់ទីតាំងមន្ទីរសន្តិសុខភ្នំដី និងក្រៅពីនេះមានឲ្យធ្វើការខ្លះទៀតដូចជាធ្វើដីដាក់ស្រូវជាដើម។ អំពើទាំងនេះត្រូវបានលោកពូសន្និដ្ឋានថា "សកម្មភាពរបស់ខ្មែរក្រហមនេះបានន័យថាវាសម្លាប់ឥតមានពិចារណា គ្មានរកយុត្តិធម៌ឲ្យកម្មាភិបាលដូចគ្នា ក៏ដូចជារាស្ត្រដទៃ

ទៀត អត់មានរកយុត្តិធម៌ទេ ឲ្យតែខុសដឹងតែរកត្បូងចបនិងសម្លាប់» ។ មានកន្លែងសម្លាប់មួយស្ថិតនៅខាងកើតភ្នំដីប្រមាណ ៥០ម៉ែត្រតែប៉ុណ្ណោះ ។ ចំពោះការធ្វើទណ្ឌកម្មអ្នកទោសវិញ លោកពូ លី ផៀន និយាយថា គាត់បានឃើញផ្ទាល់ភ្នែកនូវការធ្វើទារុណកម្មយ៉ាងសាហាវបំផុត ជួនកាលអ្នកទោសមិនទាន់ស្លាប់ផងត្រូវខ្មែរក្រហមសែងយកទៅកប់ទាំងរស់ ។ មានអណ្តូងមួយសម្រាប់សួរចម្លើយអ្នកទោសដែលស្ថិតនៅប៉ែកខាងលិចមន្ទីរឃុំឃាំងភ្នំដី ។ លោកពូម៉ៅ ម៉ុន បាននិយាយពីរឿងនេះប្រាប់ថា នៅគែមសងខាងមាត់អណ្តូងមានដាំបង្គោលពីរ ហើយមានបោះដាធ្នឹមសម្រាប់ព្យួរជើងអ្នកទោសឡើងលើ សំយុងក្បាលចុះក្នុងទឹក (បច្ចុប្បន្នអណ្តូងនេះនៅមានស្លាកស្នាមនៅឡើយ) ។ ឯអ្នកទោសដែលជាប់នៅខាងក្នុងវិញ គឺស្ថិតនៅក្នុងទ្រុងមួយឈរ ហើយគាបរើខ្លួនមិនរួចទាំងយប់ទាំងថ្ងៃ រហូតទាល់តែដល់ថ្ងៃដែលត្រូវយកទៅសម្លាប់ចោល ។ ការសម្លាប់មនុស្សកើតមានជារៀងរាល់ថ្ងៃ ។ លោកពូ ម៉ៅ ម៉ុន បានអធិប្បាយថា ប្រសិនបើអ្នកទោសណាមានទោសធ្ងន់ គឺយកមកដល់ភ្លាមសម្លាប់ភ្លាមដោយមិនបាច់សួរចម្លើយ ។ ឯអ្នកទោសស្រាលត្រូវឆ្លងកាត់ការសួរចម្លើយជាមុនសិន ។ ការសួរចម្លើយគឺផ្តោតសំខាន់ទៅលើការដជីកសួរពីអ្នកនៅពីក្រោយខ្នងនៃការធ្វើសកម្មភាពក្បត់ ។ យូរៗមានបាញ់គ្នាម្តងរវាងអ្នកទោសនិងអ្នកមើលការខុសត្រូវនៅក្នុងគុក ។ ទោះជាមានការប៉ះទង្គិចគ្នាយ៉ាងនេះក៏ដោយ មន្ទីរសន្តិសុខរបស់ភូមិភាគបូព៌ានៅតែបន្តការគ្រប់គ្រងរហូតដល់បែកឆ្នាំ១៩៧៩ ។ សមមិត្ត តែម ដែលជាអនុប្រធានភូមិភាគបូព៌ា និងជាប្រធានមន្ទីរសន្តិសុខនេះ ត្រូវបានអ្នកស្រុកសម្លាប់នៅក្រោយថ្ងៃ ៧ ខែមករា ឆ្នាំ១៩៧៩ ។ បក្ខពួកមួយចំនួនទៀតរបស់សមមិត្ត តែម ត្រូវបែកខ្ញែក ។ ខ្លះស្លាប់ ខ្លះភៀសខ្លួនទៅរស់នៅកន្លែងផ្សេង ។ ឯគុកនេះត្រូវបានប្រជាជនរុះរើយកទៅធ្វើផ្ទះសម្បែង ប៉ុន្តែបានបន្សល់ទុកខ្លោះឃ្លាងជាច្រើនគំនរ ស្លាកស្នាមរណ្តៅជាប់ជើងភ្នំដី រួមជាមួយខ្នើនគុក និងស្លាកស្នាមអណ្តូងសម្រាប់អនុវត្តទារុណកម្មលើអ្នកទោសក្នុងពេលសួរចម្លើយ ។ លោកពូ ម៉ៅ ម៉ុន បានឲ្យដឹងថា មានរណ្តៅកប់សាកសពច្រើនណាស់ រាប់ទាំងរណ្តៅធំពីរនិងរណ្តៅតូចដែលកប់មនុស្សបានម្នាក់ឬពីរនាក់ ។ តាមសម្តីសាក្សីទាំងពីរខាងលើគឺលោក ម៉ៅ ម៉ុន និងលោក លី ផៀន ថាសាកសពទាំងអស់មានចំនួនលើសពី៣០០០នាក់ ។

**៩) ទីតាំងសម្លាប់ដាយចម្ការកៅស៊ូ**

**លេខកូដភូមិសាស្ត្រ ៖ ០៣១ ១១២**

**ចំណុចខ្សែស្រប ៖ (N) ១១° ៤៩' ៣០៖១៥"**

**រយៈបណ្តោយ ៖ (E) ១០៥° ៣២' ៤៤៖២៣"**

មានអណ្តូងទឹកមួយនៅជាប់នឹងដាយចម្ការកៅស៊ូលេខ៨៤ ហើយដែលស្ថិតនៅក្នុងទឹកដីភូមិថ្នាដាកើត ឃុំទួលសុភី ស្រុកអូររាំងឪ ។ អណ្តូងមួយនេះត្រូវបានជីកតាំងពីមុនរបបខ្មែរក្រហម ដើម្បីរក្សាទឹកទុកសម្រាប់ធ្វើចម្ការ ។ ក៏ប៉ុន្តែនៅជំនាន់ខ្មែរក្រហម អណ្តូងទឹកមួយនេះត្រូវបានជ្រើសរើសយកធ្វើជាអណ្តូងសម្រាប់ដាក់សាកសព ។ ហេតុការណ៍នានាដែលបានកើតឡើងកាលពីជំនាន់ខ្មែរក្រហមនៅទីតាំងដាយចម្ការកៅស៊ូ៨៤ មានតែមនុស្សពីរនាក់គត់ដែលបានដឹងនិងឃើញផ្ទាល់ភ្នែក ។ លោកពូ សំ សន បានប្រាប់ថា «ខ្ញុំបានឃើញការសម្លាប់មនុស្សដោយផ្ទាល់ភ្នែក គឺទាញមនុស្សពីលើរថយន្តមកវាយទម្លាក់ចូលក្នុងអណ្តូង» ។ លោកពូ ហឿន ហន ក៏បានឃើញហេតុការណ៍នេះផ្ទាល់នឹងភ្នែកដែរ ។ លោកពូ ហន បានអធិប្បាយនូវដំណើររឿងថា នៅពេលដែលគាត់បានលួចរត់ចេញពីកន្លែងសម្លាប់ឪពុកម្តាយរបស់គាត់នៅទួលមនោរម្យមក គាត់បានរត់សំដៅមកតំបន់ដាយចម្ការកៅស៊ូនេះ ដែលជាកន្លែងគាត់ធ្លាប់ឃ្វាលក្របី ។ នៅពេលមកដល់ គាត់បានជ្រុលដំណើរចូលដល់កន្លែងសម្លាប់តែម្តង ហើយបានឃើញយោធាខ្មែរក្រហមឈរច្រើនច្រាំងជុំវិញមាត់អណ្តូង ។ ពេលនោះយោធាខ្មែរក្រហមបាននិយាយមកកាន់គាត់នូវសំនៀងរដឺនៗថា «អាវ៉ាថយបន្តិច បងធ្វើការសិន» ។ លោកពូក៏ប្រញាប់ប្រញាល់បកមកក្រោយវិញ ហើយបានឡើងលើដើមពោធិ៍ដើម្បីលួចមើលព្រឹត្តិការណ៍ ។ ភាពភ័យតក់ស្លុតរបស់លោកពូបានកើតឡើងភ្លាមនៅពេលដែលឃើញការសម្លាប់មនុស្សទាំងស្រស់ៗបែបនេះ ហើយនឹកឃើញអំពីការសម្លាប់របស់ខ្មែរក្រហមមកលើឪពុកម្តាយខ្លួននៅមនោរម្យ ។ ព្រឹត្តិការណ៍សម្លាប់នេះត្រូវបានលោកពូរៀបរាប់ថា ខ្មែរក្រហម

បានទាញមនុស្សម្នាក់ពីលើរថយន្តដែលចតជាប់នឹងមាត់អណ្តូងស្រាប់ ហើយវាយសំពងពីក្រោយទម្លាក់ចូលក្នុងអណ្តូង ។ លោកពូបន្តថា មានអ្នកខ្លះមិនទាន់ស្លាប់ភ្លាមទេ ប៉ុន្តែនៅពេលដែលធ្លាក់ចូលក្នុងអណ្តូងដែលមានជម្រៅ១៥ម៉ែត្រ បូករួមជាមួយការវាយអ្នកផ្សេងៗទម្លាក់ទៅទៀត គឺត្រូវតែដាច់ខ្យល់ស្លាប់ព្រមគ្នានឹងអ្នកក្រោយដែរ ។ ចំពោះប្រភេទជនរងគ្រោះដែលត្រូវយកមកសម្លាប់នៅទីនេះ គឺសុទ្ធសឹងតែជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ថាប្រព្រឹត្តក្បត់នឹងអង្គការ ។ លោកពូ ហឿន ហន បាននិយាយថា "អ្នកដែលមកស្លាប់នៅទីនេះគឺជាប្រធានកងតូច ប្រធានកងធំ ប្រធានក្រុម ប្រធានភូមិនិងកងចល័ត របស់ខ្មែរក្រហម" ។ ការសម្លាប់ប្រព្រឹត្តទៅនៅម៉ោង៨និង៣០នាទីល្ងាច តែក្នុងរយៈពេល១ថ្ងៃគត់ ។ ពីរថ្ងៃក្រោយមក លោកពូ ហឿន ហន បានទៅមើលកន្លែងសម្លាប់ គាត់បានឃើញក្នុងអណ្តូងពោរពេញទៅដោយខ្មោចដែលហើមស្អឹង ។ គាត់បន្តថា នៅសល់តែកម្ពស់២ម៉ែត្រទៀតប៉ុណ្ណោះ គឺពេញដល់មាត់លើនៃអណ្តូងហើយ ។ ចំណែកឯលោកពូ សំ សន និយាយថា ១០ថ្ងៃក្រោយពីការសម្លាប់ គាត់បានទៅមើលកន្លែងនោះ ហើយបានឃើញយ៉ាងច្បាស់នូវសភាពហើមស្អុយរលួយពោរពាសចេញពីមាត់អណ្តូងមកក្រៅ ។ គាត់និយាយថា "ខ្ញុំបានឃើញឈាមហូរចេញពីមាត់អណ្តូងមកខាងក្រៅ" ។ ចំនួនសាកសពនៅក្នុងអណ្តូងនោះ តាមដែលលោកពូទាំងពីរប៉ាន់ស្មានទៅគឺមានចំនួនពី៧០ទៅ៨០នាក់ ។

### ១០) ទីតាំងសម្លាប់កោះញែក

***លេខកូដភូមិសាស្ត្រ៖ ០៣១ ១១៣***

***ចំណុចខ្សែស្រប៖ (N) ១១$^{0}$ ៤៩' ២៨៖៩៥"***

***រយៈបណ្តោយ៖ (E) ១០៥$^{0}$ ៣២' ៥០៖៧៩"***

ទីតាំងសម្លាប់កោះញែក ស្ថិតនៅចម្ងាយប្រហែល៤០០ម៉ែត្រពីទីតាំងសម្លាប់ដាយចម្ការកៅស៊ូ៨៤ប៉ែកខាងកើត ។ ទីតាំងនេះស្ថិតនៅប៉ែកខាងជើងឆៀងខាងលិចវត្តថ្មដាប្រហែល៥០០ម៉ែត្រនៅលើដីដាំសណ្តែករបស់ម្ចាស់ចម្ការមួយក្នុងភូមិថ្មដាកើត ឃុំទួលសុភី ស្រុកអូររាំងឪ ។ តាមរបាយការណ៍ពីការិយាល័យធម្មការនិងសាសនាស្រុក បានឲ្យដឹងថា ទីតាំងសម្លាប់កោះញែកមានចំនួន១រណ្តៅ និងជនរងគ្រោះចំនួន១៦៤នាក់ ។ តាមការសាកសួរពត៌មានផ្ទាល់ពីសាក្សីដឹងឮនៅក្នុងភូមិថ្មដាកើតថាមានចំនួន២រណ្តៅ និងចំនួនជនរងគ្រោះពី១៦៤-១៧០នាក់ ។ លោកពូ សំ សន បច្ចុប្បន្នជាមេភូមិថ្មដាកើតនិយាយថា "កោះញែកមាន២រណ្តៅ ហើយក្នុងរណ្តៅនីមួយៗមានទទឹង៣ម៉ែត្រ បណ្តោយ៥ម៉ែត្រ ជម្រៅ៣ម៉ែត្រ" ។ ហេតុការណ៍សម្លាប់តាំងពីដើមដល់ចប់នៅលើទីតាំងកោះញែកត្រូវបានលោកពូឃ្លាំមើលឃើញទាំងអស់នូវសកម្មភាពពិតៗ ។ លោកពូពិពណ៌នាថា ពេលមួយ ក្រុមការងាររបស់លោកពូកំពុងបំពេញការងារនៅលើកោះញែកនេះ ស្រាប់តែមានខ្មែរក្រហមប្រមាណ១០នាក់មកប្រាប់ថាឲ្យថយចេញពីទីនេះបន្តិចសិន ព្រោះត្រូវមានការធ្វើនៅកន្លែងនេះ ។ ឮដូច្នេះប្រជាជនទាំងអស់គ្មាននរណាម្នាក់ហ៊ានជំទាស់ឡើយ ។ ផ្ទុយទៅវិញលោកពូបានលួចឡើងលើដើមអំពិលមួយដើមដែលស្ថិតនៅឆ្ងាយបន្តិចពីទីតាំងដើម្បីលបមើលហេតុការណ៍ដែលហៀបនឹងកើតមាន ។ ក្រោយពីប្រជាជនចេញអស់ទៅមួយស្របក់ លោកពូបានឃើញរថយន្តចិនជាច្រើនដឹកមនុស្សពេញៗមកឈប់ជាប់នឹងមាត់រណ្តៅដែលបានជីករួចជាស្រេច ។ ការងារបន្ទាប់របស់ខ្មែរក្រហមគឺវាយអ្នកទោសដែលមានចងស្លាបសេកនិងចងមុខរួចជាស្រេចនោះទម្លាក់ចូលទៅក្នុងរណ្តៅ ។ ការសម្លាប់ចាប់ផ្តើមនៅម៉ោង៣រសៀល ។ ឧបករណ៍ដែលខ្មែរក្រហមប្រើដើម្បីសម្លាប់ជនរងគ្រោះគឺដំបងនិងគល់ពីងពង់ ។ រយៈពេល១០ថ្ងៃក្រោយការសម្លាប់ លោកពូបានទៅមើលរណ្តៅនោះ ហើយបានឃើញសាកសពហើមរលួយស្អុយប្រេះដីក្រហមដែលគ្រាន់តែលប់ពីលើសើៗ ។ ដំបងនិងគល់ពីងពង់ដែលខ្មែរក្រហមប្រើសម្រាប់ពិឃាតមនុស្ស ស្ថិតនៅរាយប៉ាយក្បែររណ្តៅ ។ លោកពូបញ្ជាក់ថា គាត់មិនដែលឃើញមុខខ្មែរក្រហមក្រុមនេះទេពីមុនមក ព្រោះជាក្រុមដែលមកពីស្រុកឆ្ងាយៗ ។ ក្រោយឆ្នាំ១៩៧៩ រណ្តៅចំនួនពីរត្រូវបានគាស់ឡើង ។ គោលបំណងនៃការគាស់គឺដើម្បីរកមាសនិងវត្ថុមានតម្លៃផ្សេងៗដែលជាប់នៅនឹងខ្លួនសាកសព ។ ឆ្អឹងជាច្រើនត្រូវបានរើសគរវែងឡើងលើយ៉ាងរប៉ាត់រប៉ាយ ហើយមិនមានការលុបរណ្តៅឲ្យជិតវិញ

ឡើយ ។ ឆ្អឹងទាំងប៉ុន្មានត្រូវបាត់បង់អស់ដោយការបំផ្លាញពីសត្វផ្សេងៗ ។ មកទល់បច្ចុប្បន្ននេះ ស្លាកស្នាមរណ្តៅនៅតែមិនទាន់រលុបនៅឡើយ ។ ក្នុងរយៈពេលមួយថ្ងៃតែប៉ុណ្ណោះ មនុស្សស្លូតត្រង់ចំនួន១៧០នាក់ ត្រូវបានសម្លាប់នៅលើទឹកដីកោះញែកនេះ ។

## ឃុំមៀន

### ១១) ទីតាំងសម្លាប់អ្នកតាចាអាង

***លេខកូដភូមិសាស្ត្រ ៖ ០៣១ ១១៤***

***ចំណុចខ្សែស្រប ៖ (N) ១១⁰ ៤៨' ៤៧៖៤៧"***

***រយៈបណ្តោយ ៖ (E) ១០៥⁰ ២៦' ០៨៖៤៥"***

រោងអ្នកតាចិនមួយកន្លែងត្រូវបានប្រជាជននៅភូមិបឹងកណ្តាល ឃុំមៀន ស្រុកអូររាំងឪ ខេត្តកំពង់ចាម និយមហៅតាំងពីដើមមកថាជាអ្នកតាចាអាង ។ រោងអ្នកតានេះស្ថិតនៅជាប់ជ្រុងខាងលិចផ្លូវថ្នល់មួយ ។ ប្រសិនបើយើងធ្វើដំណើរចេញពីសាលាស្រុកអូររាំងឪមកគឺមានចំនួន៧គីឡូម៉ែត្រ ដោយឆ្លងកាត់តាមភូមិថ្មសំលៀង ឃុំមៀន និងឆ្លងកាត់ទីតាំងសម្លាប់មួយទៀតឈ្មោះបឹងកំពិត ។ នៅក្បែរទីតាំងសម្លាប់អ្នកតាចាអាង ប៉ែកខាងត្បូង យើងសង្កេតឃើញមានស្នាមក្រហេងក្រហូងជាច្រើនកន្លែង ។ ទីនេះគឺជាកន្លែងដែលកម្មករឡូតិ៍ជីកយកអាចម៍ដីមកផលិតជាឥដ្ឋនិងក្បឿង ប៉ុន្តែក៏មានរណ្តៅសម្លាប់មនុស្ស១នៅជាមួយនោះដែរ ។ តាមការបកស្រាយរបស់អ្នកមីង ពិន សុខន ថាមានការសម្លាប់មនុស្សដាក់ក្នុងរណ្តៅមួយស្ថិតនៅជាប់នឹងមាត់ស្ទឹងមួយដែលតភ្ជាប់មកពីបឹងកំពិត ។ គាត់បានឃើញដោយផ្ទាល់ភ្នែកនូវមនុស្សពីរនាក់ដែលត្រូវបាញ់សម្លាប់ដោយយោធាខ្មែរក្រហមខាងភូមិភាគនិរតី ។ អ្នកស្លាប់ទាំងពីរនាក់នោះជាបុរសម្នាក់និងស្ត្រីម្នាក់ ។ តាមការអះអាងរបស់អ្នកមីងថាអ្នកទាំងពីរនេះជាកម្មាភិបាលខ្មែរក្រហមខាងភូមិភាគបូព៌ា ហើយត្រូវបានចោទថាក្បត់ ។ ជនក្បត់ទាំងពីរត្រូវបានបាញ់សម្លាប់ភ្លាមៗនៅនឹងរណ្តៅក្បែររោងអ្នកតាចាអាង ។ ការបាញ់សម្លាប់នេះគឺក្រោយពេលសម្លាប់រួមមួយដែលធ្វើឡើងដោយខ្មែរក្រហមនៅភូមិភាគបូព៌ាមកលើប្រជាជនស្លូតត្រង់មួយចំនួនដែលជាប់គុកនៅវត្តមុនីរង្សី ហៅវត្តកំពង់បឹង ។ ហេតុការណ៍សម្លាប់ជនរងគ្រោះដែលជាប់គុកនៅវត្តកំពង់បឹងនេះ អ្នកមីង ពិន សុខន បានរៀបរាប់ថា មុននឹងត្រូវយកមកសម្លាប់នៅក្បែររោង



សុខ ហេង ថតនៅពីមុខរណ្តៅសាកសពដែលត្រូវទឹកលិចនៅរដូវវស្សា ភូមិបឹងកណ្តាល ឃុំមៀន

អ្នកតាចាអាងនេះ ជនរងគ្រោះទាំងនោះស៊ើរស្លាប់ស៊ើររស់ទៅហើយ ព្រោះជាប់នៅមន្ទីរសន្តិសុខឯវត្តកំពង់បឹងនោះគ្មានបានអ៊ីហូបទេ ។ អ្នកទោសខ្លះយកក្រមាដែលនៅជាប់នឹងខ្លួនបរិភោគអស់ជាងពាក់កណ្តាល ។ ទិដ្ឋភាពនៅមន្ទីរសន្តិសុខវត្តកំពង់បឹងគឺយកទីធ្លាវត្តទាំងមូលធ្វើជាបរិវេណសន្តិសុខរបស់ស្រុក ហើយយកសាលារាប់បាត្រ (ឧបដ្ឋានសាលា) ដែលមានពីរជាន់ធ្វើជាកន្លែងឃុំឃាំង ។ ជាន់ក្រោមឃុំឃាំងប្រភេទអ្នកទោសកម្រិតធ្ងន់ ហើយតម្រូវដាក់ខ្នោះទាំងយប់ទាំងថ្ងៃ ។ ឯជាន់លើនៃសាលាឆាន់សម្រាប់ឃុំឃាំងប្រភេទអ្នកទោសកម្រិតស្រាល ។ អ្នកទោសប្រភេទនេះអាចបញ្ចេញឲ្យទៅធ្វើការងារជាមួយប្រជាជនធម្មតាបាននៅពេលថ្ងៃ ។ មន្ទីរនេះត្រូវបានបង្កើតឡើងដោយខ្មែរក្រហមខាងភូមិភាគបូព៌ា ហើយត្រូវបំផ្លាញចោលវិញដោយខ្មែរក្រហមខាងភូមិភាគនិរតី ។ ចាប់តាំងពីកម្មាភិបាលខ្មែរក្រហមខាងនិរតីចូលមកគ្រប់គ្រងភូមិភាគបូព៌ា មន្ទីរនេះហាក់មានភាពរប៉ាត់រប៉ាយ រហូតដល់មានការរុះរើចេញទាំងអស់ ហើយលែងមានការឃុំឃាំងអ៊ីទៀតដែរ ។ ប៉ុន្តែព្រឹត្តិការណ៍នេះកើតឡើងក្រោយការសម្លាប់មនុស្សនៅក្បែររោងអ្នកតាចាអាងរួចទៅហើយ ។ កម្មាភិបាលខ្មែរក្រហមខាងភូមិភាគបូព៌ាមួយចំនួន ត្រូវបានកម្ទេចចោលដោយកម្មាភិបាលខ្មែរក្រហមខាងនិរតី នៅពីលើរណ្តៅដែលខ្លួនបានកម្ទេចប្រជាជនស្លូតត្រង់កាលពីលើកមុន ។ លោកតា សុខ ហេង អាយុ៥៦ឆ្នាំ ជាប្រជាជនរស់នៅភូមិកំពង់បឹង ឃុំមៀន ស្រុកអូររាំងឪ បាននិយាយពីរឿងនេះថា កន្លែងអ្នកតាចាអាងនេះមានសម្លាប់មនុស្សស្លូតត្រង់ផងនិងមានសម្លាប់មនុស្សដែលធ្លាប់ជាឃាតករផង ។ រឿងនេះដូចអ្នកមីង ពិន សុខន និយាយថា ជាការចោទប្រកាន់គ្នាឯងថាក្បត់នឹងអង្គការបក្ស ។ លោកតា សុខ ហេង និយាយបន្តបញ្ជាក់ថាគាត់បានឃើញដោយផ្ទាល់នឹងភ្នែកនូវព្រឹត្តិការណ៍សម្លាប់គណៈឃុំពីររូបដែលជាកម្មាភិបាលខ្មែរក្រហមខាងបូព៌ា ។ ដំបូងឃើញសម្លាប់គណៈឃុំជាស្ត្រីមុន ដោយយកឈើនិងចុងកាំភ្លើងទៅរុកចំទ្វារមាសរបស់ស្ត្រីគណៈឃុំនោះ រួចអូសចុះឡើងជាច្រើនសា

ប៊ុល ពិន ថតនៅពីមុខរណ្តៅសាកសព ៣-២ ឋិតនៅភូមិជ្រៃតាសូ ឃុំអំពិលតាពក ស្រុកអូររាំងឪ ខេត្តកំពង់ចាម



រួចទើបបាញ់ចំទ្វារមាសជាច្រើនគ្រាប់រហូតដល់ស្លាប់ ។ បន្ទាប់មកបានបាញ់រះទៅលើម្នាក់ទៀត ។ លោកពូបានប្រាប់ពីចំនួនជនរងគ្រោះដែលបានស្លាប់នៅក្នុងរណ្តៅជិតអ្នកតាចាអាងថាមានចំនួនពី៥០ទៅ៦០នាក់ដាក់ក្នុងរណ្តៅតែមួយប៉ុណ្ណោះ ។ លោកពូបន្តថា ក្រោយព្រឹត្តិការណ៍ប៉ុន្មានថ្ងៃ គាត់បានដើរមកមើលក៏ឃើញសាកសពទាំងមុនទាំងក្រោយហើមស្អុរហើយស្អុយទៀត ។ ការសម្លាប់មនុស្សនៅក្បែររោងអ្នកតាចាអាងនេះគឺមានសម្លាប់ទាំងប្រជាជនស្លូតត្រង់និងកម្មាភិបាលខ្មែរក្រហមដូចគ្នាបន្ទាប់ពីមានភាពវឹកវរដោយគណៈភូមិភាគបូព៌ាក្បត់នឹងបដិវត្តន៍ ។

**ឃុំអំពិលតាពក**

***១២) ទីតាំងសម្លាប់ ព-២***

***លេខកូដភូមិសាស្ត្រៈ ០៣១១ ១៥,១៦***

***ចំណុចខ្សែស្របៈ (N) ១១º ៤៩' ៤៣:៤០"***

***រយៈបណ្តោយៈ (E) ១០៥º ៣១' ១៧:៧៦" និង***

***ចំណុចខ្សែស្របៈ (N) ១១º ៥០' ១៤:៧៧"***

***រយៈបណ្តោយៈ (E) ១០៥º ៣១' ២៤:៤១"***

ទីតាំងសម្លាប់ ព-២ ជាអតីតមន្ទីរពេទ្យយោធារបស់ភូមិភាគបូព៌ាកាលពីអំឡុងឆ្នាំ១៩៧៥-៧៧ ។ បច្ចុប្បន្នទីតាំងនេះស្ថិតនៅខាងជើងសាលាហ៊ីកហ៊ឺនយោធាស្រុកអូររាំងឪ ដែលស្ថិតក្នុងភូមិជ្រៃតាសូ ឃុំអំពិលតាពក ស្រុកអូររាំងឪ ។ ចាប់ពីចុងឆ្នាំ១៩៧៧រហូតដល់ចុងឆ្នាំ១៩៧៨ ទីតាំង ព-២ បានក្លាយទៅជាទីកន្លែងសម្លាប់មនុស្សយ៉ាងសាហាវមួយនៅក្នុងស្រុកអូររាំងឪ ។ មូលហេតុនៃការសម្លាប់មនុស្សយ៉ាងសាហាវបែបនេះត្រូវបានលោកអ៊ឹ ប៊ុល ពិន អាយុ៦១ឆ្នាំជាអតីតកម្មាភិបាលខ្មែរក្រហមកាន់កាប់ខាងកសិកម្មនិយាយរៀបរាប់ថា មានការបែកបាក់ផ្ទៃក្នុងរវាងកម្មាភិបាលខាងភូមិភាគបូព៌ានិងនិរតី ។ សោ ភឹម ជាលេខាភូមិភាគបូព៌ា ត្រូវបានតាមរកចាប់ខ្លួនតាមបញ្ជាអង្គការ ពីបទក្បត់ចូលដៃជាមួយយួន ។ កម្មាភិបាលក្រោមបង្គាប់របស់ សោ ភឹម ត្រូវចាប់យកមកសម្លាប់ជាបន្តបន្ទាប់នៅ ព-២ ដោយកម្មាភិបាលខ្មែរក្រហមខាងភូមិភាគនិរតីដែលមានតាម៉ុកជាប្រធានភូមិភាគ ។ លោកអ៊ឹនិយាយបន្តថា កម្មាភិបាលខាង សោ ភឹម បានភៀសខ្លួនចូលព្រៃជាបន្តបន្ទាប់ បន្ទាប់ពីមានការគំរាមកំហែងជាញឹកញាប់ពីខាងនិរតី ។ សូម្បីតែគាត់ដែលជាកម្មាភិបាលតូចតាចខាងកសិកម្មក៏ត្រូវភៀសខ្លួនចូលព្រៃដែរ ដោយខ្លាចការតាមសម្លាប់នេះ ។ គាត់បានបន្តថា កម្មាភិបាលខាងបូព៌ាដូចគាត់ត្រូវស្លាប់ទាំងអស់ដោយចាញ់ឃោសនារបស់ពួកខាងនិរតីថា(និរតី) មិនធ្វើអ្វីចំពោះកម្មាភិបាលខាងបូព៌ាទេ ប្រសិនបើអ្នកទាំងនោះវិលពីព្រៃមកចូលក្នុងអង្គភាពវិញ ។ នៅសល់តែកម្មាភិបាលពីររូបតែប៉ុណ្ណោះដែលនៅរស់ ក្នុងនោះមានគាត់ (ប៊ុល ពិន) ម្នាក់ដែរ ។ ប៊ុល ពិន និយាយថា គាត់មិនបានចូលមកតាមការឃោសនារបស់ខាងនិរតីទេ ព្រោះគាត់មិនជឿ ។ ម្យ៉ាងទៀត រឿងរ៉ាវដែលគាត់រត់ចូលព្រៃនេះបានកើតមានមុនការលុកលុយចូលមកពីខាងនិរតី ។ ប៊ុល ពិន បាននិយាយរឿងនេះថា គាត់មានទំនាស់ជាមួយគណៈតំបន់ពីរឿងស្បៀងអាហារសម្រាប់ប្រជាជនដែលហូបមានការខ្វះខាត ផ្ទុយនឹងថ្នាក់លើៗដែលមានម្ហូបអាហារបរិបូរណ៍ ។ គាត់និយាយថា ធ្វើរបៀបនេះគឺផ្ទុយទាំងស្រុងទៅនឹងការរៀនសូត្រដែលគាត់បានរៀនតាមសៀវភៅទស្សនាវដ្តី «ទង់បដិវត្តន៍លេខ១១» ។ គាត់ត្រូវគណៈតំបន់តាមចាប់ខ្លួនដល់មន្ទីររបស់គាត់ ។ ប៉ុន្តែការចាប់ខ្លួនគាត់មិនទាន់បានផង ត្រូវខាងនិរតីចូលមកកាន់កាប់ជំនួសបន្ទាប់ពីមានការឃោសនាថា «សោ ភឹម ប្រធានភូមិភាគបូព៌ាបានក្បត់នឹងបដិវត្តន៍ហើយ» ។ គណៈតំបន់នោះត្រូវចាប់ខ្លួនមកសម្លាប់នៅ ព-២ ឯគាត់ក៏បានរួចខ្លួនពីការតាមចាប់ ហើយបន្តសំងំលាក់ខ្លួននៅក្នុងព្រៃតទៅទៀតដោយលាក់ប្រវត្តិរបស់ខ្លួនដែលជាកម្មាភិបាលខាងបូព៌ា ។ សោ ភឹម បានធ្វើអត្តឃាតព្រោះដឹងថាមិនអាចយកឈ្នះបាន ។ កូនចៅទាំងអស់របស់ សោ ភឹម នៅក្នុងស្រុកអូររាំងឪដែលពីមុនធ្លាប់បានធ្វើបាបនិងសម្លាប់ប្រជាជនស្លូតត្រង់ដោយការចោទប្រកាន់នានា ត្រូវបានសម្លាប់ទាំងអស់នៅចុងឆ្នាំ១៩៧៨ នៅឯចម្ការកៅស៊ូក្បែរមន្ទីរ ព-២ ដែលពីមុនធ្លាប់តែមានកម្មករចៀរជ័រកៅស៊ូពេញៗនោះ ។ កម្មករទាំងអស់ត្រូវបណ្តេញចេញ ។ អណ្តូងទឹកចំនួនពីរក្នុងដីចម្ការកៅស៊ូតាឈៀនត្រូវជ្រើសរើសជាទីតាំងសម្លាប់មនុស្ស ។ លោក ប៊ុល ពិន បានលាតត្រដាងការពិតអំពីការសម្លាប់មនុស្សនៅ ព-២ ថា មានការសម្លាប់មនុស្ស

ទាំងចាស់ទាំងក្មេង ទាំងទាហានដែលដេកព្យាបាលនៅក្នុងមន្ទីរពេទ្យ ប្រជាជនស្លូតត្រង់ និងកម្មាភិបាលខាងភូមិភាគបូព៌ាជាច្រើននាក់ ។ ជនរងគ្រោះដែលស្លាប់នៅទីនេះគឺយកមកពីឃុំចក ឃុំដំរិល និងឃុំអំពិលតាពក ។ លោក ប៊ិល ពិន បានបញ្ជាក់ថា សូម្បីតែទាហាន លន់ ណុល ដែលចាប់បានក្នុងសង្គ្រាម ហើយបានបញ្ជូនមកដាក់នៅវត្តព្រះធាតុកាលពីឆ្នាំ១៩៧៥ ក៏យកមកសម្លាប់នៅ ព-២ ដែរ ។ ចំណែកឯប្រពន្ធកូន ព្រមទាំងសាច់ញាតិរបស់ទាហានទាំងនោះ ត្រូវសម្លាប់ទាំងអស់នៅក្នុងអណ្តូងតាស៊ាន ។ មានរថយន្តជាច្រើនបានដឹកអ្នកទោសយកមកសម្លាប់ ។ អ្នកឃើញហេតុការណ៍ផ្ទាល់ភ្នែកដូចលោកអ៊ំ ប៊ិល ពិន ស្ទើរតែមិនជឿនូវហេតុការណ៍ដែលបានកើតឡើងនេះទាល់តែសោះ ។ គាត់និយាយថា ឃាតករមានវ័យក្មេងៗ និយាយរដឹងៗស្ទើរស្តាប់មិនបាន ។ អណ្តូងចំនួនពីរនៅលើទឹកដីចម្ការកៅស៊ូដែលបច្ចុប្បន្នមានឈ្មោះ ឈួន ឡាយ ជាម្ចាស់ដីនោះ ពោរពេញទៅដោយសាកសពហើមស្អុយរលួយ ស្ទើរតែមិនអាចចូលទៅជិតបាន ។ អណ្តូងនីមួយៗមានទំហំជាង១០ម៉ែត្របួនជ្រុង និងជម្រៅ១២ម៉ែត្រ ។ ក្រោយរំដោះឆ្នាំ១៩៧៩ អណ្តូងទាំងពីរនេះត្រូវបានគាស់កកាយ ។ ឆ្អឹងនិងលលាដ៍ក្បាលជាច្រើនត្រូវបានលើកចេញមកគរនៅខាងក្រៅអណ្តូង ។ លោកអ៊ំ មឿង ហ៊ាន អាយុ៦១ឆ្នាំ រស់នៅឃុំអំពិលតាពក ស្រុកអូររាំងឪ បាននិយាយថា គាត់ស្ទើរតែមិនជឿថានៅទីតាំង ព-២ មានចំនួនមនុស្សស្លាប់ច្រើនយ៉ាងនេះសោះ ព្រោះកាលពីគាត់មិនទាន់រត់ចូលព្រៃ ទីតាំងនេះនៅជាមន្ទីរពេទ្យទាហាននៅឡើយទេ ។ លោកអ៊ំបន្តថា គ្រាន់តែឆ្អឹងដែលដឹកយកទៅ (មិនដឹងយកទៅទីណា) មានចំនួនច្រើនរទេះគោណាស់ ។ ឯលលាដ៍ក្បាលក៏ច្រើនដូចគ្នា ។ គាត់និយាយថា នៅពេលគាស់រណ្តៅ គាត់សង្កេតឃើញមានសម្លៀកបំពាក់ទាហានជាច្រើនកំប្លែដែលមិនទាន់រលួយ ។ តាមការឃើញនូវបរិមាណឆ្អឹងនិងតាមទំហំនៃអណ្តូងទាំងពីរ លោកអ៊ំសន្និដ្ឋានថាមានសាកសពរាប់ពាន់នាក់ ។ លោកតា ពេញ ជឹម អាយុ៥៦ឆ្នាំ ជាជំទប់លេខ១ឃុំអំពិលតាពក បាននិយាយថា ការយកប្រជាជននិងកម្មាភិបាលខ្មែរក្រហមខាងបូព៌ាទៅសម្លាប់នៅ ព-២ គឺមានចំនួន ២២៥៤នាក់ ។ គាត់បានអះអាងថា គាត់ជាអ្នកដែលមកជីក ហើយបានរាប់ចំនួនដើម្បីធ្វើស្ថិតិកាលពីឆ្នាំ១៩៨១-៨២ ។

អណ្តូងទាំងពីរឃ្លាតពីគ្នាចម្ងាយប្រហែល១២០០-១៣០០ម៉ែត្រ ។ ក្នុងការកំណត់យកកូអរដោនេភូមិសាស្ត្រក្រុមដែនទីយើងបានកំណត់យកចំណុចពីរ ព្រោះគម្លាតពីរណ្តៅមួយទៅមួយប្រវែងឆ្ងាយពេក ។ ទីតាំង ព-២ តែមួយ ក៏ប៉ុន្តែមានការបំបែកជាពីរ គឺទីតាំងសម្លាប់ព-២(១) និងទីតាំងសម្លាប់ព-២(២) ។

## សន្និដ្ឋាន

ចុងឆ្នាំ១៩៧៨ នៅស្រុកអូររាំងឪមានការសម្លាប់មនុស្សយ៉ាងសាហាវមួយបានកើតឡើង ។ កម្មាភិបាលខ្មែរក្រហមខាងភូមិភាគបូព៌ាបានកាប់សម្លាប់ប្រជាជនដោយចោទប្រកាន់ថាជាខ្មាំងរបស់អង្គការ ។ បន្ទាប់មកទៀត ខ្មែរក្រហមខាងនិរតីបានមកគ្រប់គ្រងបន្តពីលើខ្មែរក្រហមខាងបូព៌ា ហើយយកកម្មាភិបាលខាងបូព៌ាទៅសម្លាប់វិញម្តង ។ ប្រជាជនខ្លះបាននាំគ្នារត់ចូលព្រៃដើម្បីងើបឡើងតស៊ូនឹងរបបនេះ ។ ទីតាំងទាំងប៉ុន្មានខាងលើដែលបានអធិប្បាយមក បង្ហាញអំពីការកាប់សម្លាប់ប្រជាជនដោយឥតញញើតដៃពីសំណាក់ខ្មែរក្រហម ។ ក្នុងកិច្ចសម្ភាសន៍ទាំងឡាយ សុទ្ធតែបានបញ្ជាក់យ៉ាងច្បាស់ពីការបំផ្លាញវត្តអារាមផ្សឹកព្រះសង្ឃ ការធ្វើទារុណកម្មគ្រប់បែបយ៉ាង ទាំងកម្លាំងកាយកម្លាំងចិត្ត បូករួមទាំងការបោកបញ្ឆោតនានាក្នុងការយកមនុស្សទៅសម្លាប់ចោល ។ សាក្សីគ្រប់រូបដែលបានផ្តល់បទសម្ភាសន៍សុទ្ធតែប្រាថ្នាសុំកុំឲ្យជួបរបបដែលមានតែការបំផ្លាញជីវិតមនុស្សបែបនេះទៀត ហើយបាននិយាយគ្រប់មាត់ថា ជីវិតប្រជាជនកម្ពុជានឹងអស់ពីលើទឹកដីកម្ពុជា ប្រសិនបើរបបនេះ (កម្ពុជាប្រជាធិបតេយ្យ) នៅតែបន្តកាន់អំណាចរហូតដល់ទសវត្សរ៍ឆ្នាំ១៩៨០ ។ វិញ្ញាណក្ខន្ធប្រជាជនកម្ពុជារាប់លាននាក់ដែលបានស្លាប់នៅទូទាំងប្រទេសកម្ពុជា ដោយសារការកសាងបដិវត្តន៍មហាលោតផ្លោះមហាអស្ចារ្យរបស់ ប៉ុល ពត ពិតជាមិនបានស្ងប់ឡើយ ប្រសិនបើមេដឹកនាំធំៗទាំងនោះមិនត្រូវបាននាំខ្លួនចូលតុលាការដើម្បីវិនិច្ឆ័យទោស ។

**ផេង ពង្សរ៉ាស៊ី**

# តើជាកម្មពៀរពីអតីតឬអ្វី?

## បទសម្ភាសន៍ជាមួយព្រះមហាសុមេធាធិបតី ទេព វង្ស សម្តេចព្រះសង្ឃរាជគណៈមហានិកាយនៃកម្ពុជា

### ថ្ងៃទី៨ ខែតុលា ឆ្នាំ២០០១


ព្រះមហាសុមេធាធិបតី ទេព វង្ស

***សួរ*** : *ខ្ញុំព្រះករុណាចង់សួរព្រះតេជគុណថា តើក្នុងរបបខ្មែរក្រហមរឿងរ៉ាវនៃការសម្លាប់មនុស្សវាជារឿងរបស់មនុស្សលោកឬជាបុណ្យបាបព្រះតេជគុណ?*

***ឆ្លើយ*** : *នេះបើតាមលោកតាពិចារណាក៏មិនជ្រៅជ្រះមិនដាច់ស្រេចដែរ ។ ហេតុម៉េចបានថាដូច្នោះ? មកអំពីសត្វជាអ្នកអាស្រ័យកម្ម ។ "កម្ម"បានន័យថាអំពើដែលធ្វើ ។ មិនដឹងជារឿង ប៉ុល ពតនេះ ដែលប៉ុលពតជាអ្នកមានគំនិតចាប់ផ្តើមទីមួយរបស់គេឬក៏គេពុំមានទេ? បើថាពុំមានទេនោះ ការក្រហល់ក្រហាយទុក្ខសោកវេទនាវិនាសកម្មបាត់បង់អាយុជីវិត អានេះវាពៀរវេរាមួយពីអតីតកាលមក "សោច បុព្វេ ច កត្ត បុញ្ញកា" នេះវាហុចឲ្យពីអតីតកាលមក "អតីតា ជាត បច្ចុប្បន្នា ធម្មា" នោះ ។ ឧទាហរណ៍ដូចជាព្រះពុទ្ធបរមគ្រូជាម្ចាស់លោកទៅសម្លាប់យក្សកាលដែលលោកនៅជាប្រជាជន ប៉ុន្តែតាមច្បាប់លោកថាប្រជាជនមែន ប៉ុន្តែប្រជាជនតួអង្គពោធិសត្វបានទៅសម្លាប់យក្សនោះវាបាន ហើយដល់សម្លាប់យក្សនោះទៅ ដោយសារតែយក្សហ្នឹងវាស៊ីមនុស្សរហូតដល់ស៊ីកូនស្តេចទៀត បានជាស្តេចហ្នឹងឲ្យរកអ្នកមានមហិទ្ធិឫទ្ធិមានអំណាចដើម្បីសម្លាប់យក្សហ្នឹង បានព្រះពោធិសត្វនេះលោកក៏ចេញខ្លួនទៅធ្វើការនោះទៅ ។ ដល់ធ្វើការហ្នឹងទៅក៏សម្លាប់យក្សហ្នឹង មុននឹងសម្លាប់យក្សវាស្រែកចងពៀរវេរាជាមួយគ្នា ថាខ្ញុំទើបតែមានអាយុ៨០ទេ ហើយព្រះអង្គអនាគតនឹងបានត្រាស់ទៅជាព្រះពុទ្ធមួយអង្គ ពីព្រោះយក្សវាបានឃើញកងចក្រនៅនឹងបាតដៃព្រះអង្គ ដូច្នេះសូមកុំសម្លាប់ខ្ញុំ បើសម្លាប់ខ្ញុំហើយខ្ញុំអាយុទើបតែ៨០ ដល់ព្រះអង្គបានត្រាស់ទៅជាព្រះពុទ្ធអនាគតខាងក្រោយទៅនេះគឺថាអាយុ៨០ដូចតែខ្ញុំអ៊ីចេះឯង ។ ខ្ញុំសូមចងពៀរមិនឲ្យអ្នកឯងបានអាយុលើសពី៨០នោះទេ ។ ដោយអំពើដែលស្រេកឃ្លានចង់បាននោះផង ដើម្បីបង្រ្កាបកុំឲ្យមានអាសុរីនៅក្នុងសង្គមជាតិនោះផង ក៏សម្លាប់យក្សហ្នឹងទៅ ។ ដល់សម្លាប់យក្សហ្នឹងទៅ ព្រះអង្គកសាងបណ្តើរៗរាប់អសង្ខេយ្យជាតិមក ហើយដល់បានត្រាស់ទៅមានព្រះជន្មបានតែ៨០ទេតើ ដល់ពេល... ចូលព្រះនិព្វាន ហៅថាអនុបាទិសេសនិព្វាន អាយក្សហ្នឹងមកចាប់កំណើតជាជ្រូក ហើយសូករៈអ្នកចិញ្ចឹមជ្រូកនោះមានដឹងជាជ្រូកដែលអាយក្សហ្នឹងចាប់កំណើតជាជ្រូកអី ម៉្លោះហើយចង់បានបុណ្យនឹងព្រះ សម្លាប់អាជ្រូកហ្នឹងយកទៅធ្វើចង្ហាន់ថ្វាយព្រះ ដល់ធ្វើចង្ហាន់ថ្វាយព្រះ អាពិសពុលរបស់យក្សនោះដែលជាពៀរវេរានោះ បានព្រះអង្គទ្រង់សោយចង្ហាន់ហ្នឹងទៅក៏វាកើតរោគអីចឹងទៅ ប៉ុន្តែព្រះអង្គទ្រង់ជ្រាបរួចមុនបាត់ទៅហើយថាពៀរវេរា បានន័យថា "ចង្ហាន់មួយត្រាស់ ចង្ហាន់មួយនិព្វាន ចង្ហាន់នេះមែនមាន គុណគាប់ប្រសើរ" ដូចជាចង្ហាន់នាង សុជាតា ហ្នឹងត្រូវបានត្រាស់ ដល់ចង្ហាន់នាយចុននេះត្រូវបាននិព្វាន ដូច្នេះនាយចុនអត់មានទោសកំហុសថាសម្លាប់ព្រះទេ នេះលោកបានអានិសង្ស អីចឹង ។ ដល់រឿងមួយទៀតវាជារឿងរបស់ព្រះ ប៉ុន្តែរឿងមិនមែនព្រះ សាវ័ករបស់ព្រះ ដូចជាព្រះមោគ្គល្លាន អានោះពៀរវេរារបស់ខ្លួនដោយសារតែស្រឡាញ់ភរិយានោះខ្លាំងពេកដល់ហើយយកម្តាយឯងហ្នឹងទៅបំបរបង់ចោលរស់នៅក្នុងព្រៃ*

បាត់បង់អាយុជីវិតទៅជាចំណីសត្វ ។ ពៀរកាលនោះវាតាមតោងមកដល់ព្រះមោគ្គល្លានបានព្រះអរហត្ត វាកើតជាចោរទាំង ៥០០ទៅសម្លាប់មោគ្គល្លានឲ្យវិនាសអន្តរាយ អាហ្នឹងពៀរហ្នឹងវាតគ្នាអ៊ីចឹង ដូច្នេះរឿងប៉ុលពតនេះលោកតាវិភាគអត់ដាច់ដែរទេ មិនដឹងជាប៉ុលពតចាប់ផ្តើមធ្វើជាដំបូង ឬក៏ពៀររបស់មនុស្សទាំងឡាយដែលបានគ្រោះថ្នាក់ ទាំងចៅឯងទាំងលោកតានេះ ក៏កម្សត់អត់បាយអត់បបរដូចតែគ្នាដែរហ្នឹង ។

**សួរ :** អ៊ីចឹងមានន័យថា ជនរងគ្រោះដល់ទៅបីលាននាក់នៅក្នុងរបបខ្មែរក្រហមហ្នឹង សុទ្ធតែជនដែលមានពៀរពីអតីតជាតិ?

**ឆ្លើយ :** លោកតាបញ្ជាក់អត់បានច្បាស់លាស់ទេ ដូចលោកតាប្រាប់មិញថា មិនដឹងជាប៉ុលពតគេចាប់ផ្តើមធ្វើ ឬក៏ជាពួកមួយមកពីផលហេតុអ្វី ។ បើថាប៉ុលពតគេមិនចាប់ផ្តើមធ្វើទេ អានេះពៀររបស់ពួកយើងហ្នឹង វាមានពៀរពីអតីតមក រួចបើយើងគិតមើលទៅវាដូចជាលោកតា ដូចជាចៅឯងអ៊ីចឹង វាពៀរដូចថាសេសសល់ វិសេសកម្មនោះ បានជាលោកតាបានរស់ ចៅឯងបានរស់ ហើយចៅឯងដូចជាកើតមុននោះបន្តិចបន្តួចទេ កុមារទេកាលសម័យនោះមើលទៅ ។

**សួរ :** អ៊ីចឹងព្រះតេជគុណឈ្មោះយល់ថា តើអំពើរបស់មេដឹកនាំខ្មែរក្រហមដែលធ្វើឲ្យបាត់បង់ជីវិតប្រជាជនដ៏ច្រើនសន្ធឹកសន្ធាប់ហ្នឹង តើគួរតែត្រូវបានកាត់ទោសឬក៏បណ្តោយទៅតាមកម្មពៀរ?

**ឆ្លើយ :** មិនមែនបណ្តោយតាមកម្មពៀរទេ ។ អ៊ីត្រូវតែវិនិច្ឆ័យទាំងអស់ ក៏ប៉ុន្តែវិនិច្ឆ័យឲ្យមានយុត្តិធម៌ផង សូមឲ្យវិនិច្ឆ័យមានយុត្តិធម៌តាមរយៈសាសនាផង ។ ឧទាហរណ៍ ជីវិតវាមានពីរហៅថា ចលនវត្ថុ អចលនវត្ថុ ។ ចលនវត្ថុដូចជាលោកតាអ៊ីចឹងចៅឯងអ៊ីចឹង ធ្វើសកម្មភាព ហៅថាចលនវត្ថុ ។ ប៉ុន្តែចុះអចលនវត្ថុ? អចលនវត្ថុហ្នឹងដូចជាវត្ថុគ្មានកម្រើក ឧទាហរណ៍ដូចជាគេហដ្ឋាន ផ្ទះសម្បែង សាលារៀន វត្តអារាម ជាអចលនវត្ថុ ។ តើយើងពិចារណាថាអចលនវត្ថុហ្នឹងមានពៀរដែរឬទេ បើវាអត់ធ្វើសកម្មភាពអត់ធ្វើកម្មអីនឹងគេសោះ អានេះវាទៅដោយឡែកមួយទៅ ។ ចុះបើអាជាចលនវត្ថុដូចជាមនុស្សនិងមនុស្សថាមនុស្សវាធ្វើកម្មហ្នឹងហើយ ដល់ធ្វើកម្មគេត្រូវវិនិច្ឆ័យដោយឡែក ពីព្រោះក្នុងពេលនោះវាមិនវិនាសកម្មតែអាយុជីវិតឯណា វាវិនាសកម្មទាំងអចលនវត្ថុ ទាំងចលនវត្ថុទៅ ចង់រលាយអស់មួយកម្ពុជាហើយយើងគិតមើល អានេះបានយើងត្រូវវិនិច្ឆ័យហ្នឹងដោយមានយុត្តិធម៌ផង កុំឲ្យប្រកបនូវការគំរាមកំហែងការប្រមាថមើលងាយមើលថោកតបត ក្រែងពៀរហ្នឹងវាតគ្នាតទៅទៀត ។ ដូចថាយើងចង់សម្លាប់ ដូចព្រះពុទ្ធចង់សម្លាប់យក្សហ្នឹង អាយក្សហ្នឹងវាតពៀរមកទៀតមក ឯយើងវិនិច្ឆ័យដូចគ្នាអ៊ីចឹងដែរ វិនិច្ឆ័យចង់តពៀរនឹងប៉ុលពតហ្នឹង អាពៀរហ្នឹងវាអត់ចប់ទេ បានជាព្រះលោកថាពៀរកុំតពៀរ អាយុវឌ្ឍនការណ៍ហ្នឹងនិយាយថា ពៀរកុំតពៀរ ។ ដូច្នេះវិនិច្ឆ័យយ៉ាងម៉េចឲ្យវាមានយុត្តិធម៌ទៅលើសកម្មភាពរបស់មនុស្ស រួចបើចេះតែអូសទាញអាអ្នកដទៃផង អាអ្នកគ្នាមិនដឹងអីទេសោះ ក៏ចេះតែអូសតែទាំងអស់តែគ្នាទៅហ្នឹង ។ លោកតាយល់ថា រឿងប៉ុលពត បើតាមប៉ុន្មានស្មានទៅ បើទោះជាសម្លាប់ក៏មិនដល់២០-៣០នាក់ទេ អានេះផ្ទាល់របស់វា ហើយវាប្រើគេក៏អត់មានប្រើដែរ ប៉ុន្តែទាស់ប៉ុលពតកំហុសត្រង់វាគ្មានច្បាប់ឲ្យអនុវត្ត ពីព្រោះវាលុបបំបាត់សាសនា មិនឲ្យមានសាសនា ហើយមនុស្សអត់មានបុណ្យមានបាបទេ ទាំងអស់គ្នាពេលនោះអត់មានបុណ្យមានបាបទេ តាមលោកតាដែលនៅរស់៣ឆ្នាំ៨ខែនិង២០ថ្ងៃ អត់មានបុណ្យមានបាបព្រោះអស់សាសនាទៅហើយ ម៉្លោះហើយវាទៅជាមនុស្សអនាធិបតេយ្យ អត់មានច្បាប់មានទម្លាប់ អ្នកណាស្អប់អ្នកណាទៅសម្លាប់អ្នកនោះទៅ នៅក្នុងសហករណ៍លោកតាដូចគ្នាអ៊ីចឹងដែរ អត់មានរឿងមានទោស អាមនុស្សមួយឆ្កួតឆ្នាំ៧៧ វិកលចរិត ឃ្មាលតែក្របីមិនគង់ដែរ រួចស្រាប់តែថាវាឈ្មោះគ្នានឹងអាបង១វានោះទៅ វាធ្វើអាបង១មិនកើត វាយកអាមនុស្សឆ្កួតប្អូននេះ នៅក្បែរផ្ទះលោកតាហ្នឹង បាញ់ចោល ១យប់១ថ្ងៃនៅឯនោះទម្រាំគេយកទៅកប់ ។ មនុស្សឆ្កួតអ៊ីចឹងវាចាប់ចងមក ដាក់កង់មកគ្នាវាឌុបកង់៣នាក់ រួចអាម្នាក់ដែលជាប់ពិរុទ្ធហ្នឹងផង ចងជាប់មកដល់ក្បែរផ្ទះលោកតាប្រហែលជាចម្ងាយពីផ្ទះលោកតាប្រហែល១០០ម៉ែត្រ កាលនោះលោតចុះពីកង់ទៅរត់ទៅក្បែរផ្ទះលោកតាហ្នឹង ផុតតែភូមិ ផ្ទះលោកតានៅក្រោយគេ បាញ់ក្បែរផ្ទះលោកតាហ្នឹង មិនបាន៣០ម៉ែត្រពីផ្ទះលោកតាផង ។ គិតមើលី មនុស្សអ៊ីចុះ១ហើយទៅសម្លាប់

គ្នាទៅដែរ ដូច្នេះវាជារឿងមួយវាគ្មានច្បាប់ហាមឃាត់ វាគ្មានច្បាប់តម្រូវឲ្យទោសម្លាប់ទេ អានេះជារឿងមួយសំខាន់ ដល់អីចឹង មនុស្សនិងមនុស្សនោះ ប្រជាជននិងប្រជាជននោះ វាគំនុំគំកួនគ្នា វាស្អប់ខ្ពើមគ្នាបន្តិចបន្តួចទៅ វាចេះតែសម្លាប់ ដូចយើងសព្វថ្ងៃចឹងមើល៍ គេមានច្បាប់មានអីការពារសិទ្ធិមនុស្ស ការពាររក្សាសិទ្ធិរក្សាអីទាំងអស់ទៅ បើទោះជាមានសម្លាប់ក៏សម្លាប់ដោយចោរប្លន់ សម្លាប់ដោយមនុស្សផ្សេងៗគ្នាទៅ ។ អានេះដំណើរវាអីចេះ បានលោកតាមិនមែនថាអនុគ្រោះមិនឲ្យវិនិច្ឆ័យទោសទេ វិនិច្ឆ័យទោសត្រូវតែវិនិច្ឆ័យ ក៏ប៉ុន្តែវិនិច្ឆ័យឲ្យវាសមទៅតាមយុត្តិធម៌សម្រាប់មនុស្ស ដូច្នេះត្រូវតែយកច្បាប់សាសនាទៅពិចារណាផង "បាណា" កុំឲ្យសម្លាប់ សម្លាប់គេវាបាប អាហ្នឹងឲ្យពិចារណា កុំតែយកទៅតាមអំណាចចិត្តគំរាមកំហែងគ្នា អាអ្នកមិនដឹងអីទេសោះស្រាប់តែចាប់គ្នាយកមកវិនិច្ឆ័យថាសុទ្ធតែទោសហើយ ។ ប្រល័យពូជសាសន៍ទោសអី ខ្មែរក្រហមខ្មែរក្រហាំងអីហ្នឹង ។ អាគ្នាអ្នកដឹងខ្លួនគេឆាប់គេចរត់មកមុនហើយ នៅតែអូសទាញគ្នាយកទៅទៀត អានេះវាអត់មានយុត្តិធម៌ទេ អានេះត្រូវតែច្បាប់ពិភពលោកទាំងមូលហ្នឹង យើងយកសឹងគ្រប់សាសនាទាំងអស់យកមកពិចារណាតែម្តងទៅ សាសនាព្រះពុទ្ធ សាសនាហិណ្ឌូ សាសនាគ្រិស្ត សាសនាឥស្លាម យកមកបញ្ចូលក្នុងច្បាប់សព្វថ្ងៃនេះទៅដើម្បីវិនិច្ឆ័យទៅលើរឿងនេះឲ្យបានយុត្តិធម៌ផង ។

**សួរ ៖** ចំពោះព្រះតេជគុណ ពាក្យថាយុត្តិធម៌សម្រាប់ព្រះតេជគុណ ឬក៏សម្រាប់ព្រះពុទ្ធសាសនា មានន័យយ៉ាងដូចម្តេច?

**ឆ្លើយ ៖** "យុត្តិធម៌" ពាក្យថា ទៀងត្រង់ សច្ចៈ "សច្ចំវេ អមតវាចា" ពុទ្ធភាសិតសម្តែងថា សច្ចវាចា សច្ចំវេ អមតៈ ។ "អមតៈ"ប្រែថាមិនស្លាប់ ពាក្យពិតហៅថាមិនស្លាប់ អានេះហើយដែលវិនិច្ឆ័យទៅលើទោសអ្នកទាំងឡាយទាំងពួងហ្នឹងវាទៀងទាត់ពិតប្រាកដ គឺថាវាអត់អន្តរាយដល់ច្បាប់ទេ ។

**សួរ ៖** ប្រសិនបើមានតុលាការមួយដែលវិនិច្ឆ័យទោសបានត្រឹមត្រូវនិងយុត្តិធម៌ ហើយដាក់ទោសទៅលើជនដែលបានប្រព្រឹត្តអំពើយង់ឃ្នងនៅក្នុងសម័យខ្មែរក្រហម តើការដែលធ្វើយ៉ាងដូច្នេះអាចជាកម្មពៀរសម្រាប់អ្នកដែលធ្វើការវិនិច្ឆ័យដាក់ទោសទៅលើជនដែលមានកំហុសដែរឬទេ?

**ឆ្លើយ ៖** បើមានយុត្តិធម៌នោះអត់មានពៀរវេរាគ្នាទៀតទេ គឺសងគ្នា បួនសងបួនគឺចប់គ្នាតែម្តង អានេះអត់មានតួគាល់ពៀរតពៀរគ្នាតទៅទៀតទេ ។ អានេះតាមច្បាប់សាសនា ។ រួចច្បាប់នោះ ពៀរវេរាបាបកម្មហ្នឹងវាមានពីរសណ្ឋានដែរ ។ ដូចជាព្រះពុទ្ធសាសនាសម្តែងថា និព្វានមានពីរ ខបាទិសេសនិព្វាន គឺនិព្វានក្នុងលោកិយ អនុបាទិសេសនិព្វានគឺនិព្វានក្នុងលោកុត្តរ ដូចព្រះពុទ្ធបរមគ្រូជាអម្ចាស់របស់យើងអីចេះ លោកបាននិព្វានលោកិយ៤៥ឆ្នាំដែរ ហើយបានលោកចូលអនុបាទិសេសនិព្វាន ។ ដូច្នេះបាបក៏មានពីរដូចគ្នាដែរ មានបាបក្នុងលោកិយ មានបាបលោកុត្តរ ដូចតែគ្នាអីចឹងដែរ ប៉ុន្តែបាបលោកិយហ្នឹងគឺវិនិច្ឆ័យច្បាប់រៀបចំវិនិច្ឆ័យទោសនេះ វាមានបាបនៅក្នុងលោកិយ ប៉ុន្តែបើថាវិនិច្ឆ័យទៅវាមិនចប់វាមិនគ្រប់ទេនោះទៅលោកុត្តរនៅតែមានបាបតទៅទៀតហើយ គេចអត់ផុតទេ សត្វជាអ្នកអាស្រ័យកម្ម បានន័យថាអំពើដែលធ្វើនោះ ប៉ុន្តែយើងកុំឲ្យមានពៀរវេរា គឺថាបួនសងបួនវាចប់គ្នាទៅ កុំឲ្យបួនយកទោសងប្រាំវាទៅជាពៀរមួយទៀតតទៅទៀតហើយ ។

**សួរ ៖** ករុណាលោកតា តាមពុទ្ធវចនាលោកថែងថា "ពៀររម្ងាប់ដោយការមិនចងពៀរ" ។ អីចឹងការដែលយើងនាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោស ចាត់ទុកជាការចងពៀរដែរឬទេ?

**ឆ្លើយ ៖** ទេ តែយើងយកអានេះបើតាមថាត្រូវតែយកមកនេះវាអត់មានពៀរទេ ក៏ប៉ុន្តែបើពៀរតទៅទៀតនោះអាបួនទោសងដប់នោះ ។ បើដល់កាត់ទោសនោះវាចេះតែខុសទៅ វាចេះតែអូសទាញទាំងអាអ្នកទាំងអស់គ្នាហ្នឹង បើមិនពៀរនឹងប៉ុលពតចុះប៉ុលពតទៅយកឯណា បើប៉ុលពតស្លាប់បាត់ទៅហើយ ។ អានេះត្រូវមានពិចារណាត្រង់នេះផង ។

**សួរ ៖** ព្រះតេជគុណ ចំពោះជនរងគ្រោះក្នុងសម័យខ្មែរក្រហម ដែលព្រះតេជគុណមានពុទ្ធដីកាថាជាមនុស្សមានពៀរ ហើយចុះចំពោះខ្មែរក្រហមដែលធ្វើអំពើមកលើមនុស្សដែលមានពៀរ តើគួរតែត្រូវវិនិច្ឆ័យទោសឬក៏យ៉ាងម៉េច?

**ឆ្លើយ ៖** អាត្រង់ណេះវាពិចារណាទៅលើសច្ចធម៌ដែរ យើងគួរទុកឲ្យមនុស្សនោះទទួលបាបពៀរហ្នឹងទៅអនាគត ហៅថាទៅ

លោកុត្តរធម៌ទេ? ឆ្លងទៅអនាគតទេ? ឬយើងជាពួកមួយ យើងស៊ីសងគ្នាបច្ចុប្បន្ននេះ? អានេះអាត្មាមិន ព្រោះអត់មាន វិន័យធម៌អត់មានតុលាការទេ អាត្មាមិនមែនតុលាការទេ អាហ្នឹង អាស្រ័យលើតុលាការ ។ បើស៊ីសងគ្នានឹងលោកិយនេះក៏ស៊ីសង ទៅ ។ ប៉ុន្តែស៊ីសងឯណា ចុះបើប៉ុលពតក្តី ហ៊ូយន់ ហ៊ូនឹមក្តី ងាប់អស់ហើយ សុនសេនអីនោះ សុទ្ធតែប៉ុលពតសម្លាប់អស់ ទៅហើយ ប៉ុលពតស្លាប់ដោយខ្លួនឯងអស់ប៉ុន្មាននាក់ទៅហើយ ។ រួចក្នុងនោះវាមិនមែនមានតែប៉ុណ្ណោះទេ វាមានដៃគូនឹងប៉ុលពត នោះច្រើនទៀតក៏មិនដឹងដែរ មិនមែនប៉ុលពតធ្វើតែម្នាក់ឯង ឯណា ។ អានេះត្រូវបែងចែកទើបបានគេទៅមុនយ៉ាងណា អាដែលអ្នកនៅក្រោយយើងវិនិច្ឆ័យរបៀបណាដើម្បីយក យុត្តិធម៌ហ្នឹងឲ្យគ្នា ដូចឧទាហរណ៍យើងចង់និយាយថាវាមាន ប្រកតែមួយទេ យើងទៅយកមនុស្សនោះមករកយុត្តិធម៌ឲ្យទេ ឬយើងយកយុត្តិធម៌ទៅឲ្យមនុស្សនោះ អានេះយើងចង់... ដូចជាព្រះពុទ្ធជាម្ចាស់និងយក្សនោះ ហើយក៏ដូចជាព្រះមោគ្គល្លាន នោះ ។ ហើយឧទាហរណ៍ដូចជាអ្នកមកធ្វើថ្មី ក្រោយដូចជាព្រះ ទេវទត្ត អានេះគេធ្វើថ្មីហើយ ដល់ធ្វើថ្មីមើល៍ មានអ្នកណាវិនិច្ឆ័យ គ្នា? អត់មានអ្នកណាវិនិច្ឆ័យទេ មានតែលោកុត្តរវិនិច្ឆ័យ ព្រះធរណីស្រូបយកទៅបាត់ទៅ នេះសម័យព្រះដែលវាប្រឆាំង នឹងព្រះនោះ ។ ដូចជានាង ចិញ្ចា ដែលជាភេទនារី មិនសុទ្ធតែ ប្រឆាំងនឹងព្រះអីចឹង តើមានអ្នកណាវិនិច្ឆ័យបើព្រះលោកអត់ ឲ្យវិនិច្ឆ័យ អីចឹងទៅលោកុត្តរវិនិច្ឆ័យទៅ សុទ្ធតែព្រះធរណី ស្រូបទាំងអស់ទៅ ប៉ុន្តែមិនដឹងជាវារបៀបណាព្រះធរណីស្រូប នោះ បើយើងអត់ដឹងទាំងអស់គ្នា ប៉ុន្តែវាមានតែច្បាប់ ។ នេះ បានថាយើងពិចារណាផងដែរ ចង់ឲ្យមានសុខសន្តិភាពនៅក្នុង ពិភពលោកក៏យើងគិតគួរពិចារណាទៅតាមនោះទៅ ។ ចង់មាន សុខសន្តិភាពដូចក្នុងសង្គមកម្ពុជា យើងក៏យើងត្រូវតែសម្រួល តាមនោះចុះ ប្រយ័ត្នតែរកទៅវាមិនទៅជាសុខសន្តិភាព ទៅជា យុត្តិធម៌ វាទៅឲ្យកើតជាឲ្យកើតប្រតិកម្មណាមួយទៀតឡើង រឿងរ៉ាវនឹងតទៅទៀត អាហ្នឹងវាកាន់តែធ្ងន់ណាស់តទៅទៀត ហើយ ពីព្រោះយើងបានសន្តិភាពហើយ ។ អីចឹងយើងសម្រួល របៀបណាដើម្បីឲ្យសង្គមយើងមានសន្តិភាព ស្ថិរភាពវែងតទៅ ទៀត កុំឲ្យវាមានជម្លោះឈ្លោះប្រកែកឲ្យទៅជាមនុស្សទាំងអស់ គ្នាហ្នឹងវា កុំចាំថាតែខ្មែរនិងខ្មែរ សូម្បីតែជនសាសន៍ដទៃៗទៀត ហ្នឹងគេចូលមកក៏បានសុខសន្តិភាពជាមួយយើងដែរ គេមិនមែន ចូលមកនៅរស់ដណ្តើមយកអំណាចដណ្តើមយកអី គេចូលមកជា ទេសចរណ៍ គេចូលមករៀនសូត្រវប្បធម៌សេដ្ឋកិច្ចនៅក្នុងប្រទេស យើង នាំសេដ្ឋកិច្ច នាំវប្បធម៌ ទំនាក់ទំនងសាមគ្គីភាពមិត្តភាព ជាមួយគ្នា គេមកបានទុក្ខក៏មិនល្អមើលដែរ គឺថាយើងពិចារណា ត្រង់ណេះឲ្យបានវែងឆ្ងាយតាមសាសនា ។

**សួរ ៖** ប្រសិនបើឧបមាថាយើងមិនផ្តន្ទាទោសមេខ្មែរក្រហមនៅ ក្នុងពេលបច្ចុប្បន្ននេះទេ តើព្រះតេជគុណជឿជាក់ថាថ្ងៃក្រោយ ទៅគេនឹងទទួលផលនៃកម្មរបស់គេដែរឬទេ?

**ឆ្លើយ ៖** អ៊ូ អត់គេចផុតទេ ។ មើលព្រះពុទ្ធជាម្ចាស់ មើលព្រះ មោគ្គល្លាន អានេះសត្វជាអ្នកអាស្រ័យកម្ម កម្មបានន័យថា អំពើដែលធ្វើ បាបនិងបុណ្យដូចស្រមោលអន្ទោលតាមប្រាណ មិនដែលចៀសបាន ត្រង់ក្តីអកុសល ។ អត់គេចផុតទេ ។ ប៉ុលពត ងាប់ទៅហើយហ្នឹង ហ៊ូយន់ ហ៊ូនឹម ងាប់ទៅហើយហ្នឹង ។ ក្រុមលន់ណុល ពួកលន់ណុល លន់ណុលងាប់ទៅហើយហ្នឹង ។ សុទ្ធតែអំពើអាក្រក់របស់ខ្លួនហើយ មិនដឹងជាទៅសោយកម្ម របៀបណាទេ មើលដូចជាព្រះបាទអជាសត្តុ បានតែធូរស្រាល មែន ប៉ុន្តែនៅត្រឹមថ្នាក់មោហគន្ធិសព្វថ្ងៃហ្នឹង បើតាមច្បាប់គេ ឆ្កាង ។ អ្នកដែលគេចេះដឹងពីមុន ដែលគេទ្រង់ព្រះអារ្យអ្នក ដឹងនោះ ដាក់ឆ្កាងបោះដែកគោលជើងហ្នឹងបោះដែកគោលដៃ ឆ្កាងដូចព្រះយេស៊ូគ្រិស្តអីចឹងក៏មិនដឹង ។

**សួរ ៖** ព្រះតេជគុណប្រាកដថាគេបានទទួលកម្មគេទេ ប៉ុន្តែមិន ដឹងទទួលនៅពេលណា បើក្នុងជាតិនេះជនរងគ្រោះមើលឃើញថា អ្នកដែលធ្វើឲ្យគេរងគ្រោះនោះនៅរស់ដោយសុខសប្បាយសោយ សុខអីចឹង មិនដឹងជាគេទៅទទួលកម្មគេហ្នឹងនៅពេលណាទៅ?

**ឆ្លើយ ៖** យី! អាហ្នឹងអត់ទៀងទេ មិនឃើញព្រះពុទ្ធ តាំងពី សម្លាប់យក្សនោះមកទល់គ្នានឹងបានត្រាស់នេះ គិតមើល៍ទល់គ្នា នឹងបានត្រាស់ ។

**សួរ ៖** ប៉ុន្តែប្រជាជនត្រូវការឃើញភ្លាមៗនៅក្នុងជាតិនេះ ថាអ្នកដែលធ្វើឲ្យគេឈឺចាប់ត្រូវទទួលផលនៃអំពើរបស់គេ ។

***ឆ្លើយ*** ៖ *អានេះគេថា មួយដូចលោកតាចង់និយាយថា បាបក្នុងលោកិយ បុណ្យក្នុងលោកិយ បាបទៅលោកុត្តរ បុណ្យទៅលោកុត្តរ ។ ដែលយើងទាំងអស់គ្នានេះជាអ្នកកាន់ព្រះពុទ្ធសាសនាហូរហែតមកហើយហ្នឹង គឺប្រាថ្នាតែសេចក្តីសុខ មានឋានសួគ៌ ឋាននិព្វានជាដើម ។ ហើយមិនដឹងពេលណាទៅដល់ឋានសួគ៌ឋាននិព្វានទេ ទាល់តែចេះតែសន្សំបន្ទំបារមី គិតតែព្រះពុទ្ធជាម្ចាស់ហ្នឹង បួនអសង្ខេយ្យទៅទៀតបានទៅដល់ព្រះនិព្វាន ក៏ប៉ុន្តែពេលនោះលោកច្រើនតែកើតឯឋានសួគ៌ ។ កាលលោកមកសន្សំបុណ្យបានទៅ រួចលោកទៅកើតចាកខន្ធពីមនុស្សលោកហ្នឹងទៅកើតឋានសួគ៌ទៅ ។ ចឹងបានជាថានេះបុណ្យនិងបាបជាមួយតែគ្នាហ្នឹង កើតមកជាមនុស្សគឺបុណ្យនិងបាបជាមួយតែគ្នាហ្នឹងឯង អ្នកណាធ្វើបុណ្យបានច្រើនទៅសោយឋានសួគ៌ទៅ អ្នកណាធ្វើបាបបានច្រើនចុះនរកទៅ ទៅតាមកាលៈទេសៈ ប៉ុន្តែសេចក្តីស្រេកឃ្លានចង់បានរបស់មនុស្សវាដូចតែគ្នាហ្នឹងឯង ។ លោកតាចង់តែធ្វើអីបានតែថ្ងៃហ្នឹង ចង់ធ្វើម៉ោងនេះចង់បានតែម៉ោងនេះហើយ ក៏ប៉ុន្តែទំហំវត្ថុដែលវាមិនឲ្យផលទេនោះ យើងទៅទទួលយកអាណាមុននោះទៅ យើងចង់បានធ្វើអី យើងចង់បានបាយ ក៏ប៉ុន្តែបាយវាមិនទាន់បានទេ យើងបានបបរក៏នាំគ្នាញ៉ាំបបរសិនទៅ ហើយយើងចង់បានដូចថាចង់ធ្វើស្ពានកាត់ទន្លេសាប ដងទន្លេសាបនេះ ក៏ប៉ុន្តែយើងរកស្ពានកាត់មិនបានធ្វើស្ពានមិនទាន់ យើងនាំគ្នាជិះទូកសិនទៅ ជិះកាណូតសិនទៅណ៎ ។ អានេះបានវាសមទៅតាមការសន្សំបុណ្យសន្សំកុសលសន្សំសុខរបស់ខ្លួន ប៉ុន្តែបើយើងប្រកបទៅដោយអវិជ្ជា ហៅថាលោភធម៌ លោភៈ ទោសៈ និងមោហៈ ឧបាទានធម៌ ប្រកាន់ទៅលើ កម្មឧបាទាន តុបាទាន ទិនបាទាន អត្តលហុបាទាន ។*

***សួរ*** ៖ *តើព្រះតេជគុណចង់ឲ្យប្រជារាស្ត្រខ្មែរលើកលែងទោសឲ្យមេខ្មែរក្រហម ឬក៏ផ្តន្ទាទោសឲ្យស័ក្តិសមនឹងអំពើរបស់គេ?*

***ឆ្លើយ*** ៖ *ចំណុចទាំងអស់នេះដូចអាត្មាបាននិយាយរួចមកហើយថា ទោសក្នុងលោកុត្តរ ទោសក្នុងលោកិយ ។ តែបើយើងចង់ឲ្យបានទៅលោកុត្តរក៏ស្រេចនឹងចិត្តអស់អ្នក ។ ចុះយើងចង់ឲ្យបានលោកិយអាហ្នឹងស្រេចនឹងចិត្ត ។ ព្រោះលោកតានៅ៣ឆ្នាំ ៨ខែ និង២០ថ្ងៃ គ្រាន់តែជាប់គុកវាអស់៨៥ថ្ងៃហើយ ពីថ្ងៃ៨កើតខែអាសាធ ទៅទល់គ្នា៣កើត ខែអស្សុជ បានរួចខ្លួនមកស្បែកដណ្តប់ឆ្អឹងទាំងអស់ នេះគុកមានជញ្ជាំង ។ វ៉ៃលោកតាហើមខ្លួនដូចត្រីស្អុយអីចឹង កាំភ្លើងបីដើមណ៎ អាមួយអាម៉េភ្លឹបដាក់ដើមទ្រូងភ្លឹប អាមួយខាងស្តាំអាម៉េភ្លឹប ឲ្យលើកដៃចុចក្លៀកភ្លឹប អានេះលោកតាអត់ភ្លេចទេ ហើយពីឆ្វេងដៃអីចឹងចម្ងាយប្រហែលកៀននោះ អាម៉េតម្រង់ពីនោះមក ។ រួចលោកតាមិនមែនបាត់ស្មារតីទេ លើកដៃអីចឹង ប៉ុន្តែបើយើងចង់និយាយឲ្យពៀរតពៀរជាមួយគ្នាតទៅទៀត គ្រាន់តែលោកតាលើកដៃអីចេះ រួចអាកាំភ្លើងមួយនៅពីមុខ អាមួយនៅពីចំហៀងអីចេះ គ្រាន់តែអានេះវាត់ទៅអីចេះហ្នឹង អានេះវាត់ទៅអីចេះហ្នឹង (លោកតាបង្ហាញកាយវិការកៀសកាំភ្លើងចេញ) វាបាញ់តែគ្នាវាផាប់ទៅបាត់តែគ្នាវាទៅហើយ ប៉ុន្តែលោកតាស៊ូទ្រាំ អានេះពៀររបស់លោកតាពីអតីតកាល តែលោកតានៅតែរើបម្រះដោយសន្តិវិធីក្នុងរបៀបសាសនា ពីព្រោះលោកតាបាត់បង់សាសនាដូចបាត់ជីវិតលោកតាអីចឹង ដូចជាបាត់ជីវិតប្រជាជនអីចឹង លោកតាមើលឃើញ ដូចជាបាត់ជីវិតប្រជាជនមហាជននៅក្នុងប្រទេសយើងទាំងមូល បានជាមនុស្សគ្មានបុណ្យ គ្មានបាបសម្លាប់គ្នាអត់ដឹងខុសដឹងត្រូវដូចលោកតាបាននិយាយអីចឹងបានលោកតាខំរើបម្រះ រើទាល់តែមានព្រះពុទ្ធសាសនាឡើងវិញបានមនុស្សមានបុណ្យមានបាបវិញទៅ បានរកសន្តិភាពជូនប្រជាជនឲ្យវិញ លោកតាស៊ូទ្រាំអត់បាយល្ងាចរាល់ថ្ងៃហ្នឹងដើម្បីតែសុខដល់កូនដល់ចៅ ។ ដូច្នេះលោកតាអត់បញ្ចេញថាសម្រាប់អ្នកទាំងអស់គ្នាហ្នឹងឲ្យវិនិច្ឆ័យទោសក្នុងបច្ចុប្បន្នឬក៏ទៅអនាគតអាហ្នឹងគឺថាលោកតាអត់បញ្ចេញឲ្យទេ ។ ព្រោះលោកតា លោកតាអត់មានទេ ក្នុងបច្ចុប្បន្នលោកតាមិនឲ្យមាន ទៅអនាគតលោកតាមិនឲ្យមាន នេះសម្រាប់ខ្លួនលោកតាផ្ទាល់ ។*

## ពាក្យស្លោកខ្មែរក្រហម

**◆ ស្លាប់ដើម្បីផលប្រយោជន៍ប្រជាជនមានទម្ងន់ជាងភ្នំព្រះសុមេរុនៅទៀត ស្លាប់ដើម្បីពួកមូលធនសក្តិភូមិនិងពួកប្រតិកិរិយា មានទម្ងន់មិនបានស្លាបក្ងានផង។**

*(កំណត់ហេតុរបស់សមមិត្ត ញ៉ុក សារុន)*

# រូបថតឯកសារ

មជ្ឈមណ្ឌលឯកសារកម្ពុជាមានតម្កល់ទុករូបថតក្នុងរបបកម្ពុជាប្រជាធិបតេយ្យជាច្រើនប្រភេទ ហើយមានចំនួនសន្លឹកសន្ធាប់ ។ នៅក្នុងចំណោមរូបថតទាំងអស់នេះគឺមានតែរូបថតមួយចំនួនតូចតែប៉ុណ្ណោះដែលយើងអាចស្គាល់ថាជានរណានិងនៅទីកន្លែងណា ។ មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងសិក្សាស្រាវជ្រាវរកអត្តសញ្ញាណនៃរូបថតទាំងនោះជាបន្តបន្ទាប់ ។

ខាងក្រោមនេះគឺលទ្ធផលថ្មីមួយដែលបានមកពីការចុះស្រាវជ្រាវ ÷

***រូបថតទី១៖***

«ទុយ» មានស្រុកកំណើតនៅខេត្តតាកែវ ។ មុនពេលចូលធ្វើការនៅមន្ទីរស-២១ ទុយ ឋិតនៅក្នុងកងពល៧០៣ ។ «ណាន» មកពីខាងបស្ចិមតំបន់៣១ (អ្នកទី៣មិនស្គាល់ឈ្មោះ) និង «ទិត» មកពីបស្ចិមតំបន់៣១ ។ អ្នកទាំងបួននាក់នេះសុទ្ធតែជាយុទ្ធជនសួរចម្លើយនៃមន្ទីរស-២១ (គុកទួលស្លែង) រហូតដល់ឆ្នាំ ១៩៧៩ ។




***រូបថតទី២៖***

«ចាន់» អ្នកសរុបឯកសារចម្លើយសារភាពនៅមន្ទីរស-២១ មានកូន៥នាក់ ។ នៅខាងមុខ ចាន់ គឺប្រពន្ធនិងកូនរបស់ ចាន់ ។ ចាន់ ស្ថិតនៅក្នុងក្រុមរបស់ ឌុច ។ នៅឆ្នាំ ១៩៧៩ ចាន់ បានរត់ចូលព្រៃជាមួយ ឌុច ។




«ម៉ុន» ជាគណៈអចិន្ត្រៃយ៍មន្ទីរស-២១ ឬជាជំនួយការមន្ទីរស-២១(នៅឆ្នាំ១៩៧៦) ។ ក្រោយមកប្រហែលជាពាក់កណ្ដាលឆ្នាំ១៩៧៧ នៅពេលដែលកំពុងធ្វើស្រែនៅព្រៃស ឌុច បានចាប់ខ្លួន ម៉ុន ព្រមទាំងប្រពន្ធនិងកូន បញ្ជូនមកមន្ទីរស-២១ ។ ការចាប់នេះគឺដោយមានការឆ្លើយដាក់ពីមេបញ្ជាការកងពល៧០៣ដែលត្រូវបានចាប់ដាក់មន្ទីរស-២១ ។ នៅពីខាងមុខ ម៉ុន គឺជាប្រពន្ធនិងកូនរបស់ ម៉ុន ។

«ឌុច» ជាប្រធានមន្ទីរស-២១ បានរៀបការនៅឆ្នាំ១៩៧៦ឬ៧៧ជាមួយនារីពេទ្យ«ប្រធានពេទ្យ៩៨» ។ ឌុច មានកូនបីនាក់ ។ នៅពីមុខ ឌុច គឺជាប្រពន្ធនិងកូនស្រីរបស់ ឌុច ។




***រូបថតទី៣:*** *រូបទី១ខាងឆ្វេងដៃគឺ «ហ៊ី» មេបញ្ជាការវរសេនាតូចនៃកងពល៧០៣ ។ បន្ទាប់មកបានក្លាយជាអនុប្រធានមន្ទីរ ស-២១ ។ ហ៊ី បានរៀបការពេលមកធ្វើការនៅមន្ទីរស-២១ (គ្មានកូន) ។ នៅឆ្នាំ១៩៧៩ ក្រោយពេលដែលរត់ចេញពីមន្ទីរ ស-២១ បានប្រហែលជា៣-៤ខែ ហ៊ី ត្រូវ ឌុច ចាប់យកទៅសម្លាប់នៅក្នុងព្រៃនៅភូមិភាគពាយ័ព្យ ។*




***រូបថតទី៤:***

*រូបថតនេះថតនៅក្នុងឆ្នាំ១៩៧៦ មុនពេលចេញទៅការពារបុណ្យខួបជ័យជម្នះនៅពហុកីឡដ្ឋានអូឡាំពិក ។ ក្នុងរូបនេះមានឈ្មោះ «តេវ» កងការពារមន្ទីរស-២១ ។ នៅពីក្រោយ តេវ ឈ្មោះ «អ៊ឹម» កងការពារមន្ទីរស-២១ ។ នៅបន្ទាប់ តេវ គឺជាជាងថតរូបដែលមិនស្គាល់ឈ្មោះ ។ នៅពីក្រោយជាងថតរូបនោះ ឈ្មោះ «យ៉ាន» កងការពារមន្ទីរ ស-២១ ។ នៅជួរមុខរូបទី៤ឈ្មោះ «ឃូ ហ៊ុយ» (ឬ ហ៊ីម ហ៊ុយ) ។ នៅខាងក្រោយ ហ៊ីម ហ៊ុយ (អត់ពាក់មួក) គឺ «សារឿន» ជាងជួសជុលរថយន្តនៅមន្ទីរ ស-២១ ។ ក្រៅពីនេះមិនស្គាល់ឈ្មោះ ។*




***រូបថតទី៥:*** *រូបថតនេះគឺសមមិត្ត «ពីន» ដែលជាមេបញ្ជាការកងពល៧០៣ ។ រូបឈរនៅខាងមុខគឺជានិរសាររបស់ ពីន (មិនស្គាល់ឈ្មោះ) ។*

**អ៊ីសា ឧស្មាន**

## ទ្រឹស្ដីខ្មែរក្រហម

◆ **អាវុធជាកត្តាមួយសំខាន់ តែមិនមែនជាកត្តាឱ្យឈ្នះសង្គ្រាមទេ កត្តាសម្រេចធំបង្អស់ គឺមនុស្ស មិនមែនជាសម្ភារម្យ៉ាងទេ។**

*(ដកស្រង់ចេញពីសៀវភៅញុក ទំព័រទី៦០)*

# ទិន្នន័យទីតាំងរួមនៃអំពើប្រល័យពូជសាសន៍

## ការធ្វើផែនទីវាលពិឃាតនៃប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩៥-២០០០

(តពីលេខមុន)

| ល.រ | ល.រទីតាំង | ឈ្មោះទីតាំង | ទិន្នន័យរណ្តៅនិងជនរងគ្រោះតាមជាក់ស្តែង | | ទិន្នន័យរណ្តៅនិងជនរងគ្រោះតាមរបាយការណ៍ | | របាយការណ៍ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|
| | | | ប៉ាន់ស្មានរណ្តៅ | ប៉ាន់ស្មានជនរងគ្រោះ | ប៉ាន់ស្មានរណ្តៅ | ប៉ាន់ស្មានជនរងគ្រោះ | |
| ២០៥ | ១៥០១០១ | កូនត្នោត | ៣ | ៤០០ | គ្មាន | ៤០០ | ១៩៩៧ |
| ២០៦ | ១៥០១០២ | រំលេច | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ២០៧ | ១៥០១០៣ | វត្តរំលេច | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ២០៨ | ១៥០១០៤ | តាពងបាល់ | ១០០ | ៥០០ | ១០០-១៥០ | គ្មាន | ១៩៩៧ |
| ២០៩ | ១៥០២០១ | បន្ទាយពោធិ៍ជ្រៃ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ២១០ | ១៥០២០៤ | បន្ទាយពោធិ៍ជ្រៃ | ៥ | ៨០០០-៩០០០ | លើសពី១ | ១០៣៦៣ | ១៩៩៧ |
| ២១១ | ១៥០៣០១ | ទួលលៀប | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ២១២ | ១៥០៣០២ | ទួលលៀប | ៥០០ | ៧០០០ | ៤០០-៥០០ | ៤០០០ | ១៩៩៧ |
| ២១៣ | ១៥០៣០៣ | មន្ទីរតាវ៉ីត | ៥០ | ១៥០ | ៥០-៦០ | ១០០-១៥០ | ១៩៩៧ |
| ២១៤ | ១៥០៣០៤ | មន្ទីរតាវ៉ីត | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ២១៥ | ១៥០៣០៥ | អណ្តូងតាប៉ក់ | ២ | ១៥០ | ២ | ១០០-១៥០ | ១៩៩៧ |
| ២១៦ | ១៥០៣០៦ | អណ្តូងតាប៉ក់ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ២១៧ | ១៥០៥០១ | បន្ទាយអាទារី | ៧ | ៧០០ | ៧ | ៧០០ | ១៩៩៧ |
| ២១៨ | ១៥០៥០២ | បន្ទាយអាទារី | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ២១៩ | ១៧០៧០១ | ព្រៃតាឯក | ១ | ៥១ | ១ | ៥១ | ១៩៩៧ |
| ២២០ | ១៧០៧០២ | ព្រៃគោកតានង់ | ១ | ៥២ | ១ | ៥២ | ១៩៩៧ |
| ២២១ | ១៧០៧០៣ | គោកតាម៉ែន | ១ | ២៥០០ | ១ | ២៥០០-៣០០០ | ១៩៩៧ |
| ២២២ | ១៧០៧០៤ | អណ្តូងតាម៉ាន់ | ១ | ៧០ | ១ | ៧០ | ១៩៩៧ |
| ២២៣ | ១៧០៧០៥ | កោះថ្មី | ១ | ៣៨ | ១ | ៣៨ | ១៩៩៧ |
| ២២៤ | ១៧០៧០៦ | ព្រៃកូតាមុនី | ២០០ | ៣៥០ | ២០០ | ២៥០-៣០០ | ១៩៩៧ |
| ២២៥ | ១៧០៧០៧ | កោះថ្មី | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២២៦ | ១៧០៩០១ | វត្តខ្សាច់ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ២២៧ | ១៧០៩០២ | វត្តខ្សាច់ | ១ | ១២ | អណ្តូង | ១២ | ១៩៩៧ |
| ២២៨ | ១៧០៩០៣ | វត្តខ្សាច់ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ២២៩ | ១៧០៩០៤ | ទួលតាតៃ | ៣០ | ២៥០០ | លើសពី១ | ២៥០០-៣០០០ | ១៩៩៧ |
| ២៣០ | ១៧០៩០៥ | វត្តលលៃ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ២៣១ | ១៧១១០១ | វត្តតាយ៉ែក | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ២៣២ | ១៧១១០២ | ត្រពាំងបឹង | ៣ | ២០០ | អណ្តូងនិងរណ្តៅ | ២០០ | ១៩៩៧ |
| ២៣៣ | ១៧១១០៣ | សាលារៀនចិនណាំគួរ | ១ | ១៥ | ១ | ១៥ | ១៩៩៧ |
| ២៣៤ | ១៧១១០៤ | ព្រៃច្បារពីងពង់ | ១៥ | ២០០ | ១៥ | ២០០ | ១៩៩៧ |
| ២៣៥ | ១៧១១០៥ | ត្រពាំងកប់បាត់ | ២ | ៣០ | ២ | ៣០ | ១៩៩៧ |
| ២៣៦ | ១៧១១០៦ | ព្រៃចិនទុង | ២ | ១៥ | អណ្តូង | ១៦ | ១៩៩៧ |
| ២៣៧ | ១៩០៤០១ | ផ្ទះខាំវៀង | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ២៣៨ | ១៩០៤០២ | បឹងចោងហោង | គ្មាន | ១០០០ | គ្មាន | គ្មាន | ១៩៩៧ |
| ២៣៩ | ១៩០៤០៣ | គីឡូម៉ែត្រលេខ៤ | គ្មាន | ១០០០ | គ្មាន | គ្មាន | ១៩៩៧ |
| ២៤០ | ១៩០៤០៤ | ធនាគារ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ២៤១ | ២០០១០២ | ទួលកន្ទុយឆ្កែ | គ្មាន | គ្មាន | ច្រើនរយ | ១៥០០-២០០០ | ១៩៩៧ |
| ២៤២ | ២០០១០៣ | បុស្ស | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ២៤៣ | ២០០៣០១ | វត្តកំពង់អំពិល | គ្មាន | ៤២៥ | គ្មាន | ៤២៥ | ១៩៩៧ |
| ២៤៤ | ២០០៣០២ | ខ្ពបអំពិល | ៩ | ៤២៥ | លើសពី១ | ៤២៥ | ១៩៩៧ |
| ២៤៥ | ២០០៣០៣ | វត្តបាក្រុង | គ្មាន | ៤០៤ | គ្មាន | គ្មាន | ១៩៩៧ |
| ២៤៦ | ២០០៣០៤ | ទួលពពកវិល | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ២៤៧ | ២០០៣០៥ | ភូមិពពកវិល | គ្មាន | គ្មាន | ៤០០-៥០០ | ២០០០-២៥០០ | ១៩៩៧ |
| ២៤៨ | ២០០៤០១ | វត្តកំពង់ត្រាច | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ២៤៩ | ២០០៤០២ | ព្រៃរំដេង | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ២៥០ | ២០០៤០៣ | ព្រៃបុសត្នោត | ១០-១៥ | ១០០០-១៥០០ | ១០-១៥ | ១០០០-១៥០០ | ១៩៩៧ |

**(នៅមានត)**

តួលេខដែលចុះផ្សាយនៅក្នុងលេខនេះសម្រាប់ខេត្តព្រៃវែង ពោធិ៍សាត់ សៀមរាប ក្រុងព្រះសីហនុ ស្វាយរៀង និងខេត្តតាកែវ ។

◆ ចំពោះពត៌មានដែលដាក់ថា "គ្មាន" មានន័យថាពុំមានសាក្សីឬតួលេខ ប៉ុន្តែវត្តមានទីតាំងបានមកពីប្រភពផ្សេង ។

◆ ចំពោះពត៌មានដាក់ស្តែងនិងពត៌មានតាមរបាយការណ៍ មានន័យខុសគ្នាត្រង់ថា ពត៌មានដាក់ស្តែងគឺបានមកពីសាក្សីដែលបញ្ជាក់ប្រាប់នៅទីតាំងកើតហេតុ ។ ពត៌មានតាមរបាយការណ៍ មានន័យថា សាក្សីផ្សេងទៀតដែលប្រាប់តួលេខអំពីទីតាំងផងដែល ។

# ខ្មាន់កាំភ្លើងខ្មែរក្រហម



ផៃ ផៃភាព ហៅ ហ៊ី (បច្ចុប្បន្ន)

រយៈពេល៦ខែបន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម ផៃ ផៃភាព ហៅ ហ៊ី អតីតអនុលេខាកងវរសេនាតូចពិសេសប្រចាំកងពលលេខ៧០៣នៃកងទ័ពខ្មែរក្រហម ត្រូវបានជនាញការវៀតណាមនិងរដ្ឋាភិបាលនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ចាប់ខ្លួនដោយចោទប្រកាន់ថាមានជាប់ពាក់ព័ន្ធជាមួយរបបខ្មែរក្រហម ។ អស់រយៈកាលជាង៧ឆ្នាំដែល ហ៊ី ត្រូវជាប់នៅក្នុងមន្ទីរឃុំឃាំង ។ ហ៊ី បានទទួលស្គាល់ថា គាត់ពិតជាបានចូលរួមបម្រើបដិវត្តន៍ខ្មែរក្រហម ។

ហ៊ី បានរិះគន់ថា "ខ្ញុំមានការឈឺចាប់ណាស់ ។ ខ្ញុំមានតួនាទីត្រឹមតែជាអ្នកកាន់កាំភ្លើងប្រយុទ្ធតទល់ជាមួយកងទ័ពវៀតណាម ប៉ុន្តែហេតុអ្វីបានជាខ្ញុំត្រូវទទួលកំហុសទាំងនេះ ចំណែកឯមេដឹកនាំខ្មែរក្រហមជាច្រើននាក់បែរជានៅមានសេរីភាពនិងកំពុងរស់នៅយ៉ាងសុខសាន្ត ។ ខ្ញុំបានត្រឹមតែអនុវត្តតាមបញ្ជារបស់គេប៉ុណ្ណោះ ។ នេះមិនយុត្តិធម៌ទាល់តែសោះ ប្រសិនបើស្លាប់គឺស្លាប់ទាំងអស់គ្នា ពីព្រោះយើងជាអ្នកដឹកនាំគេ" ។

នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៩ ហ៊ី ត្រូវចាប់ខ្លួនបញ្ជូនទៅមន្ទីរឃុំឃាំងព្រែកតូច ស្ថិតនៅក្នុងស្រុកស្អាង ខេត្តកណ្តាល ។ គាត់ត្រូវបានជនាញការវៀតណាមប្រចាំស្រុកស្អាងសួរចម្លើយនិងឃុំខ្លួនបណ្តោះអាសន្នចំនួន២ខែទើបបញ្ជូនមកមន្ទីរឃុំឃាំង គ-៣ នៅភ្នំពេញអស់រយៈពេល៤ឆ្នាំ ។ ក្នុងអំឡុងឆ្នាំ១៩៨៥ គាត់ត្រូវបានបញ្ជូនចេញពីមន្ទីរឃុំឃាំង គ-៣ ឆ្ពោះទៅមន្ទីរឃុំឃាំងជើងអណ្តែងស្ថិតនៅក្នុងស្រុករមាសហែក ខេត្តស្វាយរៀង ។ គាត់ត្រូវនៅជាអ្នកទោសអស់រយៈពេលជាង៣ឆ្នាំថែមទៀត ។ ហ៊ី បានហៅខ្លួនគាត់ថាជា "អ្នកទោសនយោបាយ" ។

ហ៊ី កើតនៅឆ្នាំ១៩៥២ ក្នុងខេត្តតាកែវ ។ ឆ្នាំ១៩៧០ គាត់បានចូលធ្វើជាកងទ័ពរំដោះនៅក្នុងតំបន់៣៣ ភូមិភាគនិរតី (ខេត្តតាកែវ) ។ គាត់បានស្ម័គ្រចិត្តចូលធ្វើខ្មែរក្រហមដោយសារគាត់មានឈឺចាប់ចំពោះទាហាន លន់ ណុល ដែលបាញ់សម្លាប់បាតុករជាច្រើននាក់ក្នុងពេលកំពុងដើរក្បួនបាតុកម្មប្រឆាំងនឹងការធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ។

ចាប់តាំងពីចូលបម្រើក្នុងចលនាបដិវត្តន៍ខ្មែរក្រហម គាត់បានលត់ដំខ្លួនរហូតបានក្លាយទៅជាខ្មាន់កាំភ្លើងមួយរូបដ៏ពូកែ ។ គាត់បាននិយាយថា "អង្គការបានអប់រំថា ការធ្វើបដិវត្តន៍នេះគឺមិនមែនដើម្បីបម្រើផលប្រយោជន៍បុគ្គលឬបក្សពួកណាទេ នេះដោយសារប្រទេសយើងក្រីក្រ ហើយស្ថិតក្រោមរណបអាមេរិកាំង ម្ល៉ោះហើយយើងត្រូវរើខ្លួនទាំងអស់គ្នា" ។ នៅឆ្នាំ១៩៧២ អង្គការបានដកគាត់ពីតំបន់៣៣ មកធ្វើជាប្រធានកងអនុសេនាធំនៃកងវរសេនាតូចពិសេសស្ថិតក្នុងតំបន់២៥ប្រចាំភូមិភាគពិសេស(ខេត្តកណ្តាល) ។ កងវរសេនាតូចពិសេសមានមេបញ្ជាការបីនាក់គឺ ហ៊ី, ម៉ាត់ និង អ៊ឹម ។ នៅឆ្នាំ១៩៧៣ គាត់បានឃើញយុទ្ធជននៅក្នុងអង្គភាពរបស់គាត់បាញ់យន្តហោះ

សន្តេតការណ៍ចំនួន២គ្រឿងដែលបើកបរដោយជនជាតិអាមេរិកាំង ។ យន្តហោះមួយគ្រឿងបានធ្លាក់នៅឃុំកោះខែល ស្រុកស្អាង ខេត្តកណ្តាល និងមួយគ្រឿងទៀតធ្លាក់នៅវត្តប្រាសាទ ស្រុកបាទី ខេត្តតាកែវ ។

នៅក្នុងយុទ្ធសាស្ត្រវាយលុកទ្រង់ទ្រាយធំដើម្បីរំដោះយកទីក្រុងភ្នំពេញ គាត់បានទទួលបញ្ជាពី សមមិត្តហ៊ី (ឃឹម វ៉ាត ហៅ ហ៊ី) ឲ្យទៅវាយលុកនៅមុខសញ្ញាចម្ការដូង ។ គាត់បើកការវាយលុកចំនួនមួយសប្តាហ៍ទើបទទួលបានជ័យជម្នះលើសមរភូមិខ្សែត្រៀមនៃទាហាន លន់ ណុល ។ ប្រហែលម៉ោង៦ល្ងាច គាត់បាននាំទ័ពចូលទៅដល់ខាងកើតពហុកីឡដ្ឋានជាតិអូឡាំពិក ។ ប៉ុន្មានម៉ោងក្រោយមកទៀត កម្លាំងរបស់គាត់បានប្រយុទ្ធគ្នាជាមួយទាហាន លន់ ណុល ដែលកំពុងលាក់ខ្លួននៅតាមផ្ទះប្រជាជន ។ ទាហាន លន់ ណុល បានបាញ់សម្លាប់យុទ្ធជននៅក្នុងអង្គភាពរបស់គាត់ស្លាប់ចំនួន២នាក់ ម្នាក់ឈ្មោះ ខ្មៅ ជាប្រធានកងហា និងម្នាក់ទៀតឈ្មោះ ថា ជាប្រធានក្រុម ។


ផែ ផៃភាព ហៅ ហ៊ី (ឆ្នាំ១៩៧៧)

បន្ទាប់ពីមានហេតុការណ៍បាញ់គ្នាជាមួយទាហាន លន់ ណុល ហ៊ី (ឃឹម វ៉ាត) បានចេញបញ្ជាឲ្យគាត់រៀបចំកម្លាំងដើម្បីជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ។ ហ៊ី បានប្រកាសតាមមីក្រូថា "សូមបងប្អូនចាកចេញពីទីក្រុងចំនួនមួយសប្តាហ៍ ពីព្រោះអង្គការត្រូវការបោសសម្អាតខ្មាំងដែលបង្កប់ខ្លួននៅតាមផ្ទះនិងដើម្បីរៀបចំសម្អាតទីក្រុង ។ ម្យ៉ាងទៀតអាមេរិកមិនទាន់អស់ចិត្តចំពោះការបាញ់សង្គ្រាមនៅឡើយទេ ដូច្នេះសូមបងប្អូនចាកចេញឲ្យបានឆាប់ ចៀសវាងទទួលរងការទម្លាក់គ្រាប់ បេ-៥២ របស់អាមេរិក" ។

ហ៊ី បានលើកឧទាហរណ៍ថា ក្រោយពេលរំដោះហើយបានមិនដល់១ខែផង កប៉ាល់ម៉ាយ៉ាហ្គេរបស់អាមេរិកបានបើកចូលដែនសមុទ្រកម្ពុជា ។ កប៉ាល់នេះត្រូវបានកងពលលេខ១៦៤ របស់ មាស មុត ចាប់បាននៅកោះត្រល់ ។ ដោយសារមានជម្លោះអំពីរឿងកប៉ាល់ម៉ាយ៉ាហ្គេ ធ្វើឲ្យយុទ្ធជននៃកងពល១៦៤ស្លាប់មួយចំនួន ហើយទាហានអាមេរិកក៏មានស្លាប់ខ្លះដែរ ។

នៅចុងឆ្នាំ១៩៧៥ អង្គការបានចាប់ផ្តើមរៀបចំកងទ័ពឡើងវិញ បន្ទាប់ពីប្រជាជនត្រូវបានជម្លៀសចេញពីទីក្រុង ។ កងពលទាំងអស់របស់ខ្មែរក្រហមត្រូវបានរៀបចំជាថ្មីនៅពហុ-កីឡដ្ឋានជាតិអូឡាំពិក ។ គាត់នៅចាំបានថាថ្នាក់ដឹកនាំដែលបានចូលរួមក្នុងពិធីរៀបចំកងពលរួមមាន វ៉ន វេត, នួន ជា, សុន សេន និង តាម៉ុក លេខាភូមិភាគពិសេស ចំណែកឯ ប៉ុល ពត មិនមានវត្តមាននៅទីនោះទេ ។ គាត់បាននិយាយថា ឃឹម វ៉ាត ហៅ សមមិត្តហ៊ី ត្រូវបានអង្គការចាត់តាំងឲ្យធ្វើជាអនុប្រធានមន្ទីរ ស-២១ ។ ចំណែក អ៊ុយ ប៉េងឡេង ធ្វើជាលេខាកងវរសេនាតូចពិសេស ហើយគាត់ត្រូវបានអង្គការចាត់តាំងធ្វើជាអនុលេខាកងវរសេនាតូចពិសេសនៃកងពលលេខ៧០៣ប្រចាំអគ្គសេនាធិការ ។ កងពលលេខ៧០៣មានមេបញ្ជាការបីនាក់គឺ សមមិត្ត ណាត, សមមិត្ត ពីន និងសមមិត្ត ញ៉ី ។

ហ៊ី ទទួលស្គាល់ថា គាត់ធ្លាប់បានទទួលបញ្ជាពីសមមិត្ត ពីន ឲ្យជ្រើសរើសយុទ្ធជនដែលមានប្រវត្តិរូបស្អាតស្អំយកទៅបម្រើការនៅមន្ទីរ ស-២១ ។ យុទ្ធជនដែលគាត់បានជ្រើសរើសរួមមាន ហ៊ឹម ហ៊ុយ, ស៊ឹម ម៉េល ហៅ ម៉ាន និង លន់ ។ គាត់បានបញ្ជាក់ថា មុនពេលចាត់តាំងទៅស-២១ ហ៊ឹម ហ៊ុយ និង លន់ មានតួនាទីជាមេក្រុម ។ ម៉ាន មានតួនាទីជាយុទ្ធជននិរសា ។ តាមឯកសារប្រវត្តិរូបកម្មាភិបាលស-២១ ហ៊ឹម ហ៊ុយ ជាប្រធានកងវរសេនាតូចដែលមានតួនាទីចាប់និងការពារអ្នកទោស ។ សព្វថ្ងៃ ហ៊ឹម ហ៊ុយ ជាកសិកររស់នៅខេត្តកណ្តាល ។ ម៉ាន និង លន់ មានតួនាទីជាយុទ្ធជនស្ទួរចម្លើយនៅមន្ទីរ ស-២១ ។ ប៉ុន្តែ

ម៉ាន និង លន់ ត្រូវអង្គការកម្ទេចនៅឆ្នាំ១៩៧៧ ។

ចាប់ពីឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៧ ក្នុងខណៈដែល អ៊ុយ ប៉េងឡេង ត្រូវបានចាត់តាំងជាគណៈកម្មាធិការការពារក្រុង គាត់ត្រូវចាត់តាំងឲ្យត្រួតពិនិត្យចំពោះអង្គភាពការពារក្រុង ចាប់ពីក្បាលថ្នល់រហូតដល់ព្រែកក្ដាម ។ ក្រៅពីការងារយាមល្បាតក្រុងគាត់ត្រូវចុះទៅត្រួតពិនិត្យយុទ្ធជនធ្វើស្រែនៅព្រៃស និងបាគូនៅប៉ែកខាងត្បូងឆៀងខាងលិចក្រុងភ្នំពេញ ។ អង្គការបានប្រគល់ម៉ូតូម៉ាក សេ.អិល មួយគ្រឿងសម្រាប់ជាមធ្យោបាយក្នុងការធ្វើដំណើរ ។ ម្ដងម្កាលគាត់បានប្រាស់រថយន្តម៉ាកហ្ស៊ីប ផលិតនៅប្រទេសចិន ដើម្បីធ្វើអន្តរាគមន៍ចំពោះគោលដៅដែលមានបាតុភាពមិនប្រក្រតី ។

នៅឆ្នាំ១៩៧៧ ហ៊ី បានទៅចូលរួមប្រជុំនៅអគ្គសេនាធិការកងទ័ពអំពីការរៀបចំកម្លាំងបញ្ជូនទៅខេត្តស្វាយរៀងដើម្បីទប់ទល់នឹងកងទ័ពវៀតណាម ។ គាត់បាននិយាយថា "សមាសភាពចូលរួមប្រជុំនៅយប់នោះមាន តាខៀវ (សុន សេន), តាណាត, តាពីន និងប្រធានវរសេនាធំនៃកងពលលេខ៧០៣ជាច្រើននាក់ទៀត ។ ដំណើរការប្រជុំបានប្រព្រឹត្តទៅប្រហែលជាមួយម៉ោង ចាប់ពីម៉ោង៧រហូតដល់ម៉ោង៨យប់ ។ កម្មាភិបាលដែលចូលរួមប្រជុំបានឡើងធ្វើការប្ដេជ្ញាចិត្តថា"នឹងការពារឲ្យបាន" ។

លើកដំបូងនៃការប្រយុទ្ធគ្នាជាមួយកងទ័ពវៀតណាមនៅភ្នំក្រោល ភាគខាងត្បូងខេត្តស្វាយរៀង បានធ្វើឲ្យគាត់ត្រូវរបួសស្មានិងចង្កេះ ហើយយុទ្ធជននៅក្នុងកងវរសេនាតូចជាច្រើននាក់បានទៀតស្លាប់បាត់បង់ជីវិត ។ គាត់បាននិយាយដោយម៉ឺងម៉ាត់ថា ការចាញ់សង្គ្រាមលើកដំបូងនេះបានធ្វើឲ្យគាត់កាន់តែមានកម្លាំងចិត្តបន្តការវាយបកទៅកងទ័ពវៀតណាមទៀត ។ គាត់បានចាប់ផ្ដើមរៀបចំទ័ពជាលើកទីពីរ ហើយវាយរុញច្រានកងទ័ពវៀតណាមទៅដល់ផ្សារដីភូ និងបន្តវាយលុកចូលដល់ខេត្តតាយនិញនៃប្រទេសវៀតណាម ។

ហ៊ី បាននិយាយថា គាត់ធ្លាប់ចាប់បានកងទ័ពវៀតណាមប្រមាណជាង៣០នាក់ក្នុងនោះមានស្ត្រីអាយុប្រហែល២០ឆ្នាំចំនួន៣នាក់បញ្ជូនទៅឲ្យសមមិត្ត ពីន លេខាកងពល ។ គាត់បានបញ្ជាក់ថា ខ្មាំងដែលចាប់បានត្រូវបញ្ជូនទៅកងពល ហើយកងពលបញ្ជូនបន្តទៅសេនាធិការទៀត ។ ជារឿយៗ គាត់បានស្ដាប់វិទ្យុស្ដីពីការធ្វើសម្ភាសន៍ឈ្លើយសឹកវៀតណាម ។

ហ៊ី បានបន្តថា ខណៈអំឡុងពេលប្រយុទ្ធជាមួយកងទ័ពវៀតណាមកាន់តែខ្លាំង អង្គការបានចាប់ខ្លួនកម្មាភិបាលចាប់ពីកងអនុសេនាធំឡើងទៅកាន់តែច្រើន ។ គាត់បានរៀបរាប់ថា មិត្តភក្តិរបស់គាត់ជាច្រើននាក់ត្រូវអង្គការចាប់ខ្លួនបញ្ជូនទៅមន្ទីរ ស-២១ ដូចជា អ៊ុយ ប៉េងឡេង ជាលេខាកងវរសេនាតូចពិសេស, ផល ជាលេខាកងកាំភ្លើងធំ, សឿន ជាលេខាកងវរសេនាធំលេខ៣២ និង ចេវ ជាលេខាកងវរសេនាធំលេខ៣៣ ។ ឈ្មោះដែលគាត់បានបញ្ជាក់ខាងលើនេះគឺសុទ្ធតែមានចម្លើយសារភាពតម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ហ៊ី បានរំឭកឡើងវិញថា យុទ្ធជនរាប់ពាន់នាក់បានត្រូវកងទ័ពវៀតណាមព័ទ្ធជាប់ និងសម្លាប់នៅក្នុងទឹកដីវៀតណាម ។ បន្ទាប់ពីគាត់បានរំដោះខ្លួនចេញពីទឹកដីវៀតណាម គាត់បានទទួលដំណឹងថា តាណាត ត្រូវអង្គការចាប់ខ្លួនមកមន្ទីរស-២១ ហើយតាពីនត្រូវបានបាញ់សម្លាប់នៅលើសមរភូមិ ។ ប្រមាណជាមួយខែបន្ទាប់កងទ័ពវៀតណាមទទួលជ័យជម្នះលើរបបខ្មែរក្រហម អង្គការបានដកគាត់ឲ្យមកធ្វើជាលេខាកងវរសេនាធំប្រចាំកងពល៣៨០ ។ គាត់បានបញ្ជាក់ថា អំឡុងពេលនោះគាត់លែងមានទឹកចិត្តប្រយុទ្ធទៅទៀតហើយ ពីព្រោះមិត្តភក្តិរបស់គាត់ជាច្រើននាក់ត្រូវអង្គការដកមកសេនាធិការស-២១ ដូច្នេះមិនយូរមិនឆាប់គាត់ក៏នឹងមានវាសនាដូចអ្នកទាំងនោះដែរ ។

បច្ចុប្បន្ននេះ ហ៊ី រស់នៅក្នុងខេត្តកណ្ដាល ។ បន្ទាប់ពីគាត់ត្រូវបានដោះលែងឲ្យមានសេរីភាពវិញ គាត់សង្ឃឹមថានឹងបានមករស់នៅជួបជុំប្រពន្ធនិងកូនស្រីរបស់គាត់ ។ ប៉ុន្តែសេចក្ដីសង្ឃឹមរបស់គាត់ត្រូវបាត់បង់ទៅវិញ ។ អំឡុងពេលគាត់ជាប់នៅក្នុងមន្ទីរឃុំឃាំង ប្រពន្ធរបស់គាត់បានរៀបការប្ដីថ្មី ។ គាត់និយាយថា "ប្រហែលជាគេហ៍ (ប្រពន្ធរបស់គាត់) គិតថាខ្ញុំស្លាប់បាត់ទៅហើយ បានជាគេហ៍រៀបការប្ដីថ្មី" ។ ហ៊ី បានបន្ទោសខ្លួនឯងថា "ដោយសារតែខ្ញុំដើរតាមខ្មែរក្រហម ទើបធ្វើឲ្យខ្ញុំបាត់បង់ប្រពន្ធ ហើយរូបខ្ញុំនិងកូនស្រី ត្រូវរស់នៅក្នុងសភាពគោកយ៉ាកបំផុត" ។

**ហ៊ុយ វណ្ណៈ**

**(តពីលេខមុន)   ចំណុចទី៥: បង្ខំឱ្យឆ្លើយ**

ដំណើរប្រមូលផ្តុំណាហ្ស៊ីស្ថិតក្រោមការត្រួតពិនិត្យមើលការខុសត្រូវរបស់ វ៉ូល ហ្វេង សហ្ស៊ី ។ ដំណើរនេះមិនខុសគ្នាពីមន្ទីរ ស-២១ទេ ពេលគឺថា «អំពើហិង្សាហួសវិស័យជាបាតុភាពប្រចាំថ្ងៃទៅហើយ» ។ ឯកសារមួយចំនួនបានមកពីគុកនេះ និងជាពិសេសបានមកពីអ្នកដែលធ្វើការខាងទារុណកម្ម បង្ហាញនូវអំពើដ៏គួរឲ្យភ័យរន្ធត់ និងនិយាយយ៉ាងស្ងៀមស្ងាត់អំពីការឈឺចាប់ដែលពិបាកនឹងរៀបរាប់ ទោះជាអ្នកទាំងនោះនាំយើងទៅជួបជនរងគ្រោះក៏ដោយ ។ ឧទាហរណ៍ នៅខែកក្កដា ឆ្នាំ១៩៧៧ អ្នកសួរចម្លើយម្នាក់បានភ្ជាប់ចំណារមួយច្បាប់ដែលមិនមានចុះហត្ថលេខាជាមួយនឹងចម្លើយសារភាពរបស់ កែ គឹមហួត អតីតលេខាតំបន់៧ ភូមិភាគពាយ័ព្យ ។ កំណត់ហេតុនេះសរសេររៀបរាប់ថា÷




**សម្លេងពីមន្ទីរ ស-២១**
**ចំណុចទី៥: បង្ខំឱ្យឆ្លើយ**
**ដោយសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ**

«១) នៅព្រឹកថ្ងៃទី១៨ ខែកក្កដា ឆ្នាំ៧៧ ខ្ញុំសម្រេចថា ត្រូវតែធ្វើទារុណកម្ម ។ ខ្ញុំបានប្រាប់អ្នកទោសថាខ្ញុំធ្វើដូច្នេះ ពីព្រោះខ្ញុំភ្ជាប់ចំណុចខ្សោយដែលវានិយាយមិនទាន់បាន ហើយការសង្កត់សួររបស់ខ្ញុំមិនបានលទ្ធផលអ្វីសោះ ។ នេះជាដំណើររបស់ខ្ញុំ ។ ខ្ញុំឃើញវាធ្លាក់ទឹកមុខ តែមិនមានប្រតិកម្មអ្វីឡើយ ។ នៅពេលចាប់ផ្តើមសួរ វានៅតែដដែល ។ ចំពោះសុខភាពវាវិញ វាបានស៊ីបបរ ប៉ុន្តែវាដេកមិនបានទេ ។ ពេទ្យនៅមើលវាហើយ ។

២) នៅព្រឹកថ្ងៃទី២០ ខែកក្កដា ឆ្នាំ៧៧ ខ្ញុំចាប់ផ្តើមវាយវាម្តងទៀត ។ ពេលនេះប្រតិកម្មវាគឺថា វាមិនមែនជាជនក្បត់ទេ ប៉ុន្តែអ្នកដែលចោទប្រកាន់វាទេដែលជាជនក្បត់ ។ សុខភាពវានៅមិនទាន់រឹងប៉ឹងទេ ប៉ុន្តែមិនមែនជារឿងធ្ងន់ធ្ងរអ្វីទេ ។

៣) ល្ងាចនិងយប់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ៧៧ ខ្ញុំសង្កត់វាម្តងទៀតដោយប្រើខ្សែភ្លើងនិងលាមក ។ វាស្រែកថា «ពួកឯងរំអញឲ្យស្លាប់តែម្តងទៅ» ។ គេឲ្យវាស៊ីអាចម៍២-៣ស្លាបព្រា ហើយក្រោយមកទើបវាឆ្លើយពីឈ្មោះ ហ៊ីង, ចូវ, ភ៉ា ។ល ។

៤) យប់នោះខ្ញុំវាយវាដោយខ្សែភ្លើងម្តងទៀត ។

ឥឡូវនេះវាខ្សោយបន្តិចហើយ ។ ពេទ្យបានទៅមើលវាហើយ ។ វាបានសុំឲ្យសម្រាកសិន ៗ»

សម្តីរបស់អ្នកសួរចម្លើយម្នាក់ទៀតបង្ហាញយ៉ាងច្បាស់នូវទំនាក់ទំនងលម្អៀងរវាងអ្នកធ្វើទារុណកម្មនិងជនរងគ្រោះ ។ លោក ម៉ៃឃើល ហ្វូខល បានប្រៀបធៀបអ្នកទាំងពីរទៅនឹង«ការប្រយុទ្ធ១ទល់១» ហើយនិងល្បែងអុក÷

«មុនដំបូងខ្ញុំសួរខ្លាំងអំពីជីវិតនិងបក្សពួកវា ។ នៅពេលដែលខ្ញុំធ្វើយ៉ាងនេះ ខ្ញុំនិយាយពីរឿងវិន័យរបស់មន្ទីរ«ស-២១» ហើយខ្ញុំប្រាប់វាថា ខ្លួនឯងថោកជាងសំរាមទៅទៀត ។ ខ្ញុំឲ្យវាគោរពខ្ញុំ ។ ខ្ញុំប្រាប់វាថា បើអញឲ្យឯងនិយាយអ្វី ឯងត្រូវតែនិយាយដាច់ខាត ។ ខ្ញុំឲ្យវាថ្វាយបង្គំរូបសត្វឆ្កែមួយក្បាល (ដែលជាវិធីធ្វើទារុណកម្មទៅមួយមានរូបឆ្កែដែលមានដាក់ក្បាលហូជីមិញ) ។ ខ្ញុំបានវាយវានិងសួរវារហូតដល់វានិយាយថាវាធ្លាប់ធ្វើជា សេ.អ៊ី.អា ។ ក្រោយពីខ្ញុំវាយវាថែមទៀត វានិយាយថាវាចូលធ្វើសេ.អ៊ី.អានៅឆ្នាំ១៩៦៩ ។

នៅពេលវាឆ្លើយសារភាព ខ្ញុំមិនចាំបាច់រំវាឈ្លេចយកប្រវត្តិរបស់វាដែលមិនទាន់និយាយទេ ប៉ុន្តែនៅពេលវារួញរាមិនចង់ឆ្លើយ ឬនិយាយដល់ចំណុចខ្សោយនៅក្នុងប្រវត្តិវា ខ្ញុំរំវា ហើយរំវាឲ្យបញ្ជាក់ឲ្យបានច្បាស់ចំណុចទាំងឡាយនៅក្នុងប្រវត្តិវាដែលពត៌មានសំខាន់ៗមានលក្ខណៈច្របូកច្របល់» ។

យើងគ្មានពាក្យអ្វីនឹងថ្លែងទេនៅពេលជួបឯកសារនិងរូបថត

គួរឲ្យរន្ធត់បែបនេះនៅមន្ទីរ ស-២១ ។ ពិតណាស់ ហ្សង់ អាមេរី និង អេឡែន ស្ការី បានបញ្ជាក់ដោយប្រើពាក្យយ៉ាង ប៉ិនប្រសប់ថា បទពិសោធន៍ធ្វើទារុណកម្មមិនអាចរកអ្វីមកនិយាយបានទេ ។ ស្ការី ថែមទាំងលើកឡើងថា ការឈឺចាប់បានលុបបំបាត់ភាសា ។ ប្រហែលជាយ៉ាងនេះហើយបានជាគ្មាននិយមន័យច្បាប់ច្បាស់លាស់សម្រាប់ពាក្យទារុណកម្ម ។ បើដូច្នេះមែន ហេតុអ្វីបានជាអ្នកនិពន្ធជាច្រើននៅតែបន្តព្យាយាមសរសេរអំពីទារុណកម្មនេះទៀត? ហេតុអ្វីបានជាយើងគួរសរសេររឿងនេះ? ។ ការឈឺចាប់មិនអាចយកមក"សរសេរឲ្យបានល្អទេ" ។ អាមេរី បានកត់សម្គាល់ថា "ទារុណកម្មពិតជាព្រឹត្តិការណ៍ដ៏គួរឲ្យរន្ធត់បំផុតដែលមនុស្សលោកអាចរក្សានៅក្នុងខ្លួនផ្ទាល់" ។ លោកបន្ថែមទៀតថា "សម្រែកឈឺចាប់ពិបាកនឹងយកភាសាមកប្រើឲ្យត្រូវណាស់ ។ ទោះបីជាប្រហែលមកអំពីយ៉ាងនេះហើយ បានជាអ្នកនិពន្ធក៏ដូចជាអ្នកអាន ហ៊ានរហូតដល់ប្រើប្រធានបទដែលអាក្រក់គួរឲ្យខ្លាច គួរឲ្យចាប់អារម្មណ៍ និងមិនអាចនិយាយចេញ ។

យើងមានអារម្មណ៍ធ្លាក់ថ្លើមក្តុកនៅពេលគិតដល់ការធ្វើទារុណកម្មនៅមន្ទីរ ស-២១ តាមរយៈការមើលរូបថតនិងបើកឯកសារមើលម្តងមួយសន្លឹកៗនោះ ។ តាមគំនិតដែលទទួលបាននេះនាំឲ្យមានការគិតមមៃថា អំពើទុយ៌សទាំងអស់ដែលរាលដាលនៅរបបកម្ពុជាប្រជាធិបតេយ្យ គឺមិនខុសពីទិដ្ឋភាពនៅក្នុងគុកនេះទេ ។ ពេលមើលរូបថតគ្រប់សន្លឹកនិងចម្លើយសារភាពទាំងអស់ធ្វើឲ្យយើងដឹងពីវាសនារបស់អ្នកទោស ។ យើងប្រទះការពិពណ៌នាពីអំពើឃោរឃៅនិងអត្ថហេតុនៃការស្លាប់ជាបន្តបន្ទាប់ ។ នៅពេលជាមួយគ្នានេះដែរ យើងមិនបានឃើញអ្វីដែលកើតឡើងពិតប្រាកដចំពោះចិត្តគំនិតនិងរាងកាយរបស់ជនរងគ្រោះ និងបុគ្គលិកលក្ខណៈរបស់ជនដៃដល់ឡើយ ។ អ្វីដែលបានកើតឡើងគឺជារឿងអាក្រក់គួរឲ្យខ្លាចណាស់ ប៉ុន្តែការណ៍នេះកើតឡើងចំពោះមនុស្សផ្សេងទៀតយូរណាស់មកហើយ ។ យើងគិតថា "អំពីអាក្រក់គ្មានសីលធម៌"មានកើតឡើងនៅកន្លែងផ្សេងៗទៀត ។

## បញ្ហានៃការសិក្សាអំពីការធ្វើទារុណកម្ម

ការសិក្សារបស់យើងអំពីទារុណកម្មនៅមន្ទីរ ស-២១ មានកម្រិតដោយសារតែយើងមិនបាននៅជិតអ្វីដែលបានកើតឡើងកន្លងមក និងប្រភពឯកសារពត៌មានទាក់ទងនឹងប្រធានបទនេះមិនសូវសម្បូរបែប ។ ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ១៩៨០ មានតែអ្នកនៅរស់រានមានជីវិតពីមន្ទីរ ស-២១ ចំនួនបីនាក់ប៉ុណ្ណោះ ដែលបាននិយាយយ៉ាងពិស្តារអំពីអ្វីដែលខ្លួនបានជួបប្រទះ ។ សក្ខីកម្មរបស់ជនរងគ្រោះដែលមានវាសនារួចពីសេចក្តីស្លាប់ទាំងនេះពិតជាមានតម្លៃនិងផុសចេញពីដួងចិត្តពិតៗ ។ ប៉ុន្តែរឿងរ៉ាវដែលនិយាយចេញមកនេះមានកម្រិត ដែលបានមកពីការឃោសនានៅទសវត្សរ៍ឆ្នាំ១៩៨០ បានមកពីកិច្ចសម្ភាសន៍ដែលសោះកក្រោះ និងបានមកពីការចងចាំស្រពេចស្រពិលរបស់ខ្លួនដែលជួបប្រទះព្រឹត្តិការណ៍យូរមកហើយ ។ មិនតែប៉ុណ្ណោះសោត អ្នកទាំងនេះមិនអាចរ៉ាយរ៉ាប់អំពីលក្ខខណ្ឌនៅក្នុងគុកនៅឆ្នាំ១៩៧៦ គឺមុនពេលដែលត្រូវចាប់ខ្លួនឡើយ ។

ស្រដៀងគ្នានេះដែរ មានតែអតីតអ្នកធ្វើការនៅមន្ទីរ ស-២១ ចំនួន៦នាក់ប៉ុណ្ណោះ គឺ ឌុច ឆ្មាំគុក៣នាក់ អ្នកថតរូបម្នាក់និងម្នាក់ទៀតធ្វើការខាងឯកសារដែលត្រូវបានធ្វើសម្ភាសន៍យ៉ាងលម្អិតនាពេលថ្មីៗនេះ ។ ក្នុងចំណោមអ្នកធ្វើការនៅមន្ទីរ ស-២១ ទាំង៦នាក់ មានតែម្នាក់គត់ គឺឈ្មោះ ហ៊ឹម ហ៊ុយ ដែលសារភាពថាខ្លួនពិតជាបានសម្លាប់មនុស្សមែន ។ ហ៊ឹម ហ៊ុយ និយាយថាគាត់មិនមែនជាអ្នកធ្វើទារុណកម្មទេ ។ គ្មានអ្នកណាម្នាក់ក្នុងចំណោមអ្នកដែលសារភាពថា បានធ្វើទារុណកម្មអ្នកទោស ហ៊ានចេញមុខឡើយ ។ អតីតអ្នកធ្វើការនៅក្នុងគុកមួយចំនួនដូចជាហ៊ុយ ជាដើម ត្រូវបានចាប់យកទៅអប់រំនៅទសវត្សរ៍ឆ្នាំ១៩៨០ ដោយសារបានធ្វើសកម្មភាពនៅមន្ទីរ ស-២១ ក៏ប៉ុន្តែគ្មានអ្នកទោសណាម្នាក់ធ្លាប់និយាយឲ្យពិស្តារអំពីសកម្មភាព ហើយក៏គ្មានអ្នកណាម្នាក់ត្រូវបានយកមកកាត់ទោសតាមច្បាប់ដែរ ។

នៅមន្ទីរ ស-២១ កម្រមានជនរួចពីសេចក្តីស្លាប់ណាស់ ហើយសក្ខីកម្មផ្ទាល់មាត់ឬការចងចាំអំពីគុកតាមរយៈសំណេរក៏កម្រមានដែរ ។ ការណ៍នេះវាផ្ទុយស្រឡះពីស្ថាប័នផ្សេងៗទៀត ដូចជានៅក្នុងមន្ទីរព្រហ្មទណ្ឌនៅប្រទេសសូវៀត ប្រទេសចិន និងជំរំណាហ្ស៊ីជាដើម ដែលនៅទីនោះមានសល់ស្នាដៃនិពន្ធ

និងអ្នកនៅរស់ផុតពីសេចក្តីស្លាប់ជាច្រើននាក់ ។ ឯកសារទាក់ទងការធ្វើទារុណកម្មនិងអំពើឃោរឃៅគ្មានត្រាប្រណីក៏មានច្រើនដែរនៅប្រទេសផ្សេងៗទៀត ។ ឧទាហរណ៍ស្នាដៃដែលទាក់ទងនឹងរឿងជនដៃដល់ជាជនជាតិអាល្លឺម៉ង់សម្លាប់រង្គាលទៅលើជនជាតិជ្វីហ្វរបស់ គ្រីស្តូហ្វ័រ ប្រោននីង, ដានីញែល ហ្គោលហាហ្គិន, រ៉ូល ហ៊ីលប៊ឺក និង ហ្គីតា សឺរ៉ែនី មិនអាចដូចគ្នានឹងមន្ទីរ ស-២១ទេ ហើយក៏មិនដូចគ្នានឹងកំណត់ប្រវត្តិរបស់ ហ្សង់ អាមេរី, ប្រីម៉ូ ឡេវី, អាឡិចសាន់ដ័រ សូលហ្សិននីតស៊ីន និង ចាកូបូ ទីម័រមែន ឬការសិក្សាស្រាវជ្រាវរបស់ រ៉ាលិនទីន ដានីញែល ទៅលើប្រទេសស្រីលង្កាដែរ ដែលស្នាដៃនេះមានផ្អែកខ្លះៗទៅលើកិច្ចសម្ភាសន៍ជាមួយអតីតអ្នកសួរចម្លើយនិងជនរងគ្រោះ ។ ក្នុងការសិក្សាស្រាវជ្រាវអំពីទារុណកម្មនៅមន្ទីរស-២១ យើងផ្តោតសំខាន់ទៅលើឯកសារដកស្រង់បានមកពីជនរងគ្រោះដែលត្រូវបានសួរចម្លើយដែលឥឡូវនេះបានស្លាប់អស់ហើយ ឬចម្លើយសារភាពដែលបង្ហាញពីទស្សនៈអំនួតទស្សនៈឆ្លើយយករួចខ្លួន ឬឆ្លើយមិនឲ្យមានកំហុសរបស់អ្នកធ្វើទារុណកម្មផ្ទាល់តែម្តង ។ បើគ្មានការបញ្ជាក់អះអាងពីភាពត្រឹមត្រូវតាមរយៈប្រភពឯកសារផ្សេងទៀតទេ យើងមិនអាចនិយាយថាតើឯកសារទាំងអស់នេះនិយាយបំផ្លើសឬនិយាយមិនអស់នូវខ្លឹមសារនៃអ្វីដែលកើតឡើងនៅមន្ទីរ ស-២១ ឡើយ ។ ក្រោយពីចូលប្រឡូកក្នុងគំនរឯកសារអស់ជាច្រើនឆ្នាំមកខ្ញុំទស្សន៍ទាយថាមានអំពើសាហាវយង់ឃ្នងរាប់មិនអស់និងទារុណកម្មរាប់រយជំពូកដែលមិនមានអ្នកណាកត់ត្រាទុក ។ អ្វីដែលយើងអាចអានបានមានតែដានមិនសូវច្បាស់លាស់នៃអ្វីដែលកំពុងតែដំណើរការកាលពីពេលនោះ ហើយតាមរយៈដាននេះ យើងគ្រាន់តែដឹងល្អៀងៗប៉ុណ្ណោះអំពីការបំផ្លិចបំផ្លាញដែលកើតឡើងនៅមន្ទីរ ស-២១ ។





ទោះបីជាមានឧបសគ្គទាំងអស់នេះយ៉ាងណាក៏ដោយ ក៏ការធ្វើទារុណកម្មនិងអំពើឃោរឃៅមានសារសំខាន់ណាស់ចំពោះមន្ទីរ ស-២១ និងចំពោះសមត្ថភាពរបស់យើងក្នុងការស្វែងយល់អំពីគុកនេះ ។ យើងចាំបាច់ត្រូវបង្កើតដំណើរដើមទងនៃការស្រង់បានជាចម្លើយសារភាពនេះ ។ យើងត្រូវស្វែងយល់អំពីការគិតរបស់អ្នកគ្រប់គ្រងគុក និងយល់ពីហេតុផលដែលនាំឲ្យអ្នកទាំងនោះប្រើទារុណកម្ម ។ សំខាន់បំផុត ដូចដែល អាឡិចសាន់ដ័រ ហ៊ិនតុន បានស្នើដែរថា យើងត្រូវ«ធ្វើឲ្យមានមនុស្សធម៌ឡើងវិញ» ចំពោះជនរងគ្រោះនៅក្នុងរបបខ្មែរក្រហម ដោយបញ្ជាក់ច្បាស់អំពីការឈឺចាប់ដែលបានកើតឡើងចំពោះបុគ្គលទាំងនេះ ។

ក៏ប៉ុន្តែអ្វីដែលធ្វើឲ្យមានការចាប់អារម្មណ៍ចំពោះការដាក់ទារុណកម្មនៅក្នុងគុកគឺមិនមែនជាសភាពឃោរឃៅទេ ទោះបីជាទារុណកម្មដែលត្រូវបានធ្វើឡើងមានភាពឃោរឃៅយ៉ាងណាក៏ដោយ ។ ក៏ប៉ុន្តែអ្វីដែលចាប់អារម្មណ៍នោះគឺដំណើរការដែលគិតថាសមហេតុសមផល ។ អំនួតក្នុងការជ្រើសរើសទារុណកម្មមកប្រើនិងសរសេរឡើង ស្តាប់ទៅមិនគួរឲ្យបាក់ទឹកចិត្តទេ ។ យើងអាចយល់បាននូវការផ្ទុះចេញនូវសភាពឃោរឃៅបានដោយងាយនៅក្នុងខ្លួនយើងឬអ្នកដទៃ ប៉ុន្តែយើងពិតជាពិបាកយល់ណាស់ចំពោះសភាពឃោរឃៅដែលរៀបចំទុកជាមុន ។ ការពន្យល់មួយទៅលើភាពមានអំនួតនេះ ដូចគ្នាទៅនឹងការសង្កេតរបស់ ដារី រីចាលី នៅក្នុងការសិក្សាស្រាវជ្រាវរបស់គាត់អំពីទារុណកម្មនៅប្រទេសអ៊ីរ៉ង់ដែរ គឺថា ទារុណកម្មមិនមែនជាវិធីសាស្ត្រល្អណាស់ណាទេក្នុងការជម្រិតយកភ័ស្តុតាងនិងចម្លើយ

សារភាពជាក់លាក់ ហើយក៏មិនមែនជាទម្រង់នៃការសប្បាយ ដោយបានធ្វើបាបអ្នកដទៃដែរ និងធ្វើឲ្យមានហេតុផលក្នុងការផ្តល់អំណាចដល់អ្នកដែលធ្វើទារុណកម្ម ជាពិសេសនៅពេលដែលអ្នកធ្វើទារុណកម្មទាំងនោះជាតំណាងរបស់រដ្ឋ ។ អ្នកនិពន្ធផ្សេងៗទៀតដែលសរសេរអំពីទារុណកម្ម បានបញ្ចេញទស្សនៈប្រហាក់ប្រហែលគ្នានេះដែរ ។

ដោយចាំជាប់នូវរូបមន្តរបស់ វីចាលី នៅក្នុងគំនិត យើងអាចយល់បានថា ទារុណកម្មនៅមន្ទីរ ស-២១ គឺមិនមែនត្រឹមតែជារឿងរបស់យុវជនយុវនារីដែលបង្ហុះខ្លួនដាក់ទៅលើអ្នកទោសដែលគ្មានការការពារខ្លួនទាល់តែសោះនោះទេ ទោះជាអ្នកនោះបានធ្វើជារឿយៗក៏ដោយចុះ ហើយក៏មិនមែនជាការពង្រីកឲ្យកាន់តែវែងនូវដំណើរការនីតិវិធីរបស់នគរបាលដែរ ទោះជារបស់ទាំងអស់នេះ (មានជាអាទិ៍ដូចជា រូបថតពាក់កណ្តាលខ្លួនស្នាមផ្តិតមេដៃ និងការវាយអ្នកទោសពីដំបូងដៃ) ជារឿងដែលកើតឡើងរៀងរាល់ថ្ងៃនៅមន្ទីរស-២១ យ៉ាងណាក៏ដោយ ។ តែផ្ទុយទៅវិញ ទារុណកម្មនៅមន្ទីរស-២១ ត្រូវបានធ្វើឡើងដោយចេតនានិងបង្ខំ ។ ការវាយដំនិងធ្វើទារុណកម្មគឺពិតជាគ្មានមេត្តា ប៉ុន្តែជាទូទៅ ទារុណកម្មមានការអនុញ្ញាតពីសំណាក់មេៗជាមុនសិនទើបអាចធ្វើទៅបាន ។ តែជួនកាល មេៗនៅពីលើក៏មិនអនុញ្ញាតឲ្យធ្វើទារុណកម្មដែរ ។ អ្នកសួរចម្លើយដែលប្រើទារុណកម្ម "ហួសហេតុ" (ទារុណកម្មដែលធ្វើឲ្យអ្នកទោសស្លាប់មុនពេលបញ្ចប់ចម្លើយសារភាពចប់ចុងចប់ដើម) បានទិតៀនខ្លួនឯងនៅក្នុងការប្រជុំស្វ័យទិតៀន ហើយមានពេលខ្លះដែលអ្នកធ្វើខុសត្រូវបានផ្តន្ទាទោសទៀតផង ។ នៅក្នុងចម្លើយសារភាពចំនួន៨ច្បាប់ដែលធ្វើឡើងនៅចុងឆ្នាំ១៩៧៨ អ្នកសួរចម្លើយកត់សម្គាល់ថា ចម្លើយសារភាពនេះស្រង់ចេញដោយមិនមានការធ្វើទារុណកម្មឡើយ ។ កាលនោះ គុកនៃមន្ទីរ ស-២១ ដំណើរការយ៉ាងរលូននិង"សមហេតុផល"ជាងកាលពីឆ្នាំ១៩៧៦ ដែលកាលនោះបុគ្គលិកភាគច្រើនគឺជាអ្នកដែលទើបតែជ្រើសរើសថ្មីៗ ហើយមជ្ឈិមបក្សបានសំណូមពរ"ឲ្យកាត់បន្ថយការវាយដំ" ។ នៅឆ្នាំ១៩៧៧និង១៩៧៨ នៅក្នុងការសួរចម្លើយមួយចំនួន អ្នកសួរចម្លើយបានចាប់ផ្តើមធ្វើទារុណកម្មជាមុនលើកលែងតែគ្រប់គ្រងខ្លួនឯងមិនបានប៉ុណ្ណោះ ហើយវាយម្តងទៀតនៅពេលអ្នកទោសមានការប្រឆាំងមានះ និងក្នុងករណីដែល"ស្មុគស្មាញ" ។ ទារុណកម្មជាឧបករណ៍មួយ៉ាង ជាវិធីចុងក្រោយ ជាផ្នែកទាំងស្រុងនៃអ្វីដែល ហ៊ូខូល ហៅថា "ការស្វែងរកការពិតតាមរបៀបផ្តាច់ការ" ។ អ្នកសួរចម្លើយដែលអនុវត្តទារុណកម្ម យល់ថាវាជាការងាយណាស់ គ្រាន់តែធ្វើតាមបញ្ជារបស់ថ្នាក់លើ ជាពិសេសនៅពេលដែលជីវិតរបស់ខ្លួនស្ថិតនៅក្នុងគ្រោះថ្នាក់ជានិច្ចនោះ ។ តាមដែលយើងអាចនិយាយបានគឺថាអ្នកទាំងនោះមិនសូវជាមានការសោកស្តាយចំពោះអំពើរបស់ខ្លួនប៉ុន្មានទេ ។

ការដាក់កម្រិតឲ្យធ្វើទារុណកម្មត្រូវបានកំណត់ឡើងមិនមែនដោយការគោរពចំពោះជនរងគ្រោះទេ ហើយក៏មិនមែនដោយសារអ្នកគ្រប់គ្រងយល់ថាការធ្វើបែបនេះមិនល្អដែរ ប៉ុន្តែគឺដោយសារវាមានទំនាក់ទំនងជាមួយនឹងការសួរចម្លើយមួយផ្នែកផ្សេងទៀត ពោលគឺ "ការធ្វើនយោបាយ" ដែលមាន



ន័យ ស្មើនឹងការពន្យល់អំពីនយោបាយរបស់បក្សដល់អ្នកទោស និងការដកស្រង់ចម្លើយសារភាព ។ គេគិតថា ការលាយបញ្ចូលគ្នារវាងទារុណកម្ម ការជំរុញ និងឃោសនា អាចបង្ហាញទំនាក់ទំនងអំណាច ព្រមទាំងផ្តល់នូវការបង្ខំ ការចោទប្រកាន់ និងឯកសារដែលបក្សត្រូវការជាចាំបាច់ ។ ការធ្វើទារុណកម្មហួសកម្រិតនឹងអាចរាំងស្ទះឬពន្យារពេលដល់ការផលិតនូវអត្ថបទចាំបាច់ទាំងនេះ ។

### “ការដាក់ទណ្ឌកម្ម” និង “ការធ្វើនយោបាយ”

ភាពតានតឹងដែលកើនឡើងរវាងការធ្វើទារុណកម្មនិងការធ្វើនយោបាយ មានចងក្រងឡើងនៅក្នុងសៀវភៅកំណត់ហេតុសិក្សារបស់អ្នកសួរចម្លើយដែលសរសេរនៅឆ្នាំ១៩៧៦ និងសៀវភៅកំណត់ហេតុពីរដែលសរសេរដោយអ្នកសួរចម្លើយធំៗ នៅឆ្នាំ១៩៧៦និង១៩៧៨ ។ ភាពតានតឹងកើតឡើងដោយសារនៅពេលអ្នកសួរចម្លើយទាំងអស់ត្រូវបានជំរុញឲ្យប្រើអំពើហិង្សា ។ ក្នុងចំណោមអ្នកសួរចម្លើយទាំងអស់ មានតែមួយចំនួនតូចប៉ុណ្ណោះដែលបានរៀនសូត្រអំពីនយោបាយឬការសួរចម្លើយ ។ សៀវភៅកំណត់ហេតុសរសេរថា ទារុណកម្មជា “រឿងទីពីរបន្ទាប់បន្សំនិងបំពេញបន្ថែម” នយោបាយ ប៉ុន្តែសៀវភៅនេះសរសេរបន្ថែមថា “ការធ្វើនយោបាយ”តែមួយមុខក៏មិនទាន់គ្រប់គ្រាន់ដែរ គឺត្រូវប្រើអំពើហិង្សាជានិច្ច : “យកនយោបាយជាមូលដ្ឋាន” ។ ឈ្លបសួរឲ្យបានរួចហើយសឹមធ្វើទារុណកម្ម ។ ២ឆ្នាំក្រោយមក សៀវភៅកំណត់ហេតុដ៏សំខាន់របស់អ្នកសួរចម្លើយនេះបញ្ជាក់អំពី “ការធ្វើឲ្យអាម៉ាស់មុខ” គឺជាផ្នែកមួយនៃការធ្វើនយោបាយ ហើយសរសេរទៀតថា “វាយតែមួយមុខមិនគ្រប់គ្រាន់ទេ” ប៉ុន្តែ “វាយ + នយោបាយ = សំខាន់” ។



ការធ្វើទារុណកម្មនៅមន្ទីរ ស-២១
វិចិត្រករៈ វ៉ាន់ ណាត (អតីតអ្នកទោសនៅមន្ទីរ ស-២១)

អ្នកទោសនៅមន្ទីរស-២១ត្រូវបានធ្វើឲ្យបាត់បង់តម្លៃជាមនុស្សតាំងពីពេលចូលខ្លួនមកដល់កន្លែងនេះដំបូងម្ល៉េះ ។ ជាទូទៅអ្នកទោសដែលត្រូវបិទមុខជិតនិងដាក់ខ្នោះ ត្រូវបានទាញទម្លាក់ពីលើរថយន្តនៅពេលយប់ ។ អ្នកទោសត្រូវទាត់និងច្រានឲ្យដើរទៅមុខ និងវាយដំប្រំផាក់នៅពេលបណ្តើរចូលទៅក្នុងដើម្បីធ្វើឯកសារនិងថតរូប ។ ដូចដែល វ៉ាន់ ណាត រំឭកឡើងវិញថា អ្នកទោសទៅដល់កន្លែងមួយដែលអាក្រក់ជាងប្រេតនរកទៅទៀត ។

វាយនិងធ្វើទារុណកម្មខុសគ្នានៅត្រង់ការប្រើអាវុធគ្រឿងម៉ាស៊ីន ឬការធ្វើឲ្យអាម៉ាស់មុខ (ដូចជាទារុណកម្មឲ្យថ្វាយបង្គំរូប ហូជីមិញ ដែលមានខ្លួនជាឆ្កែ) ប៉ុន្តែការវាយនៅពេលសួរចម្លើយ អាចចាត់ចូលជាទារុណកម្ម ហើយឯកសារជាច្រើនប្រើពាក្យ“វាយ”និង“ធ្វើទារុណកម្ម”ជំនួសឲ្យគ្នាទៅវិញទៅមក ។ នៅពេលមានការចាប់ផ្តើមសួរចម្លើយ ការត្រួតពិនិត្យខាងក្រៅកម្រមានណាស់ ។ ដូចលោក សហ្វស្គី លើកឡើងទាក់ទងនឹងជំរំប្រមូលផ្តុំរបស់អាល្លឺម៉ង់ដែរថា “ពីទារុណកម្មដើម្បីជម្រិតយកចម្លើយ ទៅជាទារុណកម្មដែលគ្មានគោលដៅច្បាស់លាស់ គឺមានការប្រែប្រួលជានិច្ច” ។ សុខុមាលភាពរបស់អ្នកទោសមិនមានអ្នកណាគិតគូរថែទាំអ្វីឡើយ ធ្វើយ៉ាងម៉េចឲ្យតែស្រង់ចម្លើយសារភាពបានពេលនៅរស់ប៉ុណ្ណោះ ក្រោយពីសួរហើយ ស្លាប់ក៏ស្លាប់ទៅ គ្មានអ្នកណាខ្វល់ឡើយ ។ (**នៅមានត**)

# ភ្នំសន្លុង៖ មន្ទីរសន្តិសុខភូមិភាគនិរតីរបស់ តាម៉ុក

ក្នុងឆ្នាំសិក្សា១៩៨៥-៨៦ ខ្ញុំជាសិស្សថ្នាក់ទី ៤ “គ” នៃសាលាបឋមសិក្សាច្បារអំពៅទី១ ។ ខ្ញុំចាំបានថា ខ្ញុំនិងមិត្តរួមថ្នាក់ធ្លាប់បានអានសៀវភៅរៀនអានថ្នាក់ទី៤“ភាគ១” ដែលមានចំណងជើងថា “ទារុណកម្មនៅគុកភ្នំសន្លុង” ។ ឃ្លាមួយនៅក្នុងអត្ថបទរៀនអានដែលខ្ញុំចាំច្បាស់គឺ “ភ្នំសន្លុងជាឋាននរកលោកិយ ជាជំរំមហាសោកនាដកម្ម ជាផ្នូររួមរបស់និស្សិត សិស្ស យុវជន និង យុវតី...” ។ ពេលនោះខ្ញុំឆ្ងល់ថា តើនិស្សិត សិស្ស យុវជន និងយុវតី ទាំងនោះមានកំហុសអ្វី? តើហេតុអ្វីបានជាខ្មែរក្រហមសម្លាប់អ្នកទាំងនោះ?

១៦ឆ្នាំក្រោយមក ខ្ញុំមានឱកាសបានដឹងឮរឿងរ៉ាវអំពីគុកភ្នំសន្លុងម្តងទៀត ។ ពេលវេលាបានកន្លងផុតទៅ ប៉ុន្តែភ្នំសន្លុងរក្សាទុកនូវរឿងរ៉ាវតែមួយ ។ “គុកភ្នំសន្លុង” មានទីតាំងនៅក្នុងឃុំសន្លុង ស្រុកទ្រាំង ខេត្តតាកែវ ។ បរិវេណដីជុំវិញភ្នំប្រមាណ៤គីឡូម៉ែត្រ និងភូមិជុំវិញបរិវេណភ្នំ ព្រមទាំងទីតាំងភ្នំទាំងមូលត្រូវបានយកធ្វើជាមន្ទីរសន្តិសុខភូមិភាគនិរតីពីដើមឆ្នាំ១៩៧៦ រហូតដល់ឆ្នាំ១៩៧៩ ក្រោមការគ្រប់គ្រងរបស់សមមិត្ត ម៉ុក លេខាភូមិភាគនិរតី និងប្រធានដឹកនាំផ្ទាល់២រូប គឺសមមិត្ត សេង និងសមមិត្ត សឿន ។

អ្នកទោសមន្ទីរសន្តិសុខភូមិភាគនិរតីភាគច្រើនជាអតីតកងទ័ព កម្មាភិបាលរបបខ្មែរក្រហម ព្រមទាំងប្រពន្ធកូនសាច់ញាតិដែលត្រូវចោទប្រកាន់ថាក្បត់នឹងអង្គការ ។ អ្នកទោសត្រូវបានបែងចែកឲ្យធ្វើការនិងរស់នៅដាច់ដោយឡែកពីគ្នា ។ អ្នកទោសភេទស្រីរស់នៅក្នុងភូមិកញ្ជ្រោបប៉ែកខាងលិចភ្នំ ចំណែកអ្នកទោសភេទប្រុសរស់នៅក្នុងភូមិលោកប៉ែកខាងជើងភ្នំ ភូមិព្រះត្រកួនប៉ែកខាងលិចភ្នំ និងភូមិក្រាមប៉ែកខាងត្បូងភ្នំ ។ អគារឃុំឃាំងមួយត្រូវសាងសង់ឡើងនៅក្នុងចម្ការស្វាយក្នុងភូមិកញ្ជ្រោប ដើម្បីឃុំឃាំងអ្នកទោសដែលបានប្រព្រឹត្តកំហុសលួចឆក់របស់របរសម្ភូហភាព ធ្វើការមិនពេញដៃពេញជើង និងប៉ុនប៉ងរត់គេចខ្លួន ។ ទីតាំងសម្រាប់អ្នកទោសមាន២ គឺនៅក្នុងចម្ការស្វាយ និងនៅភ្នំតូច ។

ម៉ន ធ្លាប់បានចេញចូលភ្នំសន្លុង បានឲ្យដឹងថា ចុងឆ្នាំ១៩៧៥ ប្រជាជនដែលរស់នៅភូមិជុំវិញភ្នំសន្លុងត្រូវបានជម្លៀសចេញឲ្យទៅរស់នៅឆ្ងាយ ហើយការប្រែក្លាយភូមិនិងភ្នំសន្លុងឲ្យទៅជាមន្ទីរឃុំឃាំង បានចាប់ផ្តើមយ៉ាងគគ្រឹកគគ្រេងតាំងពីពេលនោះមករហូតដល់ឆ្នាំ១៩៧៩ ។ ខ្មែរក្រហមបានដឹកប្រជាជនទាំងរថយន្តៗមកទម្លាក់ចុះនៅជុំវិញភ្នំ ។ បន្តិចម្តងៗ ភ្នំសន្លុងដែលធ្លាប់តែស្ងាត់ជ្រងំ ក៏ប្រែក្លាយជាអ៊ូអរអឺងអាប់ទៅដោយអ្នកទោស ។

នៅដើមឆ្នាំ១៩៧៦ សៀន ត្រូវចាប់ខ្លួនបញ្ជូនទៅឃុំឃាំងនិងលត់ដំនៅភ្នំសន្លុង ។ កំហុសរបស់ សៀន គ្មានអ្វីធំដុំទេ គឺដោយសារគាត់មានបងប្រុសម្នាក់ឈ្មោះ ស៊ុន ជាអតីតទាហានក្នុងរបប លន់ ណុល ។ សៀន មានដើមកំណើតនៅភូមិព្រះសុខ ឃុំសន្លុង ស្រុកទ្រាំង ខេត្តតាកែវ ។ ក្រោយឆ្នាំ១៩៧៥ សៀន ត្រូវជម្លៀសទៅស្រុកអង្គរបូរី ។ នៅឆ្នាំ១៩៧៦ សៀន និងយុវជនចំនួន៣០នាក់ផ្សេងទៀត ត្រូវបានចាប់និងបញ្ជូនខ្លួនពីស្រុកអង្គរបូរីមកភ្នំសន្លុង ។ នៅពេលដែលឮថាខ្លួនត្រូវបញ្ជូនទៅមន្ទីរសន្តិសុខភ្នំសន្លុង សៀន មានអារម្មណ៍ធូរស្បើយក្នុងចិត្ត ដោយសារគាត់គិតថាគាត់បានវិលត្រឡប់មករស់នៅបានឃើញនិងធ្វើការលើវាលស្រែក្នុងភូមិកំណើតរបស់គាត់វិញ ។ ផ្ទុយស្រឡះពីអ្វីដែល សៀន បានរំពឹងទុក ការងារ ទារុណកម្ម និងជីវិតរស់នៅភ្នំសន្លុង បានធ្វើឲ្យគាត់នឹកខ្លាចលែងចង់ឮឈ្មោះភ្នំសន្លុង ។ តាមសម្តីរបស់ សៀន គឺ“សែនមហាលំបាកវេទនាណាស់ ។ ធ្វើការនិងហូបចុកដូចសត្វធាតុ” ។ សៀន បញ្ជាក់ថា ប្រវត្តិជួរបត់ភ្នំសន្លុងធ្វើឲ្យគាត់ចងចាំនិងមិនអាចបំភ្លេចបានរហូតសព្វថ្ងៃ ។ “ទោះជាចង់បំភ្លេចក៏បំភ្លេចមិនបាន ក្បាលខ្ញុំស្នាម២កាំបិត ដៃខ្ញុំស្នាមចងខ្សែ ហើយខ្លួនប្រាណខ្ញុំឈឺចាប់និងធ្វើទុក្ខមិនទាន់បាត់ឡើយ” ។

ឈឿន ត្រូវចាប់ខ្លួនដោយសារជាប្អូនស្រីរបស់ ញ៉ិន

ទាហានស័ក្តិ២សម័យលន់ណុល ។ ស្នាកស្នាមដំបៅនិងភាពទ្រុឌទ្រោម ធ្វើឲ្យ ឈឿន បំភ្លេចភ្នំសន្ទុកមិនបានឡើយ ។ "អ្នកទោសជាប់នៅភ្នំសន្ទុកសែនពិបាកខ្លាំងណាស់ ទាំងការហូបចុកនិងទារុណកម្ម ។ មកដល់ឥឡូវ សុខភាពខ្ញុំនៅតែធ្វើទុក្ខ ហើយការចងចាំក៏មិនសូវល្អដែរ ពីព្រោះខ្ញុំស្លុតអារម្មណ៍បាក់ស្បាត" ។


ឈឿន

ឈឿន ធ្លាប់ត្រូវប្រធានកងឈ្មោះ ណោម ចាប់ចងបាញ់កាំភ្លើងសម្លុតកំហែង ដោយចោទថាគាត់បានដើរបំផុសបំផុលឲ្យអ្នកទោសលួចរត់ចេញពីមន្ទីរឃុំឃាំង ។ ឈឿន បដិសេធការចោទប្រកាន់របស់ ណោម "ខ្ញុំឯណាទៅហ៊ានដល់ថ្នាក់ដល់ទៅបំផុសបំផុលឲ្យគេរត់ បើខ្លួនឯងរកតែពុំទ្វោ" ។

ការងាររបស់អ្នកទោសនៅភ្នំសន្ទុកតែងប្រែប្រួលនិងផ្លាស់ប្តូរពីកន្លែងមួយទៅកន្លែងមួយតាមការចាត់តាំងនិងរដូវកាល ។ ការងាររបស់អ្នកទោសគឺ ជីកស្រះ ជីកប្រឡាយ សែងទឹក លើកទំនប់ ដាំដំណាំ គាស់ថ្ម និងវាយថ្ម។ អ្នកទោសចាប់ផ្តើមធ្វើការងារតាំងពីព្រលឹមរហូតដល់យប់កណ្តាលអធ្រាត្រ ហើយទទួលបានត្រឹមតែបបរាវលាយជាមួយដើមត្រកៀត គល់ចេក និងត្រកួន ពេលថ្ងៃត្រង់និងពេលយប់ ។ ការងាររបស់ ប្រុញ នៅភ្នំសន្ទុកផ្លាស់ប្តូរពីការដ្ឋានមួយទៅការដ្ឋានមួយ ។ ពីដំបូងជីកប្រឡាយលើកទំនប់នៅខាងកើតភ្នំ បន្ទាប់មកសែងទឹកពីបុស្សឫស្សីស្រុកមកភ្នំសន្ទុក និងក្រោយមកផ្លាស់ទៅខាងគាស់ថ្ម ។

ទូន មានភារកិច្ចធ្វើកញ្ច្រែងល្អីមុនពេលត្រូវផ្លាស់ទៅខាងគាស់ថ្មនិងវាយថ្មជាមួយ ប្រុញ ។


ទូន

ឈឿន ក្នុងកងយុវនារី មានភារកិច្ចស្ទូងដកនិងបន្តុបផ្តើដផល ។ ការងាររបស់ ឈឿន ចាប់តាំងពីព្រលឹមរហូតដល់ព្រលប់ ប៉ុន្តែរបបអាហាររបស់ ឈឿន "មានតែទឹកបបរាវកក្កូក២ពេលប៉ុណ្ណោះក្នុងមួយថ្ងៃ" ។ ប្រុញ បញ្ជាក់ថា "ការហេវហត់ធ្វើឲ្យអ្នកទោសមិនថាស្រីមិនថាប្រុស លែងមានការខ្មាសអៀន ដើរលែងចៀសគ្នា ឲ្យតែក្រឡេកឃើញផ្លែអ្វីឬសត្វអ្វីដែលអាចហូបបាន គឺសម្រុកដណ្តើមតែម្តង សូម្បីតែស្លឹកអំពិលជូរនិងកណ្តុរក៏ដណ្តើមគ្នាដែរ" ។

ស្ថានភាពការងារនិងរបបអាហាររបស់អ្នកទោសពីមួយថ្ងៃទៅមួយថ្ងៃធ្វើឲ្យអ្នកទោសកាន់តែទន់ខ្សោយនិងបាក់កម្លាំង ។ ដើម្បីបានរស់និងគេចផុតពីការដាក់ទណ្ឌកម្ម អ្នកទោសត្រូវតែតស៊ូធ្វើការទាំងឈឺថ្កាត់ ដើម្បីសម្រេចការងារតាមផែនការដែលបក្សបានដាក់ចុះ ។ អ្នកទោសមួយចំនួនដួលសន្លប់និងស្លាប់នៅនឹងកន្លែង ។ ម៉ោងប្រហែល៩នាព្រឹកមួយក្នុងឆ្នាំ១៩៧៦ នៅពេលកំពុងភ្ជួរស្រែនៅខាងជើងភ្នំ សៀន បានឃើញនារីម្នាក់កំពុងធាក់រហាត់ទឹក ស្រាប់តែដួលធ្លាក់ដីងើបលែងរួច ។ ពេលនោះឈ្លបដែលឈរយាមអ្នកទោសបានដើរសំដៅទៅរកនារីម្នាក់នោះ ហើយយកចំពុះទង់ចាក់សម្លាប់នារីនោះនៅនឹងកន្លែងតែម្តង ។ ដោយសារហេវហត់ខ្លាំងពេក នៅក្នុងកងយុវជនជាមួយ ប្រុញ យុវជនម្នាក់បានឈប់សម្រាកក្នុងពេលដែលសមាជិកឯទៀតកំពុងនាំគ្នាដេញកណ្តុរក្នុងស្រែ ។ ពេលនោះសមមិត្ត សៀន ដែលជាអនុប្រធានមន្ទីរសន្តិសុខ បានដកកាំភ្លើងខ្លីបាញ់យុវជននោះចោលភ្លាមតែម្តង ។ យុវជនដែលមានរូបកាយស្គមកំព្រឹងម្នាក់ផ្សេងទៀតមកពីតានី ស្រុកទូកមាស ខេត្តកំពត បានដួលស្លាប់ក្នុងពេលកំពុងគាស់ថ្មនៅខាងលិចភ្នំ ។

ការធ្វើដំណើរ ការនិយាយស្តី របស់អ្នកទោស ត្រូវហាមប្រាមយ៉ាងតឹងរ៉ឹងបំផុត ។ អំពើល្មើសនឹងបញ្ញត្តិខាងលើត្រូវចាត់ទុកជាការប្រឆាំងនឹងអង្គការ មានបំណងមិនល្អ ចង់រត់គេចខ្លួន និងចង់បះបោរ ។ អ្នកប្រព្រឹត្តល្មើសនឹងបញ្ញត្តិត្រូវចាប់បញ្ជូនទៅឃុំឃាំង ធ្វើទារុណកម្មសួរចម្លើយ និងប្រហារជីវិតក៏មាន ។ ក្នុងឆ្នាំ១៩៧៦ សៀន ត្រូវប្រធានកងយុវជនឈ្មោះ ពុង បញ្ជូនខ្លួនទៅដាក់ឃុំឃាំងនិងសួរចម្លើយអស់រយៈពេល៧ថ្ងៃ ដោយសារត្រូវចោទប្រកាន់ថាបានបំផុសបំផុលអ្នកទោសឲ្យរត់គេចខ្លួន ។ នៅក្នុងពេលសួរចម្លើយ ពុង បានប្រើខ្សែរគោចងដៃរបស់ សៀន យ៉ាងតឹងរហូតចេញឈាម និងប្រើកាំបិតកាប់លើក្បាលរបស់គាត់ចំនួន២កាំបិតបន្សល់ស្នាកស្នាមរហូតដល់សព្វថ្ងៃ ។ វាសនារបស់ ប្រុញ ក៏មិនខុសពីវាសនារបស់ សៀន ដែរ ។ គាត់ត្រូវបញ្ជូនខ្លួនទៅឃុំឃាំង ធ្វើទារុណកម្មយ៉ាងខ្លាំង រហូតដល់

លែងចង់រស់ និងមិនសង្ឃឹមថាបានរស់ឡើយ ។

អ្នកដែលបានប្រព្រឹត្តកំហុសជាក់ស្តែងដូចជា លួចនិងរត់គេចខ្លួន បើត្រូវឈ្លបឃើញឬតាមចាប់បាន គឺត្រូវសម្លាប់ចោលភ្លាមតែម្តង ហើយការសម្លាប់នេះត្រូវធ្វើឡើងក្នុងអង្គមិទ្ទិងនៅចំពោះមុខសមាជិកក្រុមឬកងតែម្តង ។ សៀន ប្រុញ និង ញូវ ចាំបានថា ក្នុងឆ្នាំ១៩៧៧មានការសម្លាប់ជាលក្ខណៈមិទ្ទិងចំនួន២ដង ។ អ្នកទោសជាបុរសម្នាក់ត្រូវចាប់ខ្លួនដោយសារបានលួចស្ករនៅក្នុងរោងបាយ ។ អ្នកទោសស្ត្រីម្នាក់ទៀតត្រូវចាប់ខ្លួនដោយសារបានរត់គេចចេញពីមន្ទីរសន្តិសុខ ។ អ្នកទោសទាំងពីរនេះត្រូវសម្លាប់ដោយវិធីតែមួយ គឺវះពោះខ្វះយកថ្លើមរួចរុញទម្លាក់ទៅក្នុងរណ្តៅ ។ ប្រុញ នៅចាំបានថា យុវជនម្នាក់ទៀតឈ្មោះ យក្ស បានលួចរត់គេចខ្លួន ហើយឡើងទៅពួនលើចុងត្នោត ។ ឈ្លបរបស់មន្ទីរសន្តិសុខបានតាមចាប់គាត់ហើយលួងលោមឲ្យគាត់ចុះពីលើចុងត្នោតមកវិញ ប៉ុន្តែគាត់មិនព្រមចុះមកសោះ ។ ទីបំផុត យក្ស បានសម្រេចចិត្តលោតចុះពីលើចុងត្នោតធ្វើអត្តឃាត ។ ប្រុញ បញ្ជាក់ថា «អាយក្សវាដឹងថាទោះជាចុះមកវិញក៏មិនរស់ដែរ ទើបវាធ្វើអ៊ីចឹង» ។

ឈឿន អះអាងថា ចំនួនអ្នកទោសដែលត្រូវសម្លាប់នៅភ្នំសន្ទុកមានចំនួនច្រើន ។ គាត់ប្រាប់ហេតុផលថា «នៅពេលយប់ អ្នកទោសមួយចំនួនត្រូវរុញឡើងរថយន្តដឹកចេញជាបន្តបន្ទាប់ ។ ចំនួនអ្នកទោសថយចុះពីមួយថ្ងៃទៅមួយថ្ងៃ ពីមួយខែទៅមួយខែ» ។ សៀន បញ្ជាក់ថា អ្នកទោសដែលស្លាប់ភាគច្រើនជាអតីតទាហាន កម្មាភិបាលរបបខ្មែរក្រហម និងអ្នកមានចំណេះដឹង ។ គាត់លើកពីល្បិចកលរបស់ប្រធានមន្ទីរសន្តិសុខសមមិត្ត សេង និង សឿន ក្នុងការសម្លាប់អ្នកទោសថា ក្នុងឆ្នាំ១៩៧៦ សេង និង សឿន បានប្រកាសរកអ្នកដែលចេះអក្សរជ្រោជ្រះដើម្បីឲ្យជួយធ្វើការងារនៅក្នុងការិយាល័យ ។ អ្នកទោសជាច្រើននាំគ្នាចុះឈ្មោះ រៀបរាប់ពីកម្រិតវប្បធម៌របស់ខ្លួន ដើម្បីបានប្តូរពីការងារក្រោមកម្តៅថ្ងៃទៅធ្វើការងារក្នុងការិយាល័យ ។ ទីបំផុត អ្នកទាំងនោះត្រូវដឹកតាមរថយន្តចេញទៅភ្នំតូច ហើយត្រូវសម្លាប់ចោលនៅភ្នំសន្ទុកទាំងអស់ ។ ប្រុញ អះអាងថា គាត់បានឮឈ្លបនិយាយគ្នាអំពីការងារប្រជុំរវាងអនុប្រធានមន្ទីរសន្តិសុខឈ្មោះ សឿន និង តាម៉ុក អំពីអ្នកទោសក្នុងមន្ទីរសន្តិសុខភូមិភាគ ។ តាមផែនការរបស់ តាម៉ុក គឺទីតាំងភ្នំសន្ទុកត្រូវដាក់អ្នកទោសឲ្យបានគ្រប់១ម៉ឺន៥ពាន់នាក់ ។ ប្រុញ ឮឈ្លបនោះនិយាយថា «ឥឡូវមានតែ១ម៉ឺន២ពាន់នាក់ នៅខ្វះ៣ពាន់នាក់ទៀតទើបគ្រប់តាមផែនការតា(ម៉ុក)ដាក់ឲ្យ» ។

ទាំងអ្នកទោស ប្រជាជនដែលធ្លាប់ចេញចូលមន្ទីរសន្តិសុខភូមិភាគ និងប្រជាជនមូលដ្ឋាន ធ្លាប់ឃើញ តាម៉ុក រួមជាមួយនិរសានិងអ្នកបើកបររថយន្តចេញចូលភ្នំសន្ទុកជាញឹកញាប់ ។ ប្រុញ ធ្លាប់បានឃើញ តាម៉ុក ជិះរថយន្តចូលភ្នំសន្ទុកនៅឆ្នាំ១៩៧៦និង១៩៧៧ ។ ចំណែក ម៉ន ប្រជាជនមូលដ្ឋានធ្លាប់ចូលទៅដឹកស្មៅនិងអំពៅក្នុងភ្នំសន្ទុកទៅចែកតាមសហករណ៍ក៏ធ្លាប់ជួប តាម៉ុក និងអ្នកបើកបររថយន្តរបស់តាម៉ុក នៅភ្នំសន្ទុកដែរ ។ ម៉ន អះអាងថា «តាម៉ុក ជិះឡានហ្ស៊ីបមកជាមួយកូនក្មេង២នាក់ ម្នាក់ជានិរសា និងម្នាក់ជាអ្នកបើកបររថយន្ត» ។ ក្នុងចំណោមកូនក្មេង២នាក់ដែល ម៉ន អះអាងថាបានជួប មានម្នាក់ឈ្មោះ សារុធ ។ ក្នុងវ័យ១៥ឆ្នាំ សារុធ គឺជាអ្នកបើកបររថយន្តឲ្យ តាម៉ុក ។ សារុធ បញ្ជាក់ថា គាត់ធ្លាប់ជូន តាម៉ុក ទៅភ្នំសន្ទុក ប៉ុន្តែមិនដឹងថា តាម៉ុក ទៅធ្វើអ្វីនៅភ្នំសន្ទុកឡើយ ហើយគាត់ក៏ធ្លាប់បានឃើញអ្នកទោសវាយថ្មនៅភ្នំសន្ទុកដែរ ។

ឥឡូវនេះ សំណួរដែលស្ថិតក្នុងអារម្មណ៍របស់ខ្ញុំអស់រយៈពេល១៦ឆ្នាំមានចម្លើយហើយ ។ ប្រជាជនដែលជាប់ឃុំឃាំងនៅភ្នំសន្ទុកទាំងអស់គឺជា«ខ្មាំងជាប់និន្នាការនយោបាយនិងវណ្ណៈ» របស់អង្គការ ។ បក្សកុម្មុយនិស្តកម្ពុជាត្រូវតែកម្ទេចខ្មាំងជាប់និន្នាការទាំងនេះ ដោយសារប្រជាជនប្រភេទនេះគឺជាសមាសភាពដែលអាចបង្កកម្លាំង បន្តទំនាស់ពីតូចទៅធំ ពីបរិមាណទៅគុណភាព គំរាមកំហែងដល់ការកសាងបដិវត្តន៍សង្គមនិយមដ៏មហាអស្ចារ្យនិងមហាលោតផ្លោះរបស់ខ្មែរក្រហម ។ បដិវត្តន៍សង្គមនិយមរបស់ខ្មែរក្រហមក្នុងរយៈពេលជាង៣ឆ្នាំ បានធ្វើឲ្យប្រជាជនកម្ពុជាស្លូតត្រង់រាប់លាននាក់ស្លាប់បាត់បង់ជីវិត ។ ផ្ទុយមកវិញ មេដឹកនាំខ្មែរក្រហមនៅតែបន្តអះអាងថា បដិវត្តន៍របស់ខ្លួនគឺដើម្បីប្រជាជន កម្មករ និងកសិករ ។

**អៀ ម៉េងទ្រី**

# តម្លៃនៃភ័ស្តុតាង

**(តចប់)**

៤) *របាយការណ៍ដែនទី (១៩៩៧និង១៩៩៨)*

មើលការពិភាក្សាទាក់ទងនឹង កែ ពក និង ម៉ុក នៅក្នុងចំណុច «គ» ខាងលើ ។ របាយការណ៍ដែនទីផ្តល់នូវភ័ស្តុតាងប្រយោលយ៉ាងសន្ធឹកសន្ធាប់ដែលបង្ហាញថា កែ ពក បានដឹងឮ ឬគួរតែបានដឹងឮអំពីការសម្លាប់ដ៏ធំនៅក្នុងភូមិភាគដែលខ្លួនជាអ្នកដឹកនាំផ្ទាល់ ។

៥) *កំណត់ហេតុអំពីទស្សនកិច្ចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍នៅភូមិភាគពាយ័ព្យ ថ្ងៃ ២០-២៤ សីហា ឆ្នាំ ១៩៧៥*

(មើលការពិភាក្សានៅចំណុច "ក" ខាងលើ) ។ ប្រសិនបើមានការបង្ហាញថា កែ ពក ជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ នៅក្នុងខណៈពេលដែលឯកសារនេះត្រូវបានរៀបចំឡើង កែ ពក មានការទទួលខុសត្រូវចំពោះមាតិកានៅក្នុងកំណត់ហេតុនេះ ។

មូធី និងអ្នកដទៃទៀត ផ្តល់នូវឧទាហរណ៍ពីឯកសារបន្ថែមទៀតមួយចំនួនដែលអាចយកមកប្រើនៅក្នុងការជម្រះក្តីករណី កែ ពក ។ ឧទាហរណ៍ទាំងនេះទាក់ទងជាពិសេសទៅនឹងការចោទប្រកាន់ដែលអាចទៅរួចពីបទទារុណកម្មនិងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។

## ង) ខៀវ សំផន ហៅ ហែម

ឯកសារជាផ្លូវការបង្ហាញថា ខៀវ សំផន ជាគណៈប្រធានរដ្ឋនៃបក្សកុម្មុយនិស្តកម្ពុជា ទោះបីភាពសំខាន់«តាមព្រឹត្តន័យ»នៃតួនាទីនេះមិនមានលក្ខណៈច្បាស់លាស់ក៏ដោយ ។ ភ័ស្តុតាងឯកសារក៏បង្ហាញអំពីសមាជិកភាពរបស់ ខៀវ សំផន នៅក្នុងគណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនិស្តកម្ពុជាមួយរយៈពេលដែរ ។ ជាងនេះទៀត ភ័ស្តុតាងឯកសារ ខៀវ សំផន ជាគណៈមន្ទីរ ៨៧០ ដែលជាមន្ទីរផ្ទាល់ខ្លួនរបស់ ប៉ុល ពត មជ្ឈិមបក្សនៃបក្សកុម្មុយនិស្តកម្ពុជាក្រោយដើមឆ្នាំ១៩៧៧ ។ ឯកសារសំខាន់ៗជាច្រើនដែលទាក់ទងនឹងការរំលោភបំពានរបស់កូនចៅនៅពីក្រោមៗ ត្រូវបានចម្លងជូនមន្ទីរ ៨៧០ ដែលបញ្ជាក់ថា ខៀវ សំផន បានដឹងឮពីអំពើឃោរឃៅទាំងនេះ ។ ភ័ស្តុតាងឯកសារក៏បង្ហាញដែរថាការពិនិត្យទៅលើរបាយការណ៍ទាំងនេះគឺជាការទទួលខុសត្រូវផ្ទាល់របស់គណៈមន្ទីរ ៨៧០ ។

ទំនាក់ទំនងការងារជិតដិតរបស់ ខៀវ សំផន ជាមួយ ប៉ុល ពត ដែលមាននៅក្នុងឯកសារនិងសុន្ទរកថាខែមេសា ឆ្នាំ១៩៧៧ ដែលក្នុងនោះ ប៉ុល ពត បាននិយាយអំពីការបង្ក្រាបខ្មាំងនោះជាការបន្ថែមទៅលើភ័ស្តុតាងនៃការដឹងឮនិងការចូលដៃរបស់ ខៀវ សំផន ។ កំណត់ហេតុកិច្ចសម្ភាសន៍ក៏ផ្តល់នូវការរៀបរាប់កាន់តែច្បាស់អំពីបទល្មើសនានារបស់ ខៀវ សំផន ទោះជាភ័ស្តុតាងក្នុងលក្ខណៈនេះមិនសូវជាមានទម្ងន់យ៉ាងណាក៏ដោយ ។ ក្នុងខណៈដែលភ័ស្តុតាងប្រឆាំងនឹង ខៀវ សំផន នៅតែជាភ័ស្តុតាងប្រយោលច្រើនលើសលប់ ការកាត់សេចក្តីទៅលើករណី ខៀវ សំផន គឺពិតជាការលំបាកមួយ ។ ទោះជាយ៉ាងនេះក្តី មានសំណុំរឿងមានទម្ងន់សមរម្យមួយប្រឆាំងនឹង ខៀវ សំផន ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនិងទារុណកម្ម ។

ឧទាហរណ៍មួយចំនួនមកពីឯកសារទាក់ទងនឹង ខៀវ សំផន មានដូចខាងក្រោម ដែលមានអមដោយការពិភាក្សាយ៉ាងសង្ខេបទៅលើវិធីក្នុងការយកឯកសារមកប្រើប្រាស់ជាភ័ស្តុតាងនៅក្នុងអង្គជំនុំជម្រះក្តីព្រហ្មទណ្ឌ ហើយប្រសិនបើមាន តើភ័ស្តុតាងអ្វីដែលអាចផ្តល់ជាសារប្រយោជន៍បំផុតនៅក្នុងដំណើរការកាត់សេចក្តី៖

១) *"សេចក្តីសម្រេចរបស់គណៈកម្មាធិការមជ្ឈិមទៅលើបញ្ហាជាច្រើន» ៣០ មីនា ១៩៧៦ (ប្រែសម្រួលនិងបោះពុម្ពសាជាថ្មីនៅក្នុងសៀវភៅ«ផែនការអនាគត» ដែលនិពន្ធដោយលោក ដេវីដ ឆេនដល័រ) ។*

ក) ចំណុចទី១ ចែងថា «អំណាចក្នុងការកម្ទេច(ប្រជាជន) នៅក្នុងនិងក្រៅជួរ» ។ ការអនុវត្តចំពោះផ្លូវច្បាប់ប្រឆាំងនឹង ខៀវ សំផន មានលក្ខណៈប្រហាក់ប្រហែលនឹងករណី នួន ជា ដែរ (មើលចំណុច "ក" ខាងលើ) ។




ខ) ចំណុចទី៦ ប្រកាសថា កងកម្លាំងប្រដាប់អាវុធ “រំដោះកម្ពុជា” មហាវិហារគ្រិស្ត ។ ការអនុវត្តចំពោះផ្លូវច្បាប់ប្រឆាំងនឹង ខៀវ សំផន មានលក្ខណៈប្រហាក់ប្រហែលនឹងករណី នួន ជា ដែរ (មើលចំណុច “ក” ខាងលើ) ។

គ) ចំណុចទី៧ គម្រោងសេចក្តីសម្រេចរបស់គណៈកម្មាធិការមជ្ឈិមគឺជា “ប្រព័ន្ធរបាយការណ៍ប្រចាំសប្តាហ៍ជូនចំពោះ ម-៨៧០ ឲ្យមជ្ឈិមបក្ស” ។ ចំណុចនេះបង្ហាញថា ចាប់ពីថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ប្រព័ន្ធរបាយការណ៍ទៅកាន់មន្ទីរ៨៧០ ត្រូវបានយកទៅអនុវត្តនៅក្នុងឬមុនកាលបរិច្ឆេទនេះ ។ អត្ថិភាពនៃប្រព័ន្ធនេះផ្តល់ជាភស្តុតាងប្រយោលបញ្ជាក់ថា ខៀវ សំផន ក្នុងតួនាទីជាគណៈមន្ទីរ៨៧០ យ៉ាងហោចណាស់ក៏បានដឹងពីអំពើឃោរឃៅរបស់ខ្មែរក្រហមមួយចំនួនដែរ ។

ឃ) ខៀវ សំផន គឺជាគណៈប្រធានរដ្ឋ ។ តាមឯកសារ ខៀវ សំផន ស្ថិតក្នុងតួនាទីនយោបាយដែលមិនចេញសកម្មភាព ។ ទោះជាយ៉ាងនេះក៏ដោយ ឯកសារបញ្ជាក់ច្បាស់ថា ខៀវ សំផន ជាថ្នាក់ដឹកនាំនៃបក្សកុម្មុយនិស្តកម្ពុជា ។ ដូច្នេះ ខៀវ សំផន អាចមានអាជ្ញាបញ្ញាស៊ីវិល «តាមច្បាប់» និង «ព្រឹត្តន័យ» ។

**២)** *ឯកសារលេខកំណត់ហេតុអំពីទស្សនកិច្ចអចិន្ត្រៃយ៍នៅភូមិភាគពាយ័ព្យ ថ្ងៃ ២០-២៤ សីហា ១៩៧៥*

មើលការពិភាក្សានៅក្នុងចំណុច «ក» ខាងលើ ។ ប្រសិនបើមានការបង្ហាញថា ខៀវ សំផន ជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ នៅក្នុងខណៈពេលដែលឯកសារនេះត្រូវបានរៀបចំឡើងនោះ ខៀវ សំផន មានការទទួលខុសត្រូវចំពោះមាតិកាដែលមាននៅក្នុងកំណត់ហេតុ ។

### ច) កាំង ហ្កិចអៀវ ហៅ ឌុច

ឯកសារមានច្រើនជាង នួន ជា ទៅទៀត ដែលច្បាស់សឹងតែអាចដាក់ឲ្យ ឌុច មានការទទួលខុសត្រូវចំពោះមុខច្បាប់ ។ ដោយ ឌុច ជាអ្នកទទួលរបាយការណ៍ច្រើនសន្ធឹកសន្ធាប់ស្តីអំពីការធ្វើទារុណកម្ម និង «កម្ទេច» និងជាប្រធានគុក ស-២១ ដែលមានឯកសារគ្រប់គ្រាន់បញ្ជាក់បង្ហាញច្បាស់ថា ឌុច បំពេញតាមតម្រូវការធាតុផ្សំនៃការទទួលខុសត្រូវលើការបញ្ជាពីបទទារុណកម្មនិងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។

ឧទាហរណ៍មួយចំនួនមកពីឯកសារទាក់ទងនឹង កាំង ហ្កិចអៀវ មានដូចខាងក្រោម ដែលមានអមដោយការពិភាក្សាយ៉ាងសង្ខេបទៅលើវិធីក្នុងការយកឯកសារមកប្រើប្រាស់ជាភ័ស្តុតាងនៅក្នុងអង្គជំនុំជម្រះក្តីព្រហ្មទណ្ឌ ហើយប្រសិនបើមានតើភ័ស្តុតាងអ្វីដែលអាចផ្តល់ជាសារប្រយោជន៍បំផុតនៅក្នុងដំណើរការកាត់សេចក្តី÷

**១)** *ឯកសារលេខកំណត់ហេតុប្រជុំខាងមន្ទីរអង្គការ ៧០៣ និងមន្ទីរ ស-២១ (៩ កញ្ញា ១៩៧៦)*

ឆ្លើយតបទៅនឹងការរើសបានខិតប័ណ្ណដែលខ្មែរក្រហមយល់ថាមានបញ្ហា អ្នកចូលរួមប្រជុំណែនាំសមមិត្ត ប៉ាង និង ខាំមី ថា «អ្នកណាយើងសង្ស័យត្រូវយកចេញ» ។ ក្នុងតួនាទីជាគណៈមន្ទីរ ស-២១ ឌុច បានចូលរួមក្នុងអង្គប្រជុំនោះ ។ កំណត់ហេតុនេះបានចុចយកតែអ្នកបាចខិតប័ណ្ណដោយមូលហេតុជំនឿនិន្នាការនយោបាយ ។ «ដកចេញ» អាចសន្និដ្ឋានបានថា «សម្លាប់» ។ ប្រសិនបើដូច្នោះមែន ឌុច ចូលក្នុងបទ «បំណងឧក្រិដ្ឋ» ហើយនឹងចូលក្នុងបទ «អំពើពិរុទ្ធ» ទៀត ប្រសិនបើមានការបង្ហាញថាសមមិត្ត ប៉ាង ឬ ខាំមី ពិតជាបានអនុវត្តការ «ដកចេញ»ជនសង្ស័យមែនក្រោយពីកិច្ចប្រជុំថ្ងៃនោះ ។

**២)** *សំបុត្រផ្ញើជូនចំពោះ ឌុចៈ ចាត់ការសួរ ix រួចហើយ ២៥ កញ្ញា ១៩៧៦*

ទាក់ទងដល់ការសួរចម្លើយបុរសម្នាក់គេដាក់ឯរថា «ix» «ម៉ែន សាន ហៅ យ៉ា» ឈ្មោះ ប៉ុន បានរាយការណ៍ទៅ ឌុច ថា «ថ្ងៃ២៥ កញ្ញា ៧៦ ទទួលការណែនាំពីអង្គការឲ្យធ្វើទារុណកម្ម ។ យើងខ្ញុំផ្តើមធ្វើទារុណកម្មពេលព្រឹកប្រហែល២០រំពាត់ផ្តៅតូច ។ ពេលល្ងាចយើងធ្វើទារុណកម្មប្រហែល២០-៣០រំពាត់ខ្សែភ្លើងវេញពាក្នុង» ។ ការរៀបរាប់បែបនេះចូលទៅក្នុងនិយមន័យច្បាប់នៃពាក្យថា ទារុណកម្ម ហើយការដឹងឮរបស់ ឌុច គឺត្រូវបានបង្ហាញចេញតាមរយៈនេះច្បាស់ណាស់ ។ ប្រសិនបើ ឌុច មិនបានចាត់វិធានការដាក់ទណ្ឌកម្មឬសរសេរឬប្រាប់អ្នកធ្វើទារុណកម្មទេនោះ ឌុច ច្បាស់ជាមានការទទួលខុសត្រូវចំពោះការបញ្ជាពីបទធ្វើទារុណកម្ម ។

*សំបុត្រផ្ញើមកឌុច (២៦ កញ្ញា ១៩៧៦)*

នៅក្នុងសំណេរដដែលទាក់ទងនឹងការធ្វើទារុណកម្មមកលើឈ្មោះ ix កូនចៅក្រោមបង្គាប់របស់ ឌុច សរសេរថា «ល្ងាចយើងខ្ញុំស្នើបងឌុច សូមធ្វើវិធានការ «ក្តៅ» ផង «ត្រជាក់ផង» ។ ក្រោយពីទទួលការអនុញ្ញាតហើយ ដល់ក្បាលល្ងាចនោះ យើងខ្ញុំចូលទៅកំញើញឲ្យត្រៀមខ្លួនម៉ោង៨ឬ៩យប់ផ្តើមធ្វើទារុណកម្មបន្តទៀត ។ ម៉ោងប្រហែលជិត១០យប់យើងខ្ញុំចូលបម្រុងធ្វើទារុណកម្មតែដៃទទេ ។ ix ចាប់ផ្តើមសារភាពដោយសួរបញ្ជាក់យើងខ្ញុំថារាយការណ៍ដូចម្តេចខ្លះ» ។ ពត៌មាននៅក្នុងឯកសារនេះបង្ហាញទាំងធាតុផ្សំនៃបំណងឧក្រិដ្ឋនិងអំពើពិរុទ្ធពីបទធ្វើទារុណកម្ម ។ ការបន្តធ្វើទារុណកម្មក៏ជាភ័ស្តុតាងមានទម្ងន់បញ្ជាក់ថាការធ្វើទារុណកម្មទៅលើរូប ix មិនត្រូវបានដាក់ទណ្ឌកម្មឲ្យបានគ្រប់គ្រាន់ឡើយ ។

**៣)** *បញ្ជីរឈ្មោះអ្នកទោសយកចូលក្នុងមន្ទីរ ស-២១*

ឯកសារនេះមានរាយឈ្មោះមនុស្សចំនួន១០នាក់ដែលត្រូវបាន«កម្ទេច»នៅថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ប្តុបន្ទិចក្រោយកាលបរិច្ឆេទនោះមានមនុស្សបីនាក់ទៀតត្រូវបាន«កម្ទេច»។ មនុស្សពីរនាក់ទៀតត្រូវបានសម្លាប់នៅថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ។ ក្នុងតួនាទីជាគណៈមន្ទីរ ស-២១ ឌុច បានដឹង (ឬគួរតែដឹង) អំពី "ការកម្ទេច" ទាំងនេះ ។ ទោះបីជាឯកសារមិនបានរៀបរាប់ពីមូលហេតុនាំឲ្យអ្នកទោសត្រូវ«កម្ទេច» យ៉ាងណាក៏ដោយ ក៏ភស្តុតាងផ្សេងទៀតអាចបញ្ជាក់ថាការសម្លាប់ទាំងនេះមានលក្ខណៈជាប្រព័ន្ធ និងធ្វើឡើង (យ៉ាងហោចណាស់មួយផ្នែកដែរ) ដោយសារមូលហេតុនៃការពាក់ព័ន្ធក្រុមនយោបាយឬក្រុមផ្សេងទៀតរបស់ជនរងគ្រោះ ។ ឯកសារនេះបង្ហាញភស្តុតាងមួយចំនួនថា "ការកម្ទេច" កំពុងត្រូវបានធ្វើឡើងនៅក្នុងលក្ខណៈរៀបចំត្រឹមត្រូវនិងជាប្រព័ន្ធ ។ ឧបមាថាសាលាក្តីឬតុលាការមួយទាញបានថាឌុចដឹងឬគួរតែដឹងអំពីការសម្លាប់នេះ បើដូច្នេះមែន ការចូលដៃក្នុងបទល្មើសរបស់ ឌុច ទាញឲ្យ ឌុច មានការទទួលខុសត្រូវលើការបញ្ជាចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។

**៤)** *ឯកសារ ព្រាំ គី*

ឯកសារមួយនេះដែលមានចម្លើយសារភាពរបស់ឈ្មោះ ព្រាំ គី រួមមានការអះអាងថាឈ្មោះ លឿ លេខាស្រុកថ្មស ត្រូវ "អង្គការសម្លាប់ចោលហើយ" ហើយថា "អង្គការក៏កម្ទេចប្អូនជីដូនមួយរបស់ លឿ"ដែរ ។ ព្រាំ គី ក៏បានសរសេរថា ស័ក្តិ៣ កង ស័ក្តិ២ខាន់ និងស័ក្តិ១ ឡេវ ដែលច្បាស់ថាធ្វើទាហានជំនាន់ លន់ ណុល "ត្រូវបានយកសម្លាប់ចោលទាំងអស់" ។ ព្រាំ គី ក៏សរសេរទៀតថា បងប្រុសរបស់ ភួន ដែលជាទាហាន លន់ ណុល ព្រមទាំងឪពុកម្តាយរបស់ ដួ ណា ធ្វើពេទ្យ ត្រូវបាន "អង្គការយកទៅសម្លាប់" ។ ឯកសារចម្លើយសារភាពនេះត្រូវបានបញ្ជូនឲ្យ ឌុច ។ អំណះអំណាងដែលថាទាហានរបស់អតីតរបប លន់ ណុល ត្រូវបានយកទៅសម្លាប់ចោល បង្ហាញថាការសម្លាប់ទាំងនេះគឺផ្អែកទៅលើគំនិតនយោបាយដែលជាការសន្មត ហើយមិនមែនជាផ្នែកមួយនៃជម្លោះប្រដាប់អាវុធនោះទេ ។ ការសម្លាប់ផ្សេងៗទៀតក៏ត្រូវបានធ្វើឡើងដោយមូលហេតុនយោបាយដែរ ។ ទោះបីជាឯកសារចម្លើយសារភាពជាទូទៅមានទម្ងន់ភស្តុតាងមិនសូវធ្ងន់យ៉ាងណាក៏ដោយ ក៏ប៉ុន្តែប្រសិនបើភស្តុតាងដទៃទៀត (ដូចជាកសិណសាក្សីឃើញហេតុការណ៍ផ្ទាល់ភ្នែក) អាចបញ្ចូលគ្នាជាមួយនឹងភស្តុតាងដែលមានស្រាប់នេះ វាអាចជួយទាញឲ្យ ឌុច មានការទទួលខុសត្រូវលើការបញ្ជាចំពោះបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។

**៥)** *ឯកសារទាក់ទងនឹង ឌុច*

ប៉ុន ដែល ឌុច ស្គាល់ បានសង្ខេបចម្លើយសារភាពរបស់ ផាន់ និង ញ៉ែប សួង ។ ផាន់ បានបញ្ចូលឈ្មោះមនុស្សពីរនាក់ដែលត្រូវបាន "កម្ទេច" ចោលហើយដោយសារ "បានបង្កទំនាស់" ។ ញ៉ែប សួង ដាក់ឈ្មោះមនុស្សធម្មតាប្អូននាក់ដែលខ្លួននិយាយថាធ្វើសកម្មភាពប្រឆាំងនឹងអង្គការ ហើយដែលត្រូវបានអង្គការសម្លាប់ចោលហើយ ។ ករណីនេះដូចជាករណីមុនៗដែរ ការសម្លាប់អ្នកប្រឆាំងនយោបាយដែលមានការយល់ព្រមគឺបង្ហាញច្បាស់ណាស់ ។ ឌុច បានចារកំណត់សម្គាល់មួយចំនួននៅលើចម្លើយសារភាពដោយមិនមាននិយាយអំពីការជំទាស់នឹងការសម្លាប់អ្វីឡើយ ។ ប្រសិនបើបំណែកឯកសារចម្លើយសារភាពដែលពាក់ព័ន្ធគ្នាត្រូវបានសាលាក្តីឬតុលាការផ្តល់ទម្ងន់នោះ ឌុច មានការទទួលខុសត្រូវលើការបញ្ជាពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។

មូឌី និងអ្នកផ្សេងទៀត ពិភាក្សាទៅលើឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាចំនួន១១លេខ ដែលទាក់ទងនឹងការកាត់ក្តីផ្នែកព្រហ្មទណ្ឌប្រឆាំងនឹង ឌុច ។ ដូចឧទាហរណ៍ខាងលើបានបញ្ជាក់ស្រាប់ ឃើញថាមិនសូវមានអ្វីគួរឲ្យឆ្ងល់ទេ គឺ ឌុច អាចត្រូវបានចោទប្រកាន់ពីបទទារុណកម្មនិងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។

## ៦) ម៉ម ណៃ ហៅ ចាន់

ដូច ឌុច ដែរ ភស្តុតាងប្រឆាំងនឹង ម៉ម ណៃ (ហៅចាន់) មានទម្ងន់ណាស់ ។ តាមចំណារនៅលើឯកសារដាក់ថាជាប្រធានផ្នែកសួរចម្លើយនៅមន្ទីរស-២១ ម៉ម ណៃ បានធ្វើរបាយការណ៍ជាច្រើនដែលបង្ហាញថា ម៉ម ណៃ ខ្លួនឯងបានបញ្ជាឬចូលរួម

ក្នុងការធ្វើទារុណកម្មទៅលើអ្នកទោសនិងស្រង់យកចម្លើយសារភាពពីអ្នកទោស ។ មានសំណុំរឿងដែលមានទម្ងន់ប្រឆាំងនឹង ម៉ម ណៃ ពីបទទារុណកម្ម ហើយភ័ស្តុតាងប្រយោលទាញឲ្យ ម៉ម ណៃ ចូលក្នុងបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដូចជាវិសុទ្ធកម្មលើអ្នកទោសនៅទួលស្លែងដែលធ្វើឡើងដោយកូនចៅរបស់ខ្លួនផ្ទាល់ ដែលសកម្មភាពនេះត្រូវរៀបចំជាឯកសារយ៉ាងត្រឹមត្រូវ ។

ឧទាហរណ៍ចេញពីឯកសារមួយចំនួនដែលទាក់ទងនឹងការកាត់ទោសដែលអាចកើតឡើងប្រឆាំងនឹង ម៉ម ណៃ មាននៅក្នុងសំណុំឯកសារទួលស្លែងដែលជាកម្មសិទ្ធិរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ឧទាហរណ៍ទាំងនេះមានដូចតទៅនេះ ÷

ម៉ម ណៃ បានចេញអនុស្សរណៈជាច្រើនច្បាប់ទៅកាន់ ឌុច ដោយដាក់ឈ្មោះអ្នកទោសថ្មីដែលត្រូវបាននាំមកកាន់ទួលស្លែង ។ ចំណារសរសេរដោយដៃនៅតាមជាយៗឯកសារអនុស្សរណៈមួយចំនួនបង្ហាញថាមានមនុស្សមួយចំនួនត្រូវបាន «កម្ទេច» ។ ម៉ម ណៃ ដឹងយ៉ាងច្បាស់អំពីដំណើរប្រព្រឹត្តទៅនៃការងារខាងក្នុងទួលស្លែង និងអំពីការស្លាប់របស់អ្នកទោស ។ អង្គហេតុនេះក៏មានការគាំពារតាមរយៈភ័ស្តុតាងជាក់ស្តែងនិងឯកសារភ័ស្តុតាងមួយចំនួនតម្កល់ទុកនៅ(វាលពិឃាត) ជើងឯក ។ អនុស្សរណៈតម្កល់ទុកនៅបណ្ណសារទួលស្លែងដែលជាកម្មសិទ្ធិរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បញ្ជាក់ច្បាស់ថា ម៉ម ណៃ បានដឹងឬគួរតែដឹងអំពីទារុណកម្មនិងការសម្លាប់ ហើយមិនបានចាត់វិធានការទប់ទល់ ឬដាក់ទណ្ឌកម្មឲ្យរាងចាល ។

មជ្ឈមណ្ឌលឯកសារកម្ពុជាក៏មានរបាយការណ៍មួយចំនួនដែលបញ្ជាក់ថា ម៉ម ណៃ បានធ្វើទារុណកម្មដោយដៃឯងផ្ទាល់ទៅលើអ្នកទោសជាច្រើននាក់នៅទួលស្លែង ឬបានត្រួតពិនិត្យការធ្វើទារុណកម្មដោយផ្ទាល់ ។ ឯកសារប្រភេទនេះមាននៅក្នុងសំណុំឯកសារតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា និងអាចយកមកប្រើប្រាស់បានដូចជាឯកសារដទៃទៀតដែលយកមកបង្ហាញជាឧទាហរណ៍ខាងលើនេះដែរ ។

## VIII. សន្និដ្ឋាន

សរុបមក ការសិក្សាស្រាវជ្រាវរបស់ខ្ញុំបានរកឃើញការអនុវត្តមួយចំនួនទៅលើភ័ស្តុតាងឯកសារតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ដោយមានចំណាត់ការអនុវត្តចាំបាច់ជាក់ស្តែង ភ័ស្តុតាងនៅមជ្ឈមណ្ឌលឯកសារកម្ពុជាអាចធ្វើជាមូលដ្ឋានយ៉ាងសំខាន់សម្រាប់ចងក្រងសំណុំរឿងដែលមានទម្ងន់ក្នុងការចោទប្រកាន់បុគ្គលទាំង៧រូបដែលមានរាយឈ្មោះខាងលើ និងអតីតមន្ត្រីបក្សកុម្មុយនិស្តកម្ពុជា ។ ជាការសំខាន់ណាស់ក្នុងការរំឭកដល់អ្នកអានទូទៅថាឧទាហរណ៍លើកឡើងនៅក្នុងវគ្គទី V ខាងលើ បង្ហាញត្រឹមតែកំណត់ហេតុមួយដែលជាផ្នែកមួយមិនមែនតំណាងឲ្យភ័ស្តុតាងទាំងអស់តម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជាទេ ។ ដោយរួមស្រាក់គ្នាជាមួយកសិណសាក្សីផ្ទាល់ភ្នែកដូចដែលបានពិភាក្សានៅវគ្គទី VI ឯកសារភ័ស្តុតាងទាំងនេះសមនឹងធ្វើឲ្យព្រះរាជអាជ្ញាចោទមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនិងឧក្រិដ្ឋជនដែលផ្សេងទៀត ឲ្យទទួលខុសត្រូវពីបទទារុណកម្មនិងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ ការកាត់សេចក្តីករណីប្រល័យពូជសាសន៍ អំពើទាសភាព ឬការបង្ខំឲ្យធ្វើការងារជាទម្ងន់ ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិវប្បធម៌ ការរើសអើងជាតិសាសន៍ និងឧក្រិដ្ឋកម្មសង្គ្រាម ក៏អាចជំរុញឲ្យចេញជារូបរាងបានដែរ តាមរយៈឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ និយាយរួមមកវិញ ភ័ស្តុតាងឯកសារផ្តល់នូវសំណុំរឿងដ៏មានទម្ងន់សម្រាប់ការកាត់សេចក្តីចុងចោទនៅក្នុងតុលាការខ្មែរក្រហមដែលនឹងមាននៅពេលខាងមុខ ។

**ចន ឆរធីអារី**

## ពន្យល់ពាក្យពាក្យខ្មែរក្រហម

◆ **ផ្តាច់មុខ៖** គឺមានតែបក្សកុម្មុយនិស្តទើបដឹកនាំកម្មាភិបាលកុម្មុយនិស្តកម្ពុជាបាន ។ *(កំណត់ហេតុ គណហ២០៩)*

◆ **យោធាបដិវត្តល្អ៖** យោធាដែលបំពេញភារកិច្ចគ្រប់មុខបានល្អដោយគ្មានលក្ខខណ្ឌ ពេលមាន ពេលអត់ ពេលស្រួល ពេលលំបាក ពេលឈ្នះ ពេលចាញ់ជាបណ្តោះអាសន្ន ពេលឈ្នះទាំងស្រុង ចូលទីក្រុងក៏គ្មានលក្ខខណ្ឌ ។

*(កំណត់ហេតុលេខ១០៨ គណហ១៨៥)*

# ច្បាប់សិទ្ធិមនុស្សអន្តរជាតិ

ដូចដែលបានបញ្ជាក់រួចពីមុនរួចមកហើយ បញ្ហាសិទ្ធិមនុស្សមានការវិវត្តមួយបន្ទាប់ពីសង្គ្រាមលោកលើកទី២ផុតរលត់ទៅ ។ សេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្សត្រូវបានអនុម័តនៅក្នុងឆ្នាំ១៩៤៨ ហើយគឺជា “សមិទ្ធផលដែលមានលក្ខណៈទូទៅសម្រាប់បម្រើផលប្រយោជន៍ឲ្យមនុស្សនិងប្រជាជនទាំងមូលលើសកលលោក” ។ តាមលក្ខន្តិកៈនៃច្បាប់នេះ ភាគីរដ្ឋជាសមាជិកទាំងអស់ដោយធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គការសហប្រជាជាតិ បានសន្យាថានឹងសម្រេចឲ្យបាននូវការ “ជំរុញនិងលើកកម្ពស់នូវការគោរពជាសកល និងនូវការសង្កេតការណ៍លើវិស័យសិទ្ធិមនុស្សនិងសេរីភាពជាសារវន្ត” ។ ទន្ទឹមនឹងកតិការសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋនិងនយោបាយ និងកតិការសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិក្នុងវិស័យសេដ្ឋកិច្ច សង្គម និងវប្បធម៌ សេចក្តីប្រកាសជាសកលនេះបានតាក់តែងសេចក្តីព្រាងច្បាប់ជាអន្តរជាតិមួយស្តីពីសិទ្ធិ ។ មជ្ឈដ្ឋានខ្លះបានបែងចែកសិទ្ធិមនុស្សអន្តរជាតិជា៣ប្រភេទសំខាន់÷

១) មនុស្សជំនាន់ទី១ៈ សិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយមានប្រភពចេញពីទស្សនៈសិទ្ធិធម្មជាតិនៅចុងសតវត្សរ៍ទី១៨នេះ ។

២) ជំនាន់ទី២ៈ សិទ្ធិក្នុងវិស័យសេដ្ឋកិច្ច សង្គម និងវប្បធម៌ ដែលទទួលបាននូវការទទួលស្គាល់ជាផ្លូវការនៅក្នុងសតវត្សរ៍ទី២០ ។ លិខិតូបករណ៍ចម្រុះដែលទើបបង្កើតថ្មីដូចជាអនុសញ្ញាស្តីពីការលុបបំបាត់ចោលគ្រប់បែបយ៉ាងនូវការរើសអើងស្ត្រី និងអនុសញ្ញាស្តីអំពីសិទ្ធិរបស់កុមារ រួមបញ្ចូលទាំងសិទ្ធិទាំងឡាយដែលមានចែងក្នុងជំនាន់ទី១និងទី២ ហើយមជ្ឈដ្ឋានភាគច្រើន ខ្លះទៀតយល់ឃើញថា សិទ្ធិទាំងឡាយនោះគួរតែផ្តល់នូវអាទិភាពឲ្យបានស្មើៗគ្នា ។

៣) ជំនាន់ទី៣ៈ រដ្ឋកំពុងអភិវឌ្ឍទាំងឡាយបានជំរុញលើកកម្ពស់សញ្ញាណកម្មនៃច្បាប់ជំនាន់ទី៣ដែលនិយាយអំពីសិទ្ធិជាក្រុមរួមទាក់ទងទៅនឹងសិទ្ធិក្នុងវិស័យអភិវឌ្ឍនិងការទទួលស្ថានភាពរស់នៅសមស្រប ។

ក) ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងសិទ្ធិមនុស្សអន្តរជាតិ

ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ គឺជាប្រភេទឧក្រិដ្ឋកម្មទាំងឡាយក្រោមច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិដែលបុគ្គលដែលបានប្រព្រឹត្តត្រូវតែទទួលទោសព្រហ្មទណ្ឌជាកំហិត ។ ការប្រព្រឹត្តទាំងឡាយដែលរួមមានបទឧក្រិដ្ឋទាំងនេះ “ឧទាហរណ៍ការធ្វើទារុណកម្ម ការប្រព្រឹត្តដែលមានលក្ខណៈឃោរឃៅអមនុស្សធម៌នាំឲ្យបាត់បង់តម្លៃជាមនុស្ស ការនិរទេស ឃាតកម្ម ការបង្ខំឲ្យធ្វើទាសករ ការរំលោភលើផ្លូវភេទជាដើម ។ល ។” គឺជាការរំលោភបំពានលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ ។ ហេតុដូច្នេះហើយ ការរំលោភបំពានអាចដោះស្រាយ ឬកែតម្រូវដោយមធ្យោបាយនានា ជាជាងដាក់ឲ្យទទួលខុសត្រូវពីបទព្រហ្មទណ្ឌក្រោមច្បាប់អន្តរជាតិ ។ ជាទូទៅបុគ្គលអាចត្រូវបានដាក់ឲ្យទទួលខុសត្រូវពីបទព្រហ្មទណ្ឌក្រោមច្បាប់អន្តរជាតិ ចំពោះការរំលោភបំពាននៃឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើប្រល័យពូជសាសន៍ ។

ខ) ការប្រើប្រាស់ច្បាប់សិទ្ធិមនុស្សអន្តរជាតិ

មានការរំលោភបំពានជាច្រើន លើច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដែលពុំដាក់ឲ្យបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌ ។ ដូច្នេះច្បាប់សិទ្ធិមនុស្សអន្តរជាតិប្រើប្រាស់ចំពោះអ្វី? ច្បាប់សិទ្ធិមនុស្សអន្តរជាតិពិតជាចងភ្ជាប់កាតព្វកិច្ចរបស់រដ្ឋ ហើយរដ្ឋអាចទទួលខុសត្រូវចំពោះការរំលោភសិទ្ធិមនុស្ស ទោះបីការរំលោភមិនអាចបង្កើតការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលក៏ដោយ ។ ឧទាហរណ៍ គណៈកម្មាធិការរបស់អង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស អ្នកធ្វើកំណត់ហេតុ និងបេសកជនពិសេសរបស់អង្គការសហប្រជាជាតិ ក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិ មហាសន្និបាតរបស់អង្គការសហប្រជាជាតិ និងអង្គការក្រៅរដ្ឋាភិបាលទាំងអស់ អាចថ្កោលទោសចំពោះរដ្ឋទាំងឡាយអំពីការរំលោភលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ ។ បុគ្គលទាំងឡាយអាចត្រូវបានដាក់ឲ្យទទួលខុសខាងផ្នែក

រដ្ឋប្បវេណីត្រូវចំពោះការរំលោភលើច្បាប់អន្តរជាតិ ។

ការដាក់ទណ្ឌកម្មផ្សេងៗ "សេដ្ឋកិច្ច នយោបាយ និង យោធា" ក៏អាចធ្វើឡើងបានជាលក្ខណៈទ្វេភាគីឬពហុភាគី ដោយរាប់បញ្ចូលតាមរយៈអង្គការសហប្រជាជាតិ ប្រឆាំងនឹងរដ្ឋដែលកំពុងរំលោភច្បាប់សិទ្ធិមនុស្សអន្តរជាតិ ។ ច្បាប់សិទ្ធិមនុស្សបានផ្តល់នូវសិទ្ធិសកល និងបទដ្ឋាននៃការប្រព្រឹត្តសម


តុលាការឆ្នាំ១៩៧៩ កាត់ទោសអតីតយោធាខ្មែរក្រហម

ស្របដែលមនុស្សគ្រប់រូបមានសិទ្ធិទទួលបាន ។ បទដ្ឋានទាំងនេះអាចត្រូវបានប្រើប្រាស់ដើម្បីពង្រឹងឬបង្កើតការការពារតាមច្បាប់នៅក្នុងរដ្ឋ ។ ជាឧទាហរណ៍ មាត្រា៣១នៃរដ្ឋធម្មនុញ្ញកម្ពុជាដែលធ្វើសមាហរណកម្មពីរដ្ឋធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញានិងអនុសញ្ញាទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិរបស់ស្ត្រី និងសិទ្ធិរបស់កុមារ ។ វាមិនច្បាស់លាស់ថាតើលិខិតូបករណ៍ណាមួយដែលត្រូវយកមកបញ្ចូលនៅក្នុង "ខ" ដែលបាននិយាយខាងលើ ប៉ុន្តែហាក់ដូចជាបានបញ្ចូលជាអប្បបរមានូវកតិកាសញ្ញាដូចខាងក្រោម÷ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិក្នុងវិស័យសេដ្ឋកិច្ច សង្គម និងសិទ្ធិវប្បធម៌ អនុសញ្ញាស្តីពីសិទ្ធិកុមារ អនុសញ្ញាស្តីពីការលុបបំបាត់ចោលគ្រប់បែបយ៉ាងទាំងអស់នៃការរើសអើងប្រឆាំងស្ត្រីភេទ ។ ជាវិបាក ការរំលោភដោយបុគ្គលទៅលើបទដ្ឋាននិងក្រមច្បាប់ទាំងឡាយដែលបានចែងនៅក្នុងលិខិតូបករណ៍សិទ្ធិមនុស្សទាំងនេះអាចត្រូវបានផ្តន្ទាទោសក្រោមច្បាប់ក្នុងស្រុករបស់កម្ពុជា លុះត្រាណារដ្ឋធម្មនុញ្ញមួយផ្នែកនេះត្រូវបានអនុវត្តដោយសភាជាតិហើយនោះ ។

មិនតែប៉ុណ្ណោះ បទដ្ឋានសិទ្ធិមនុស្សក៏ជាការសម្តែងជាលាយលក្ខណ៍អក្សរនូវភារកិច្ចនិងកាតព្វកិច្ចផ្នែកសីលធម៌ដែរ ។ បទដ្ឋាននេះអាចប្រើប្រាស់ដើម្បីថ្កោលទោស ធ្វើឲ្យអាម៉ាស់មុខ និងគាបសង្កត់ទៅលើបុគ្គល កងកម្លាំងរើបម្រះ ឬរដ្ឋាភិបាលឲ្យគោរពសិទ្ធិមនុស្ស ។ ជាអវសាន ច្បាប់សិទ្ធិមនុស្សក៏អាចប្រើប្រាស់ដើម្បីរិះរកការសងជំងឺចិត្តតាមរយៈបណ្តឹងវិវាទក្នុងស្រុក (សូមមើលការពិភាក្សាពាក្យបណ្តឹងវិវាទរដ្ឋប្បវេណីសហរដ្ឋអាមេរិក ក្រោមច្បាប់សំណងរដ្ឋប្បវេណីដល់គ្រួសារជនរងគ្រោះ) ។

ច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងច្បាប់ព្រហ្មទណ្ឌអន្តរជាតិពុំមែនជាច្បាប់ដាច់ដោយឡែកខុសពីគ្នាឡើយ ប៉ុន្តែផ្ទុយទៅវិញ ច្បាប់ទាំងពីរនេះមានទស្សនៈនិងប្រភពអំណាចប្រហាក់ប្រហែលគ្នា ។ ច្បាប់ព្រហ្មទណ្ឌអន្តរជាតិមាននិយាយអំពីការរំលោភបំពានលើសិទ្ធិមនុស្សអន្តរជាតិ ដែលមានលក្ខណៈធ្ងន់ធ្ងររហូតដល់អាចដាក់បុគ្គលដែលប្រព្រឹត្តឲ្យទទួលខុសត្រូវព្រហ្មទណ្ឌបាន ។

**អេលីហ្សាប៊ែត វ៉ាន់ស្កាក់**

# អនាគតរបស់អង្គការណាតូនៅកូសូវ៉ូ៖ ជាការលើកស្ទួយឬក៏បំផ្លាញច្បាប់អន្តរជាតិដែលមានសព្វថ្ងៃ?

## សេចក្តីផ្តើម

ក្រោយពីសង្គ្រាមលោកលើកទី២ បានផុតរលត់ទៅ សហគមន៍អន្តរជាតិបានបង្កើតអង្គការមួយហៅថា“អង្គការសហប្រជាជាតិ”ក្នុងគោលបំណង“កុំឲ្យកូនចៅជំនាន់ក្រោយមានទុក្ខទោសដោយសារសង្គ្រាម” និងថែរក្សាពិភពលោកទាំងមូលឲ្យមានសន្តិសុខនិងសន្តិភាព ។ មធ្យោបាយដ៏ចម្បងក្នុងការថែរក្សាសន្តិសុខពិភពលោកគឺគ្រប់គ្រងការប្រើប្រាស់កម្លាំងប្រដាប់អាវុធរបស់រដ្ឋទាំងឡាយឲ្យបានត្រឹមត្រូវ ។ ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិចែងយ៉ាងច្បាស់ថា រដ្ឋទាំងឡាយត្រូវដោះស្រាយការទាស់ទែងខ្វែងគំនិតគ្នាដោយសន្តិវិធី ហើយអាចប្រើប្រាស់កម្លាំងប្រដាប់អាវុធបានលុះត្រាណាតែស្ថិតក្នុងករណីធ្ងន់ធ្ងរដែលច្បាប់នេះអនុញ្ញាត ។ ការប្រើកម្លាំងប្រដាប់អាវុធអាចធ្វើទៅបានក្នុងករណីការពារបុគ្គលឬការពារខ្លួនជាសមូហភាពតាមរយៈចំណាត់ការរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិឬតាមរយៈចំណាត់ការរបស់ភ្នាក់ងារសន្តិសុខក្នុងតំបន់ ។ នៅក្នុងចំណុចទាំងបីពិសេសខាងលើនេះ “កម្លាំងប្រដាប់អាវុធអាចអនុញ្ញាតឲ្យប្រើប្រាស់បាន ប្រសិនបើករណីចាំបាច់ក្នុងការរារាំងមិនឲ្យអំពើឈ្លានពានកើតឡើងបាន ។ រាល់ការប្រើប្រាស់កម្លាំងប្រដាប់អាវុធក្រៅពីប្រើកម្លាំងប្រដាប់អាវុធដើម្បីការពារខ្លួនគឺតម្រូវឲ្យមានការអនុញ្ញាតជាមុនសិនពីសំណាក់ក្រុមប្រឹក្សាសន្តិសុខឬមហាសន្និបាតអង្គការសហប្រជាជាតិមុនពេលចាត់វិធានការជាក់ស្តែង ។

ក្រោយពីមានការបង្កើតឡើងនូវអង្គការសហប្រជាជាតិ សង្គ្រាមត្រជាក់ក៏បានចាប់ផ្តើមឡើងដោយធ្វើឲ្យពិភពលោកបែងចែកជាពីរប្លុក ពោលគឺ ប្លុកលោកខាងកើត និងប្លុកលោកខាងលិច ។ មហាអំណាចទាំងពីរគឺ (សហរដ្ឋអាមេរិក និងសហភាពសូវៀត) សុទ្ធតែជាសមាជិករបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ។ ការប្រើកម្លាំងប្រដាប់អាវុធក្នុងលក្ខណៈខុសច្បាប់និងឯកតោភាគីបានកើតមានឡើងនៅក្នុងសម័យសង្គ្រាមត្រជាក់ ។ មិនខុសពីអ្នកសិក្សាជាន់ខ្ពស់លើច្បាប់អន្តរជាតិមួយចំនួនបានលើកឡើងនោះទេ បន្ទាប់ពីធម្មនុញ្ញអង្គការសហប្រជាជាតិចូលជាធរមាន មានសង្គ្រាមកើតឡើងជាងមួយរយករណីរវាងរដ្ឋនិងរដ្ឋ រួមទាំងការចូលទន្ទ្រានកាន់កាប់របស់សហភាពសូវៀតមកលើប្រទេសឆេកូស្លូវ៉ាគីនៅក្នុងឆ្នាំ១៩៦៨ផង ។

ការប្រើប្រាស់កម្លាំងប្រដាប់អាវុធក្នុងលក្ខណៈខុសច្បាប់មិនទាន់ចប់នៅឡើយទេ ទោះបីជាសង្គ្រាមត្រជាក់បានផុតរលត់ទៅហើយក៏ដោយ ។ យោងតាមប្រសាសន៍របស់លោក ខន់ស្តែនទីន បានឲ្យដឹងថា ការផុតរលត់នៃសង្គ្រាមត្រជាក់“មិនបានកាត់បន្ថយនូវការងាកមកប្រើកម្លាំងប្រដាប់អាវុធក្នុងលក្ខណៈឯកតោភាគីឡើយ ហើយក៏គ្មានសង្ឃឹមថានឹងមានការកាត់បន្ថយបាតុភាពបែបនេះដែរ ។ មិនតែប៉ុណ្ណោះ ហេតុផលដែលធ្វើឲ្យរដ្ឋទាំងឡាយចង់ប្រើកម្លាំងប្រដាប់អាវុធក៏នៅមានមិនចេះអស់មិនចេះហើយ ។ សង្គ្រាមត្រជាក់បានក្លែងមុខមាត់រដ្ឋទាំងនេះហើយបង្វាញពីការទាញយកផលប្រយោជន៍ជាតិឥតអៀនខ្មាសដែលជាការតស៊ូខាងវោហារសាស្ត្រនោគមវិជ្ជា“ប្រជាធិប-តេយ្យ”ជាមួយនឹង“លិទ្ធិផ្តាច់ការ” ឬ“លិទ្ធិសង្គមនិយម”ជាមួយនឹង“ការជិះជាន់តាមបែបមូលធននិយម” ។ ប្រភេទនៃទំនាស់ក្រោយសង្គ្រាមត្រជាក់បានផ្លាស់ប្តូររូបភាពរបស់វាដោយមិនសូវផ្តោតសំខាន់ទៅលើបញ្ហាកើតឡើងរវាងលោកខាងកើតជាមួយនឹងលោកខាងលិច ហើយបែរជាផ្តោតសំខាន់លើជម្លោះក្នុងតំបន់និងអង្គការតំបន់ ដូចជាអង្គការសន្ធិសញ្ញាអាត្លង់ទិចខាងជើង(ណាតូ) ឬសហភាពអឺរ៉ុប(អ៊ីយូ)ទៅវិញ ។ ឧទាហរណ៍ជាក់ស្តែងមួយចំនួននៃការប្រើកម្លាំងប្រដាប់អាវុធក្រោយសង្គ្រាមត្រជាក់របស់រដ្ឋមួយចំនួនដែលធ្វើមិនត្រឹមត្រូវតាមធម្មនុញ្ញអង្គការសហប្រជាជាតិ រួមមានការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកទៅលើប្រទេសអ៊ីរ៉ាក់ក្នុងឆ្នាំ១៩៩៣

ឆ្នាំ១៩៩៦និងឆ្នាំ១៩៩៨ ការវាយប្រហារដោយកាំជ្រួចមីស៊ីលនៅប្រទេសអាហ្វហ្គានីស្ថាននិងនៅប្រទេសស៊ូដង់ក្នុងឆ្នាំ១៩៩៨ និងការចូលលុកលុយរបស់ប្រទេសបារាំងទៅក្នុងសាធារណរដ្ឋអាហ្វ្រិកកណ្តាលក្នុងឆ្នាំ១៩៩៧ ។

ករណីក្នុងច្បាប់អន្តរជាតិដែលកាន់តែពិបាកដាងការឈ្លានពានរបស់រដ្ឋមួយមកលើរដ្ឋមួយទៀត (ដែលមិនមែនជាលក្ខណៈការពារខ្លួន) នោះគឺការប្រើកម្លាំងប្រដាប់អាវុធក្នុងរូបភាពជាការធ្វើអន្តរាគមន៍ជាលក្ខណៈមនុស្សធម៌ ។ ការប្រើកម្លាំងប្រដាប់អាវុធដោយផ្អែកលើហេតុផលមនុស្សធម៌មិនមែនជាគោលការណ៍ដោះស្រាយ នៅក្នុងច្បាប់អន្តរជាតិទេ ។ ការប្រើកម្លាំងប្រដាប់អាវុធរបស់អង្គការណាតូនាពេលថ្មីៗនេះនៅកូសូវ៉ូ ត្រូវបានប្រទេសមួយចំនួនដែលជាសមាជិកក្នុងអង្គការណាតូទាញហេតុផលពន្យល់ថាវាជាអន្តរាគមន៍បែបមនុស្សធម៌ ។ និក្ខេបបទនេះចង់បកស្រាយវែកញែកទៅលើបញ្ហាថាតើការប្រើកម្លាំងប្រដាប់អាវុធរបស់សមាជិកនៃប្រទេសទាំង១០របស់អង្គការណាតូប្រឆាំងនឹងសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវីនៅដើមឆ្នាំ១៩៩៩មានលក្ខណៈស្របទៅនឹងធម្មនុញ្ញអង្គការសហ-ប្រជាជាតិដែរឬយ៉ាងណា ជាពិសេសថាតើវាសមហេតុផលទេដែលថានេះជាអន្តរាគមន៍ផ្អែកមនុស្សធម៌នោះ ។ ប្រសិនបើមិនស្របច្បាប់ដូចដែលខ្ញុំនឹងពិភាក្សាបន្តិចទៀតនេះ និក្ខេបបទនេះក៏នឹងពិនិត្យថែមទៀតថាតើការទទួលខុសត្រូវបែបណាដែលរដ្ឋជាសមាជិករបស់អង្គការណាតូត្រូវមានទាំងការទទួលខុសត្រូវរួមនិងដោយឡែកចំពោះសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវីនិងចំពោះសហគមន៍អន្តរជាតិទាំងមូល ។

## I. *សាវតារ*

ក្នុងពេលមានវិបត្តិក្នុងចុងឆ្នាំ១៩៩០ កូសូវ៉ូ ជាផ្នែកមួយរបស់រដ្ឋដែលមានអធិបតេយ្យភាពនៃសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវីដែលមិនមានទំនាស់ប្រទាញប្រទង់អ្វីឡើយ ទោះបីជាមនុស្សមួយចំនួនចង់បានឯករាជ្យឬស្វ័យភាពចេញពីសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវីក៏ដោយ ។ គ្មានប្រទេសជាសមាជិកអង្គការណាតូណាមួយទាញហេតុផលតាមបែបផ្សេងពីនេះឡើយ ។ នៅខែឧសភា ឆ្នាំ១៩៩៨ ប្រធានាធិបតីសហរដ្ឋអាមេរិក ប៊ីល គ្លីនតុន បាននិយាយសង្ខេបរឿងជម្លោះនៅកូសូវ៉ូដូចខាងក្រោមនេះ÷

“អ្នកឯងមានទឹកដីមួយចំណែកពីប្រទេសស៊ែបដែលមានជនជាតិអាល់បានីចំនួន៩០ភាគរយ ។ គេចង់បានស្វ័យភាពខ្លះហើយថែមទាំងចង់ឲ្យមានការដោះស្រាយនូវការព្រួយបារម្ភរបស់គេ ។ ប្រជាជនស៊ែបមិនចង់ឲ្យទឹកដីមួយផ្នែកធំរបស់ខ្លួនត្រូវបាត់បង់ឡើយ ដែលទឹកដីនេះជឿជាក់ថានឹងមានភាពស្របច្បាប់ត្រឹមត្រូវជាផ្នែកមួយនៃប្រទេសរបស់គេ” ។ កូសូវ៉ូមិនដែលក្លាយជារដ្ឋមានឯករាជ្យម្តងណាឡើយ ។ ពីមុនទឹកដីនេះជាអាណាខេត្តមួយរបស់ចក្រភពទួរគី ។ កូសូវ៉ូបានប្រគល់ឲ្យប្រទេសស៊ែប (តាំងពីឆ្នាំ១៩៩២ដែលហៅជាផ្លូវការថាសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវី) ក្រោយពីសង្គ្រាមបាល់កង់ដែលកើតឡើងពីឆ្នាំ១៩១២-១៩១៣ត្រូវបានបញ្ចប់ដោយប្រទេសទួរគីជាអ្នកទទួលបរាជ័យ ។ នៅឆ្នាំ១៩៩៩ មុនពេលមានវិបត្តិនៅកូសូវ៉ូ មានប្រជាជនកូសូវ៉ូប្រមាណ៩០ភាគរយជាជនជាតិឥស្លាមដើមកំណើតអាល់បានី ក្រៅពីនោះភាគច្រើនជាជនជាតិស៊ែបដែលកាន់គ្រិស្តសាសនាប្រកាន់វិន័យចាស់ និងជនជាតិហ្សីបស៊ី ។ តាមរដ្ឋធម្មនុញ្ញរបស់យូហ្គោស្លាវីឆ្នាំ១៩៧៤ កូសូវ៉ូត្រូវបានប្រគល់ស្វ័យភាពនៅក្នុងទឹកដីរបស់យូហ្គោស្លាវី ។ ប៉ុន្មានទសវត្សរ៍មុនពេលមានវិបត្តិកូសូវ៉ូ ទាំងជនជាតិស៊ែបទាំងជនជាតិកូសូវ៉ា-អាល់បានី បានប្តឹងប្តល់អំពីការធ្វើទុក្ខបុកម្នេញដោយមូលហេតុជាតិពន្ធុ ។ ជនជាតិភាគតិចស៊ែបនិយាយពីការធ្វើបាបនិងការប្រកាន់ពូជសាសន៍ពីសំណាក់ជនជាតិភាគច្រើនអាល់បានី ហើយការណ៍នេះត្រូវបានលោក ស្លូបូដាន មីឡូសេវិក ប្រធានាធិបតីថ្មីនៃសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវីយកមកប្រើប្រាស់នៅឆ្នាំ១៩៩០ជាលេសដើម្បីលុបចោលនូវស្វ័យភាពរបស់កូសូវ៉ូ ។

វិបត្តិនៅកូសូវ៉ូចាប់ផ្តើមឡើងនៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ១៩៨៩ កាលនោះរដ្ឋាភិបាលទីក្រុងបែលក្រាដបានប្រកាសភាពអាសន្នជាការឆ្លើយតបទៅនឹងការវាយប្រហាររបស់និស្សិតអាល់បានីនិងកម្មករអណ្តូងរ៉ែដែលគាំទ្រឯករាជ្យ ។ កងទ័ពរបស់សាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវីត្រូវបានបញ្ជូនទៅកាន់

កូសូវ៉ូ ដើម្បីធ្វើឲ្យមានច្បាប់ទម្លាប់និងសណ្តាប់ធ្នាប់ឡើងវិញ ។ មួយខែក្រោយមក អាជ្ញាធរទីក្រុងបែលក្រាដបានលុបចោលស្វ័យភាពរបស់កូសូវ៉ូ ហើយបាតុកម្មដែលធ្វើឡើងដើម្បីប្រឆាំងនឹងការប្រកាសលុបចោលស្វ័យភាពនេះត្រូវបានវាយបង្រ្កាបយ៉ាងឃោរឃៅដោយសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវី ។ នៅឆ្នាំ១៩៩០ មានការបោះឆ្នោតសម្តែងការទុកចិត្តនៅក្នុងសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវីយល់ព្រមឲ្យដកហូតស្វ័យភាពពីកូសូវ៉ូ ។ រដ្ឋធម្មនុញ្ញរបស់សាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវីក្នុងសហព័ន្ធយូហ្គោស្លាវី ។ អន្តនីតិបញ្ញត្តិបានប្រកាសថា កូសូវ៉ូជារដ្ឋឯករាជ្យមួយ ។ មានតែប្រទេសអាល់បានីទេដែលទទួលស្គាល់ឯករាជ្យភាពរបស់កូសូវ៉ូចេញពីសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវី ។ នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៩២ មានការបោះឆ្នោតជ្រើសរើសប្រធានាធិបតីនិងរដ្ឋសភានៅកូសូវ៉ូ ។ លោក អ៊ីប្រាហ៊ីម រូហ្គោវ៉ា ត្រូវបានតែងតាំងជាប្រធានាធិបតី ។ លោកត្រូវបានបោះឆ្នោតជ្រើសតាំងសាជាថ្មីនៅថ្ងៃទី ២២ ខែមីនា ឆ្នាំ១៩៩៨ ។



យោធាខ្មែរក្រហម

ត្រូវបានធ្វើវិសោធនកម្ម ហើយសិទ្ធិស្វ័យភាពរបស់ខេត្តនេះក៏ត្រូវលុបចោលតែម្តង ។ រដ្ឋាភិបាលទីក្រុងបែលក្រាដបានបង្កើតឡើងនូវប្រព័ន្ធអប់រំតែមួយ ដោយដាក់កម្រិតឲ្យប្រើប្រាស់តែភាសាអាល់បានីប៉ុណ្ណោះ ។

អន្តនីតិបញ្ញត្តិរបស់កូសូវ៉ា-អាល់បានី បានប្រកាសថាការលុបចោលសិទ្ធិស្វ័យភាពបែបនេះ គឺមិនត្រឹមត្រូវតាមច្បាប់ទេ ហើយនៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៩០ ក៏បានអនុម័តរដ្ឋធម្មនុញ្ញមួយដែលធ្វើឲ្យខេត្តនេះក្លាយជាសាធារណរដ្ឋឯករាជ្យមួយនៅ

វិបត្តិចេះតែស្រួចស្រាល់ទៅៗ ។ នៅដើមឆ្នាំ១៩៩៨ មានកងប្រដាប់អាវុធមួយក្រុមដែលមានឈ្មោះថា "កងទ័ពរំដោះកូសូវ៉ូ" បានធ្វើការវាយប្រហារមកលើរថយន្តកាមីញ៉ុងមួយគ្រឿងដែលដឹកកងកម្លាំងប្រដាប់អាវុធប៉ូលិសសហព័ន្ធយូហ្គោស្លាវី ។ ជាការឆ្លើយតបវិញ ប៉ូលីសស៊ែបបានធ្វើការវាយលុកមកលើទីក្រុងដ្រេនីកាដែលជាតំបន់ការពាររបស់ក្រុមអ្នកបះបោរ បណ្តាលឲ្យមានជនជាតិអាល់បានីបាត់បង់ជីវិតអស់ចំនួន៨០នាក់ ។ នៅចុងខែមីនា ឆ្នាំ១៩៩៨ កងទ័ពរំដោះ

កូសូវ៉ូបានប្រកាសទទួលខុសត្រូវចំពោះការវាយប្រហារទៅលើមុខសញ្ញាជនជាតិស៊ែប ។ នៅខែកក្កដា ឆ្នាំ១៩៩៨ កងទ័ពរំដោះកូសូវ៉ូបានកាន់កាប់ប្រហែលជា១ភាគ៣នៃខេត្តកូសូវ៉ូ ។ ជម្លោះកាន់តែមានលក្ខណៈធ្ងន់ធ្ងរឡើងៗ ហើយក្លាយជាសង្គ្រាមដ៏សន្ធោសន្ធៅមួយ ។

នៅខែកក្កដា ឆ្នាំ១៩៩៨ រីឆាត ហ៊ូលប្រ៊ែនស៍ បេសកជនរបស់សហរដ្ឋអាមេរិកប្រចាំនៅសហភាពអឺរ៉ុប ដែលសម្របសម្រួលធ្វើឲ្យមានកិច្ចខិតខំប្រឹងប្រែងនានាដើម្បីឲ្យមានដំណោះស្រាយប្រកបដោយសន្តិវិធីចំពោះជម្លោះនៅកូសូវ៉ូ ថ្លែងថា "កងទ័ពរំដោះកូសូវ៉ូឥឡូវនេះគឺជាដើមហេតុ" ហើយថា សហគមន៍អន្តរជាតិគួរតែ"ព្យាយាមរារាំងបន្ទុចបន្ទាក់កុំឲ្យកងទ័ពនេះមានមូលដ្ឋានរឹងមាំបាន" ។ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៩៦ លោក រូហ្គោវ៉ា ថ្លែងថា ដំណោះស្រាយវិបត្តិនេះគឺមានលក្ខខណ្ឌទាមទារឯករាជ្យភាពសម្រាប់កូសូវ៉ូ ។ នៅខែសីហា ឆ្នាំ១៩៩៧ សភាសហរដ្ឋអាមេរិកបានអនុម័តសេចក្ដីសម្រេចមួយដោយអំពាវនាវឲ្យជនជាតិភាគតិចអាល់បានីមានការសម្រេចចិត្តដោយខ្លួនឯង ប៉ុន្តែមិនរហូតដល់គាំទ្រឯករាជ្យភាពរបស់កូសូវ៉ូទេ ។ នៅខែមេសា ឆ្នាំ១៩៩៧ ចន ឃនប្លុំ បេសកជនរបស់សហរដ្ឋអាមេរិកប្រចាំនៅយូហ្គោស្លាវី ថ្លែងថា ការទាមទារឯករាជ្យរបស់កូសូវ៉ូមិនបង្ហាញពីផ្លូវដែលអាចសម្រេចសន្តិភាពនៅក្នុងតំបន់នេះបានឡើយ ។

នៅខែមីនា ឆ្នាំ១៩៩៨ សហភាពអឺរ៉ុបទាមទារឲ្យកូសូវ៉ូមានស្វ័យភាពឡើងវិញ ដោយឲ្យខេត្តនេះនៅតែជាផ្នែកមួយរបស់សាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវីដដែល ។ នៅខែឧសភា ឆ្នាំ១៩៩៨ សហគមន៍អន្តរជាតិបានចាប់ផ្តើមចាត់វិធានការដើម្បីកាត់បន្ថយការវាយប្រហាររបស់ពួកស៊ែបមកលើកងទ័ពរំដោះកូសូវ៉ូនិងអំពើភេរវកម្មរបស់កងទ័ពនេះប្រឆាំងនឹងជនជាតិស៊ែប ។ អង្គការណាតូបានធ្វើសមយុទ្ធយោធានៅប្រទេសអាល់បានីនិងម៉ាសេដូនី ។ នៅខែមិថុនា ឆ្នាំ១៩៩៨ មានការដាក់ទណ្ឌកម្មសេដ្ឋកិច្ចមកលើសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវី ។ នៅខែមិថុនា ឆ្នាំ១៩៩៨ដដែល ប្រធានក្រុមប្រឹក្សាសហភាពអឺរ៉ុប លោក រ៉ូប៊ីនឃុក បានព្រមានថា រដ្ឋដែលជាសមាជិកសហភាពអឺរ៉ុបមួយចំនួនកំពុងតែអំពាវនាវឲ្យមានអន្តរាគមន៍ផ្នែកយោធា ។ នៅខែមករា ឆ្នាំ១៩៩៩ មេដឹកនាំសហរដ្ឋអាមេរិកនិងសហភាពអឺរ៉ុប បានជួបប្រជុំគ្នានៅទីក្រុងឡុងដ៍ ហើយបានចេញឱសានវាទមួយកំណត់ថា ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ១៩៩៩ មេដឹកនាំស៊ែបនិងកូសូវ៉ូត្រូវតែឈានដល់កិច្ចព្រមព្រៀងសន្តិភាពមួយជាកំហិត ។ ជំហររបស់សាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវីចំពោះវិបត្តិនេះ គឺថា មួយផ្នែកនៃទឹកដីរបស់ខ្លួនដែលមានអធិបតេយ្យភាពកំពុងតែហៀបបែកចេញពីប្រទេសនេះតាមរយៈការប្រើអំពើហិង្សា ។

នៅក្នុងខណៈពេលនោះ កងទ័ពរំដោះកូសូវ៉ូបានកាន់កាប់ទឹកដីខេត្តកូសូវ៉ូអស់ជាង១ភាគ៣ទៅហើយ ព្រមទាំងបានប្រកាសថាកងទ័ពរំដោះកូសូវ៉ូបដិសេធមិនព្រមចូលតុចរចាឡើយ ។ នៅចុងខែសីហា អភិបាលខេត្តកូសូវ៉ូដែលជាជនជាតិស៊ែបបានត្រៀមខ្លួនផ្តល់សិទ្ធិស្វ័យភាពដល់ខេត្តនេះ ។ នៅក្នុងដំណាក់កាលនេះ រដ្ឋម៉ុងតេណេក្រូដែលជារដ្ឋមួយរបស់សាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវី បានគំរាមកំហែងថានឹងបែកចេញពីសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវី ប្រសិនបើខេត្តកូសូវ៉ូមានស្វ័យភាពឡើងវិញមែននោះ ។ កងទ័ពរំដោះកូសូវ៉ូនិងមេដឹកនាំអាល់បានីបានបដិសេធមិនព្រមប្រគល់ស្វ័យភាពនេះឡើយ ។ នៅខែកក្កដា ឆ្នាំ១៩៩៨ ចាគុប ក្រេសនីឆី ជាអ្នកនាំពាក្យរបស់កងទ័ពរំដោះកូសូវ៉ូ បានបញ្ជាក់ច្បាស់អំពីគោលបំណងរបស់អ្នកបះបោរថា ចលនាប្រដាប់អាវុធនេះគឺកំពុងតែ"ប្រយុទ្ធដើម្បីរំដោះទឹកដីអាល់បានីដែលត្រូវកាន់កាប់...និងការឯកភាពរួបរួមជាមួយអាល់បានី" ។ សេចក្តីថ្លែងការណ៍ដែលធ្វើឡើងស្របគ្នាជាមួយនឹងការកើនឡើងនូវកម្លាំងប្រដាប់អាវុធយោធារបស់កងទ័ពរំដោះកូសូវ៉ូនេះ បណ្តាលឲ្យមានការវាយប្រហារកាន់តែខ្លាំងឡើងៗដោយសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវីក្នុងគោលបំណងកាន់កាប់តំបន់នេះដូចដើមវិញ ។

នៅខែតុលា ឆ្នាំ១៩៩៨ សាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវីបានយល់ព្រមឲ្យមានបេសកកម្មត្រួតពិនិត្យមួយនៅខេត្តកូសូវ៉ូ ហៅថា "*OSCE*" និងមេថូហ៊ីចា (កិច្ចព្រមព្រៀងខែតុលា) ។ ក៏ប៉ុន្តែជម្លោះរវាងភាគីទាំងពីរចេះតែបន្តទៅមុខ ។ ប្រទេសលោកខាងលិចដែលជាអ្នកបង្កើតក្រុមទំនាក់ទំនងមួយក្រុមបានអញ្ជើញ

តំណាងមកពីភាគីទាំងសងខាងទៅជួបប្រជុំគ្នានៅទីក្រុងរ៉ែមប៊ូយេ ប្រទេសបារាំង ដើម្បីពិភាក្សារកដំណោះស្រាយចំពោះវិវាទនេះ ។ យោងតាមសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវី បានឲ្យដឹងថា ការគំរាមកំហែងឥតឈប់ឈររបស់អង្គការណាតូថានឹងប្រើកម្លាំងប្រដាប់អាវុធប្រឆាំងនឹងសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវី គឺជាកត្តាចម្បងដែលជំរុញយុទ្ធនាការកងទ័ពរំដោះកូសូវ៉ូកាន់តែមានសកម្មភាពខ្លាំងក្លាឡើង ។ លទ្ធផលចេញពីការពិភាក្សានៅប្រទេសបារាំងមិនផ្តល់សញ្ញាវិជ្ជមានឡើយ ។ សាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវីជឿជាក់ថា លក្ខខណ្ឌដំណោះស្រាយដែលស្នើឡើងគឺមិនយុត្តិធម៌ ហើយមានលក្ខណៈចាប់បង្ខំដោយក្រុមទំនាក់ទំនង ។ ដូចដែលសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវីនិយាយនៅពេលដាក់សំណុំបែបបទជូនតុលាការអន្តរជាតិថា "ប្រទេសទាំងនេះប៉ុនប៉ងបង្ខំឲ្យទទួលយកគម្រោងគ្រប់គ្រងស្វយ័តដែលរួមមានចំណុចមួយចំនួននិយាយអំពីអធិបតេយ្យភាពនិងដែនសមត្ថកិច្ចហួសហេតុនិងលើសពីអង្គភាពសហព័ន្ធទៅទៀត ។ មិនតែប៉ុណ្ណោះសោត គម្រោងនេះចែងឲ្យមានប្រទេសមួយមើលការខុសត្រូវ និងការពារកូសូវ៉ូនិងមេតូហ៊ីចា ព្រមទាំងមានការកាន់កាប់ផ្នែកយោធាពីសំណាក់កងកម្លាំងប្រដាប់អាវុធយោធារបស់អន្តរជាតិក្រោមការបញ្ជារបស់អង្គការណាតូ ។ គ្មានរដ្ឋណាដែលមិនគោរពខ្លួនឯងដល់ថ្នាក់ទទួលយកនូវសំណើរបៀបនេះទេ" ។

ដោយសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវីមិនព្រមទទួលយកសំណើរបស់ក្រុមទំនាក់ទំនងនេះ គណៈប្រតិភូរបស់សាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវីក៏បានរិះរកផ្លូវផ្តល់ជាសិទ្ធស្វ័យភាពដល់ខេត្តកូសូវ៉ូកាន់តែទូលាយជាងមុន ។ គណៈប្រតិភូបានចុះហត្ថលេខាលើសំណើរបស់ខ្លួនដែលមានចំណងជើងថា "កិច្ចព្រមព្រៀងស្តីអំពីការស្វ័យគ្រប់គ្រងនៅកូម៉េត" ។ ក្រុមទំនាក់ទំនងមិនអាចទទួលយកសំណើនេះទេ ។

អង្គការណាតូចាប់ផ្តើមបញ្ជូនទ័ពនៅក្នុងប្រទេសដែលមានព្រំប្រទល់ជាប់នឹងសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវី ។ ជាការឆ្លើយតបវិញ សាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវីបានបង្កើនកម្លាំងប្រដាប់អាវុធយោធានៅខេត្តកូសូវ៉ូ ។ វិបត្តិចេះតែរីកធំទៅៗ នៅពេលក្រុមបេសកកម្ម"OSCE"សម្រេចចិត្តរំសាយចេញពីកូសូវ៉ូ ដែលជាការបើកផ្លូវឲ្យមានការចូលលុកលុយរបស់អង្គការណាតូ ។ នៅក្នុងសារលិខិតចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៩ ប្រធានក្រុមបេសកកម្ម "OSCE" បានស្តីបន្ទោសទៅលើភាគីទាំងសងខាងថាបានប្រព្រឹត្តអំពើឃោរឃៅនៅកូសូវ៉ូ ដើម្បីឲ្យក្រុមបេសកកម្មនេះដកខ្លួនចេញ ។ លោកមានប្រសាសន៍ថា "សេចក្តីសម្រេចចិត្តរបស់ខ្ញុំត្រូវបានធ្វើឡើងក្រោយពីមានការកើនឡើងអំពើឃោរឃៅនៅកូសូវ៉ូ ហើយអ្នកដែលត្រូវស្តីបន្ទោសគឺកងកម្លាំងប្រដាប់អាវុធយូហ្គោស្លាវីនិងកងទ័ពរំដោះកូសូវ៉ូ ។ ការកសាងកម្លាំងប្រដាប់អាវុធរបស់យូហ្គោស្លាវីនៅកូសូវ៉ូ ដែលជាការរំលោភទៅលើកិច្ចព្រមព្រៀងខែតុលា ទោះជាយ៉ាងណាក៏មិនដល់ថ្នាក់ធ្វើឲ្យសភាពការណ៍កាន់តែដុនដាបទៅៗដែរ ហើយជាកត្តាដ៏សំខាន់បំផុតនៅក្នុងការគិតពិចារណារបស់ខ្ញុំ" ។

អង្គការណាតូបានចាប់ផ្តើមវាយប្រហារមកលើសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវីនៅថ្ងៃទី២៤ ខែមីនា ។ ការវាយប្រហារនេះបណ្តាលឲ្យមានជនស៊ីវិលស្លាប់រហូតដល់១២០០នាក់ និង៤០០០-៥០០០នាក់ទៀតរងរបួសធ្ងន់មួយចំនួននៅក្នុងសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវី ។ ជនជាតិអាល់បានី១ម៉ឺននាក់ត្រូវស្លាប់បាត់បង់ជីវិតនាថ្ងៃបន្ទាប់មកក្នុងអំឡុងពេលនៃការបណ្តេញជនជាតិអាល់បានីចេញពីកូសូវ៉ូពីសំណាក់សាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវី ។ ទ្រព្យសម្បត្តិត្រូវបានបំផ្លិចបំផ្លាញ ហើយជាតិគីមីត្រូវបានបាចពីលើអាកាស ។ មនុស្សរាប់ពាន់នាក់ត្រូវរងរបួស ។ អាវុធហាមឃាត់ត្រូវបានយកមកប្រើប្រាស់ក្នុងការទម្លាក់គ្រាប់បែកនេះ ដូចជាគ្រាប់បែកក្លាស្ទ័រនិងគ្រាប់បែកជាតិអ៊ុយរ៉ានីញ៉ូមដែលធ្វើឲ្យប៉ះពាល់ដល់សុខភាពក្នុងរយៈពេលយូរអង្វែង ។ គួរឲ្យកត់សម្គាល់ដែរថា ចាប់ពីឆ្នាំ១៩៩០ រហូតដល់ការវាយប្រហារតាមផ្លូវអាកាសរបស់អង្គការណាតូមកក្នុងចំណោមមនុស្សចំនួន១៥៤នាក់មាន៨០នាក់ត្រូវបាត់បង់ជីវិតនៅទីក្រុងព្រេទីកា ៥០នាក់នៅប៉ិចថាន ហើយ២៤នាក់ទៀតនៅក្រុងមួយទៀត ។ អ្នកទាំងអស់នេះស្លាប់នៅក្នុងការវាយប្រហាររបស់ក្រុមប៉ូលិសសហព័ន្ធទីក្រុងប៉ែលក្រាដមកលើ

កងទ័ពរំដោះកូសូវ៉ូ ។ យោងតាមរបាយការណ៍របស់អង្គការឃ្លាំមើលផ្នែកសិទ្ធិមនុស្ស"ហ៊ូមែនរ៉ៃថ៍" បានឲ្យដឹងថា ស្ថានការណ៍គាបសង្កត់មិនទាន់ឈានដល់កម្រិត"លុបបំបាត់ជនជាតិភាគតិច" នោះទេ ។

នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៩៩ នៅពេលយុទ្ធនាការរបស់អង្គការណាតូចេះតែបន្តទៅនៅសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវី ប្រទេសនេះបានទៅប្តឹងនៅតុលាការអន្តរជាតិសុំឲ្យបញ្ជាក់ប្រាប់ពីវិធានការបណ្តោះអាសន្នប្រឆាំងនឹងប្រទេសទាំង ១០នៃអង្គការណាតូ ដោយសុំបញ្ជាឲ្យអង្គការណាតូបញ្ឈប់ការទម្លាក់គ្រាប់បែកមកលើសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវី ។ សាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវីចោទប្រកាន់ថា ការប្រើកម្លាំងប្រដាប់អាវុធរបស់អង្គការណាតូគឺខុសច្បាប់ ហើយរំលោភទៅលើធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ និងអនុសញ្ញាស្តីពីការទប់ស្កាត់និងផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។ តុលាការអន្តរជាតិមិនបានវិនិច្ឆ័យក្តីនេះទេ ប៉ុន្តែបែរជានិយាយថារឿងនេះមិនត្រូវនឹងដែនសមត្ថកិច្ចរបស់ខ្លួនទៅវិញ ។ អត្ថបទនេះពិភាក្សាវែកញែកបញ្ហាសំខាន់ថាតើការប្រើកម្លាំងប្រដាប់អាវុធរបស់អង្គការណាតូមិនស្របច្បាប់ឬយ៉ាងណាក្រោមច្បាប់អន្តរជាតិ ។

## II. នីត្យានុកូលភាពនៃការប្រើកម្លាំងប្រដាប់អាវុធក្រោមច្បាប់អន្តរជាតិ

ធម្មនុញ្ញអង្គការសហប្រជាជាតិហាមប្រាមច្បាស់លាស់ណាស់ថា មិនឲ្យប្រើកម្លាំងប្រដាប់អាវុធ ។ មាត្រា២(៤)នៃធម្មនុញ្ញអង្គការសហប្រជាជាតិចែងថា "សមាជិកទាំងអស់ត្រូវតែរក្សាទំនាក់ទំនងអន្តរជាតិរបស់ផងខ្លួនកុំឲ្យមានការគំរាមកំហែង ឬប្រើកម្លាំងប្រដាប់អាវុធប្រឆាំងនឹងបូរណភាពទឹកដី ឬឯករាជ្យភាព ផ្នែកនយោបាយរបស់រដ្ឋនីមួយៗ ឬទង្វើទាំងឡាយណាដែលផ្ទុយទៅនឹងគោលបំណងរបស់អង្គការសហប្រជាជាតិ" ។ មាត្រាទី៣៣នៃធម្មនុញ្ញអង្គការសហប្រជាជាតិតម្រូវឲ្យរដ្ឋជាសមាជិកដោះស្រាយទំនាស់ដោយសន្តិវិធី ។

នៅក្នុងទម្រង់ការងាររបស់អង្គការសហប្រជាជាតិសព្វថ្ងៃក្នុងជំពូកVIIនៃធម្មនុញ្ញ មានតែក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិទេដែលមានអំណាចក្នុងការអនុញ្ញាតឲ្យមានការប្រើកម្លាំងប្រដាប់អាវុធ ។ ការរៀបចំជាលក្ខណៈតំបន់ឬជាភ្នាក់ងារផ្សេងៗ ប្រហែលជាអាចប្រើសម្រាប់អនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខនិងសម្រាប់ចាត់ការដោយផ្ទាល់តាមផ្លូវច្បាប់ ។ ប៉ុន្តែយោងតាមមាត្រា៥៣នៃធម្មនុញ្ញអង្គការសហប្រជាជាតិ "ចំណាត់ការបែបនេះមិនមែនត្រូវរៀបចំឡើងក្រោមការចាត់ចែងថ្នាក់តំបន់ឬភ្នាក់ងារតំបន់ដោយគ្មានការអនុញ្ញាតពីក្រុមប្រឹក្សាសន្តិសុខឡើយ" ។ ជាងនេះទៀត មាត្រា១០៣នៃធម្មនុញ្ញអង្គការសហប្រជាជាតិចែងថា "ក្នុងករណីមានការប្រទាំងប្រទើសគ្នា មិនច្បាស់លាស់រវាងកាតព្វកិច្ចរបស់រដ្ឋជាសមាជិករបស់អង្គការសហប្រជាជាតិតាមធម្មនុញ្ញបច្ចុប្បន្ន ជាមួយនឹងកាតព្វកិច្ចក្នុងកិច្ចព្រមព្រៀងអន្តរជាតិណាមួយនោះ កាតព្វកិច្ចរបស់រដ្ឋសមាជិកទាំងនោះផ្លូវតែត្រូវជ្រើសរើស គឺកាតព្វកិច្ចរបស់រដ្ឋជាសមាជិកតាមធម្មនុញ្ញបច្ចុប្បន្ន" ។ ជាការទទួលស្គាល់កាតព្វកិច្ចដែលត្រូវជ្រើសរើសនេះ មាត្រា៧នៃសន្ធិសញ្ញាបង្កើតអង្គការណាតូឆ្នាំ១៩៤៩ចែងថា "សន្ធិសញ្ញានេះមិនមានផលប៉ះពាល់ ហើយក៏មិនអាចយកទៅបកស្រាយតាមផ្លូវច្បាប់ថាឲ្យប៉ះពាល់ដល់សិទ្ធិនិងកាតព្វកិច្ចក្រោមធម្មនុញ្ញរបស់ភាគីដែលជាសមាជិករបស់អង្គការសហប្រជាជាតិ ឬការទទួលខុសត្រូវដ៏សំខាន់នៃក្រុមប្រឹក្សាសន្តិសុខក្នុងការថែរក្សាសន្តិភាពនិងសន្តិសុខអន្តរជាតិដែរ" ។

នៅឆ្នាំ១៩៧៤ មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តសេចក្តីសម្រេចលេខ៣៣១៤(XXIX)បញ្ជាក់សាជាថ្មីអំពីគោលការណ៍នៃការហាមឃាត់ការប្រើប្រាស់កម្លាំងប្រដាប់អាវុធដោយគូសបញ្ជាក់ថា "ទោះជាការគិតពិចារណានោះមានចរិតនយោបាយ សេដ្ឋកិច្ច យោធា ឬអ្វីក៏ដោយ ក៏មិនអាចយកមកធ្វើជាហេតុផលសម្រាប់ការឈ្លានពានដែរ" ។ តុលាការអន្តរជាតិបញ្ជាក់ម្តងទៀត អំពីគោលការណ៍មិនជ្រៀតជ្រែកគ្នាដែលបានកើតឡើងរវាងប្រទេសនីហ្ការ៉ាហ្គ័រនិងសហរដ្ឋអាមេរិក ជារឿងក្តីក្តាំដែលតុលាការអន្តរជាតិបើកសវនាការជំនុំជម្រះនៅក្នុងឆ្នាំ១៩៨៦ ។ ក្នុងរឿងក្តីនេះ សហរដ្ឋអាមេរិកបានដកសមាជិកភាពរបស់ខ្លួនពីតុលាការអន្តរជាតិប្រហែលមកពី

ខ្លាចចាញ់ក្តី ។ ប៉ុន្តែនៅទីបំផុតអាមេរិកចាញ់ទាល់តែបាន ។ តុលាការអន្តរជាតិបានចេញបញ្ជាបណ្តោះអាសន្នមួយ ស្នើឲ្យសហរដ្ឋអាមេរិកបញ្ឈប់ការវាយប្រហារទៅលើប្រទេសនីការ៉ាហ្គ័រ ហើយបានថ្លែងថា ÷

«ក្នុងខណៈដែលសហរដ្ឋអាមេរិកប្រហែលជាធ្វើការវាយតម្លៃលើស្ថានការណ៍ទាក់ទងនឹងសិទ្ធិមនុស្សនៅប្រទេសនីការ៉ាហ្គ័រ ការប្រើកម្លាំងប្រដាប់អាវុធមិនមែនជាវិធីសមរម្យក្នុងការត្រួតពិនិត្យឬធានាការគោរពសិទ្ធិមនុស្សឡើយ ។ តាមវិធានការដែលអនុវត្តកន្លងមក ការការពារសិទ្ធិមនុស្សដែលជាគោលដៅផ្នែកសិទ្ធិមនុស្ស មិនត្រូវគ្នាទៅនឹងការដាក់មីនកម្ទេចកំពង់ផែដែលជាការបំផ្លាញដំណើរការតម្លើងប្រេង ឬមិនត្រូវគ្នាទៅនឹងផលចំណេញដោយមានការហ្វឹកហាត់ ការបំពាក់អាវុធ និង ប្រដាប់ប្រដាផ្សេងៗទៀតឲ្យក្រុមប្រឆាំងបដិវត្តនៅនីការ៉ាហ្គ័រទេ ។ តុលាការបានទាញសន្និដ្ឋានថា អាមេរិកប្រើទឡ្ហីករណ៍ថាទង្វើរបស់ខ្លួនគឺសម្រាប់ការពារសិទ្ធិមនុស្សនោះជាការមិនសមហេតុផលតាមផ្លូវច្បាប់ទេ» ។

ទេះតែពង្រីកការយល់ព្រមឲ្យប្រើច្បាប់អន្តរជាតិច្រើនជាងការអនុញ្ញាតឲ្យប្រើកម្លាំងប្រដាប់អាវុធសម្រាប់ការពារខ្លួនអាចនាំដល់ការប្រើកម្លាំងប្រដាប់អាវុធដោយហេតុផលនយោបាយឬសេដ្ឋកិច្ច។ លោកសាស្ត្រាចារ្យ ស្កាចឈ័រ បានមានប្រសាសន៍ថា «ច្បាប់អន្តរជាតិមិនគួរអនុញ្ញាតឲ្យប្រើកម្លាំងប្រដាប់អាវុធឆ្លងប្រទេសឡើយ លើកលែងតែករណីការពារខ្លួនតែប៉ុណ្ណោះ (រួមទាំងការការពារខ្លួនជាលក្ខណៈរួមគ្នាផង) និងវិធានការអនុវត្តច្បាប់ដែលចេញបញ្ជាដោយក្រុមប្រឹក្សាសន្តិសុខ ។ ទាំងសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ ឬការសម្រេចចិត្តដោយខ្លួនឯង មិនអាចទទួលយកបានថាជាហេតុផលក្នុងការធ្វើសង្គ្រាមទេ ហើយក៏មិនមែនជាមូលហេតុត្រឹមត្រូវតាំងពីដើមរៀងអាយមកក្នុងការធ្វើឲ្យរឿងខុសទៅជាត្រូវដែរ ។ ការសន្និដ្ឋានបែបនេះមិនត្រឹមតែស្របទៅនឹងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិដូចដែលអ្នកផងយល់ជាទូទៅនោះទេ ប៉ុន្តែថែមទាំងស្របទៅនឹងការបកស្រាយតាមផ្លូវច្បាប់ដែលយល់ព្រមដោយមតិរដ្ឋភាគច្រើននាពេលបច្ចុប្បន្នទៀតផង» ។

## ការហាមប្រាមមិនឲ្យមានការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុង

មាត្រាទី២(៧) នៃធម្មនុញ្ញអង្គការសហប្រជាជាតិហាមប្រាមមិនឲ្យមានការជ្រៀតជ្រែករបស់រដ្ឋជាសមាជិកទៅក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋដែលមានអធិបតេយ្យភាពទេ ។ បម្រាមនេះពង្រីកខ្លួនកាន់តែខ្លាំងឡើងនៅក្នុងអង្គការសហប្រជាជាតិផ្ទាល់ ។ អង្គការសហប្រជាជាតិមិនអាច«ធ្វើអន្តរាគមន៍ក្នុងរឿងទាំងឡាយណាដែលសំខាន់ពាក់ព័ន្ធនឹងដែនសមត្ថកិច្ចក្នុងស្រុករបស់រដ្ឋមួយទេ» ។ គោលការណ៍នេះត្រូវបានបញ្ជាក់ជាថ្មីម្តងទៀតនៅក្នុងសេចក្តីប្រកាសរបស់មហាសន្និបាតអង្គការសហប្រជាជាតិស្តីពីគោលការណ៍នៃច្បាប់អន្តរជាតិទាក់ទងនឹងទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងរដ្ឋដោយយោលទៅតាមធម្មនុញ្ញរបស់អង្គការសហប្រជាជាតិឆ្នាំ១៩៧០÷

«គ្មានរដ្ឋឬក្រុមរដ្ឋណាមួយមានសិទ្ធិធ្វើអន្តរាគមន៍ទៅក្នុងកិច្ចការអន្តរជាតិឬកិច្ចការក្រៅប្រទេសរបស់រដ្ឋដទៃឡើយ ទោះជាដោយផ្ទាល់ឬប្រយោលក្តី ដោយមូលហេតុអ្វីក៏ដោយ ។ ការធ្វើអន្តរាគមន៍ប្រដាប់អាវុធ និងការធ្វើអន្តរាគមន៍ក្នុងទម្រង់ផ្សេងៗទៀត ឬការគំរាមកំហែងដោយមានចេតនាមកលើបុគ្គលិកលក្ខណៈរបស់រដ្ឋឬមកលើកត្តានយោបាយ សេដ្ឋកិច្ច និងវប្បធម៌ សុទ្ធតែជាការរំលោភលើច្បាប់អន្តរជាតិទាំងអស់» ។

**(នៅមានត)** **ធុច ប៊ុរ៉ា**

## ពាក្យស្លោកខ្មែរក្រហម

◆ **ចក្រពត្តិនិយមវាខ្លាំងតែសំបកក្រៅ តែភាពខាងក្នុងខ្សោយ ពីព្រោះប្រជាជនមិនគាំទ្រវា។**

◆ **អ្នកណាជាសត្រូវរបស់យើង អ្នកណាជាមិត្តរបស់យើង បញ្ហានេះជាបញ្ហាសំខាន់របស់បដិវត្តន៍យើង។**

◆ **យើងសង្ឃឹមសន្តិភាព ប៉ុន្តែចក្រពត្តិនិយមរឹងរូសច្បាំងគេ យើងដាច់ខាតមិនចុះចាញ់ ធ្វើសង្គ្រាមហើយចាំកសាង។**

*(កំណត់ហេតុរបស់សមមិត្ត ញ៉ុក សារុន)*

◆ **ទុកឲ្យកំពតប៉ោងតាមចិត្ត ដល់កាលណាបែកពោះ វាឈប់ប៉ោង។** *(សៀវភៅកំណត់ហេតុរបស់សមមិត្ត ញ៉ុក សារុន)*

# ច្បាប់ព្រហ្មទណ្ឌអន្តរជាតិគ្មានបំណងជំនួស ច្បាប់ព្រហ្មទណ្ឌក្នុងស្រុកទេ

មានមតិយោបល់ចម្រុះៗ និងការពិភាក្សាវែកញែកជាច្រើនទៅលើបញ្ហាថាតើការសម្លាប់ដែលចូលក្នុងបទព្រហ្មទណ្ឌ និងឧក្រិដ្ឋផ្សេងៗទៀតដែលប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នឹងត្រូវយកមកជំនុំជម្រះក្តីពីបទប្រល័យពូជសាសន៍ក្រោមអនុសញ្ញាប្រល័យពូជសាសន៍ឆ្នាំ១៩៤៨ ឬពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមច្បាប់ទម្លាប់អន្តរជាតិ ឬផ្អែកលើបទដ្ឋានច្បាប់ទាំងពីរយ៉ាងនេះ ឬមួយមិនយកទាំងពីរ ។ ដោយសារតុលាការកាត់ទោសខ្មែរក្រហមនឹងត្រូវធ្វើឡើងក្នុងអង្គជំនុំជម្រះនៃតុលាការក្នុងស្រុកដែលគ្មានដែនសមត្ថកិច្ចលើបទឧក្រិដ្ឋកម្ម អត្ថបទពិភាក្សានេះនឹងផ្តល់នូវការសិក្សាយ៉ាងមានសារសំខាន់ ។

«ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍» និង «ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ» គឺជានិទ្ទេសបទច្បាប់ដែលត្រូវបានបង្កើតឡើងសម្រាប់ផ្តល់នូវមូលដ្ឋានច្បាប់ដើម្បីឲ្យតុលាការបរទេសពិចារណាថាតើជាដែនសមត្ថកិច្ចនៃតុលាការក្នុងស្រុកឬអន្តរជាតិទៅលើបទឧក្រិដ្ឋកម្មដែលច្បាប់ទម្លាប់អន្តរជាតិមិនទាន់ជជែកវែកញែករកបញ្ហាឲ្យបានត្រឹមត្រូវ ក្នុងគោលបំណងចៀសវាងនូវការកាត់សេចក្តីក្រោមទ្រឹស្តីអធិបតេយ្យភាពជាតិ ។ ក្នុងករណីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែនសមត្ថកិច្ចកើតចេញពីការទទួលយករបស់រដ្ឋមួយនូវអនុសញ្ញាអន្តរជាតិដែលចែងពីបទឧក្រិដ្ឋនេះ ។ ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិវិញ ដែលជាការប្រឌិតឡើងតាមផ្លូវច្បាប់នូវតម្រូវការនៃ «សម្ព័ន្ធជម្លោះប្រដាប់អាវុធ» គឺត្រូវបានបង្កើតឡើងដោយតុលាការនៅនូរិមប៊ឺក ក្នុងគោលបំណងដើម្បីបង្ហាញឲ្យឃើញច្បាស់នូវការអនុវត្តដែនសមត្ថកិច្ចរបស់តុលាការនេះទៅលើអំពើមនុស្សឃាត និងការធ្វើបាបពលរដ្ឋអាល្លឺម៉ង់ដោយរដ្ឋាភិបាលខ្លួនក្នុងរបបណាហ្ស៊ី ។ កាលនោះសម្ព័ន្ធមួយត្រូវបានបង្កើតឡើងរវាងឧក្រិដ្ឋកម្មទាំងនោះ (ដែលនៅក្រោមទ្រឹស្តីជាប្រពៃណីនៃអធិបតេយ្យជាតិ ជាផ្នែកតែមួយគត់នៅក្នុងការជម្រះក្តីដោយតុលាការអាល្លឺម៉ង់មួយដែលគ្រាន់ទុកជាស្រេច) ជាមួយនិងឧក្រិដ្ឋកម្មសង្គ្រាមដែលប្រព្រឹត្តដោយពួកណាហ្ស៊ីនៅក្នុងសង្គ្រាមឈ្លានពាន ហើយត្រូវបានតុលាការនូរិមប៊ឺកសម្រេចថាខ្លួនមានមូលដ្ឋានច្បាប់គ្រប់គ្រាន់សម្រាប់ពង្រីកនូវដែនសមត្ថកិច្ចរបស់ខ្លួនទៅលើឧក្រិដ្ឋកម្មទាំងពីរ គឺឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។

គោលបំណងនិងហេតុផលក្នុងការក្តោបយកទាំងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិគឺជាតម្រូវការចាំបាច់ក្នុងការបង្កើតដែនសមត្ថកិច្ចទៅលើអំពើព្រហ្មទណ្ឌទាំងឡាយណាដែលត្រូវបានខំស្វែងរកយកមកកាត់ទោស ។ ជាទូទៅ (មានតែករណីលើកលែងតិចតួចប៉ុណ្ណោះ) ក្រោមច្បាប់របស់អារ្យប្រទេស គ្មានការធ្វើឲ្យអំពើស្របច្បាប់ទៅជាអំពើមិនស្របច្បាប់នោះទេ ។ បញ្ហាដែលត្រូវដោះស្រាយដោយនិទ្ទេសបទច្បាប់ទាំងពីរនេះគឺកង្វះឆន្ទៈនយោបាយ ឬសមត្ថភាពរបស់រដ្ឋក្នុងការផ្តល់យុត្តិធម៌ចំពោះការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរដែលត្រូវបានប្រព្រឹត្តឡើងក្នុងវង្វង់ដែនសមត្ថកិច្ចរបស់រដ្ឋនោះ (ឬដោយស្នាដៃពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចផ្សេងមួយទៀត) ។ ក្នុងករណីតុលាការខ្មែរក្រហមនាពេលខាងមុខនេះ គ្មានបញ្ហាអំពីរឿងដែនសមត្ថកិច្ចនៃបទឧក្រិដ្ឋកម្មទាំងពីរនេះឡើយ ។ អង្គជំនុំជម្រះនឹងធ្វើឡើងក្នុងតុលាការកម្ពុជា ដើម្បីកាត់ទោសជនទាំងឡាយណាដែលបានប្រព្រឹត្តបទឧក្រិដ្ឋកម្មនៅក្នុងប្រទេសកម្ពុជា ។

ជាឧទាហរណ៍បញ្ជាក់ពីហេតុផលកើតមានឯកឯងនៃការយកបទឧក្រិដ្ឋកម្មអន្តរជាតិមកដោះស្រាយតាមកម្រិតក្នុងស្រុក គឺថា ហេតុផលមួយអាចកត់សម្គាល់អំពីភាពមិនសមហេតុផល

ក្នុងការបដិសេធដែនសមត្ថកិច្ចដោយប្រគល់ឲ្យតុលាការជាតិក្នុងស្រុកមានអំណាចទៅលើបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិដែលប្រព្រឹត្តឡើងនៅក្នុងវង្វង់ដែនសមត្ថកិច្ចរបស់ខ្លួន ។ ភាពមិនសមហេតុសមផលត្រង់ថាឧក្រិដ្ឋកម្មទាំងនោះមិនមែនប្រព្រឹត្តឡើងនៅក្នុងសម្ព័ន្ធភាពជម្លោះប្រដាប់អាវុធជាលក្ខណៈអន្តរជាតិ ។ គោលបំណងនៃតម្រូវការ "សម្ព័ន្ធភាពជម្លោះប្រដាប់អាវុធ" ក្នុងការកាត់សេចក្តីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិគឺដើម្បីបង្កើតជាមូលដ្ឋានឲ្យមានដែនសមត្ថកិច្ចរបស់តុលាការអន្តរជាតិ ។ នេះហើយដែលបណ្តាលឲ្យមានការបដិសេធដែនសមត្ថកិច្ចរបស់តុលាការនៃរដ្ឋដែលបទល្មើសបានកើតឡើង មានន័យថាតុលាការក្នុងស្រុកមិនអាចកាត់សេចក្តីទៅលើឧក្រិដ្ឋកម្មអន្តរជាតិបានទេ ហើយការណ៍ដែលនៅតែអនុវត្តយ៉ាងដូច្នេះ បទល្មើសព្រហ្មទណ្ឌនឹងក្លាយជាបទល្មើសមិនស្របច្បាប់ ។ ទោះជាយ៉ាងណាក៏ដោយក៏អាចកត់សម្គាល់ឃើញថា អនុលោមតាមច្បាប់កាត់ទោសខ្មែរក្រហមដែលបានអនុម័តរួចហើយ អង្គជំនុំជម្រះវិសាមញ្ញត្រូវបានផ្តល់នូវដែនសមត្ថកិច្ចទៅលើគ្រប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលប្រព្រឹត្តឡើងនៅប្រទេសកម្ពុជានៅក្នុងរយៈពេលវេលាដែលកំណត់ច្បាស់រួចហើយ ។ ដោយសារតែតម្រូវការ "សម្ព័ន្ធភាពជម្លោះប្រដាប់អាវុធ"ទាក់ទងតែទៅនឹងដែនសមត្ថកិច្ច ហើយមិនបង្កើតជាធាតុផ្សំសំខាន់សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចដែលចែងនៅឯតុលាការនូរិមប៊ឺកតម្រូវការនេះមិនអាចអនុវត្តបាននៅក្នុងតុលាការក្នុងស្រុកឡើយទោះបីជាក្នុងរយៈពេលនោះវានៅមានឬមិនមានសុពលភាពក៏ដោយ ។

ការដែលថាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនិងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ត្រូវបានបញ្ចូលនៅក្នុងច្បាប់កាត់ទោសខ្មែរក្រហមរួចហើយនោះ គឺប្រហែលជាបណ្តាលមកពីកត្តាពីរយ៉ាង÷ ទី១) សេចក្តីសង្ឃឹមកាលពីមុនថានឹងបង្កើតតុលាការអន្តរជាតិដែលរៀបចំធ្វើឡើងក្រៅដែនសមត្ថកិច្ចរបស់ប្រទេសកម្ពុជាដែលតាមវិធីនេះតម្រូវឲ្យយកមកប្រើនូវឧក្រិដ្ឋកម្មអន្តរជាតិទាំងនេះដើម្បីបង្កើតបានជាដែនសមត្ថកិច្ច ។ ទី២គំនិតគួរឲ្យសោកស្តាយដែលបានផ្សព្វផ្សាយដោយអ្នកសិក្សាជាន់ខ្ពស់ និងអ្នកជំនាញការច្បាប់ជាច្រើនរូបដែលថាការសម្លាប់មានលក្ខណៈធំធេងដោយឡែកខុសគេរបៀបនេះ បើតាមនិយមន័យគឺវាមានភាពយង់ឃ្នងជាងអំពើដទៃៗទៀត ។ (ចំណែកឯការអនុវត្តអាជ្ញាយុកាលច្បាប់ដែលមានរយៈពេល១០ឆ្នាំតាមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ប្រហែលជាបានផ្តល់នូវសន្ទុះឲ្យរួមបញ្ចូលប្រភេទឧក្រិដ្ឋកម្មអន្តរជាតិទាំងនេះចូលទៅក្នុងច្បាប់កាត់ទោសខ្មែរក្រហម ដែលច្បាប់នេះពង្រីកដែនអាជ្ញាយុកាលដើម្បីដោះស្រាយបញ្ហានេះឲ្យទៅរួច) ។

បើមិនគិតពីអធិបតេយ្យជាតិវិញជាការចាំបាច់ណាស់គឺត្រូវកំណត់ឲ្យច្បាស់លាស់នូវដែនសមត្ថកិច្ចភូមិសាស្ត្រ បុគ្គលដែលអាចយកមកប្រើនៅក្នុងករណីព្រហ្មទណ្ឌ ។ លទ្ធផលដ៏អាក្រក់មួយនឹងកើតមានប្រសិនបើអាចទាយទុកមុនបានថា ប្រភេទឧក្រិដ្ឋកម្មទាំងនោះដែលត្រូវបានគិតថាមានទំហំធំគ្រប់គ្រាន់ដែលនាំឲ្យប្រមាថដល់អធិបតេយ្យភាពជាតិនោះត្រូវបានកំណត់ច្បាស់តាមផ្លូវនយោបាយនិងផ្លូវច្បាប់ ។ ប្រសិនបើគ្មានការសម្លាប់ទ្រង់ទ្រាយណាមួយកើតឡើងក្នុងចំនួនច្រើនដែលស្របនឹងនិយមន័យទាំងអស់នេះទេ ជនរងគ្រោះនឹងមានអារម្មណ៍ថាខ្លួនមិនបានទទួលបានយុត្តិធម៌ពេញលេញឡើយ ។ ការពិភាក្សាយ៉ាងសង្ខេបទាក់ទងនឹងបញ្ហាថាតើគំរូនៃបទមនុស្សឃាតដែលមានការរៀបចំទុកជាមុននិងមានទ្រង់ទ្រាយធំ ចាត់ចូលជាអំពើប្រល័យពូជសាសន៍ឬឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែរឬទេ ហើយដែលអាចយល់បានតាមផ្លូវច្បាប់នោះនៅមិនទាន់ជួយអ្វីបាននៅឡើយទាក់ទងនឹងបញ្ហានេះ ។

ការធ្វើបេះធ្វើដឹងជ្រុលរបៀបនេះគឺបណ្តាលមកពីមួយផ្នែកនៃហេតុផលថាកត្តាខាងលើដែលជំរុញឲ្យមានអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមិនត្រូវបានអ្នកណាម្នាក់មើលឃើញ ។ ការដែលថាសហគមន៍អន្តរជាតិយល់ឃើញថាការកំណត់និទ្ទេសបទច្បាប់ទាំងនេះជាការចាំបាច់ដោយហេតុផលនយោបាយនោះ មិនគួរយើងផ្តល់សារសំខាន់ឲ្យដូចជាអ្វីដែលអ្នកសិក្សាជាន់ខ្ពស់និងអ្នកធ្វើអត្ថាធិប្បាយបានផ្តល់ឲ្យទេ ។ ការណ៍ដែលបញ្ហារំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរដែលធ្វើឡើងក្រោមរបបកម្ពុជាប្រជាធិបតេយ្យទំនងជាមិនស្របនឹងការកំណត់និយមន័យនៃបទឧក្រិដ្ឋកម្មអន្តរជាតិមួយឬទាំងពីរ

គឺជាហេតុនាំឲ្យមានការឆក់ឱកាសផ្នែកនយោបាយរបស់អន្តរជាតិបាន ហើយគ្មានការទាក់ទងទៅនឹងភាពមិនស្មោះត្រង់តាមផ្លូវសីលធម៌ ដែលមានន័យស្មើនឹងករណីដ៏អាក្រក់ដែលអាចនឹងស្រមៃដល់ ។ ករណីដ៏អាក្រក់នេះអាចធ្វើឲ្យអំពើប្រល័យពូជសាសន៍ឬខក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិស្របនឹងនិយមន័យដោយពេញលក្ខណៈច្បាប់ ។

មានការលើកឡើងថា នៅក្នុងតុលាការជំនុំជម្រះក្តីខ្មែរក្រហមនាពេលខាងមុខនេះ ច្បាប់ព្រហ្មទណ្ឌសារធាតុរបស់កម្ពុជាដែលមានសុពលភាពក្នុងពេលដែលមានការប្រព្រឹត្តខក្រិដ្ឋកម្មទាំងនេះ នឹងមានលក្ខណៈគ្រប់គ្រាន់ក្នុងការផ្តល់នូវការទទួលស្គាល់តាមច្បាប់ចំពោះអ្នកដែលបានប្រព្រឹត្តអំពើអ្វីដែលហៅថា "អំពើប្រល័យពូជសាសន៍កម្ពុជា" នោះ ។ ជាងនេះទៅទៀតជាការសមស្របនិងសមរម្យហើយដែលភាគីទទួលខុសត្រូវគួរតែនាំមកកាត់ទោសដោយយោងតាមច្បាប់ដែលជនល្មើសរំលោភ ។ ចំពោះអ្នកដែលទទូចហើយទទូចទៀត ចង់ឲ្យបទខក្រិដ្ឋកម្មប្រល័យពូជសាសន៍និងខក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មានកម្រិតខ្ពស់ជាគំរូមនុស្សឃាតកន្លងមក ដែលអាចនឹងត្រូវបាននឹកស្រមៃដល់នោះ ខ្ញុំសូមនិយាយថាអ្នកទាំងនោះធ្វើទោសច្រើនជាងធ្វើគុណ ។ ដូចដែលបុគ្គលមួយចំនួនបានធ្វើការកត់សម្គាល់រួចមកហើយថា ការណ៍ដែលថាយើងកំពុងធ្វើដំណើរឆ្ពោះទៅពិភពមួយឥតខ្ចោះនិងលែងមានអំណាចនយោបាយរដ្ឋាភិបាលឬអង្គភាពដែលនឹងទទួលយកដើម្បីគាបសង្កត់និងរំលោភយ៉ាងធ្ងន់ធ្ងរដល់មនុស្សជាតិមួយផ្នែកដែលខ្លួនបានប្រព្រឹត្តមកលើដោយសារអំណាចរបស់ខ្លួន ។ គ្មានអ្វីគួរឲ្យសង្ស័យទេថា ដំណើរវិកចម្រើនឆ្ពោះទៅរករដ្ឋមួយដែលធ្វើការផ្សារដ៏ល្អប្រពៃបែបនេះ កន្លងមកត្រូវបានបន្ថែមល្បឿនតាមរយៈការអនុវត្តដែនសមត្ថកិច្ចព្រហ្មទណ្ឌក្នុង "ទម្រង់ភូមិសាស្ត្របន្ថែម" ទៅលើបញ្ហាដែលត្រូវបានផ្ញើទុកក្នុងរឿងអធិបតេយ្យភាពជាតិ ។ ប៉ុន្តែការពឹងផ្អែកតែទៅលើដែនសមត្ថកិច្ចអន្តរជាតិនិងច្បាប់ព្រហ្មទណ្ឌសារធាតុ ពិតជាគ្មានផ្លូវណាអាចគ្រប់គ្រងយុត្តិធម៌ឲ្យមានកម្រិតខ្ពស់តាមរយៈការអនុវត្តច្បាប់ព្រហ្មទណ្ឌសារធាតុក្នុងស្រុកបានឡើយ នៅក្នុងដែនសមត្ថកិច្ចមួយដែលអ្នកចាត់ចែងដំណើរការនីតិវិធីជាអ្នកទទួលខុសត្រូវចំពោះមនុស្សដែលបានទទួលរងនូវអំពើខក្រិដ្ឋកម្មដែលកំពុងពិភាក្សានេះ ។ និយាយឲ្យខ្លី បទខក្រិដ្ឋកម្មទាំងនេះមិនមែនជាខក្រិដ្ឋកម្មដែលមានការរៀបចំឡើង ហើយក៏មិនមែនមានចេតនាចង់ជំនួសច្បាប់ក្នុងស្រុកនៅក្នុងតុលាការជាតិដែលបង្កើតឡើងត្រឹមត្រូវនោះដែរ ប៉ុន្តែមានបំណងធ្វើជាវិធានការបណ្តោះអាសន្នមួយដែលខ្វះឆន្ទៈនយោបាយដែលមានលក្ខណៈចាំបាច់ក្នុងការដាក់ទណ្ឌកម្មលើអំពើឃោរឃៅរំលោភសិទ្ធិមនុស្សជាលក្ខណៈក្នុងស្រុក ។

ប៉ុន្តែគួរឲ្យសោកស្តាយ មានបុគ្គលមួយចំនួនធ្វើការខាងច្បាប់អន្តរជាតិនិងសិទ្ធិមនុស្ស មានចេតនាចង់ឃើញព្រឹត្តិការណ៍សព្វថ្ងៃមានការផ្លាស់ប្តូរស្រឡះ ហើយឲ្យគេដាក់ដែនសមត្ថកិច្ចចំពោះអំពើរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរទៅក្នុងការិយាធិបតេយ្យច្បាប់ដែលជាលំដាប់និងរហូតតទៅ ដោយគ្មានការទាក់ទងនឹងព្រឹត្តការណ៍ដែលកំពុងតែពិភាក្សានេះទៅវិញ ហើយគ្មានការទទួលខុសត្រូវចំពោះអ្នកដែលទទួលផលប៉ះពាល់ពីអំពើទាំងនេះ ។ មកដល់ពេលនេះយើងបានព្រះសេចក្តីប្រកាសមួយចំនួនដែលថាព្រឹត្តិការណ៍ថ្មីៗនេះដែលកើតឡើងនៅសភាពាណិជ្ជកម្មពិភពលោកនៅទីក្រុងញូវយ៉ក គឺជា "ខក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ" ដែលចាំបាច់ត្រូវតែមានការជម្រះក្តីជាអន្តរជាតិនិងយកជាការបាន ។ ខ្ញុំជឿជាក់ថា ខ្ញុំនិយាយនេះគឺជួសមុខឲ្យប្រជាជនភាគច្រើនដែលរស់នៅទីក្រុងញូវយ៉ក ។ ខ្ញុំសូមនិយាយថា ទីក្រុងញូវយ៉កគឺជាកន្លែងដែលមានដែនសមត្ថកិច្ចសមស្របតែមួយគត់សម្រាប់កាត់ទោសមេគំនិតដែលបានសម្លាប់មនុស្សអស់ ៥ពាន់នាក់ បន្ថែមទៅលើមនុស្សឃាតតាមវិធីធម្មតានិងហួសសម័យមួយចំនួនទៀត ។

ជាការគួរឲ្យកត់សម្គាល់ណាស់ទៅលើបញ្ហាថាតើមូលហេតុនេះបាត់ស្រមោលក្នុងល្បឿនប៉ុនណាក្នុងខណៈដែលច្បាប់អនុម័តនៅទីក្រុងរ៉ូមដែលបង្កើតបានជាតុលាការអន្តរជាតិធ្វើការសង្កត់ធ្ងន់ថាតុលាការនេះកំពុងត្រូវបានបង្កើតឡើងដើម្បីដោះស្រាយសភាពការណ៍នានា ដែលក្នុងនោះរដ្ឋាភិបាលរបស់រដ្ឋដែលមានអំពើរំលោភសិទ្ធិមនុស្សកើតឡើងមិនចង់ឬមិនមានលទ្ធភាពបើកសវនាការជំនុំជម្រះបទខក្រិដ្ឋកម្មដែលលើកមក

ពិភាក្សានេះ ។

យើងកំពុងតែព្រួយបារម្ភពីការកាត់សេចក្ដីអន្តរជាតិដែលហាក់បីដូចជាត្រូវបានធ្វើឡើងក្នុងគោលបំណងរារាំងរដ្ឋនានាមិនឲ្យកាត់សេចក្ដីបទល្មើសដែលប្រព្រឹត្តឡើងនៅក្នុងវេនដែនសមត្ថកិច្ចរបស់ខ្លួន ។ គ្មានអ្វីគួរឲ្យជឿងឆ្ងល់ទេថា អ្នកគាំទ្រតុលាការអន្តរជាតិមួយចំនួនកំពុងតែចាប់ផ្ដើមយល់ថាប្រទេសនានាដែលគ្មានឆន្ទៈកាត់សេចក្ដីការអំពើរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរដែលធ្វើឡើងនៅក្នុងវេនដែនសមត្ថកិច្ចរបស់ខ្លួននោះក៏ហាក់ដូចជាគ្មានឆន្ទៈប្រគល់ជនជាប់សង្ស័យឲ្យតុលាការព្រហ្មទណ្ឌអន្តរជាតិដែរ ។ គួរឲ្យកត់សម្គាល់អំពីការគាំទ្រដ៏រីករាយរបស់រដ្ឋាភិបាលកម្ពុជាចំពោះតុលាការព្រហ្មទណ្ឌអន្តរជាតិ ។ តើមានអ្នកណាម្នាក់គិតថារដ្ឋាភិបាលកម្ពុជាអាចប្រគល់ខ្លួន អៀង សារី នួន ជា ឬ ខៀវ សំផន ឲ្យទៅតុលាការព្រហ្មទណ្ឌអន្តរជាតិដែរឬទេ?

**វ៉ាមិន ចូហាន់សាន់**

# ភាពខុសគ្នារវាង "ឈ្មោះក្លែង" និង "ឈ្មោះហៅក្រៅ"

◆◆◆ "ឈ្មោះក្លែង" (alias) គឺគ្រាន់តែជាឈ្មោះសន្មតប៉ុណ្ណោះ ក៏ប៉ុន្តែពាក្យនេះចង់បញ្ជាក់ថា បុគ្គលម្នាក់ព្យាយាមលាក់បាំងអត្តសញ្ញាណរបស់ខ្លួន ។ ចំណែក "ឈ្មោះហៅក្រៅ" (aka) ចង់បញ្ជាក់ថា បុគ្គលម្នាក់តែងតែត្រូវបានគេស្គាល់តាមរយៈឈ្មោះហៅក្រៅរបស់គាត់ ប៉ុន្តែមិនមានលក្ខណៈច្បាស់ថាគាត់ជ្រើសរើសឈ្មោះនេះដើម្បីលាក់បាំងអត្តសញ្ញាណរបស់គាត់នោះទេ ។ ក្នុងការប្រើប្រាស់ជាក់ស្ដែង ពាក្យទាំងពីរនេះអាចប្រើផ្លាស់ប្ដូរគ្នាបាន ប៉ុន្តែខ្ញុំជឿជាក់ថា "ឈ្មោះក្លែង" ចង់បង្ហាញពីចេតនាលាក់បាំងអត្តសញ្ញាណ រីឯ "ឈ្មោះហៅក្រៅ" មិនបញ្ជាក់ពីចេតនាអាក្រក់ឡើយ ។ ឧទាហរណ៍ "៨៩" គឺជា "ឈ្មោះក្លែង" របស់ សុន សេន ។ ◆◆◆

**វ៉ាមិន ចូហាន់សាន់**

◆◆◆ ពាក្យទាំងពីរនេះមិនមានភាពខុសប្លែកគ្នាប៉ុន្មានទេ ។ ពាក្យថា "ឈ្មោះក្លែង" គឺជាឈ្មោះដែលបុគ្គលម្នាក់ប្រើប្រាស់ដើម្បីបិទបាំងអត្តសញ្ញាណរបស់ខ្លួន ។ ចំណែកឯ "ឈ្មោះហៅក្រៅ" មានន័យថា "ហៅថា" ។ ពាក្យនេះមិនមានលក្ខណៈជាផ្លូវការទេ ។ យើងច្រើនតែប្រើ "ឈ្មោះហៅក្រៅ" នេះសម្រាប់សម្គាល់ឈ្មោះហៅក្រៅរបស់បុគ្គលម្នាក់ ។ ក៏ប៉ុន្តែពាក្យនេះក៏អាចប្រើសម្រាប់សម្គាល់ឈ្មោះក្លែងរបស់បុគ្គលរូបនេះដែរ ។

ខ្ញុំសូមលើកយកឧទាហរណ៍មួយចំនួនមកបញ្ជាក់ឲ្យកាន់តែច្បាស់÷

◆ ឈ្មោះក្លែងរបស់ ម៉ុក គឺ ឈិត ជឿន ។

◆ ម៉ុក ហៅ ឈិត ជឿន ជាអតីតមេដឹកនាំខ្មែរក្រហមម្នាក់ ។

◆ ម៉ុក ជាឈ្មោះហៅក្រៅរបស់ ឈិត ជឿន ។

◆ ម៉ុក ដែលគេស្គាល់ជាទូទៅថា "ជនដៃដាច់" ជាអតីតមេដឹកនាំខ្មែរក្រហមម្នាក់ ។

◆ ម៉ុក ហៅ "ឈិត ជឿន" ជាអតីតមេដឹកនាំខ្មែរក្រហមម្នាក់ ។

ក្នុងការសរសេរអត្ថបទជាផ្លូវការ យើងតែងតែប្រើ "ឈ្មោះក្លែង" ។ ចំណែកឯ "ឈ្មោះហៅក្រៅ" ឃើញមានប្រើជាទូទៅនៅក្នុងទំព័រសារព័ត៌មាននិងអត្ថបទមិនផ្លូវការ ។

**ចន ឆរឆីអារី**

# សេចក្តីបន្ថែមទៅលើអត្ថបទ "ជនកុម្មុយនិស្តខ្មែរក្រហមនិងវៀតណាម"

*(សូមមេត្តាអានផ្នែកខាងក្រោមនេះបន្តពីលេខទី២០ រួចទើបអានបន្តទៅលេខទី២១)*

ឯកសារបណ្ណសារបង្ហាញថា នៅឆមាសទី១ ឆ្នាំ១៩៧៦ ទីក្រុងហាណូយសង្ឃឹមយ៉ាងមុតមាំថានឹងមានការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងទំនាក់ទំនងជាមួយខ្មែរក្រហម ។ នៅខែកុម្ភៈ ឆ្នាំ១៩៧៦ មុនថ្ងៃប្រជុំកំពូល សួន ធី មេដឹកនាំម្នាក់ក្នុងចំណោមមេដឹកនាំធំៗរបស់វៀតណាម បានប្រាប់ឯកអគ្គរដ្ឋទូតសូវៀតថា «ទំនាក់ទំនងរវាងកម្ពុជានិងវៀតណាមកំពុងតែទៅមុខយ៉ាងយឺតៗ» ។ បន្តិចក្រោយមក នៅខែកក្កដា ឆ្នាំ១៩៧៦ នៅក្នុងកិច្ចសន្ទនាជាមួយឯកអគ្គរដ្ឋទូតសូវៀត ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេសនៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ហ៊ីង វ៉ាន់ ឡឺយ បានប្រកាសថា ថ្នាក់ដឹកនាំវៀតណាម «ចាំបាច់ត្រូវមានការអត់ធ្មត់និងឈានទៅរកការពង្រឹងឥទ្ធិពលរបស់ខ្លួននៅក្នុងប្រទេសកម្ពុជាជាបណ្តើរៗ» ។

ជាការពិតណាស់ មេដឹកនាំវៀតណាមចាត់ទុកកិច្ចសម្ភាសន៍នៅឆ្នាំ១៩៧៦របស់ ប៉ុល ពត ជាមួយអគ្គនាយករងទីភ្នាក់ងារពត៌មានវៀតណាម ជិន ថាញ់ សួន ថាជាភ័ស្តុតាងមួយបង្ហាញពីឥទ្ធិពលដែលចេះតែកើនឡើងរបស់វៀតណាមនៅក្នុងទីក្រុងភ្នំពេញ ។ ជិន ថាញ់ សួន មកធ្វើទស្សនកិច្ចនៅកម្ពុជាជាមួយគណៈប្រតិភូក្រុមសារពត៌មានវៀតណាមដ៏ធំមួយ ។ នៅក្នុងកិច្ចសម្ភាសន៍ ប៉ុល ពត បាននិយាយពាក្យដែលវៀតណាមទន្ទឹងរង់ចាំស្តាប់តែមិនបានស្តាប់កាលពីខែមិថុនា ឆ្នាំ១៩៧៥ ។ ប៉ុល ពត និយាយជាពិសេសថា «យើងគិតអំពីទំនាក់ទំនងនិងសាមគ្គីភាពរបដិវត្តន៍កម្ពុជានិងវៀតណាម អំពីបញ្ហាយុទ្ធសាស្ត្រនិងអារម្មណ៍ដ៏ពិសិដ្ឋ ។ នៅពេលទំនាក់ទំនងមិត្តភាពនិងសាមគ្គីភាពខ្លាំង ទើបបដិវត្តន៍នៅក្នុងប្រទេសយើងរីកចម្រើនទៅមុខ ។ គ្មានជម្រើសណាផ្សេងពីនេះទេ ។ ដោយហេតុនេះហើយបានជាយើងគិតថា គណៈមជ្ឈិមបក្សទាំងពីរនិងយើងផ្ទាល់គួរតែពុះពារថែរក្សាយុទ្ធសាមគ្គីភាព និងភាពជាបងប្អូនរួមអាវុធ ហើយធ្វើឲ្យទំនាក់ទំនងទាំងអស់នេះពង្រីកនិងពង្រឹងពីមួយថ្ងៃទៅមួយថ្ងៃ» ។

ជាការច្បាស់ណាស់ថា មានតែកាលៈទេសៈធ្លាក់ដល់សភាពធ្ងន់ធ្ងរដូចឃើញស្រាប់នេះទេ ទើប ប៉ុល ពត បង្ហាញសារជាថ្មីនូវភាពស្និតល្មួតជាមួយវៀតណាម ។ មិនតែប៉ុណ្ណោះ «បងលេខ១» បានទទួលសម្ពាធយ៉ាងតឹងតែងនៅក្នុងជួរបក្សកុម្មុយនិស្តកម្ពុជា ពីសំណាក់ក្រុមបក្សដឹកនាំដែលមានច្រើននាក់ហើយមានឥទ្ធិពល ជាពិសេសនៅថ្នាក់តំបន់ដែលប្រឆាំងនឹងការកាត់ផ្តាច់ទំនាក់ទំនងជាមួយវៀតណាម ។ នៅខែកញ្ញា ឆ្នាំ១៩៧៦ ដោយសារសម្ពាធរបស់ថ្នាក់ដឹកនាំទាំងនេះ ប៉ុល ពត អាចនឹងត្រូវដកចេញពីតំណែងបណ្តោះអាសន្នទៀតផង ។ ដើម្បីកាត់បន្ថយការគាបសង្កត់នេះ ហើយចំណេញពេល ប៉ុល ពត ត្រូវបង្ខំចិត្តធ្វើសេចក្តីថ្លែងការណ៍ដែលខ្លាំងរបស់ខ្លួនបានសង្ឃឹមទុក ។ ជាការគួរឲ្យភ្ញាក់ផ្អើល ប៉ុល ពត បាននិយាយធ្វើជាការលេងសើចជាមួយមេដឹកនាំទាំងនោះជាថ្មីម្តងទៀតដើម្បីធ្វើជាការបន្ទំសុខចិត្ត និងរៀបចំខ្លួនជាស្រេចក្នុងការសហការដៃក្នុងដៃជាមួយវៀតណាម ។ នៅក្នុងខែមីនា ឆ្នាំ១៩៧៧ នៅពេលដែលយុទ្ធនាការប្រឆាំងវៀតណាមនៅក្នុងប្រទេសកម្ពុជាកំពុងតែមានសន្ទុះខ្លាំងឡើង ដឿង ជីញ សមាជិកគណៈកម្មាធិការប្រធានផ្នែកនយោបាយនិងប្រតិបត្តិនៃបក្សពលករវៀតណាម និងជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាជាតិនៃសាធារណរដ្ឋសង្គមនិយមវៀតណាម បានគូសបញ្ជាក់នៅក្នុងកិច្ចសន្ទនាមួយជាមួយឯកអគ្គរដ្ឋទូតសូវៀតថា «កម្ពុជាប្រជាធិបតេយ្យកំពុងតែកសាងសង្គមនិយម ប៉ុន្តែមេដឹកនាំកម្ពុជាមិនច្បាស់ខ្លួនឯងអំពីទម្រង់ក្នុងការកសាងសង្គមនិយមឡើយ ។ នៅក្នុងជួរថ្នាក់ដឹកនាំគ្មានការចុះសម្រុងគ្នា ហើយពឹងលើមាគ៌ាណាដែលឈ្នះ» ។

គ្មានអ្វីគួរឲ្យសង្ស័យទាល់តែសោះថា នៅឆ្នាំ១៩៧៦ ទោះបីជាទំនាក់ទំនងជាមួយទីក្រុងភ្នំពេញមានការរីកចម្រើនខ្លះក៏ដោយ ក៏ទីក្រុងហាណូយមិនត្រឹមតែបាត់ម្ចាស់ការទេ (ដែល

ខ្លួនធ្លាប់ជួបប្រទះកាលពីមុនម្តងរួចមកហើយ) ប៉ុន្តែថែមទាំងបាត់បង់នូវប្រភពព័ត៌មានពិតប្រាកដស្តីអំពីស្ថានការណ៍នៅក្នុងជួរថ្នាក់ដឹកនាំខ្មែរទៀតផង ។ យ៉ាងហោចណាស់ការពិតនេះត្រូវបានទទួលស្គាល់ដោយថ្នាក់ដឹកនាំវៀតណាម ។ នៅខែកក្កដា ឆ្នាំ១៩៧៦ យោងតាមព័ត៌មានរបស់ឯកអគ្គរដ្ឋទូតសូវៀត បានឲ្យដឹងថា ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ផាម វ៉ាន់ ដុង បាន“ប្រាប់ជាសម្ងាត់ថា សភាពការណ៍បច្ចុប្បន្ននៅកម្ពុជាមិនមានលក្ខណៈច្បាស់លាស់ចំពោះទីក្រុងហាណូយប៉ុន្មានទេ ដែលជាហេតុឲ្យមានការលំបាកក្នុងការតាមដានសភាពការណ៍វិវត្តនៅទីនោះ” ។ ផាម វ៉ាន់ ដុង ក៏បាននិយាយដែរថា ជាការចាំបាច់ក្នុងការសម្តែងការអត់ធ្មត់ ហើយថា ការពិតគួរតែបង្រៀនមេរៀនខ្លះដល់ជនជាតិខ្មែរ” (កិច្ចសន្ទនារបស់ឯកអគ្គរដ្ឋទូតសហភាពសូវៀតជាមួយនាយករដ្ឋមន្ត្រី ផាម វ៉ាន់ ដុង, ១៣ កក្កដា ១៩៧៦ ទំព័រទី៧(២) ។ ការក្តាប់មិនសូវបានរបស់ថ្នាក់ដឹកនាំវៀតណាមនូវសភាពការណ៍តស៊ូនយោបាយបច្ចុប្បន្ននៅកម្ពុជាក៏អាចត្រូវបានមើលឃើញបានដែរ តាមរយៈការពិតដែលថា កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ឡេ យន់ បានប្រាប់ឯកអគ្គរដ្ឋទូតសូវៀតថា ប៉ុល ពត និង អៀង សារី ត្រូវបានផ្លាស់ចេញពីមុខតំណែង ដោយហេតុថា “អ្នកទាំងពីរនេះជាមនុស្សមិនល្អ” ។ ឡេ យន់ បន្ថែមទៀតថា “រឿងរ៉ាវទាំងអស់នឹងមិនមានបញ្ហាអ្វីទេជាមួយកម្ពុជា ដែលមិនយូរមិនឆាប់នឹងរួមគ្នាជាមួយវៀតណាម ។ គ្មានផ្លូវជ្រើសរើសណាផ្សេងសម្រាប់ជនជាតិខ្មែរទេ” (ឯកសារសន្ទនារបស់ឯកអគ្គរដ្ឋទូតសូវៀតជាមួយលេខាទីមួយនៃគណៈកម្មាធិការមជ្ឈិមនៃបក្សពលករវៀតណាម ឡេ យន់, ១៦ វិច្ឆិកា ១៩៧៦ ទំព័រទី១១៣) ។

តាមការពិត របាយការណ៍ដែលថា ប៉ុល ពត និង អៀង សារី ត្រូវបានដកចេញពីតំណែង ដែលឥឡូវនេះស្ថិតនៅក្នុងដៃរបស់ នួន ជា “ដែលគួរឲ្យទុកចិត្ត” គឺត្រូវបានបកស្រាយខុសពីសភាពការណ៍នៅទីក្រុងភ្នំពេញនៅពាក់កណ្តាលខែវិច្ឆិកា ឆ្នាំ១៩៧៦ ។ អ្នកជិតទាស់របស់ ប៉ុល ពត មួយចំនួនដែលល្បីឈ្មោះបោះសំឡេង ដូចជា កែវ មុន្នី, កែ មាស និង ណៃ សារ៉ន ត្រូវបានចាប់ដាក់គុកនិងធ្វើទារុណកម្មដ៏ធ្ងន់ធ្ងររួចទៅហើយ ។ រដ្ឋមន្ត្រីក្រសួងកសិកម្ម នន់ សួន និងអ្នកធ្វើការជាមួយជាងពីររយនាក់ទៀតមកពីក្រសួងមន្ទីរផ្សេងៗ កងទ័ព និងក្បាលម៉ាស៊ីនដឹកនាំបក្ស ត្រូវបានចាប់ខ្លួននៅថ្ងៃទី១ ខែវិច្ឆិកា ។ នៅក្នុងខណៈដែល ឡេ យន់ ប្រាប់ឯកអគ្គរដ្ឋទូតសូវៀតថា ប៉ុល ពត និង អៀង សារី ត្រូវបានដេញចេញពីតំណែង តាមពិតនៅទីក្រុងភ្នំពេញ អ្នកទាំងពីរកំពុងតែក្តាប់អំណាចយ៉ាងណែននៅក្នុងដៃ ។

និយាយរួម កាលៈទេសៈនៃការប៉ុនប៉ងធ្វើរដ្ឋប្រហាររហូតមកដល់ឥឡូវមិនទាន់ត្រូវបានស៊ើបអង្កេតឲ្យបានគ្រប់គ្រាន់នៅឡើយទេ ។ មានដំណឹងថា កាលពីខែកញ្ញា ឆ្នាំ១៩៧៦ ដោយស្ថិតនៅក្រោមសម្ពាធប្រឆាំងនឹងខ្លួន (ពីសំណាក់ នន់ សួន ដែលជាថ្នាក់ដឹកនាំម្នាក់ក្នុងចំណោមថ្នាក់ដឹកនាំផ្សេងៗទៀត និងជាអតីតមនុស្សស្ថិតក្រោមអាណាព្យាបាលរបស់វៀតណាម) ប៉ុល ពត បានបង្ខំចិត្តប្រកាសលាលែងពីតំណែងនាយករដ្ឋមន្ត្រីកម្ពុជាប្រជាធិបតេយ្យជាបណ្តោះអាសន្នដោយមូលហេតុ “សុខភាព” ។ នួន ជា ដែលស្ថិតក្នុងលំដាប់ទីពីរបន្ទាប់ពី ប៉ុល ពត ត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រីស្តីទី ។

## ពន្យល់ពាក្យខ្មែរក្រហម

◆ **ធាតុឈានមុខៈ** គឺជាវិន័យដែករបស់យុវកក វេរកម្មមិនមុខ ក៏យុវកកឈានមុខ ។ *(កំណត់ហេតុលេខ១០៤គណាហ១៨៤)*

◆ **ជនកុម្មុយនិស្តៈ** គឺជាអ្នកអង់អាចក្លាហាន ពុះពារនូវរាល់ឧបសគ្គគ្រប់បែបយ៉ាង មោះមុត ហ៊ានធ្វើពលិកម្មគ្រប់បែបយ៉ាង មានការលះបង់ស្វនតួ បុគ្គលអាត្មាខ្លួន រហូតដល់ជីវិតខ្លួនទៀតក៏ឥតរុញរា ។ រូបភាពគឺជាមនុស្សដូចគ្នា តែខ្លឹមសារវិញខ្ពស់ឧត្តុង្គឧត្តមណាស់ ។ *(កំណត់ហេតុលេខ១២ គណាហ ១៨១)*

# សោកនាដកម្មគ្រួសារខ្ញុំ

ខ្ញុំបាទឈ្មោះ សំណុំ សារុត ឈ្មោះដើម សារុត ម៉ារីនលិន ហៅ លីន សព្វថ្ងៃជាគណនេយ្យករនៅធនាគារឯកជនមួយក្នុងរាជធានីភ្នំពេញ ។ ឪពុកឈ្មោះ សារុន សារុត មុនថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ជាមេបញ្ជាការផ្នែកសឹករងថ្មពួក ទទួលអនិច្ចកម្មក្នុងរបប ប៉ុល ពត ដោយសារត្រូវពួកខ្មែរក្រហមសម្លាប់ ។ ម្តាយឈ្មោះ អ៊ឹ សំណុំ ជាតិលានុបដ្ឋាយិការដ្ឋ បច្ចុប្បន្ននៅរស់ ។ ខ្ញុំមានបងប្អូនម្នាក់ស្លាប់ក្នុងរបប ប៉ុល ពត ដោយជំងឺគ្រុនចាញ់និងម្នាក់ទៀតស្លាប់ដោយការចងកំហឹងនឹងខ្មែរក្រហម ហើយចូលធ្វើទាហានតាមសងឈាមជូនលោកឪពុក ។ ខាងក្រោមនេះជារឿងរ៉ាវគ្រួសារខ្ញុំ÷

គ្រួសារខ្ញុំជាអ្នកភូមិច្បារអំពៅ លំនៅដ្ឋានស្ថិតនៅខាងជើងវត្តពោធិ៍ព្រះបាទ ហៅវត្តច្បារអំពៅ ប្រមាណ១៥០ ម៉ែត្រ ។ ហេតុការណ៍ចម្លែកមួយបានកើតឡើងនៅវេលាម៉ោង ២ រសៀលថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៥ ។ ខ្ញុំបានឃើញប្រជាជនដែលរស់នៅឃុំវាលស្បូវនិងឃុំព្រែកឯង ធ្វើដំណើរពាក់ពពូន...ទូល រែក...ទឹកមុខស្រពាប់ស្រពោន លាយឡំនឹងទាហាន លន់ ណុល ប្រដាប់ដោយអាវុធ ដើរកាត់មុខផ្ទះយើង ។ ខ្ញុំក៏សាកសួរមីងម្នាក់ដែលកំពុងធ្វើដំណើរក្នុងចំណោមនោះថា "មីងមកពីខាងណា?" គាត់ឆ្លើយដោយក្រៀមក្រំលាយឡំនឹងក្តីតក់ស្លុត "មកពីវាលស្បូវ...ពួកវាមកដល់ហើយ!" ពួកវាមកដល់ហើយ? ខ្ញុំឆ្ងល់និងរិះគិតចំពោះចម្លើយយ៉ាងខ្លីនេះ ។

ខ្ញុំដើរចូលមកក្នុងរបងវិញ ឃើញម្តាយរបស់ខ្ញុំ ម្តាយធំ បងថ្លៃនិងជីដូនជរាកំពុងពិភាក្សាគ្នា ម្តាយខ្ញុំក៏ប្រាប់ថា "កូនឆាប់ទៅរៀបឥវ៉ាន់" ។ ខ្ញុំស្លុតគ្រាដែលបានឮបន្ទាប់នេះ ។ ម្តាយខ្ញុំពិភាក្សាជាមួយបងថ្លៃខ្ញុំ (ជាអនុសេនីយ៍ទោនៃអគ្គសេនាធិការកងទ័ពជាតិ) ថាតើត្រូវធ្វើអ្វីខណៈនេះ? ប្រហែលជាមានតែខ្ញុំម្នាក់ទេដែលមានបញ្ហាច្រើន ពីព្រោះបងនិងប្អូនខ្ញុំនាំគ្នារៀបឥវ៉ាន់រៀងៗខ្លួន ដោយមិនខ្វល់សួរដេញដោលអ្វីទាំងអស់ ។ បងថ្លៃខ្ញុំបានប្រាប់ថា "ប្អូនត្រូវដោះសម្លៀកបំពាក់នេះចេញរួចស្លៀកពាក់ទាហាន ព្រោះយប់ពួកវាមើលយើងមិនច្បាស់" ។ តាមបន្ទាប់បងថ្លៃ ខ្ញុំស្ទុះរឹងទៅលើផ្ទះដោះសម្លៀកបំពាក់ចេញរួចជំនួសដោយសម្លៀកបំពាក់ត្រីអ៊ុីវិញ ។

ម៉ោង៤រសៀល ស្ថានការណ៍កាន់តែជ្រួលច្របល់ខ្លាំងឡើង ហ្វូងមនុស្សប្រោលពីវាលស្បូវនិងព្រែកឯងកាន់ច្រើនឡើងៗ មិនខុសពីអ្នកនៅក្នុងផ្ទះខ្ញុំដែរ ។ នៅក្នុងខណៈនោះ ខ្ញុំនឹកឃើញសុបិនកាលពីបីយប់មុន ដែលបានឃើញអ្នកភ្នំពេញទាំងអស់មានសម្លៀកបំពាក់រយីករយាក ទូលរែកឥវ៉ាន់ដើរចេញពីភ្នំពេញ បន្ទាប់មកក៏ឃើញរូបភាពដដែលហ្នឹងដើរត្រឡប់ចូលភ្នំពេញវិញ ។

ម៉ោងប្រហែល៥ល្ងាច ស្ត្រីចំណាស់ម្នាក់ភៀសខ្លួនមកពីខេត្តតាកែវបានប្រាប់ម្តាយខ្ញុំថា ៖ "នៅតំបន់រំដោះលំបាកវេទនាខ្លាំងណាស់...គេឲ្យយើងធ្វើការទាំងថ្ងៃទាំងយប់ ក្មេងតូចឲ្យកើបលាមកគោតាមស្រែបរិភោគមិនគ្រប់គ្រាន់ ពួកគេនឹងយកយើងទៅសម្លាប់បើដឹងថាជានិស្សិត មន្ត្រី រដ្ឋការ ឬអ្នកមាន ទាហានដូច្នេះសូមលោកស្រីកុំប្រាប់ការពិតបើពួកវាសួរ! ត្រូវលាក់ឲ្យជិត...ប្រាប់ពួកវាថាជាកម្មករលីសែងឬធាក់ស៊ីក្លូទើបរួចខ្លួន" ប្រាប់រួចគាត់ក៏ចាកចេញទៅ ។ ភ្លាមៗនោះ ម្តាយរបស់ខ្ញុំបានបញ្ជាក់ឡើងវិញថាឲ្យធ្វើតាមបណ្តាំនេះ ដោយនាំគ្នាធ្វើគ...ធ្វើថ្លង់ ។ ជីដូនរបស់ខ្ញុំបន្ថែមថា "មានផ្ទះគ្មានមនុស្សនៅ មានផ្លូវគ្មានមនុស្សដើរ បាយមួយគ្រាប់ជាប់កន្ទុយឆ្កែដណ្តើមគ្នាស៊ី...ចៅៗត្រូវដាំដើមល្ហុងនិងដើមគ...ដល់វេលាហើយ បើរត់ត្រូវរត់ទៅទិសឦសានទើបបានសុខ" ។ យើងយល់ពីអ្វីដែលជីដូនមានប្រសាសន៍ ដើមគគឺកុំនិយាយអ្វីបើគេសួរ ដើមល្ហុងគឺមិនចេះអ្វី ។

ស្រស់ស្រូបបបររួច យើងបាននាំគ្នាជញ្ជូនឥវ៉ាន់ចូលលេណដ្ឋានដែលធ្វើយ៉ាងមាំដោយពលទាហានរបស់ឪពុកខ្ញុំ" ។ ថ្ងៃលិចល្ងាច ។ ភាពងងឹតក៏មកដល់ ហើយភ្លើងអគ្គិសនីក៏ដាច់ ។

ម៉ោងប្រមាណជា ៦:៣០ ឬ៦:៤០ សន្ទឹកគ្រាប់កាំភ្លើងធំរបស់ទាហានរដ្ឋាភិបាលបានទម្លាក់ស្រោចមកលើភូមិច្បារអំពៅ ។ គ្រាប់ទាំងនោះបាញ់ចេញពីបន្ទាយទាហាននៅផ្សារក្បាលថ្នល់ ពីប៉ុលខិញនិងពីស្ពាតចាស់ ។ គ្រាប់ធ្លាក់ជុំវិញផ្ទះផ្ទុះដូចលាជ ។ ការវាយប្រយុទ្ធគ្នាយ៉ាងចាស់ដៃរវាងទាហានសាធារណរដ្ឋនិងពួកខ្មែរក្រហមក៏ផ្ដើមឡើងនៅត្រង់ផ្សារច្បារអំពៅ ។

នៅខាងមុខនិងនៅជុំវិញផ្ទះ ការបាញ់តគ្នាកាន់តែខ្លាំង ដោយគ្រាប់អ៊ឹម៧៩ ជាច្រើនរយគ្រាប់បានធ្លាក់ក្បែរៗផ្ទះ ។ ខ្ញុំគេងក្នុងអគ្រឹងទាហានក្បែរលេណដ្ឋាន បងថ្លៃរបស់ខ្ញុំត្រៀមលក្ខណៈការពារខ្លាចក្រែងទាហានខ្មែរក្រហមវាយប្រហារ ។ ខ្ញុំគិតថា ខ្មែរក្រហមវាពិតជាបានឃើញខ្ញុំនិងបងថ្លៃរបស់ខ្ញុំ ព្រោះថា យន្តហោះរដ្ឋាភិបាលបានទម្លាក់ភ្លើងបំភ្លឺប្រើក្នុងសមរភូមិវេលាយប់ ចំពីលើផ្ទះរបស់ខ្ញុំ ។ គ្រាប់កាំភ្លើងរ៉ុក្កែតបេ៤០របស់ខ្មែរក្រហមរត់ឆ្លងកាត់ពីលើលេណដ្ឋានទៅបុកគុម្ពឫស្សីក្រោយផ្ទះផ្ទុះគ្រាំងៗ ។ ខ្ញុំមិនទាន់តក់ស្លុតអ្វីទាំងអស់ ។ លុះម៉ោងប្រហែល១០យប់ គ្រាប់រ៉ុក្កែតមួយគ្រាប់បានធ្លាក់ចំផ្ទះលោកអនុសេនីយ៍ទោម្នាក់ដែលនៅខាងត្បូងផ្ទះ អណ្ដាតភ្លើងក៏ឆាបឆេះឡើង ។ យើងនាំគ្នាស្ទុះទៅជួយពន្លត់ដោយភ្លេចគិតថាមច្ចុរាជកំពុងបញ្ចេញចង្កូមដាក់ ។ គ្រាប់បំភ្លឺសមរភូមិលើកទីពីរធ្លាក់ពីលើភូមិយើងនៅម៉ោងប្រមាណជា១:១៥នាទី ភ្លឺដូចថ្ងៃធ្វើឲ្យខ្មែរក្រហមបាញ់គ្រាប់អ៊ឹម៧៩មួយគ្រាប់សំដៅបងថ្លៃខ្ញុំ ប៉ុន្តែគ្រាប់នោះបែរជាមកធ្លាក់ចំមាត់លេណដ្ឋាន ។ ខ្ញុំបង្ខំចិត្តទម្លាក់ខ្លួនពីលើអគ្រឹងមកក្រាបជាប់នឹងដី ឯបងថ្លៃរបស់ខ្ញុំ ដៃកាន់កាំភ្លើងវេចុះឡើងដើម្បីបំភ័ត្តភ្នែកសត្រូវ ។

ម៉ោង៤ទៀបភ្លឺនាថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥ បងថ្លៃខ្ញុំបានសុំឲ្យអ្នកទាំងអស់គ្នាចេញពីក្នុងលេណដ្ឋាន កាន់តវ៉ាន់ម្នាក់មួយបង្ហើចរត់កាត់ភ្លៀងគ្រាប់អ៊ឹម៧៩សំដៅផ្ទះធំរបស់យើងនៅខាងមុខ ។ ដល់ក្រោមផ្ទះយើងនាំគ្នាយកគុកៅអីរៀបជារបាំងការពារគ្រាប់រួចក៏នាំគ្នាក្រាប ខ្លះដេក...ឯខ្ញុំដេកកើយសាក់កាដូ ។ ម៉ោង៥:៣០នាទីភ្លឺ គ្រាប់អ៊ឹម៧៩ ដែលទំនងជាខ្មែរក្រហមបាញ់សំដៅសម្លាប់ខ្ញុំ បានមកប៉ះនឹងសរសរផ្ទះដែលខ្ញុំគេងក្បែរផ្ទុះ ក្ដាំង! ឡើងបែកផ្កាភ្លើងព្រោងព្រាត លាយឡំនឹងសំឡេងស្រែករបស់យើងរាល់គ្នា ។ ផ្សែងគ្រាប់រលាយអស់ ។ ម្ដាយខ្ញុំសួរថាមានអ្នកណាត្រូវទេ? ។ មនុស្សទី១ដែលឃើញភ្លាមនោះគឺបងប្រុសត្រូវអំបែងគ្រាប់ចំកណ្ដាលថ្ងាសឈាមហូរសស្រាក់ដោកផ្ទៃមុខ ។ ម្ដាយខ្ញុំបានយកកន្ត្រៃពេទ្យគ្លឹះអំបែងគ្រាប់ចេញរួចក៏រុំ បន្ទាប់មកលោកយាយត្រូវត្រគៀកស្ដាំ ចំណែកខ្ញុំត្រូវកែងដៃពីរចំណុច ខ្ញុំក៏លើកបង្ហាញម្ដាយខ្ញុំ ។ ឈាមក៏ហូរស្រោចភ្លាមដែរ ទទឹកដោកអាវនិងខោត្រីអ៊ីរបស់ខ្ញុំ កម្ទេចគ្រាប់ចូលដល់ឆ្អឹង ។ ម្ដាយខ្ញុំគ្មានមធ្យោបាយជួយកូនបានឡើយ ទាំងអស់គ្នាកំពុងព្រួយបារម្ភពីរបួសខ្ញុំ ។ រំពេចនោះ ម្ដាយខ្ញុំស្រែកភ្លាត់សំឡេងថា "ពួកវាមកដល់ហើយៗ!" ។ ភ្លាមៗនោះបងស្រីស្រវាបោចសក្តិចេញពីទ្រូងរបស់ប្ដីគាត់និងកន្ត្រាក់អាវចេញ ឯបងប្រុសទាញកាំភ្លើងរុញលាក់ទៅក្រោមគុ ពួកខ្មែរក្រហមពីរនាក់ចូលមកដល់ បាញ់បងថ្លៃខ្ញុំពីរគ្រាប់ដួលស្លាប់ភ្លាម ។

ចំណែកខ្ញុំគាំងស្មារតី ឈរលើកដៃដោយខ្មែរក្រហមម្នាក់ភ្ជង់ជាប់ដោយកាំភ្លើងអាកា៤៧ ។ ឯឈាមនៅតែហូរឥតឈប់ទទឹកដោកសម្លៀកបំពាក់ត្រីអ៊ី ។ ខ្មែរក្រហមនោះវាសម្លុតសួរខ្ញុំ "អ្ហែងជាកុម្ម៉ង់ដូអាមេរិកាំងឬ?" ។ ខ្ញុំឆ្លើយភ្លាមដោយភ្ញាក់ព្រើត "ទេ!ខ្ញុំជាសិស្ស.." ភ្លាមនោះដែរ ខ្ញុំហាក់ដូចជាឮសំឡេងម្ដាយខ្ញុំល្ហើយៗក្នុងត្រចៀកថា "រត់ទៅកូនៗ..." ។ ស្រាងស្មារតីខ្ញុំកៀសចុងកាណុងយមបាល រួចរត់វឹងចេញទៅក្រៅរបង ។ ឃើញខ្ញុំរត់ បងប្អូន អ្នកម្ដាយ ជីដូន ទាំងអស់គ្នារត់តាមពីក្រោយបន្ទាន់ៗគ្នាភ្លាម ។ ខ្មែរក្រហមពីរនាក់នោះវាអត់តាមយើងទេ ។ ដោយភ័យនឹងគ្រាប់ធ្លាក់ បងប្រុសរបស់ខ្ញុំដែលមានរបួសនិងប្អូនៗពីរនាក់ក៏រត់បែកខ្វែកទៅទិសខាងជើងតាមផ្លូវឆ្ពោះទៅទួលគីងរួមទាំងអ្នកភូមិជិតរបងជាមួយជាច្រើនទៀត ។ ចំណែកខ្ញុំ ជីដូន បងស្រីពីរនាក់ (ម្នាក់ពក្នួយអាយុ៦ខែ) ម្ដាយធំ និងម្ដាយរបស់ខ្ញុំ រត់តាមផ្លូវត្រង់មុខផ្ទះ ។ រត់បានប្រមាណជា៨០ម៉ែត្រពីផ្ទះ ខ្ញុំជួបនឹងខ្មែរក្រហមពីរនាក់ដោយប្រថុចញ៉ិច ពីរនាក់នោះស្លៀកពាក់ខ្មៅ ប្រដាប់ដោយកាំភ្លើងអាកា សាច់ឈាមស្លេកស្លាំងអង្គុយបឺតបារីលើកៅអីបង់ ។ ឃើញខ្ញុំវាភ្ញាក់ជ្រុះបារីពីមាត់ ស្រវាកាំភ្លើងភ្ជង់តម្រង់មកខ្ញុំ ។

ម្នាក់ស្រែកថា "កុំបាញ់! ទៅមុខទៀត" ខ្ញុំផុតពីគ្រោះថ្នាក់ជាលើកទីពីរ ។ រត់បានបួនប្រាំជំហានទៅមុខ ខ្ញុំក្រឡេកមកក្រោយ ឃើញខ្មែរក្រហមម្នាក់ភ្ជង់ម្តាយខ្ញុំហើយសម្លុតថា "តើឯងស្តាយជីវិតឬស្តាយបង្វេច?" ។ ម្តាយរបស់ខ្ញុំលុតជង្គង់សំពះអង្វរឲ្យវាទុកជីវិតទាំងឆ្លៀតស្រែកឲ្យកូនរត់ទៅៗ ។ សម្លុតម្តាយខ្ញុំរួច យោធាខ្មែរក្រហមសម្រុកចូលទៅក្នុងរបងផ្ទះខ្ញុំ ។

យើងទាំងអស់គ្នាខំប្រឹងរត់រហូតដល់ព្រៃរបោះក្បែរវត្តច្បារអំពៅ ហើយបានប្រទះឃើញសាកសពស្ត្រីម្នាក់អាយុប្រមាណ៣៥ឆ្នាំ ដេកស្លាប់ជាមួយកូនតូចអាយុប្រមាណពីរខួប ។ ស្លាប់ដោយមានស្នាមចាក់នឹងកាំបិតចំពុះទុងសុសសាច់ ។

យើងធ្វើដំណើរទៅមុខទៀតកាត់ព្រៃរបោះ ឆ្លងព្រែក បានមកដល់វត្តសំពៅង...មនុស្សច្រើនពាន់ម៉ឺននាក់មកពីគ្រប់ច្រកល្ហកដើរពពាក់ពពូនតាមផ្លូវ ខ្លះអូសសពឪពុកឬកូនរកទីសមគួរដើម្បីកប់ ។ គ្រួសារខ្ញុំអង្គុយក្រោមកុដិ លោកគង់ព័ទ្ធជុំវិញខ្ញុំកុំឲ្យខ្មែរក្រហមឃើញ យូរៗម្តងពួកវាស្រែកថា "មានទាហាន លន់ណុល ទេ?" ស្ងាត់គ្មានចម្លើយ ។

ម៉ោងប្រហែល៩ព្រឹក យន្តហោះរដ្ឋាភិបាលនៅហោះឆ្វេលចុះឡើងពីលើតំបន់នេះ យូរៗម្តងគ្រាប់ដេការបស់កងកម្លាំងម៉ារីននៅមានធ្លាក់គ្រាំងៗនៅឡើយ ។ គ្រួសារខ្ញុំបន្តដំណើរទៅទៀតដោយឆ្លងកាត់ដៃទន្លេមកដល់វត្តក្តីតាកុយ ដើរហួសវត្តបន្តិចមានពួកខ្មែរក្រហម៥-៦នាក់អង្គុយក្នុងរោងលក់នំក្បែរផ្លូវ មានកាំភ្លើងយន្តអ៊ឹម៣០មួយដើម អាកា៣ដើម និងសម្ភារពេទ្យ ។ ខ្មែរក្រហមម្នាក់សម្បុរស ខ្ពស់ស្រឡះ ទឹកមុខស្លូតបូតសួរខ្ញុំថា "មិត្តត្រូវរបួសឬ?" ខ្ញុំឆ្លើយទៅវិញថា "បាទ! ត្រូវរបួស" ខ្មែរក្រហមរូបនោះហៅខ្ញុំឲ្យចូលទៅលាងរបួសនិងចាក់ថ្នាំឃាត់ឈាមឲ្យមួយម្ជុល ។

យើងបន្តដំណើរទៅទៀត បងស្រីខ្ញុំយំអស់ទឹកភ្នែក គាត់វង្វេងវង្វាន់អស់ហើយ ដល់មុខវត្តប្រជុំវង្ស ខ្មែរក្រហមម្នាក់បានឃើញខ្ញុំប្រហែលជាវាគិតថាខ្ញុំជាទាហាន ដូច្នេះវាក៏តាមចាប់ ។ ខ្ញុំរត់កាត់ហ្វូងមនុស្សណែនតាន់តាប់ដើម្បីគេចពីពួកខ្មែរក្រហម ។ ខ្ញុំរត់គេចលុះត្រាតែដល់វត្តជ្រោយអំពិល ក៏ត្រូវបានមីងម្នាក់យកអាសាដោយអូសខ្ញុំឲ្យចូលពួនក្នុងផ្ទះគាត់បាត់ដានខ្ញុំត្រឹមនេះ ។ ខ្ញុំរួចពីស្លាប់លើកទីបី ។ នៅវេលាម៉ោងប្រហែល១:២០នាទី យើងក៏បានជួបជុំគ្នាឡើងវិញ ។

តាមផ្លូវជាតិដែលយើងបានធ្វើដំណើរមក ខ្ញុំប្រទះឃើញសាកសពជាច្រើនខ្លះជាទាហាន ខ្លះជាប្រជាពលរដ្ឋ ខ្លះហើមខ្លះពុំទាន់ហើម ខ្លះទៀតត្រូវរបួសធ្ងាយពោះគ្មានពេទ្យជួយ ។ ទាហានខ្មែរក្រហមដើរជាពីរជួរអមសងខាងផ្លូវឡើងមកភ្នំពេញ ។ នៅលើអាកាសយន្តហោះឆ្វេលចុះឆ្វេលឡើងហាក់អបអរដល់ពួកទមិឡ ប៉ុន្តែពួកម៉ារីននៅបាញ់ផ្តក់ដាក់ខ្សែទ័ពខ្មែរក្រហមនៅឡើយ ។

យប់ថ្ងៃ១៦-៤ យើងសម្រាកក្រោមផ្ទះអ្នកស្រុកនៅភូមិតាព្រហ្ម យើងគ្មានបាយញ៉ាំទេ ។ ព្រឹកឡើងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានកាន់កាប់ក្រុងភ្នំពេញ ។ អ្នករស់នៅទីក្រុងភ្នំពេញត្រូវបណ្តេញចេញក្រៅក្រុងទាំងអស់ ។ ពេលនោះអង្គការបានអនុញ្ញាតឲ្យប្រជាពលរដ្ឋទាំងឡាយស្វែងរកស្បៀង ។ គ្រួសាររបស់ខ្ញុំ លើកលែងតែខ្ញុំ ជីដូន និងបងស្រី ក្រៅពីនោះនាំគ្នាត្រឡប់ទៅផ្ទះយកបានខោអាវ៥-៦ការ៉ុង អង្ករ អំបិលជាច្រើន ។

នៅភូមិតាព្រហ្មនេះ យើងឃើញសោកនាដកម្មច្រើនឥតគណនា អ្នកខ្លះអត់ដង្ហើមឲ្យស្លាប់គ្រួសារ ខ្លះនាំគ្នាចូលឡានបិទកញ្ចក់សិន រួចបើកចុះទន្លេ ខ្លះយំបោកខ្លួនលុះត្រាតែស្លាប់ព្រោះព្រាត់គ្រួសារអស់ ខ្លះទៀតរងរបួសធ្ងន់ៗដេកដល់ស្លាប់ព្រោះគ្មានថ្នាំព្យាបាល ខ្លះត្រូវអង្គការចងបណ្តើរយកទៅ អ្នកខ្លះត្រូវបាញ់សម្លាប់ឆៅៗដោយសារតវ៉ាជាមួយអង្គការ គ្រួសារខ្លះនាំគ្នាអង្គុយអត់ដង្ហើមដល់ស្លាប់ក្នុងរថយន្ត អ្នកខ្លះលោតទឹកសម្លាប់ខ្លួន ។

ពួកអង្គការខ្មែរក្រហមបានប្រកាសឲ្យអ្នករដ្ឋការ សិស្សនិស្សិត ចុះឈ្មោះទៅទទួលសម្តេចឪ ឬធ្វើការតាមតួនាទីពេលនោះខ្លះផាក់ស៊ីក្លូសោះទៅចុះឈ្មោះប្រាប់អង្គការថាសក្តិ៥ ឯគ្រួសារខ្ញុំធ្វើមិនដឹងមិនឮ ។ ថ្ងៃមួយយើងបានឃើញពួកថ្នាក់លើ (អង្គការ) ជិះរថយន្តហ្ស៊ីបឆ្លងកាត់ភូមិ ។ ម្តាយខ្ញុំឃើញមនុស្សម្នាក់ដែលគាត់ស្គាល់កាលនៅរៀនជាមួយគ្នា (ស្គាល់ច្បាស់) គាត់ប្រាប់ថា វានោះឈ្មោះ សាឡុត ស ។ ថ្ងៃក្រោយ

មកទៀតបានជួប ជួន ជឿន អ្នកម្តាយប្រាប់ថាវាហ្នឹងធ្លាប់បបួលម៉ាក់រត់ចូលព្រៃធ្វើបដិវត្តន៍ ។

នៅពាក់កណ្តាលខែខសភា គ្រួសារខ្ញុំត្រូវអង្គការដឹកជម្លៀសតាមកាណូតឈ្មោះផ្កាយព្រឹកចេញពីតាព្រហ្មទៅមាត់ក្រសាស ។ ដល់មាត់ក្រសាសយើងធ្វើដំណើរដោយជើងជញ្ជូនឥវ៉ាន់បណ្តាក់ដូចខ្សែ តាមផ្លូវយើងយកខោអាវដូរអង្ករដូរយកត្រីសាច់គ្រាន់បានបរិភោគ អស់រយៈពេលជាងដប់ថ្ងៃក៏មកដល់ព្រែកហ្លួងសម្រាកនៅទីនោះមួយយប់ ។ ព្រឹកឡើងខ្មែរក្រហមបណ្តេញឲ្យចុះកាណូត ។ នៅពេលឡើងកាណូត យើងបានឃើញស្ត្រីម្នាក់កំពុងយំបោកក្បាល ដោយឮថាប្តីត្រូវអង្គការចងយកទៅសម្លាប់កាលពីយប់មិញ ឯកូនៗវង្វេងបាត់អស់ទៀត ទីបំផុតគាត់ក៏ដាច់ខ្យល់ស្លាប់ក្រោមក្រសែភ្នែកអាណិតអាសូរនៃអ្នករងគ្រោះដូចគ្នា និងក្រោមសំណើចក្អាកក្អាយរបស់យោធាខ្មែរក្រហម ។

កាណូតបញ្ឆេះម៉ាស៊ីន ឆ្ពោះទៅកាន់ព្រែកពោធិ៍ ។ យើងឆ្លៀតលើកដៃគ្រវីលាភ្នំពេញជាចុងក្រោយដោយក្តុកក្តួល ។ តាមផ្លូវខ្ញុំគិតជានិច្ចថាតើជីវិតយើងរាល់គ្នានៅទៅជាយ៉ាងណា បើតាំងពីនាទីដំបូងនៃការមកដល់របស់ខ្មែរក្រហម យើងឃើញតែឈាមនិងទឹកភ្នែកនោះ? តើភាពរុងរឿងនៅតំបន់រំដោះវាយ៉ាងណាដែរ បើតាមផ្លូវឃើញតែសាកសពនឹងភាពអត់ឃ្លាន?

ទុក្ខវេទនារបស់អ្នក១៧មេសាយ៉ាងណាៗនោះយើងធ្លាប់ដឹងឮអស់ហើយខ្ញុំមិនពិពណ៌នាទៀតទេ ប្រជាជនភូមិភាគបូព៌ាទាំងមូលត្រូវបក្សចោទប្រកាន់ថាក្បត់ ហើយត្រូវពួកនិរតីចូលទៅគ្រប់គ្រង ។ ទាំងអ្នកថ្មីទាំងអ្នកចាស់ ក្លាយជាអ្នកទោសរបស់អង្គការ ធ្វើការ២៤ម៉ោង សម្លាប់រង្គាលដូចសត្វ រហូតមានការតស៊ូកើតឡើង ។ សម្តេច ជា ស៊ីម ដែលកាលណោះជាអ្នកដឹកនាំមួយរូបនៅពញាក្រែក បានបបួលខ្ញុំនិងបងប្រុសឲ្យរត់ចូលព្រៃធ្វើការតស៊ូ ។ យើងបដិសេធ ។ ចុងក្រោយអ្នកភូមិខ្ញុំត្រូវជម្លៀសមកភូមិភាគកណ្តាល (កំពង់ចាម) ប្រជាជនរាប់ម៉ឺននាក់ពីភូមិភាគបូព៌ាមកកកនៅកំពង់ចាម ខ្លះត្រូវដឹកយកទៅសម្លាប់ជាបន្តបន្ទាប់ ។

ថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៩ រយៈពេលនៃការរង់ចាំកងទ័ពរំដោះបានមកដល់ ។ យើងឃើញខ្មែរក្រហមរត់បាក់ទ័ពទាំងហ្វូងៗ ។ អ្នកតស៊ូមកដល់ហើយ...យើងក៏ត្រេកអរ ហើយក៏ភិតភ័យណាស់ដែរ ព្រោះត្រូវរត់គេចពីការវាយប្រយុទ្ធគ្នារវាងពួកខ្មែរក្រហមនិងកម្លាំងរណសិរ្សសាមគ្គីសង្គ្រោះជាតិនិងកងទ័ពវៀតណាម ។

ជាងមួយខែគ្រួសារខ្ញុំបានមកដល់ច្បារអំពៅវិញ..ជាង ៩០ភាគរយនៃអ្នកភូមិយើងអត់ឃើញត្រឡប់មកភូមិវិញ ។ នៅក្នុងខែទីបី យើងក៏បានដំណឹងដ៏សោកសៅពីកូនទាហានលោកឪពុកដែលនៅរស់ប្រាប់យើងថា ឪពុកខ្ញុំបានស្លាប់ដោយសារពួកខ្មែរក្រហមខ្វេះភ្នែកទាំងគូរបស់គាត់ឲ្យក្រពើស៊ី ។

ជាបញ្ចប់នេះ ខ្ញុំសូមសួរទៅអារម្មណ៍ខ្មែរក្រហមដែលកំពុងរស់នៅសុខស្រួលសព្វថ្ងៃនេះ ថាតើមានអារម្មណ៍ដូចម្តេចបើជាឪ ជាម៉ែ ជាកូន របស់អ្នកនោះ? តើព្រលឹងរបស់ជនរងគ្រោះទាំងអស់ដែលត្រូវបង្ខំឲ្យស្លាប់ទាំងពុំទាន់ចង់ស្លាប់ ឬពុំទាន់ដល់អាយុត្រូវស្លាប់ អាចបានទៅសុគតិភពទេ?

ខ្ញុំសូមគាំទ្រដល់បំណងនៃការនាំយកពួកវាទៅកាត់ទោស និងគាំទ្រដោយសុទ្ធចិត្តដល់អ្នកទាំងឡាយដែលមានឆន្ទៈរក្សាវត្ថុតាងភស្តុតាង និងស្លាកស្នាមវាលពិឃាត ហើយសូមប្រឆាំងយ៉ាងដាច់ខាតចំពោះអ្នកដែលលើកលែងទោសឬចង់អហោសិកម្មឲ្យឧក្រិដ្ឋជនទាំងនោះ ។

អត្ថបទនេះ ខ្ញុំសូមខទ្ទិសដល់វិញ្ញាណក្ខន្ធលោកឪពុកនិងអ្នករងគ្រោះទាំងអស់ដែលស្លាប់ដោយសារនយោបាយឆ្កួតលីលារបស់ពួកអវិជ្ជាខ្មែរក្រហម ។

**សារុត ម៉ារីនលិន**

សូមសរសេរលិខិត

ឬអត្ថបទពិភាក្សាជុំវិញបញ្ហាខ្មែរក្រហម ផ្ញើមក

**ទស្សនាវដ្តី "ស្វែងរកការពិត"**

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ឬតាមទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

ឬ Email: dccam@bigpond.com.kh

# គោរពជូន
## លោកនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា

នាងខ្ញុំឈ្មោះ ស្រី គឹមឆយ ជាមន្ត្រីនៅសាលាខេត្តកំពង់ចាម ។ នាងខ្ញុំបានអានទស្សនាវដ្តី ស្វែងរកការពិត ដែលចេញផ្សាយដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ធ្វើឲ្យនាងខ្ញុំឈឺចាប់ រន្ធត់ ភិតភ័យ សាជាថ្មីឡើងវិញ បន្ទាប់ពីអារម្មណ៍ទាំងនោះរលុបបន្តិចម្តងៗក្នុងរយៈកាលកន្លងមក ។ នាងខ្ញុំសូមបន់ស្រន់កុំឲ្យរបបដ៏អប្រិយនោះកើតមានម្តងទៀតក្នុងសង្គមមនុស្ស ពិសេសសង្គមកម្ពុជាយើង ហើយក៏សុំឲ្យតុលាការយុត្តិធម៌មួយកាត់ទោសជនដៃដល់ ជនផ្តើមគំនិត (មេដឹកនាំ) ដ៏ឃោរឃៅ ឲ្យបានឆាប់ៗ ដើម្បីជាគំរូដល់មនុស្សជាតិទាំងឡាយ ។

លោកនាយកជាទីគោរព! ជាមួយនេះ នាងខ្ញុំសុំសួររកបងជីដូនមួយឈ្មោះ ស៊ុយ ស្រស់ ភេទប្រុស អាយុប្រហែល២០ឆ្នាំ (១៩៧៥) ។ កាលពីឆ្នាំ១៩៧៥ បួសជាភិក្ខុនៅវត្តចុងបឹងក្នុង ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ហើយត្រូវបានអង្គការបង្ខំឲ្យសឹក រួចទៅធ្វើការនៅជួរមុខបម្រើជាតិ ។ ឆ្នាំ១៩៧៦ ឮដំណឹងថាជាទ័ពដើរកប៉ាល់ ហើយបាត់ដំណឹងរហូតបច្ចុប្បន្ន ។ សូមលោកនាយកមេត្តាជួយស្រាវជ្រាវ ក្រែងមានឯកសារពាក់ព័ន្ធនឹងដំណើរជីវិតបងជីដូនមួយនាងខ្ញុំ ទោះស្លាប់ឬរស់ ដំណឹងរបស់គាត់នឹងធ្វើឲ្យពូមីងនាងខ្ញុំស្ងប់អារម្មណ៍ ព្រោះរហូតដល់ពេលនេះហើយគាត់នៅតែស្វែងរកគ្រូទស្សន៍ទាយអំពីកូនប្រុសទោលរបស់គាត់ទៀត ។ ជាទីបញ្ចប់ នាងខ្ញុំសូមគោរពជូនពរលោកនាយក សូមប្រកបតែសេចក្តីសុខ សុភមង្គល គ្រប់ប្រការ ។

កំពង់ចាម ថ្ងៃទី៦-៨-២០០១ **ស្រី គឹមឆយ**



ចម្រៀងខ្មែរក្រហម

# មហាជោគជ័យជាង៥ឆ្នាំចិញ្ចែង

មហាជោគជ័យដ៏ធំធេង
ជាមហាជោគជ័យដ៏មហិមា
៥ឆ្នាំ ១ខែ យើងវាយឈ្នះ
ចក្រពត្តិអាមេរិកត្រូវអន្តរធាន
ថ្ងៃ១៧ មេសា ៧៥
រំដោះភ្នំពេញនិងទឹកដី
ប្រជាជន៧លាននាក់
កាន់កាប់រដ្ឋអំណាចយ៉ាងរឹងប៉ឹង
មូលហេតុកម្លាំងមកពីយើងមានអង្គការ
ប្រមូលកម្លាំងរឹងប៉ឹងទូលាយក្ដាត់
យើងមានមាគ៌ាត្រឹមត្រូវភ្លឺស្វាង
យើងមានកងទ័ពរំដោះកម្ពុជា
សុទ្ធសឹងជាកុលបុត្រ កុលធីតា
លះបង់ដាច់ខាតជីវិតឧត្តម
យើងខ្ញុំបំពាក់ជំនឿដាច់ខាត
លើប្រជាជាតិនឹងប្រជា
ប្ដេជ្ញាលើកកម្ពស់ស្មារតីប្រយុទ្ធ
ស្មារតីប្រុងប្រយ័ត្នបដិវត្តរឹងប៉ឹង
ប្ដេជ្ញារួមមហាសាមគ្គី
សាងកម្ពុជាថ្មីល្បីមានឫទ្ធិ

អស្ចារ្យចិញ្ចែងប្រជាជនកម្ពុជា
ក្នុងប្រវត្តិកម្ពុជាពុំធ្លាប់មាន ។
ក្នុងប្រវត្តិសាស្ត្រមេឈ្លានពាន
បរិវារតិរច្ឆានត្រូវរលាយ ។
ជាថ្ងៃរលំរបបចង្រៃ
កម្ពុជាថ្លាថ្លៃយើងទាំងស្រុង ។
ដាក់លាក់រំដោះផុតពីខ្នោះឃ្នាង
ថ្កុំថ្កើងជាម្ចាស់ប្រទេសជាតិ ។
បដិវត្តកម្ពុជាដឹកនាំដាច់ខាត
ក្រោមទង់រួមជាតិរណសិរ្សកម្ពុជា ។
ប្រជាជនយើងអង់អាចអស្ចារ្យ
មោះមុតហានក្លាខ្លាំងសម្បើម ។
ប្រជាជនកម្ពុជាយើងដ៏ឆ្នើម
៥ឆ្នាំក្នុងសង្គ្រាមខ្វះខ្វារ ។
លើអង្គការបដិវត្តកម្ពុជា
មាគ៌ាម្ចាស់ការឯករាជ្យរឹងប៉ឹង ។
យ៉ាងខ្ពស់បំផុតការពារជាតិយើង
ការពារប្រជាជនយើងជាដាច់ខាត ។
គ្រវីទង់សម្រុកបន្តទៀត
ក្រោមអង្គការបដិវត្តមហាអស្ចារ្យអើយ ។

ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្ដីចំនួន១០០០ច្បាប់ជារៀងរាល់លេខនឹងដាក់លក់នៅក្នុងរាជធានីភ្នំពេញតែប៉ុណ្ណោះ មួយច្បាប់ក្នុងតម្លៃ ៧០០០រៀល

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្ដីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន ។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្ដីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@bigpond.com.kh. Thank you.

A magazine of the Documentation Center of Cambodia: *Searching for the truth*. Number 24, December 2001.
Funded by the Royal Ministry of Foreign Affairs, Oslo, Norway, Section for the Human Rights and Humanitarian Assistance; Canadian International Development Agency (CIDA) through the Civil Society Fund; the Royal Danish Government and the Royal Netherlands Government, *The Hague*.